HUMAN RIGHTS WATCH

January 2010

1-56432-593-8

# “ស្បែកដាច់ជាប់ខ្សែភ្លើង”
# ការចាប់ខ្លួនខុសច្បាប់
# ការឃុំឃាំងតាមអំពើចិត្តនិងទារុណកម្មលើអ្នកប្រើប្រាស់គ្រឿងញៀន
# នៅក្នុងប្រទេសកម្ពុជា

សទ្ទានុក្រមគ្រាមភាសា...... ២

ផែនទីមណ្ឌលឃុំឃាំងប្រទេសកម្ពុជា...... ៣

**I.** សេចក្ដីសង្ខេប ...... ៤

**II.** អនុសាសន៍ ...... ១២

ចំពោះអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ក្រសួងការពារជាតិ ក្រសួងមហាផ្ទៃ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងសាលាក្រុងភ្នំពេញ...... ១២

ចំពោះរដ្ឋសភានៃប្រទេសកម្ពុជា...... ១៣

ចំពោះក្រសួងសុខាភិបាល ...... ១៤

ចំពោះភ្នាក់ងារអង្គការសហប្រជាជាតិ ...... ១៥

ចំពោះស្ថាប័នសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ...... ១៦

ចំពោះម្ចាស់ជំនួយទ្វេភាគី និងពហុភាគី និងអង្គការក្រៅរដ្ឋាភិបាល ដែលផ្ដល់ជំនួយដល់ប្រទេសកម្ពុជា ស្ដីពីបញ្ហាមេរោគអេដស៍និងជំងឺអេដស៍នៅក្នុងប្រទេសកម្ពុជា ...... ១៨

**III.** វិធីសាស្ត្រ...... ២០

**IV.** ប្រវត្តិ...... ២៣

ការប្រើប្រាស់គ្រឿងញៀនក្នុងប្រទេសកម្ពុជា...... ២៣

មណ្ឌលឃុំឃាំងគ្រឿងញៀនរបស់ប្រទេសកម្ពុជា ...... ២៤

របាយការណ៍មុនៗស្ដីពីការរំលោភបំពាននៅក្នុងមណ្ឌលសង្គមកិច្ច...... ៣២

ច្បាប់គ្រឿងញៀនប្រទេសកម្ពុជា......................................................................................................៣៤
**V.** លទ្ធផលរកឃើញ.................................................................................................................... ៣៩
ការរំលោភបំពានអំឡុងពេលចាប់ខ្លួន.........................................................................................៤០
ការរំលោភបំពានក្នុងពេលឃុំខ្លួន.................................................................................................៥៥
ការព្យាបាលគ្រឿងញៀននិងស្ថានភាពរស់នៅ............................................................................. ៩២
ក្រុមប្រជាពលរដ្ឋជាក់លាក់..........................................................................................................១២២
**VI.** សេចក្តីសន្និដ្ឋាន ..................................................................................................................... ១៤០
**VII.** សេចក្តីថ្លែងអំណរគុណ............................................................................................................ ១៤៣
ឧបសម្ព័ន្ធ១ ៖ ការឆ្លើយឆ្លងជាមួយរាជរដ្ឋាភិបាលកម្ពុជា....................................................... ១៤៤

# សទ្ទានុក្រម

| | |
|---|---|
| "ឆ្មា" | អ្នកជាប់ឃុំឃាំងដែលមានភារកិច្ចមើលខុសត្រូវលើ "កណ្តុរ" (ដែលជាអ្នកជាប់ឃុំឃាំងផ្សេងៗទៀត) |
| "អនុកង" | អនុកងមានអំណាចទៅលើអ្នកជាប់ឃុំឃាំងផ្សេងៗទៀតនៅក្នុងបន្ទប់ក្នុងមណ្ឌល ។ ពួកគេស្ថិតនៅក្រោមបញ្ជារបស់មេកង |
| "ស៊ីកាវ៉ែម" | ការរួមភេទតាមមាត់ |
| "ស៊ីស្វា" | ជាទណ្ឌកម្ម ដោយឱ្យអ្នកជាប់ឃុំឃាំងរត់បុកនឹងជញ្ជាំងរហូតដល់ចេញឈាមមាត់ |
| "ស៊ីផ្អែត" | រួមភេទ |
| "លោតកង្កែប" | ជាប្រភេទទណ្ឌកម្មដោយលោតទៅមុខពីទីតាំងមួយទៅចម្ងាយមួយដែលបានកំណត់ |
| "ទឹកកក" | មេតំហ្វេតាមីនដែលមានទម្រង់ជាកញ្ចក់ថ្លា |
| "មេក្រុម/អនុក្រុម" | ជាអ្នកជាប់ឃុំឃាំងដែលមានអំណាចទៅលើក្រុមការងារ ប្រមាណដប់នាក់នៃអ្នកជាប់ឃុំឃាំង ។ ពួកគេស្ថិតក្រោមបង្គាប់របស់មេកងឬអនុកង |
| "ក្តគោ" | ដំបងប៉ូលិស |
| "មេកង ឬមេបន្ទប់" | អ្នកជាប់ឃុំឃាំងដោយមានអំណាចគ្រប់គ្រងបន្ទប់ក្នុងមណ្ឌល |
| "រមៀលធុងសាំង" | ទណ្ឌកម្មដោយរមៀលនៅលើដីឆ្ពោះទៅកាន់ចម្ងាយណាមួយ |
| "ស្វាដំដូង" | ជាប្រភេទទណ្ឌកម្មដោយរមៀលទៅមុខក្បាលចុះក្រោមអោបជាប់នឹងជង្គង់ឆ្ពោះទៅចម្ងាយមួយ ។ |
| "ខ្សែអយ" | ខ្សែភ្លើងដែលវេញចូលគ្នាធ្វើជាខ្សែតី |
| "ស្វាគមន៍" | ការទះកំផ្លៀងចំមុខរបស់អ្នកជាប់ឃុំឃាំងថ្មីដែលមកដល់បន្ទប់ |
| "យ៉ាម៉ា" | មេតំហ្វេតាមីន |

# ផែនទីមជ្ឈមណ្ឌលឃុំឃាំងគ្រឿងញៀននៅប្រទេសកម្ពុជា




មជ្ឈមណ្ឌលឃុំឃាំងគ្រឿងញៀននៅប្រទេសកម្ពុជា។© អង្គការឃ្លាំមើលសិទ្ធិមនុស្ស ២០០៩

# I. សេចក្តីសង្ខេប

*“[ បុគ្គលិក ] បានយកខ្សែអេយវាយ...វាត់របូតដល់ធ្វើឱ្យស្បែកដាច់ជាប់នឹងខ្សែភ្លើង...”*

*—កុមារាឈ្មោះម្នាស់ អាយុ ១៦ឆ្នាំ បានពិពណ៌នាអំពីការវាត់នឹងខ្សែភ្លើងដែលបានឃើញផ្ទាល់ភ្នែកនៅ “មណ្ឌលយុវនីតិសម្បទាសង្គមកិច្ចចោមចៅ”*[1]

---

ប្រជាពលរដ្ឋកម្ពុជាដែលប្រើប្រាស់គ្រឿងញៀនបដិសេធទស្សនៈដែលថា ការញៀនគ្រឿងញៀនគឺជាស្ថានភាពបង្កការឈឺចាប់ដោយខ្លួនឯង ដែលបណ្តាលមកពីភាពឥតសណ្តាប់ ធ្នាប់នៃចរិតឬកំហុសឆ្គងផ្លូវចិត្ត។ នៅពេលអង្គការឃ្លាំមើលសិទ្ធិមនុស្សបានសម្ភាសអ្នកទាំងនោះ ពួកគេបាននិយាយដោយពាក្យសម្តីដ៏ស្រទន់និងសុភាពរាបសារដូចៗគ្នា។ ពួកគេបាននិយាយចេញមកដោយចំហ និងដោយស្មោះត្រង់នូវទុក្ខលំបាកនៃកុមារភាពរបស់ពួកគេ (ដែលមានករណីជាច្រើនកំពុងកើតឡើង) អំពីជីវិតរស់នៅតាមវិថីនានា ឬអំពីការធំដឹងក្តីនៅក្នុងជំរំជនភៀសខ្លួននៅប្រទេសថៃ។ ជាទូទៅពួកគេជាក្មេងដែលមានការអប់រំតិចតួច ហើយបាននិយាយអំពីការប្រើប្រាស់គ្រឿងញៀនអស់រយៈពេលមួយវែង។ ទោះបីទុក្ខលំបាកជាច្រើនកើតមានក្នុងជីវិតពួកគេក៏ដោយ សម្លេងរបស់ពួកគេ បានប្រែទៅជាល្វីងនៅពេលរំឭកអំពីការចាប់ខ្លួននិងការឃុំឃាំងរបស់ពួកគេក្នុងមណ្ឌលឃុំឃាំងគ្រឿងញៀនរបស់រដ្ឋាភិបាល។ ពួកគេបាននិយាយចំៗដោយឥតលាក់លៀម អំពីកន្លែងទាំងនោះ។ អតីតអ្នកជាប់ឃុំឃាំងម្នាក់ឈ្មោះកក្កដា បាននិយាយខ្លីៗហើយច្បាស់លាស់ថា :- “ខ្ញុំគិតថាកន្លែងនេះមិនមែនជាមណ្ឌលស្តារនីតិសម្បទាទេ ប៉ុន្តែវាគឺជាមជ្ឈមណ្ឌលសម្រាប់ធ្វើទារុណកម្ម”[2]

---

[1] អង្គការឃ្លាំមើលសិទ្ធិមនុស្ស សម្ភាសកុមារាម្នាស់ នៅភ្នំពេញ – មិថុនា ២០០៩។ អត្តសញ្ញាណរបស់អ្នកដែលត្រូវបានសម្ភាស ត្រូវបានលាក់ដោយប្រើជំនួសនូវរហស្សនាម ហើយព័ត៌មានខ្លះ មិនត្រូវបានបញ្ចេញដោយហេតុការពារជីវិតឯកជន និង សុវត្ថិភាពរបស់ពួកគេ។

2 អង្គការឃ្លាំមើលសិទ្ធិមនុស្ស សម្ភាសកក្កដា ខែឧសភា ២០០៩ ភ្នំពេញ

ការវាយតម្លៃរបស់កក្កដា ត្រូវបានបញ្ជាក់ថាពិតតាមរយៈការស្រាវជ្រាវផ្ទាល់ ដោយអង្គការឃ្លាំមើលសិទ្ធិមនុស្ស។ អ្នកជាប់ឃុំឃាំងជាច្រើនទទួលរងនូវអំពើហិង្សា ជាការសប្បាយលើទុក្ខរបស់អ្នកដទៃ រួមមានការឆក់នឹងដំបងអគ្គិសនី និងការវាយនឹងខ្សែតីដែលវេញពីខ្សែភ្លើង។ លំហាត់ប្រាណដ៏ពិបាកក្រៃលែងនិងពលកម្ម គឺជាផ្នែកសំខាន់បំផុតសម្រាប់អ្វីដែលគេគិតថាជា"ការព្យាបាល"គ្រឿងញៀន។ អ្នកជាប់ឃុំឃាំងមួយចំនួន ត្រូវបានបង្ខំឱ្យបរិច្ចាគឈាមរបស់ខ្លួន។ អ្នកជាប់ឃុំច្រើននាក់មានអាការៈរោគសញ្ញាកង្វះខាតជីវជាតិអាហារ។ ជនដែលគេឃុំឃាំងនៅក្នុងមណ្ឌលបែបនេះ ភាគច្រើនលើសលុប ជាកុមារដែលមានអាយុក្រោមអាយុ១៥ឆ្នាំ ព្រមទាំងអ្នកជំងឺផ្លូវចិត្ត។ អ្នកដែលស្ថិតនៅក្នុងមណ្ឌលបែបនេះ ត្រូវបានឃុំឃាំងដោយរំលោភលើបទដ្ឋានច្បាប់ប្រទេសកម្ពុជា និងច្បាប់អន្តរជាតិ។

នៅក្នុងប្រទេសកម្ពុជាប្រជាពលរដ្ឋ "ដែលសង្គមមិនរាប់អាន" មានដូចជាអ្នកគ្មានផ្ទះសម្បែង អ្នកសុំទាន អ្នកប្រើប្រាស់គ្រឿងញៀន កុមារអនាថារស់តាមចិញ្ចើមថ្នល់ និងអ្នកបម្រើផ្លូវភេទ ជាញឹកញាប់ត្រូវបានចាប់ខ្លួន និងឃុំឃាំងក្នុងមណ្ឌលរបស់រដ្ឋាភិបាល។ នេះជារបាយការណ៍អំពីការស៊ើបអង្កេតលើការប្រព្រឹត្តមកលើប្រជាពលរដ្ឋមួយក្រុម ក្នុងចំណោមប្រជាពលរដ្ឋ "ដែលសង្គមមិនរាប់អាន" - គឺអ្នកប្រើប្រាស់គ្រឿងញៀន – ដោយមន្ត្រីប្រតិបត្តិច្បាប់ និងបុគ្គលិកបម្រើការនៅមណ្ឌលឃុំឃាំងគ្រឿងញៀនរបស់រដ្ឋាភិបាល។ ម្យ៉ាងទៀត ខណៈពេលដែលអ្នកប្រើប្រាស់គ្រឿងញៀន ត្រូវបានគេបញ្ជូនទៅកាន់មជ្ឈមណ្ឌល "ដាក់បញ្ចូលគ្នាទាំងអស់" អង្គការឃ្លាំមើលសិទ្ធិមនុស្សជឿថា នៅទីនោះមានមណ្ឌលចំនួន១១កន្លែង ដែលបង្កើតឡើងជាពិសេសសម្រាប់អ្នកប្រើប្រាស់គ្រឿងញៀននៅក្នុងប្រទេសកម្ពុជា។ មជ្ឈមណ្ឌលទាំងអស់ កំពុងដំណើរការយ៉ាងគ្មានរបៀបដោយអាជ្ញាធររដ្ឋាភិបាលដែលរួមមាន :- កងរាជអាវុធហត្ថ នគរបាល ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (សង្គមកិច្ច) និងអាជ្ញាធររាជធានីភ្នំពេញ។ នៅក្នុងឆ្នាំ ២០០៨ មានអ្នកជាប់ឃុំឃាំងជាង២០០០នាក់ ស្ថិតក្នុងមជ្ឈមណ្ឌលបែបនេះ នៅទូទាំងប្រទេស។

ចំនួនអ្នកដែលចូលមជ្ឈមណ្ឌលទាំងនេះដោយស្ម័គ្រចិត្ត មានតិចបំផុតប្រហែល១ឬ២ភាគរយនៃចំនួនសរុប។ ប្រហែលចំនួនពាក់កណ្តាលដែលចូលក្នុងមណ្ឌលកែប្រែគ្រឿងញៀន បន្ទាប់ពីចាប់ខ្លួនដោយប៉ូលិស ឬឡោមព័ទ្ធចាប់ខុសច្បាប់ដោយអាជ្ញាធរផ្សេងៗ ដោយសារការប្រើប្រាស់គ្រឿងញៀន ឬភាពរសាត់អណ្តែតគ្មានគោលដៅ។ ចំនួនពាក់កណ្តាលផ្សេងទៀត ត្រូវបានចាប់ខ្លួនទៅតាមសំណើរបស់ឪពុកម្តាយឬញាតិសណ្តានរបស់ពួកគេ។ ក្នុងករណីបែបនេះ ក្រុមគ្រួសារត្រូវបង់ប្រាក់ជាទៀតទាត់ឱ្យមជ្ឈមណ្ឌល ដោយតាមការពិតទោះបីច្បាប់ប្រទេសកម្ពុជាទាមទារឱ្យមានការព្យាបាលអ្នកញៀនគ្រឿងញៀន នៅក្នុងមជ្ឈមណ្ឌលរដ្ឋាភិបាលដោយឥតបង់ថ្លៃក៏ដោយ។

ដំណើរការចាប់ខ្លួននិងការឃុំឃាំងជាបន្តបន្ទាប់ ទំនងធ្វើតាមគំរូពីរធំៗ។ នៅក្នុងតំបន់ខ្លះដូចជាភ្នំពេញ ដែលជារាជធានីប្រទេសកម្ពុជា ប្រជាពលរដ្ឋក្រីក្រដែលប្រើប្រាស់គ្រឿងញៀន (ព្រមទាំងក្រុម "ដែលសង្គមមិនរាប់អាន" ផ្សេងៗទៀត) ត្រូវបានឡោមព័ទ្ធជាប្រចាំ ដោយប៉ូលិស បុគ្គលិកសង្គមកិច្ច និងអ្នកដទៃទៀត។ ប្រសិនបើពួកគាត់មានប្រាក់គ្រប់គ្រាន់នោះ ឬមានឪពុកម្តាយសុខចិត្តបង់ប្រាក់កាស ពួកគាត់អាចសូកដើម្បីរួចខ្លួនពីការឃុំឃាំងរបស់ប៉ូលិស ឬសង្គមកិច្ច។ ប្រសិនបើគ្មានប្រាក់ទេ គេនឹងបញ្ជូនពួកគាត់ទៅកាន់មជ្ឈមណ្ឌលឃុំឃាំងគ្រឿងញៀន។ នៅតំបន់ផ្សេងៗ ទៀតក្នុងប្រទេសកម្ពុជា ដូចជាទីនៅប្រជុំជនទីរួមខេត្តខ្លះ ប្រជាលរដ្ឋក្រីក្រដែលប្រើប្រាស់គ្រឿងញៀន មិនត្រូវបានគេយកចិត្តទុកដាក់ឡើយ បើមិនដូច្នេះទេ នឹងត្រូវគេចាប់ខ្លួន ចោទប្រកាន់និងត្រូវបញ្ជូនទៅកាន់ពន្ធនាគារ។ នៅក្នុងតំបន់ទាំងនេះ មជ្ឈមណ្ឌលឃុំឃាំងគ្រឿងញៀន ធ្វើការឃុំឃាំងជាបឋម ឬដាច់ដោយឡែកចំពោះអ្នកដែលមានគ្រួសារមានប្រាក់គ្រប់គ្រាន់ឱ្យទៅប៉ូលិស និង/ឬបុគ្គលិកមជ្ឈមណ្ឌល ដើម្បីឱ្យធ្វើការចាប់ខ្លួននិងការឃុំឃាំងបន្ទាប់មក។ ស្ថានភាពខុសគ្នានេះ មិនត្រូវបានគេសង្កេតមើលឱ្យបានល្អិតល្អន់ឡើយ ខណៈពេលដែលប៉ូលិសនៅតែធ្វើការបោសសម្អាតតាមដងផ្លូវទីរួមខេត្តជាប្រចាំ ចំណែកឯប្រជាពលរដ្ឋត្រូវបានគេបញ្ជូនទៅកាន់មជ្ឈមណ្ឌលនៅរាជធានីភ្នំពេញ តាមការស្នើសុំនិងការបង់ប្រាក់ពីឪពុកម្តាយឬសាច់ញាតិ។

ទោះបីជាស្ថានភាពដូចម្តេចក៏ដោយប្រជាពលរដ្ឋកម្ពុជាដែលប្រើប្រាស់គ្រឿងញៀន ត្រូវបានចាប់ និងឃុំឃាំងដោយខុសច្បាប់។ ប៉ូលិសកម្រនិយាយប្រាប់មូលហេតុចាប់ខ្លួនដល់អ្នកទាំងនោះ ឬក៏មិនបានបង្ហាញហេតុផលដែលពួកគេកំពុងចាប់អ្នកណាម្នាក់ឡើយ។ ពុំមានសិទ្ធិទទួលបានការប្រឹក្សាខាងផ្លូវច្បាប់ ក្នុងពេលស្ថិតក្នុងការឃុំឃាំងរបស់ប៉ូលិស ឬការឃុំឃាំងជាបន្ទាប់នៅក្នុងមជ្ឈមណ្ឌលឡើយ។ ពុំមានការអនុញ្ញាតឱ្យឃុំឃាំងពីតុលាការ ឬមានការពិនិត្យកំហុសអ្វីឡើយ។

ការស្រាវជ្រាវបានបង្ហាញឱ្យឃើញថាការញៀនគ្រឿងញៀន គឺពុំមែនជាកំហុសឆ្គងផ្នែកឆន្ទៈ ឬកម្លាំងសីលធម៌នោះទេ ប៉ុន្តែវាជាល័ក្ខខ័ណ្ឌវេជ្ជសាស្ត្រដែលកើតឡើងវិញនិងរ៉ាំរ៉ៃ ដែលផ្អែកលើមូលដ្ឋានពន្ធុនិងសរីរវិទ្យា ដែលជះឥទ្ធិពលទៅលើមនុស្សណាម្នាក់។ អ្នកដែលញៀនគ្រឿងញៀន មានសិទ្ធិទទួលបានការព្យាបាលតាមវេជ្ជសាស្ត្រសមស្របនិងប្រកបដោយប្រសិទ្ធិភាពឱ្យផុតពីការញៀនគ្រឿងញៀន ដែលតម្រូវទៅតាមសេចក្តីត្រូវការចាំបាច់របស់បុគ្គលម្នាក់ៗ និងសភាពនៃការញៀនរបស់ពួកគេទៅលើគ្រឿងញៀន។ ទោះជាយ៉ាងណាក៏ដោយ "ការព្យាបាល" និង "ស្តារនីតិសម្បទា" ដែលស្ថិតនៅក្នុងមជ្ឈមណ្ឌល គឺមិនអាចទទួលយកបានឡើយដោយផ្អែកលើបញ្ហាក្រមសីលធម៌ ដែលមិនត្រឹមត្រូវទៅតាមវិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រ ហើយមានស្ថានភាពយ៉ាងវេទនា។

ការបង្ខំបញ្ចេញញើសខណៈពេលហាត់ប្រាណឬធ្វើពលកម្ម ហាក់បីដូចជាមធ្យោបាយដ៏សាមញ្ញបំផុតសម្រាប់"ព្យាបាលឱ្យជាដាច់"ពីការញៀនគ្រឿងញៀន។ បុគ្គលិកមជ្ឈមណ្ឌល តែងនិយាយប្រាប់អ្នកជាប់ឃុំឃាំងជាញឹកញយថា ពួកគេត្រូវតែធ្វើការឱ្យបែកញើស ដើម្បីបំបាត់ជាតិញៀនចេញពីខ្លួន។ នៅក្នុងមជ្ឈមណ្ឌលមួយចំនួនរបបនៃការហាត់ប្រាណ និងការបញ្ចេញពលកម្ម គឺត្រូវបានបង្កើនដោយលំហាត់តាមបែបយោធា ដោយមានថ្នាក់បង្រៀនជាក្រុមអំពីបញ្ហាគ្រឿងញៀន និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ តាមករណីដែលកើតឡើងជាច្រើន ពលកម្មដោយបង្ខំ និងសកម្មភាពបណ្តុះបណ្តាលវិជ្ជាជីវៈ គឺគ្រាន់តែជាមូលហេតុសម្រាប់ផ្តល់ផលចំណេញដល់បុគ្គលិកមជ្ឈមណ្ឌលប្រឆាំងនឹងអ្នកជាប់ឃុំឃាំងខ្លួនឯងប៉ុណ្ណោះ។

ប្រសិនបើអាជ្ញាធរប្រទេសកម្ពុជាគិតថា ពួកគេកំពុងកាត់បន្ថយការញៀនគ្រឿងញៀន តាមរយៈគោលនយោបាយឃុំឃាំងដោយបង្ខិតបង្ខំនៅមជ្ឈមណ្ឌលទាំងនេះ ពួកគេពិតជាខុសហើយ។ ពុំមានភស្តុតាងណាដែលថាការហាត់ប្រាណដោយបង្ខំ ពលកម្មដោយបង្ខំ និងលំហាត់តាមបែបយោធា ផ្តល់ផលប្រយោជន៍ដល់ការព្យាបាលបែបនោះទេ។ បន្ទាប់ពីរស់នៅក្នុងមណ្ឌល អស់រយៈពេលប៉ុន្មានខែក្រោយមក គេបានប្រកាសថាបុគ្គលទាំងនោះត្រូវបាន "ជាសះស្បើយ" ពីព្រោះលែងមានសាធាតុញៀននៅក្នុងខ្លួនទៀតហើយ។ អតីតអ្នកជាប់ឃុំឃាំងម្នាក់ឈ្មោះពុធ កំណត់បាននូវគុណវិបត្តិដែលមើលឃើញជាក់ស្តែងនូវវិធីដោះស្រាយពេលបច្ចុប្បន្ននេះថា :-

> "ខ្ញុំគិតថាការបញ្ឈប់ការប្រើគ្រឿងញៀន ទទួលជោគជ័យតែនៅក្នុងមណ្ឌលទេ។ ក៏ប៉ុន្តែ គេនឹងប្រើទៀតបន្ទាប់ពីពួកគេចាកចេញពីមណ្ឌល។ អ្នកជាប់ឃុំឃាំងគ្រឿងញៀនភាគច្រើន ត្រឡប់ទៅរកគ្រឿងញៀនវិញ... អ្នកខ្លះត្រូវបានបញ្ជូនទៅមណ្ឌលបីដង បួនដង ប្រាំដង"។[3]

ប្រព័ន្ធដែលមានស្រាប់របស់មណ្ឌលឃុំឃាំងគ្រឿងញៀនដោយបង្ខំ មិនកាត់បន្ថយចំនួនប្រជាពលរដ្ឋកម្ពុជាដែលប្រើប្រាស់គ្រឿងញៀនឡើយ។ បុគ្គលិកអង្គការក្រៅរដ្ឋាភិបាល និងគ្រូពេទ្យវិជ្ជាជីវៈនៅក្នុងប្រទេសកម្ពុជា បានធ្វើការិះគន់មណ្ឌលទាំងនោះថា " គ្មានប្រសិទ្ធិភាពទេ" ហើយថា "គ្រាន់តែធ្វើឱ្យតែល្អមើល។[4] ជាក់ស្តែង អតីតអ្នកធ្លាប់ជាប់ឃុំឃាំងបាននិយាយថា ការឃុំឃាំងពួកគេមិនបាន "ស្តារនីតិសម្បទា" ពួកគេទេ ប៉ុន្តែបានធ្វើឱ្យពួកគេចុះអន់ថយផ្នែកជំនាញ ធនធាន និងទំនាក់ទំនងសង្គមមនុស្ស ដែលពួកគេជាច្រើននាក់ ធ្លាប់មានពីមុនមក និងមិនបានជួយបញ្ចូលពួកគេទៅក្នុងសហគមន៍របស់ពួកគេវិញទេ។ តាមសម្តីរបស់បួន ជ្រលងនិយាយថា :- "បន្ទាប់ពីខ្ញុំបានចេញពីមណ្ឌល អ្វីៗគ្រប់យ៉ាងត្រូវបានបញ្ចប់ទាំងអស់។ ខ្ញុំបាត់បង់ការងារ មិត្តស្រី

---

[3] អង្គការឃ្លាំមើលសិទ្ធិមនុស្សសម្ភាសពុធ -ភ្នំពេញ ខែមេសា ២០០៩

[4] អង្គការឃ្លាំមើលសិទ្ធិមនុស្ស សម្ភាសគ្រូវពេទ្យវិជ្ជាជីវៈកម្ពុជាម្នាក់ -ភ្នំពេញ ឧសភា ២០០៩។ អង្គការឃ្លាំមើលសិទ្ធិមនុស្ស សម្ភាសបុគ្គលិកអង្គការក្រៅរដ្ឋាភិបាល -ភ្នំពេញ ឧសភា ២០០៩

របស់ខ្ញុំបោះបង់ចោល។ ដូច្នេះ ខ្ញុំបានចាប់ផ្តើមប្រើគ្រឿងញៀនឡើងវិញ។ ខ្ញុំមិនបានប្រើគ្រឿងញៀនទេ នៅពេលដែលគេចាប់ខ្ញុំ" ។[5]

បុព្វហេតុពិតប្រាកដ ដែលជំរុញឱ្យមានមជ្ឈមណ្ឌលឃុំឃាំងគ្រឿងញៀននៅប្រទេសកម្ពុជា គឺទំនងមកពីធាតុផ្សំគ្នានៃបញ្ហាគ្រប់គ្រងសង្គម ការដាក់ទណ្ឌកម្មលើកំហុសឆ្គងផ្នែកសីលធម៌ពីការប្រើគ្រឿងញៀននិងផលចំណេញ។ ជាក់ស្តែង អ្នកណាដែលមិនបំពេញតាមលក្ខណៈវិនិច្ឆ័យនៃការញៀនគ្រឿងញៀនរបស់រដ្ឋាភិបាលផ្ទាល់ទេ នោះពួកគេនឹងត្រូវឃុំឃាំងជាញឹកញាប់។ ឧទាហរណ៍ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន (អ.ជ.ប.គ.ញ) រាយការណ៍ថា នៅក្នុងឆ្នាំ២០០៨ មានមនុស្ស ៧០០ នាក់ សុទ្ធសឹងត្រូវបានឃុំឃាំងដោយសារប្រើប្រាស់គ្រឿងញៀនប្រភេទមេតំហ្វេតាមីនទឹកកកនៅក្នុងមណ្ឌលដែលគ្រប់គ្រងដោយរដ្ឋាភិបាល ទោះបីចំនួន ២៥ ភាគរយនៃអ្នកទាំងនោះ "មិនញៀន" ក៏ដោយ យោងតាមការវាយតម្លៃផ្ទាល់របស់ អ.ជ.ប.គ.ញ។

គួបផ្សំនឹងភាពគ្មានប្រសិទ្ធិភាពព្យាបាលរបស់មជ្ឈមណ្ឌលឃុំឃាំង បុគ្គលិកមណ្ឌលបានអនុវត្តអំពើឃោរឃៅយ៉ាងខ្លាំងក្លាដោយប្រើកណ្តាប់ដៃនិងស្បែកជើងកវែង ដំបង និងដំបងឆក់ ចរន្តអគ្គិសនី។ ភាពត្រេកត្រអាលសប្បាយនឹងការប្រព្រឹត្តកម្មនៃអំពើហិង្សាដែលកើតចេញដោយឯកឯង និងប្រកបដោយចិត្តឆុងឆាំង បានក្លាយជាមធ្យោបាយប្រតិបត្តិការរបស់មណ្ឌលទាំងអស់នោះ។ អង្គការឃ្លាំមើលសិទ្ធិមនុស្សបានដឹងថា ការអនុវត្តន៍ទារុណកម្មនិងការប្រព្រឹត្តដ៏អមនុស្សធម៌ត្រូវបានគេអនុវត្តយ៉ាងទូលំទូលាយនៅទូទាំងមជ្ឈមណ្ឌលឃុំឃាំងគ្រឿងញៀនទាំងអស់ ក្នុងប្រទេសកម្ពុជា។

ចំនួនអ្នកដែលត្រូវបានសម្ភាសយ៉ាងច្រើនលើសលុបសម្រាប់របាយការណ៍នេះ ធ្លាប់បានទទួលរងអំពើឃោរឃៅនិងប្រព្រឹត្តកម្មយ៉ាងអមនុស្សធម៌ដែលនឹងពិពណ៌នាខាងក្រោម ឬក៏ពួកគេបានឃើញផ្ទាល់តាំងពីគ្រាដំបូង។ អតីតអ្នកជាប់ឃុំឃាំងបានរាយការណ៍ថា ពួកគេត្រូវបានឆក់ខ្សែភ្លើងដោយដំបងចរន្តអគ្គិសនី វាយវាត់ដោយខ្សែភ្លើងវេញចូលគ្នា រងការវាយដំ បង្ខំ

---

[5] អង្គការឃ្លាំមើលសិទ្ធិមនុស្ស សម្ភាសជ្រលង - ភ្នំពេញ ខែ កក្កដា ២០០៩

ឱ្យហាត់ប្រាណយ៉ាងឈឺចាប់ដូចជារមៀលខ្លួននៅលើដី និងចងច្រវាក់ឱ្យឈរកណ្តាលថ្ងៃជាដើម។ អំពើរំលោភជាច្រើនគឺសម្រាប់ការដាក់វិន័យ ត្រូវបានគេប្រព្រឹត្តដោយសារការរំលោភបន្តិចបន្តួចលើវិន័យមណ្ឌល ទោះបីនៅពេលខ្លះវាពុំមែនជាលេសដែលចាំបាច់ក៏ដោយ។ លើសពីនេះទៀត អង្គការឃ្លាំមើលសិទ្ធិមនុស្សបានទទួលសេចក្តីរាយការណ៍អំពីអ្នកជាប់ឃុំឃាំង ដែលទទួលរងការរំលោភផ្លូវភេទដោយបុគ្គលិកមជ្ឈមណ្ឌល។ អ្នកដទៃទៀតបានរាយការណ៍ថា ពួកគេត្រូវបានបង្ខំឱ្យបរិច្ចាគឈាម ដើម្បីបានគេចផុតពីការវាយដំ ឬដើម្បីទទួលបានការដោះលែងពីមជ្ឈមណ្ឌល។

ជាទម្លាប់ បុគ្គលិកមណ្ឌលតែងតាំងអ្នកជាប់ឃុំឃាំងមួយចំនួន ដើម្បីអនុវត្តការគ្រប់គ្រងប្រចាំថ្ងៃភាគច្រើនលើអ្នកជាប់ឃុំឃាំងផ្សេងទៀត និងអនុវត្តវិន័យរបស់មណ្ឌល។ អំពើឃោរឃៅលើរាងកាយដ៏ធ្ងន់ធ្ងរ ដែលពេលខ្លះធ្វើតាមបញ្ជាផ្ទាល់របស់បុគ្គលិក គឺកើតឡើងជាធម្មតា នៅក្នុងមណ្ឌល។

អតីតអ្នកជាប់ឃុំឃាំងបានត្អូញប្រាប់អង្គការឃ្លាំមើលសិទ្ធិមនុស្សអំពីគុណភាពនិងបរិមាណអាហារដែលបានផ្តល់ឱ្យពួកគេ។ ពួកគេបាននិយាយដែរថា ពួកគេមានការស្រេកឃ្លានជានិច្ច។ អាហារដែលគេផ្តល់ឱ្យ ច្រើនតែស្អុយរលួយឬមានសត្វល្អិត ទំនងជាខ្វះជីវជាតិនិងកាឡូរីយ៉ាងខ្លាំង។ អ្នកជាប់ឃុំឃាំងបានរាយការណ៍អំពីរោគសញ្ញាស្របទៅតាមកង្វះជីវជាតិអាហារ។

ក្នុងឆ្នាំ២០០៨ ប្រហែលក្រោមមួយភាគបួននៃអ្នកជាប់ឃុំឃាំងនៅក្នុងមជ្ឈមណ្ឌលឃុំឃាំងគ្រឿងញៀនរបស់រដ្ឋាភិបាល មានអាយុ១៨ ឬក្រោម១៨ឆ្នាំ។ ពួកគេត្រូវបានឃុំឃាំងជាមួយមនុស្សចាស់ដោយផ្ទុយទៅនឹងច្បាប់អន្តរជាតិ។ កុមារដែលជាប់ឃុំឃាំងបានប្រាប់យើងខ្ញុំអំពីការឃុំខ្លួន ការឆក់ដោយដំបងចរន្តអគ្គិសនី និងធ្វើការងារដោយបង្ខំ។ កុមារទាំងនោះក៏បាននិយាយដែរថា ពួកគេត្រូវបានបង្ខំឱ្យបរិច្ចាគឈាមរបស់ខ្លួន។

ជាការអនុវត្តន៍ជាក់ស្តែង មជ្ឈមណ្ឌលឃុំឃាំងគ្រឿងញៀនរបស់រដ្ឋាភិបាលប្រើមធ្យោបាយដែលងាយៗ ដោយការយកអ្នកជំងឺផ្លូវចិត្តចេញពីសហគមន៍និងពីក្រសែភ្នែកសាធារណជន។ អង្គការឃ្លាំមើលសិទ្ធិមនុស្ស បានសម្ភាសអតីតអ្នកជាប់ឃុំឃាំង ដោយពួកគេបានរៀបរាប់អំពីអំពើហិង្សាលើរាងកាយដ៏រន្ធត់ មកលើអ្នកជំងឺផ្លូវចិត្តដែលរស់នៅក្នុងមណ្ឌល។ ពុំមានសេវាឬធនធាននៅក្នុងមណ្ឌលសម្រាប់គ្រប់គ្រងបញ្ហាសុខភាពផ្លូវចិត្តទេ។

ដោយមើលឃើញការរំលោភបំពានយ៉ាងរាលដាលមកលើអ្នកជាប់ឃុំឃាំង រាជរដ្ឋាភិបាលកម្ពុជាគួរតែបិទមជ្ឈមណ្ឌលឃុំឃាំងគ្រឿងញៀនរបស់ប្រទេសកម្ពុជាជាស្ថាពរ។ រដ្ឋាភិបាលគួរចាប់ផ្តើមធ្វើការស៊ើបអង្កេតដោយល្អិតល្អន់ជាបន្ទាន់ និងចាត់វិធានការផ្លូវច្បាប់ (រួមទាំងការកាត់ទោសបទឧក្រិដ្ឋ) ចំពោះជនល្មើសដែលបានប្រព្រឹត្តទារុណកម្ម ការប្រព្រឹត្តដែលឃោរឃៅ និងអមនុស្សធម៌ ការឃុំឃាំងតាមអំពើចិត្ត និងការរំលោភសិទ្ធិមនុស្សដទៃទៀត និងបទឧក្រិដ្ឋដែលកើតមានឡើងនៅក្នុងមជ្ឈមណ្ឌលឃុំឃាំងគ្រឿងញៀនប្រទេសកម្ពុជា។ អង្គការឃ្លាំមើលសិទ្ធិមនុស្សបានចាត់ទុកថា ការឃុំឃាំងអ្នកទាំងនោះគឺបានរំលោភលើច្បាប់ប្រទេសកម្ពុជា និងច្បាប់អន្តរជាតិ ហើយពួកគេត្រូវតែបានដោះលែងជាបន្ទាន់។ គេមិនអាចបង្ហាញនូវហេតុផលអំពីការឃុំឃាំងជាបន្តរបស់ពួកគេបានឡើយ។ ទន្ទឹមគ្នានេះដែរ អង្គការឃ្លាំមើលសិទ្ធិមនុស្ស សូមអំពាវនាវដល់រាជរដ្ឋាភិបាលកម្ពុជា បង្កើតវិធានការជម្រើសសម្រាប់ការព្យាបាលការញៀនគ្រឿងញៀន។ ដោយមិនបង្អែបង្អង់រដ្ឋាភិបាលគួរពង្រីកកន្លែងព្យាបាលការញៀនគ្រឿងញៀននៅតាមសហគមន៍ដោយស្ម័គ្រចិត្ត ហើយត្រូវធានាថា ការព្យាបាលបែបនោះមានលក្ខណៈសមស្របទៅតាមវេជ្ជសាស្ត្រ និងស្របតាមបទដ្ឋានអន្តរជាតិ។

## II. អនុសាសន៍

**ចំពោះអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ក្រសួងការពារជាតិ ក្រសួងមហាផ្ទៃ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងសាលាក្រុងភ្នំពេញៈ**

- បិទជាស្ថាពរចំពោះមជ្ឈមណ្ឌលឃុំឃាំងគ្រឿងញៀន និងមជ្ឈមណ្ឌលសង្គមកិច្ច ដែលជាកន្លែងដែលប្រជាពលរដ្ឋត្រូវបានឃុំឃាំងដោយរំលោភបំពានទៅលើច្បាប់អន្តរជាតិ និងច្បាប់នៃប្រទេសកម្ពុជា។
- ដោះលែងអ្នកជាប់ឃុំឃាំងបច្ចុប្បន្នដែលរស់ក្នុងមជ្ឈមណ្ឌលឃុំឃាំងគ្រឿងញៀនកម្ពុជា ពីព្រោះការបន្តឃុំឃាំងពួកគេមិនអាចនិយាយដោះសារដោយផ្អែកលើមូលដ្ឋានច្បាប់ និងសុខភាពបានឡើយ។
- ធានាឱ្យមានការស៊ើបអង្កេតជាបន្ទាន់ ដោយឯករាជ្យនិងល្អិតល្អន់ និងចាត់វិធានការខាងផ្លូវច្បាប់ (រួមទាំងការនាំខ្លួនទៅកាត់ទោសអំពីបទឧក្រិដ្ឋ) លើជនល្មើសដែលប្រព្រឹត្តទារុណកម្ម ប្រព្រឹត្តកម្មទណ្ឌកម្មដែលឃោរឃៅ អមនុស្សធម៌ ឬដែលបន្ថោកបន្ទាប ការឃុំឃាំងតាមអំពើចិត្ត និងការរំលោភសិទ្ធិមនុស្សផ្សេងៗ និងបទឧក្រិដ្ឋ ដែលកើតមាននៅក្នុងការឃុំឃាំងរបស់នគរបាល និងមជ្ឈមណ្ឌលឃុំឃាំងគ្រឿងញៀន និងមណ្ឌលសង្គមកិច្ច។
- បញ្ឈប់ការចាប់ខ្លួនតាមអំពើចិត្តនៃអ្នកប្រើប្រាស់គ្រឿងញៀន និងជន"ដែលសង្គមមិនរាប់អាន" ដូចជាអ្នកគ្មានលំនៅឋាន អ្នកសុំទាន កុមាររស់តាមចិញ្ចើមថ្នល់ អ្នករកស៊ីផ្លូវភេទ និងអ្នកជំងឺផ្លូវចិត្ត។
- បង្កើតស្ថាប័នឯករាជ្យ ដើម្បីទទួលពាក្យបណ្តឹងផ្ទាល់ និងស៊ើបអង្កេតអំពីបណ្តឹងស្តីពីការធ្វើទារុណកម្មនិងប្រព្រឹត្តកម្ម ឬទណ្ឌកម្មឯទៀតដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប និងបទរំលោភផ្សេងៗដែលបានប្រព្រឹត្តដោយមន្ត្រីប្រតិបត្តិច្បាប់ និងបុគ្គលិកមជ្ឈមណ្ឌលឃុំឃាំងគ្រឿងញៀន និងមជ្ឈមណ្ឌលសង្គមកិច្ច។

- អនុញ្ញាតឱ្យអង្គការសិទ្ធិមនុស្សនិងអង្គការច្បាប់ដែលឯករាជ្យ ដើម្បីចុះសួរសុខទុក្ខជាប្រចាំនៅប៉ុស្តិ៍នគរបាល ដើម្បីត្រួតពិនិត្យស្ថានភាពឃុំឃាំង និងធ្វើសម្ភាសអ្នកជាប់ឃុំឃាំង។ រហូតដល់ពេលដែលមជ្ឈមណ្ឌលត្រូវបិទ អនុញ្ញាតឱ្យអង្គការសិទ្ធិមនុស្ស និងអង្គការច្បាប់ឯករាជ្យ ដើម្បីចុះសួរសុខទុក្ខមជ្ឈមណ្ឌលឃុំឃាំងគ្រឿងញៀនទាំងអស់ និងមជ្ឈមណ្ឌលរបស់សង្គមកិច្ច។

## ចំពោះរដ្ឋសភាជាតិកម្ពុជា

- ដកចេញបទប្បញ្ញត្តិដែលមានក្នុងច្បាប់គ្រឿងញៀនបច្ចុប្បន្ន (និងពង្រាងច្បាប់) ដែលអនុញ្ញាតឱ្យតុលាការស៊ីវិល បង្ខំប្រជាពលរដ្ឋឱ្យចូលព្យាបាលគ្រឿងញៀន ទៅតាមការស្នើសុំរបស់ប្តី ប្រពន្ធ ឪពុកម្តាយ សាច់ញាតិរបស់អ្នកនោះឬស្នើពីព្រះរាជអាជ្ញា។
- កំណត់ថាគ្មាននរណាម្នាក់ត្រូវទទួលរងការឃុំឃាំង និងការព្យាបាលគ្រឿងញៀន ដោយបង្ខិតបង្ខំ លើកលែងតែករណីដែលជាកម្មវត្ថុចាំបាច់និងហ្មត់ចត់បំផុត ដែលមានចែងក្នុងល័ក្ខខ័ណ្ឌដូចខាងក្រោម :-

- ផ្អែកលើមូលដ្ឋានមតិយោបល់ព្យាបាលពីររបស់គ្រូពេទ្យវិជ្ជាជីវៈ ដែលបុគ្គលណាម្នាក់ខ្វះសមត្ថភាពដើម្បីយល់ព្រមដោយខ្លួនឯងផ្ទាល់ ឬដែលជីវិតពួកគេអាចស្ថិតក្នុងគ្រោះថ្នាក់ដែលអាចកើតឡើងភ្លាមៗ ដោយសារតែការញៀនគ្រឿងញៀន។
- ការឃុំខ្លួនមិនត្រូវមានរយះពេលយូរជាងរយះពេលនៃការព្យាបាលជាចាំបាច់ ដើម្បីឱ្យនរណាម្នាក់ វិលត្រឡប់ទៅកាន់ស្ថានភាព ដែលពួកគេអាចធ្វើសេចក្តីសម្រេចចិត្តដោយស្វ័យភាពលើសុខភាពផ្ទាល់ខ្លួនរបស់ពួកគេ។ ក្នុងករណីឃុំខ្លួនដទៃទៀត ត្រូវតែផ្អែកតាមលក្ខន្តិកៈដែលកំណត់ពេលវេលាច្បាស់លាស់ ដើម្បីពិនិត្យលើភាពចាំបាច់នៃការបន្តការឃុំខ្លួន។

- បុគ្គលដែលត្រូវបានឃុំខ្លួន មានសិទ្ធិទទួលបាននូវការថែទាំសុខភាពប្រសើបំផុត តាមដែលអាចរកបាន ៖ មានន័យថាការព្យាបាលតាមផែនការវេជ្ជបញ្ជាជាបុគ្គល (ដែលមានការពិនិត្យជាទៀងទាត់) និងការផ្តល់ការព្យាបាលដោយផ្អែកលើភស្តុតាង (រួមបញ្ចូលការព្យាបាលដោយប្រើសារធាតុជំនួស) មិនត្រូវមានអ្នកណាម្នាក់ ដែលស្ថិតក្នុងការ ឃុំខ្លួន និងការព្យាបាលដោយបង្ខិតបង្ខំ អាចគេផ្តល់ឱ្យនូវទម្រង់ព្យាបាល ដើម្បីជាការពិសោធន៍ឡើយ ។
- អ្នកជាប់ឃុំឃាំង ឬអ្នកតំណាងផ្លូវច្បាប់របស់ពួកគេមានសិទ្ធិតវ៉ាចំពោះការសម្រេចចិត្តឃុំខ្លួននៅចំពោះមុខស្ថាប័នឯករាជ្យ នៃអ្នកជំនាញការផ្អែកញៀនគ្រឿងញៀន ។
- កែប្រែក្របខ័ណ្ឌច្បាប់និងគោលនយោបាយសម្រាប់ការព្យាបាលការញៀនគ្រឿងញៀន រួមទាំង*ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនបច្ចុប្បន្ន* និងសេចក្តីព្រាងច្បាប់គ្រឿងញៀនដែលកំពុងតែធ្វើ ។ កិច្ចដំណើរការកែទម្រង់ច្បាប់គួររួមបញ្ចូលការ ពិគ្រោះយោបល់គ្នាពីអ្នកជំនាញខាងសិទ្ធិមនុស្សដើម្បីផ្តល់ជាយោបល់នូវវិធានការ ដែលសមស្របទៅនឹងបញ្ហាសិទ្ធិមនុស្ស និងការការពារដែលបង្កើតមូលដ្ឋាន សម្រាប់កំណែទម្រង់បែប នោះ ។
- កែទម្រង់*ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន* ដើម្បីធ្វើឱ្យថ្នាំមេតាដូននិង ប៊ូប្រេណ័រ ហ្វីន (buprenorphine) អាចរកបាននៅក្នុងប្រទេសកម្ពុជាសម្រាប់គោលបំណងផ្តល់ការព្យាបាលការញៀនគ្រឿងញៀនដោយប្រើសារធាតុជំនួស ។

## ចំពោះក្រសួងសុខាភិបាល

- ពង្រីកសិទ្ធិទទួលបានការព្យាបាលការញៀនគ្រឿងញៀនដោយស្ម័គ្រចិត្តនៅតាម សហគមន៍ និងធានាឱ្យបានការព្យាបាលត្រឹមត្រូវតាមលក្ខណៈវេជ្ជសាស្ត្រ និងសមស្របតាមបទដ្ឋានអន្តរជាតិ ។

- ពង្រីកសិទ្ធិទទួលបានការព្យាបាលការញៀនគ្រឿងញៀនដោយស្ម័គ្រចិត្ត នៅតាមសហ-គមន៍ និងធានាការព្យាបាលដល់កុមារ និងធានាថាសេវាបែបនេះ ធ្វើឡើងសមស្រប តាមអាយុជាក់លាក់ត្រឹមត្រូវតាមលក្ខណៈវេជ្ជសាស្ត្រ ដោយបញ្ចូលផ្នែកអប់រំផងដែរ ។
- ពង្រីកសិទ្ធិទទួលបានការព្យាបាលការញៀនគ្រឿងញៀនដោយស្ម័គ្រចិត្ត នៅតាមសហគមន៍ ដែលឆ្លើយតបទៅនឹងតម្រូវការពិសេសរបស់ស្ត្រីនិងកុមារដែលប្រើប្រាស់គ្រឿងញៀន ។
- ធានាថាគ្មានការចំណាយខុសច្បាប់ទាំងឡាយ ត្រូវបានទាមទារសម្រាប់សេវាព្យាបាលគ្រឿងញៀនដោយស្ម័គ្រចិត្តនៅតាមសហគមន៍ ដែលផ្តល់ដោយរដ្ឋាភិបាលស្ថិតក្រោមច្បាប់កម្ពុជាស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដែលចែងថាការព្យាបាល ដែលឥតបង់ថ្លៃ ។

## ចំពោះភ្នាក់ងារអង្គការសហប្រជាជាតិ

- ស្នើសុំបិទជាស្ថាពរចំពោះមជ្ឈមណ្ឌលឃុំឃាំងគ្រឿងញៀន និងមណ្ឌលសង្គមកិច្ច ដែលជាកន្លែងឃុំខ្លួន ប្រជាពលរដ្ឋដោយរំលោភទៅលើច្បាប់អន្តរជាតិ និងច្បាប់កម្ពុជា ។
- ទំនាក់ទំនងឱ្យបានច្បាស់ទៅកាន់រាជរដ្ឋាភិបាលកម្ពុជា ថាប្រព័ន្ធព្យាបាលគ្រឿងញៀនដោយបង្ខិតបង្ខំ គឺរំលោភបំពានទៅលើច្បាប់សិទ្ធិមនុស្សអន្តរជាតិនិងច្បាប់កម្ពុជា ហើយវាមិនបានបង្ហាញភស្តុតាងវិទ្យាសាស្ត្រណា ឬពុំមានបទដ្ឋានស្តីអំពីអ្វី ដែលចាត់ទុកថាជាការព្យាបាលការញៀនគ្រឿងញៀនប្រកបដោយប្រសិទ្ធិភាពនោះដែរ ។
- ពិនិត្យឡើងវិញនូវរាល់មូលនិធិ កម្មវិធី និងសកម្មភាពទាំងឡាយដែលសំដៅជួយដល់មជ្ឈមណ្ឌលឃុំឃាំងគ្រឿងញៀនកម្ពុជា និងមជ្ឈមណ្ឌលសង្គមកិច្ច ដើម្បីធានាឱ្យ ប្រាកដថាមិនមានមូលនិធិដែលកំពុងគាំទ្រគោលនយោបាយ ឬកម្មវិធីទាំងឡាយ ដែលរំលោភបំពានច្បាប់អន្តរជាតិស្តីពីសិទ្ធិមនុស្ស ដូចជាការហាមឃាត់លើការឃុំឃាំងតាមអំពើចិត្ត ទារុណកម្មនិងប្រព្រឹត្តកម្ម ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប ។

- ជំរុញយ៉ាងសកម្មទៅដល់រដ្ឋាភិបាលកម្ពុជា ដើម្បីពង្រីកការព្យាបាលការញៀនគ្រឿងញៀនដោយស្ម័គ្រចិត្តតាមសហគមន៍ និងធានាថាការព្យាបាលទាំងនេះត្រឹមត្រូវតាមវេជ្ជសាស្ត្រ និងសមស្របតាមបទដ្ឋានអន្តរជាតិ។
- បង្កើតឯកសារស្តីពីគោលជំហររបស់អង្គការសុខភាពពិភពលោក ការិយាល័យ គ្រឿងញៀននិងឧក្រិដ្ឋកម្មអ.ស.ប យូនីសែហ្វ និងការិយាល័យឧត្តមស្នងការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា ដែលបង្កើតគោលការណ៍ស្តីពីការពារថៃទាំក្នុងការព្យាបាលអ្នកញៀនគ្រឿងញៀន រួមមានការបដិសេធនូវប្រព័ន្ធព្យាបាល ដែលជានីតិវិធីដែលឃុំឃាំងនិងព្យាបាល អ្នកប្រើប្រាស់គ្រឿងញៀនដោយបង្ខិតបង្ខំ។
- គាំទ្រនិងផ្តល់កម្មវិធីកសាងសមត្ថភាពព្យាបាលគ្រឿងញៀន ដល់បុគ្គលិកក្រសួងសុខាភិបាល និងអង្គការក្រៅរដ្ឋាភិបាល។
- អង្គការយូនីសែហ្វ គួរគាំទ្រការពង្រីកនូវសិទ្ធិទទួលបានការព្យាបាលគ្រឿងញៀន ដោយស្ម័គ្រចិត្តនៅតាមសហគមន៍សម្រាប់កុមារ (ដោយស្ថិតក្រោមក្រសួងសុខាភិបាល និងអង្គការក្រៅរដ្ឋាភិបាល) ដោយធ្វើឱ្យប្រាកដថាសេវាទាំងនេះ សមស្របទៅតាមអាយុតាមលក្ខណៈវេជ្ជសាស្ត្រ និងបញ្ចូលផ្នែកអប់រំផងដែរ។

## ចំពោះស្ថាប័នសិទ្ធិមនុស្សអង្គការសហប្រជាជាតិ

## ចំពោះអ្នករាយការណ៍ពិសេសអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា

- ទំនាក់ទំនងឱ្យបានច្បាស់ទៅកាន់រាជរដ្ឋាភិបាលកម្ពុជា ថាប្រព័ន្ធព្យាបាលគ្រឿងញៀនដោយបង្ខិតបង្ខំ គឺរំលោភបំពានទៅលើច្បាប់សិទ្ធិមនុស្សជាតិនិងអន្តរជាតិ ហើយវាមិនបានបង្ហាញភស្តុតាងវិទ្យាសាស្ត្រណា ឬពុំមានបទដ្ឋានស្តីអំពីអ្វីដែលចាត់ទុកថាជាការការព្យាបាលការញៀនគ្រឿងញៀនមានប្រសិទ្ធិភាពទេ។
- ស្នើឱ្យបិទជាស្ថាពរចំពោះមណ្ឌលកែប្រែគ្រឿងញៀន និងមណ្ឌលសង្គមកិច្ច ដែលនៅ ទីនោះប្រជាជនត្រូវបានឃុំឃាំងដោយរំលោភបំពានទៅលើច្បាប់អន្តរជាតិ និងច្បាប់កម្ពុជា។

- ធ្វើការជាមួយរាជរដ្ឋាភិបាលកម្ពុជា ដើម្បីបង្កើតនូវអង្គភាពឯករាជ្យ ដើម្បីទទួលនិងស៊ើបអង្កេតដោយផ្ទាល់នូវពាក្យបណ្តឹងអំពីទារុណកម្ម និងការរំលោភបំពានផ្សេងទៀត ដើម្បីប្រយុទ្ធប្រឆាំងនឹងនិទណ្ឌភាព។

**ចំពោះអ្នករាយការណ៍ពិសេសសហប្រជាជាតិស្តីពីទារុណកម្ម និងក្រុមការងារសហប្រជាជាតិ ស្តីពីការឃុំឃាំងតាមអំពើចិត្ត**

- លើកឡើងការព្រួយបារម្ភទៅរាជរដ្ឋាភិបាលកម្ពុជា ចំពោះការចោទប្រកាន់ អំពីការឃុំខ្លួនតាមអំពើចិត្ត ការធ្វើទារុណកម្ម អំពើព្រៃផ្សៃ ប្រព្រឹត្តកម្មឬទណ្ឌកម្មអមនុស្សធម៌ ឬបន្ថោកបន្ទាប និងការរំលោភបំពានដទៃទៀតដែលបានប្រព្រឹត្តមកលើអ្នកប្រើប្រាស់គ្រឿងញៀន (រួមទាំងកុមារផង) ដោយមន្ត្រីអនុវត្តន៍ច្បាប់ និងបុគ្គលិកមជ្ឈមណ្ឌលឃុំឃាំង គ្រឿងញៀននៅក្នុងប្រទេសកម្ពុជា
- សូមអញ្ជើញធ្វើទស្សនកិច្ចនៅកម្ពុជា ដើម្បីស៊ើបអង្កេតការលើការចោទប្រកាន់អំពីការឃុំឃាំងតាមអំពើចិត្តទារុណកម្មនិងប្រព្រឹត្តកម្មឬ ទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប និងការប្រព្រឹត្តរំលោភបំពានដទៃទៀត ទៅលើអ្នកប្រើប្រាស់គ្រឿងញៀន ដោយមន្ត្រីអនុវត្តន៍ច្បាប់ និងបុគ្គលិកមណ្ឌលឃុំឃាំងគ្រឿងញៀនក្នុងប្រទេសកម្ពុជា។

**ចំពោះគណៈកម្មាធិការ និងអនុគណៈកម្មាធិការអ.ស.ប ប្រឆាំងការធ្វើទារុណកម្ម គណៈកម្មាធិការអ.ស.ប ស្តីពីសិទ្ធិកុមារ គណៈកម្មាធិការអ.ស.ប ស្តីពីការលុបបំបាត់ការប្រកាន់រើសអើងប្រឆាំងនិងស្ត្រី**

- ស្នើសុំព័ត៌មានបន្ថែមទៀតពីរាជរដ្ឋាភិបាលកម្ពុជា ក្នុងសេចក្តីរាយការណ៍ទៀតទាត់របស់ខ្លួន ស្តីពីការឃុំឃាំង និងការប្រព្រឹត្តមកលើអ្នកប្រើប្រាស់គ្រឿងញៀននៅក្នុងមណ្ឌលឃុំឃាំងគ្រឿងញៀនក្នុងប្រទេសកម្ពុជា រួមទាំងស្ត្រីនិងកុមារផង។
- បញ្ចូលក្នុងសេចក្តីសង្កេតសន្និដ្ឋាន តាមដានការងារ និង/ឬទស្សនកិច្ច និងអនុសាសន៍លើវិធានការជាក់លាក់ សំដៅបញ្ចប់ការរំលោភបំពានមកលើអ្នកដែលប្រើប្រាស់គ្រឿងញៀនដោយមន្ត្រីប្រតិបត្តិច្បាប់ និងបុគ្គលិកមជ្ឈមណ្ឌលឃុំឃាំងគ្រឿងញៀន និងមជ្ឈមណ្ឌលសង្គមកិច្ចព្រមទាំងដាក់ជនល្មើសឱ្យទទួលខុសត្រូវ។

## ចំពោះម្ចាស់ជំនួយទ្វេភាគីនិងពហុភាគី និងអង្គការក្រៅរដ្ឋាភិបាល ដែលផ្តល់ជំនួយដល់កម្ពុជា លើបញ្ហាគ្រឿងញៀន ឬមេរោគអេដស៍/ជំងឺអេដស៍ ក្នុងប្រទេសកម្ពុជា

- សូមអំពាវនាវជាសាធារណៈ ១.បញ្ចប់នូវការរំលោភបំពានដែលកើតមានឡើងនៅមជ្ឈមណ្ឌលឃុំឃាំងគ្រឿងញៀន ក្នុងប្រទេសកម្ពុជា ២.ស៊ើបអង្កេតលើការចោទប្រកាន់នូវបទរំលោភបំពានបែបនេះ និង ៣.ត្រូវដាក់ជនរំលោភបំពានទាំងនោះឱ្យទទួលខុសត្រូវ។
- លើកឡើងជាមួយគូពិភាក្សា ដែលមកពីភាគីរាជរដ្ឋាភិបាលកម្ពុជា ស្តីពីការរំលោភបំពានរួមមានការឃុំឃាំងតាមអំពើចិត្ត ទារុណកម្មនិងប្រព្រឹត្តកម្ម ឬទណ្ឌកម្មឯទៀតដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាបហើយចាំបាច់ត្រូវស៊ើបអង្កេតករណី និងត្រូវដាក់ជនប្រព្រឹត្តល្មើសឱ្យទទួលខុសត្រូវ។
- ពិនិត្យឡើងវិញនូវមូលនិធិ កម្មវិធី និងសកម្មភាពដែលគាំទ្រប្រតិបត្តិការរបស់មជ្ឈមណ្ឌលឃុំឃាំងគ្រឿងញៀនក្នុងប្រទេសកម្ពុជា ដើម្បីធានាថាគ្មានមូលនិធិត្រូវបាននិងកំពុងប្រើប្រាស់ដើម្បីអនុវត្តគោលនយោបាយ ឬកម្មវិធីទាំងឡាយដែលរំលោភបំពាន ច្បាប់សិទ្ធិមនុស្សអន្តរជាតិ ដូចជាការហាមប្រាមលើការឃុំឃាំងតាមអំពើចិត្ត ការធ្វើទារុណកម្ម និងប្រព្រឹត្តកម្ម ឬទណ្ឌកម្មឯទៀតដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប។

- គាំទ្រការពង្រីកបន្ថែមនូវការព្យាបាលគ្រឿងញៀនដោយស្ម័គ្រចិត្ត នៅមូលដ្ឋានសហគមន៍ រួមទាំងសេវាកម្មសមរម្យសម្រាប់ស្ត្រី និងកុមារ ។
- ផ្តល់ការគាំទ្រដោយផ្ទាល់និងរៀបចំគម្រោងកសាងសមត្ថភាពសម្រាប់ការព្យាបាលការញៀនគ្រឿងញៀន ទៅដល់បុគ្គលិកក្រសួងសុខាភិបាល និងអង្គការក្រៅរដ្ឋាភិបាល ។

## III. វិធីសាស្ត្រ

របាយការណ៍នេះគឺផ្អែកលើការប្រមូលព័ត៌មានកំឡុងពេល ១១ សប្តាហ៍ ក្នុងការចុះស្រាវជ្រាវក្នុងប្រទេសកម្ពុជា នៅចន្លោះពីខែកុម្ភៈ និងខែកក្កដា ឆ្នាំ២០០៩។ អង្គការឃ្លាំមើលសិទ្ធិមនុស្សបានសម្ភាសអ្នកផ្តល់ព័ត៌សំខាន់ៗចំនួន៧៤នាក់។ អ្នកផ្តល់ព័ត៌មាន សំខាន់ៗរួមមាន មនុស្សចំនួន៥៣ នាក់ ដែលជាអ្នកកំពុងប្រើប្រាស់គ្រឿងញៀន ឬធ្លាប់ប្រើប្រាស់គ្រឿងញៀនពីមុន ហើយយ៉ាងហោចណាស់ធ្លាប់បានជាប់ឃុំឃាំងក្នុងមជ្ឈមណ្ឌលឃុំឃាំងគ្រឿងញៀនមួយ។ ប្រាំពីរនាក់ទៀតកំពុងប្រើប្រាស់ ឬធ្លាប់បានប្រើប្រាស់គ្រឿងញៀនពីមុន តែមិនធ្លាប់ត្រូវបានឃុំឃាំង នៅក្នុងមណ្ឌលឃុំឃាំងគ្រឿងញៀនទេ។ ចំនួនបីនាក់ទៀតមិនបានបញ្ជាក់ប្រាប់ថាខ្លួនគាត់ជាអ្នកប្រើប្រាស់គ្រឿងញៀននោះឡើយ ក៏ប៉ុន្តែពួកគេក៏បានជាប់ឃុំឃាំង នៅក្នុងមជ្ឈមណ្ឌលដែរ ពីព្រោះពួកគេគឺជាជនគ្មានលំនៅឋាន ជាអ្នកសុំទាន ឬក៏ជាក្មេងអនាថាតាមចិញ្ចើមផ្លូវ។[6] អតីតអ្នកជាប់ឃុំឃាំងទាំងអស់ត្រូវបានជាប់ឃុំឃាំងក្នុងរយៈពេលបី ឆ្នាំគិតត្រឹមថ្ងៃដែលពួកគេត្រូវបានសម្ភាស។ អ្នកផ្តល់ព័ត៌មានសំខាន់ៗ ១៣ នាក់ស្ថិតក្រោមអាយុ១៨ឆ្នាំ។ អង្គការឃ្លាំមើលសិទ្ធិមនុស្សក៏បានធ្វើកិច្ចសម្ភាសន៍ជាមួយបុគ្គលិក ដែលជាអតីតនិងបច្ចុប្បន្នកំពុងបម្រើការនៅអង្គការក្រៅរដ្ឋាភិបាល និងភ្នាក់ងារអង្គការសហប្រជាជាតិ ដែលជាអ្នកមានចំណេះដឹងនិងបទពិសោធន៍ទៅលើស្ថានភាពរបស់អ្នកប្រើប្រាស់គ្រឿងញៀននៅក្នុងប្រទេសកម្ពុជា។

អង្គការឃ្លាំមើលសិទ្ធិមនុស្ស បានសម្ភាសអតីតអ្នកជាប់ឃុំឃាំងក្នុងមជ្ឈមណ្ឌលឃុំឃាំងគ្រឿងញៀនប្រាំពីរក្នុងចំណោមមជ្ឈមណ្ឌលឃុំឃាំងអ្នកប្រើប្រាស់គ្រឿងញៀនទាំង ១១ របស់រដ្ឋាភិបាល រួមទាំងមជ្ឈមណ្ឌលដែលគ្រប់គ្រងផ្សេងៗគ្នា ដោយសាលាក្រុងភ្នំពេញ ក្រសួងសង្គមកិច្ច

[6] ការបន្ថែមពីលើបទសម្ភាសន៍ចំនួនប្រាំបី ជាមួយអតីតអ្នកជាប់ឃុំឃាំងមិនត្រូវបានបញ្ចូលនៅក្នុងសេចក្តីរាយការណ៍នេះទេ។ ពីព្រោះអ្នកត្រូវបានសម្ភាសបានជាប់ឃុំនៅក្នុងមជ្ឈមណ្ឌលឃុំឃាំងគ្រឿងញៀនមុនរយៈពេលបីឆ្នាំនៃការស្រាវជ្រាវនេះ ឬដោយសារអ្នកផ្តល់បទសម្ភាសន៍មិនអាចចងចាំច្បាស់លាស់គ្រប់គ្រាន់ពេលដែលពួកគេត្រូវបានឃុំខ្លួន។ "កុមារ" ដែលបានប្រើនៅក្នុងរបាយការណ៍នេះ គឺពោលដល់ជនដែលមានអាយុក្រោម១៨ឆ្នាំ។ អនុសញ្ញាស្តីពីសិទ្ធិកុមារ (CRC) ក្នុងមាត្រា១ អនុម័តនៅថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ១៩៨៩ 1577 U.N.T.S.3 (ចូលជាធរមាននៅថ្ងៃទី ២ ខែកញ្ញា ឆ្នាំ១៩៩០) ប្រទេសកម្ពុជាបានផ្តល់សច្ចាប័នលើអនុសញ្ញាស្តីពីសិទ្ធិកុមារនៅថ្ងៃទី ១៥ ខែតុលា ឆ្នាំ១៩៩២។

អតីតយុទ្ធជននិងយុវនីតិសម្បទា (សង្គមកិច្ច) កងរាជអាវុធហត្ថ និងនគរបាលជាតិ។ អ្នកដែលផ្តល់ការសម្ភាសន៍ រួមមានអតីតអ្នកជាប់ឃុំឃាំងពីមណ្ឌលប្រាំមួយក្នុងចំណោមមណ្ឌលឃុំឃាំងធំ៧ជាងគេប្រាំពីរ។ បទសម្ភាសន៍ត្រូវបានធ្វើនៅខេត្តបន្ទាយមានជ័យ បាត់ដំបង កំពង់ចាម សៀមរាប និងរាជធានីភ្នំពេញ។

ក្នុងចំណោមអ្នកផ្តល់ព័ត៌មាន គឺមានអតីតអ្នកជាប់ឃុំឃាំងមួយចំនួនតូច ដែលតូវបានឃុំខ្លួនពីមជ្ឈមណ្ឌលសង្គមកិច្ចមួយ (នៅព្រៃស្ពឺដែលនៅក្បែរភ្នំពេញ) ដោយមិនបានចុះបញ្ជីជាផ្លូវការថាជាមជ្ឈមណ្ឌលព្យាបាលគ្រឿងញៀនទេ។[7] វាហាក់បីដូចជាថា អ្នកប្រើប្រាស់គ្រឿងញៀន (ព្រមទាំងអ្នកដទៃទៀត) ត្រូវបានឃុំខ្លួននៅទីនោះជាប្រចាំ។ ថ្វីបើអ្នកខ្លះដែលប្រើប្រាស់គ្រឿងញៀនបានរាយការណ៍ថាត្រូវបានឃុំឃាំងនៅមជ្ឈមណ្ឌលសង្គមកិច្ចមួយនៅកោះគ (ដែលគេស្គាល់ថាកោះរំដួល) ក្នុងអំឡុងពេលធ្វើរបាយការណ៍នេះ ការផ្តល់សាក្ខីភាពរបស់ពួកគេមិនបានបញ្ចូលនៅក្នុងរបាយការណ៍នេះទេ ពីព្រោះមជ្ឈមណ្ឌលមិនដំណើរការទេនៅពេលនេះ។ យើងខ្ញុំមិនអាចបញ្ជាក់អត្តសញ្ញាណ និងជួបជាមួយអតីតអ្នកជាប់ឃុំឃាំងដែលមកពីមជ្ឈមណ្ឌលមួយចំនួននៅខេត្តបន្ទាយមានជ័យ ខេត្តកោះកុង ខេត្តព្រះសីហនុ និងខេត្តកណ្តាលទេ។

អ្នកផ្តល់បទសម្ភាសន៍ទាំងអស់បានយល់ព្រមផ្ទាល់មាត់ក្នុងការផ្តល់ព័ត៌មាន។ បទសម្ភាសន៍ត្រូវបានធ្វើឡើងជាលក្ខណៈឯកជន ហើយជាបុគ្គលទាំងឡាយត្រូវបានធានាថា ពួកគេអាចបញ្ចប់បទសម្ភាសន៍នៅពេលណាក៏បាន ឬអាចបដិសេធសុំមិនឆ្លើយនូវសំណួរណាមួយ ដោយគ្មានផលវិបាកអ្វីឡើយ។ បទសម្ភាសន៍មានលក្ខណៈពាក់កណ្តាលរចនាសម្ព័ន្ធ និងគ្របដណ្តប់លើប្រធានបទមួយចំនួនទាក់ទងទៅនឹងការប្រើប្រាស់គ្រឿងញៀន ការចាប់ខ្លួន និងការឃុំឃាំង។ នៅកន្លែង ដែលអ្នកផ្តល់បទសម្ភាសន៍បាននិយាយជាភាសាខ្មែរ នោះការបកប្រែភាសាត្រូវបានធ្វើឡើងឆ្លាស់គ្នាជាបន្តបន្ទាប់រវាងភាសាអង់គ្លេស និងភាសាខ្មែរ។ អត្តសញ្ញាណរបស់អ្នកផ្តល់បទសម្ភាសន៍ ត្រូវបាន

[7] មជ្ឈមណ្ឌលព្រៃស្ពឺ ក៏បានធ្វើការយ៉ាងជិតស្និទ្ធជាមួយមន្ទីរសង្គមកិច្ច បណ្តុះបណ្តាលវិជ្ជាជីវៈ និងនីតិសម្បទាសាលាក្រុងភ្នំពេញ។

លាក់ ដោយមានការជ្រើសរើសយករហស្សនាមជំនួសម្តងម្កាល ហើយក្នុងករណីខ្លះមានព័ត៌មានខ្លះមិនបានបញ្ចេញឱ្យដឹងទេដើម្បីការពារសុវត្ថិភាពនិងជីវិតឯកជនរបស់ពួកគេ។

នៅក្នុងខែកញ្ញា ឆ្នាំ២០០៩ អង្គការឃ្លាំមើលសិទ្ធិមនុស្សបានសរសេរលិខិតទៅកាន់ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ដើម្បីស្នើសុំព័ត៌មានស្តីពីមជ្ឈមណ្ឌលឃុំឃាំងគ្រឿងញៀនប្រទេសកម្ពុជា ផ្តល់នូវចម្លើយទៅលើការរំលោភបំពាន ដែលយើងបានចងក្រងជាឯកសារ។ លិខិតនេះត្រូវបានភ្ជាប់មកជាមួយក្នុងឧបសម្ព័ន្ធ១។ នៅត្រឹមដើមខែវិច្ឆិកា ២០០៩ អង្គការឃ្លាំមើលសិទ្ធិមនុស្ស មិនបានទទួលការឆ្លើយតបចំពោះលិខិតនេះឡើយ។

# IV. ប្រវត្តិ

## ការប្រើប្រាស់គ្រឿងញៀននៅក្នុងប្រទេសកម្ពុជា

ខណៈដែលគ្រឿងញៀនដូចជាហេរ៉ូអ៊ីននិងកញ្ឆា ត្រូវបានប្រើពាសពេញផ្ទៃប្រទេសកម្ពុជានៅក្នុងទសវត្សរ៍ទី៩០ ប្រទេសនេះបានបង្ហាញភស្តុតាងនូវសញ្ញាកើនឡើងនៃការប្រើប្រាស់គ្រឿងញៀនយ៉ាម៉ា (មេតំហ្វេតាមីន) នៅចុងទសវត្សរ៍នេះ។ ថ្មីៗនេះ ការប្រើប្រាស់សារធាតុខុសច្បាប់ជាចម្បងនៅក្នុងប្រទេសកម្ពុជាបានលេចឡើងគឺថ្នាំយ៉ាម៉ា និងទឹកកក (មេតំហ្វេតាមីនទឹកកក)។ អ្នកចាក់គ្រឿងញៀន គឺទំនងជាចាក់ហេរ៉ូអ៊ីន។ សារធាតុហិតដូចជាប្រភេទកាវ ត្រូវគេបានប្រើសម្រាប់ហិតជាទូទៅ ជាពិសេសចំណោមកុមាររស់តាមចិញ្ចើមថ្នល់។ កញ្ឆានិងកេតាមីន ដែលមានទំហំតិចជាងគេ ក៏នៅមានប្រើផងដែរ។ អ្នកប្រើប្រាស់គ្រឿងញៀនភាគច្រើនគឺមានអាយុចន្លោះពី ១៨ទៅ២៥ឆ្នាំ ក្នុងនោះមានចំនួនតិចតួចគឺជាស្ត្រី។ ការប្រើប្រាស់គ្រឿងញៀនពីរឬច្រើនប្រភេទគឺជារឿងធម្មតាបំផុត។[8]

តាមការប៉ាន់ស្មានជាក់លាក់នៃអ្នកប្រើប្រាស់គ្រឿងញៀននៅក្នុងប្រទេសកម្ពុជាគឺមានចំនួនខុសៗគ្នា។ តួលេខអ្នកប្រើប្រាស់គ្រឿងញៀនជាផ្លូវការឆ្នាំ២០០៨របស់រដ្ឋាភិបាល មានចំនួន ៥,៨៩៨ នាក់ដែលជាតួលេខកៀក ៥,៧៩៧ នាក់សម្រាប់ឆ្នាំ២០០៧។[9] ក៏ប៉ុន្តែ តួលេខនេះ ត្រូវបានចាត់ទុកថាជាការស្មានទាប។ នៅឆ្នាំ២០០៧ មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ កាមរោគនិងជំងឺសើស្បែក (NCHADS) បានធ្វើការសិក្សាមួយដោយប៉ាន់ស្មានថាមានចន្លោះពី ៩,១០០ ទៅ ២០,១០០ នាក់ ដែលបានប្រើប្រាស់គ្រឿងញៀននៅក្នុងប្រទេសកម្ពុជា ក្នុងចំណោមអ្នកទាំងនោះ

[8] មជ្ឈមណ្ឌលព័ត៌មានគ្រឿងញៀន អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន "របាយការណ៍សង្ខេបស្តីពីទិន្នន័យគ្រឿងញៀនឆ្នាំ២០០៨" "ភ្នំពេញ ខែមេសា ឆ្នាំ២០០៩ មិនបានផ្សព្វផ្សាយ (ច្បាប់ចម្លងរក្សាទុកនៅអង្គការឃ្លាំមើលសិទ្ធិមនុស្ស), អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន "របាយការណ៍ស្តីពីលទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀនក្នុងប្រទេសកម្ពុជា ឆ្នាំ២០០៧" ខែ មិថុនា ឆ្នាំ២០០៨, ទំព័រទី៥២-៥៤។ របាយការណ៍របស់អង្គការ UNODC/UNAIDS, "Cambodia Country Advocacy Brief: Injecting Drug Use and HIV," 2009, p.2

[9] មជ្ឈមណ្ឌលព័ត៌មានគ្រឿងញៀន, អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន, "របាយការណ៍សង្ខេបស្តីពីទិន្នន័យគ្រឿងញៀន ឆ្នាំ២០០៨," ភ្នំពេញ ខែមេសា ឆ្នាំ២០០៩, មិនផ្សព្វផ្សាយ (ច្បាប់ចម្លងរក្សាទុកនៅអង្គការឃ្លាំមើលសិទ្ធិមនុស្ស)។ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន, "របាយការណ៍ស្តីពីលទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀនក្នុងប្រទេសកម្ពុជា ឆ្នាំ២០០៧" ខែ មិថុនា ឆ្នាំ២០០៨, ទំព័រទី៥២។

មានប្រហែលពី១,១០០ ទៅ ៣,០០០នាក់ ដែលជាអ្នកចាក់គ្រឿងញៀន។[10] ការិយាល័យគ្រឿងញៀននិងឧក្រិដ្ឋកម្មនៃអង្គការសហប្រជាជាតិ បានធ្វើសេចក្តីរាយការណ៍តាមការប៉ាន់ស្មានអំពីអត្រាប្រេវ៉ាឡង់ ប្រជាពលរដ្ឋទូទៅដែលប្រើប្រាស់គ្រឿងញៀន គឺមានចំនួន៤ភាគរយនៃចំនួនប្រជាពលរដ្ឋទាំងមូល ដែលជាសញ្ញាប្រកាសឱ្យដឹងអំពីតួលេខអ្នកប្រើប្រាស់គ្រឿងញៀនខ្ពស់ដោយស្មើ ៥០០,០០០ នាក់ ក្នុងប្រទេសកម្ពុជា។[11]

## មជ្ឈមណ្ឌលឃុំឃាំងគ្រឿងញៀននៅប្រទេសកម្ពុជា

នៅក្នុងឆ្នាំ២០០៨ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន (អ.ជ.ប.គ.ញ) បានធ្វើសេចក្តីរាយការណ៍ថាអ្នកប្រើប្រាស់គ្រឿងញៀនចំនួន ២,៣៨២ នាក់ ត្រូវបានជាប់ឃុំឃាំងនៅក្នុងមជ្ឈមណ្ឌលឃុំឃាំងគ្រឿងញៀនរបស់រដ្ឋាភិបាល។[12] តួលេខនេះគឺជាការកើនឡើង ៤០ភាគរយ ពីចំនួនអ្នកដែលត្រូវឃុំខ្លួននៅក្នុងឆ្នាំ២០០៧(១,៧១៩)។[13] យោងទៅតាមទិន្នន័យរបស់អ.ជ.ប

---

[10] "ការប្រមាណទំហំប្រជាពលរដ្ឋអ្នកប្រើប្រាស់គ្រឿងញៀន ២០០៧" ផ្នែកអង្កេតតាមដាននៃមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ (NCHADS), ក្រសួងសុខាភិបាល ២០០៨ មិនផ្សព្វផ្សាយ (ឯកសារចម្លងមានដាក់តម្កល់ទុកនៅអង្គការឃ្លាំមើលសិទ្ធិមនុស្ស)។

[11] របាយការណ៍របស់លោក M. Devaney, G. Reid & S. Baldwin, ""ការវិភាគស្ថានភាពស្តីពីការប្រើប្រាស់គ្រឿងញៀនខុសច្បាប់ និងការឆ្លើយតបនៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិច" វិទ្យាស្ថានប៊ើណែត និងមជ្ឈមណ្ឌលគ្រឿងញៀននិងគ្រឿងស្រវឹង" ២០០៦ ទំព័រ១០

[12] "របាយការណ៍ឆ្នាំ២០០៨ពី the National Residential Treatment Center Minimum Dataset: 2008," មជ្ឈមណ្ឌលព័ត៌មានគ្រឿងញៀន - អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន - បានធ្វើបទបង្ហាញនៅកិច្ចប្រជុំក្រុមការងារបច្ចេកទេសគ្រឿងញៀន/អេដស៍(DHA), នៅសណ្ឋាគារណាហ្គា នៅថ្ងៃទី៤ មិថុនា ឆ្នាំ ២០០៩ (ច្បាប់ថតចំលងរក្សាទុកជាឯកសារនៅអង្គការឃ្លាំមើលសិទ្ធិមនុស្ស)។ "ការព្យាបាល" ដែលប្រើក្នុងរបាយការណ៍នេះ ត្រូវបានកំណត់ថាជា"ដំណើរការដែលចាប់ផ្តើមនៅពេលអ្នកប្រើប្រាស់សារធាតុគីមីចិត្តសកម្ម មកទាក់ទងជាមួយអ្នកផ្តល់សេវាសុខភាពឬសេវាសហគមន៍នានា ហើយអាចបន្តឆ្លងកាត់ការធ្វើអន្តរាគមន៍ជាក់លាក់រហូតឈានដល់ការទទួលបានកំរិតសុខភាពខ្ពស់បំផុត និងទទួលបានសុខមាលភាព។ ការព្យាបាលនិងស្តារនីតិសម្បទា ត្រូវបានកំណត់ថាជាវិធីទូលំទូលាយក្នុងការកំណត់អត្តសញ្ញាណ ជំនួយការថែទាំសុខភាព និងសាមាហរណកម្មសង្គម ដោយគោរពដល់ជនដែលមានបញ្ហា បណ្តាលមកពីការប្រើប្រាស់សារធាតុគីមីចិត្តសកម្ម។ និយមន័យទាំងអស់នេះរួមមានសញ្ញាណអ្នកប្រើប្រាស់សារធាតុមានសិទ្ធិទទួលការព្យាបាលដោយមនុស្សធម៌និងការគោរព"។ (គណៈកម្មាធិការជំនាញរបស់អង្គការសុខភាពពិភពលោកទទួលបន្ទុកការញៀនគ្រឿងញៀន។ របាយការណ៍ទី៣០ :- របាយការណ៍បច្ចេកទេសរបស់អង្គការសុខភាពពិភពលោក លេខ៨៧៣ ១៩៩៨។ របាយការណ៍មាននៅក្នុងគេហទំព័រ http://whqlibdoc.who.int/trs/WHO_TRS_873.pdf ។ក្នុងប្រទេសកម្ពុជា ដោយសារអ្នកជាប់ឃុំឃាំងមិនបានធ្វើការទាក់ទងអ្នកផ្តល់សេវាសុខភាព ហើយដោយសារមានតិចតួចឬគ្មានសោះអំពី"ការកំណត់អត្តសញ្ញាណ ជំនួយការថែទាំសុខភាព និងសាមាហរណកម្មសង្គម" នៅក្នុងមជ្ឈមណ្ឌលបែបនេះ ដែលជាហេតុនាំឱ្យមានការយល់ខុសថាមជ្ឈមណ្ឌលប្រទេសកម្ពុជា ជាមជ្ឈមណ្ឌលព្យាបាលឬស្តារនីតិសម្បទា។ របាយការណ៍នេះគឺពោលដល់មជ្ឈមណ្ឌលប្រទេសកម្ពុជាជា "មណ្ឌលឃុំឃាំងគ្រឿងញៀន"

[13] ដោយសារ អ.ជ.ប.គ.ញ បានផ្សព្វផ្សាយបញ្ជីខុសៗគ្នានៃចំនួនមជ្ឈមណ្ឌលឃុំឃាំងគ្រឿងញៀនរបស់រដ្ឋាភិបាល តួលេខទាំងនេះមិនអាចទុកចិត្តបាន ហើយចំនួនអ្នកជាប់ឃុំឃាំងពិតប្រាកដអាចខ្ពស់ជាងនេះ។ មជ្ឈមណ្ឌលព័ត៌មានគ្រឿងញៀន អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធគ្រឿងញៀន, "របាយការណ៍សង្ខេបស្តីពីទិន្នន័យគ្រឿងញៀន ឆ្នាំ២០០៨, "ភ្នំពេញ ខែមេសា ឆ្នាំ២០០៩, មិនផ្សព្វផ្សាយ (ច្បាប់ចម្លងរក្សាទុកជាឯកសារនៅអង្គការឃ្លាំងមើលសិទ្ធិមនុស្ស)។ ទិន្នន័យដែលប្រមូលរវាងខែកក្កដា-ធ្នូ២០០៧ បានពិពណ៌នាស្ថានភាពស្រដៀងគ្នាដូចតួលេខក្នុងឆ្នាំ២០០៨។ អ្នកភាគច្រើនបានបញ្ចូលក្នុងមជ្ឈមណ្ឌល (៥០.៧ភាគរយ) មានអាយុ

.គ.ញ បានឱ្យដឹងថាចំនួនភាគច្រើននៃអ្នកទាំងនោះ(១,៤៨៣ ឬ ៦២ភាគរយ) គឺមានអាយុចាប់ពី ១៩ ឆ្នាំ ដល់ ២៥ឆ្នាំ។ ស្ត្រីមានចំនួន១៥នាក់គត់(ឬ០.៦ភាគរយ)។ សេចក្តីរាយការណ៍ទូទៅអំពីប្រភេទគ្រឿងញៀនបានប្រើប្រាស់នោះគឺមានប្រភេទ មេតំហ្វេតាមីន(៥១ ភាគរយ)និងប្រភេទមេតំហ្វេតាមីនទឹកកក (៤២ភាគរយ)។[14]

អ.ជ.ប.គ.ញ រាយការណ៍ដែរថា មានតែមួយភាគរយប៉ុណ្ណោះដែលចូលទៅអប់រំកែប្រែដោយស្ម័គ្រចិត្ត ហើយចំនួន៦១ភាគរយទៀតនាំចូលតាមរយៈ "គ្រួសារ" និង៣៨ភាគរយ "ដោយតុលាការ"។[15] កិច្ចពិភាក្សាខាងក្រោមនេះ ត្រង់ផ្នែក"តុលាការ"គឺជាឈ្មោះមិនសមស្របទេ ព្រោះថាអ្នកជាប់ឃុំឃាំង មិនត្រូវបានឃុំឃាំងតាមដីកាតុលាការ ឬតាមការគ្រប់គ្រងរបស់តុលាការទេ។ ដូច្នេះពាក្យដែលថា"តុលាការ"នៅទីនេះមានន័យថា ជាជនដែលត្រូវចាប់ខ្លួនដោយនគរបាលដោយគ្មានការស្នើនិង/ឬការបង់ប្រាក់ពីឪពុកម្តាយ ឬសាច់ញាតិឡើយ។

ទិន្នន័យរបស់រដ្ឋាភិបាល ក៏បានបង្ហាញផងដែរថា នៅក្នុងឆ្នាំ២០០៨មានចំនួនអ្នកជាប់ឃុំឃាំង៥៦៣នាក់(ឬ២៤ភាគរយ) ដែលមានអាយុត្រឹមឬក្រោម១៨ឆ្នាំ។ អ្នកជាប់ឃុំឃាំង១០៤នាក់

---

ចន្លោះ១៩-១៨ឆ្នាំ។ ចំនួនលើស៩ភាគរយមានអាយុតិចជាង១៦ឆ្នាំ ហើយ២២ភាគរយមានអាយុចន្លោះ១៦-១៨ ស្ទើរតែទាំងអស់។ គ្រឿងញៀនដែលប្រាថ្នាចង់បានបំផុតគឺប្រភេទមេតំហ្វេតាមីន(៤៧ភាគរយ) និងមេតំហ្វេតាមីនទឹកកក(៣៤ភាគរយ)។ ការចូលមជ្ឈមណ្ឌលដោយស្ម័គ្រចិត្តមានតែ២.៣ភាគរយប៉ុណ្ណោះ ការបញ្ជូលដោយគ្រួសារ មានចំនួន៥១.៤ភាគរយ និងដោយតុលាការ មាន៤៦.៤ភាគរយ។ ចំនួន១.១ភាគរយការការបញ្ចូលជាស្ត្រី។ ចំនួនប្រជាជនដែលបានបញ្ចូលមជ្ឈមណ្ឌលចាប់ពីខែកក្កដាដល់ខែធ្នូ២០០៧ មាន៧៤០នាក់។ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន, "របាយការណ៍ ស្តីពីលទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀនក្នុងប្រទេសកម្ពុជាឆ្នាំ២០០៧" ខែមិថុនា ឆ្នាំ២០០៨ ទំព័រ ៧៤-៧៥។

14 សូមកត់សំគាល់ថាទិន្នន័យមិនបានឆ្លុះបញ្ចាំងអំពីការប្រើប្រាស់ថ្នាំប្រភេទផ្សេងៗដោយមនុស្សដដែលទេ ដែលជាការពិពណ៌នាជាទូទៅអំពីការប្រើប្រាស់គ្រឿងញៀនក្នុងប្រទេសកម្ពុជា។

15 "របាយការណ៍ឆ្នាំ២០០៨ពី the National Residential Treatment Center Minimum Dataset: 2008," មជ្ឈមណ្ឌលព័ត៌មានគ្រឿងញៀន - អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន - បានធ្វើបទបង្ហាញនៅកិច្ចប្រជុំក្រុមការងារបច្ចេកទេសគ្រឿងញៀន/អេដស៏(DHA) នៅសណ្ឋាគារណាហ្គា នៅថ្ងៃទី៤ មិថុនា ឆ្នាំ ២០០៩ (ច្បាប់ថតចម្លងរក្សាទុកជាឯកសារនៅអង្គការឃ្លាំមើលសិទ្ធិមនុស្ស)។

(ឬស្មើ៤ភាគរយ)ជាកុមារមានអាយុតិចជាង១៥ ឆ្នាំ។ អ្នកជាប់ឃុំឃាំង១១៦(ឬ៥ ភាគរយ) ត្រូវបានចាត់ជាប្រភេទ"ក្មេងរស់តាមចិញ្ចើមថ្នល់"។[16]

មជ្ឈមណ្ឌលឃុំឃាំងគ្រឿងញៀនរបស់រដ្ឋាភិបាលកម្ពុជា ត្រូវបានដំណើរការដោយអង្គភាពផ្សេងៗរបស់រដ្ឋាភិបាល :- ដូចជាកងរាជអាវុធហត្ថនៃកងយុទ្ធពលខេមរភូមិន្ទ (ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងការពារជាតិ) អគ្គស្នងការដ្ឋាននគរបាលជាតិ ក៏ត្រូវបានស្គាល់ថាជានគរបាលស៊ីវិលឬនគរបាលព្រហ្មទណ្ឌ (ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងមហាផ្ទៃ) ក្រសួងសង្គមកិច្ចអតីតយុទ្ធជននិងយុវនីតិសម្បទា (ក៏ត្រូវបានស្គាល់ថាក្រសួងសង្គមកិច្ច) និងមន្ទីរសង្គមកិច្ចរបស់សាលាក្រុងភ្នំពេញ។[17]

"ផែនការជាតិប្រាំឆ្នាំស្តីពីការត្រួតពិនិត្យគ្រឿងញៀន(២០០៥-២០១០)របស់អ.ជ.ប.គ.ញ. ដែលរួមបញ្ចូលផែនការអភិវឌ្ឍន៍ប្រព័ន្ធស្តារនីតិសម្បទា និងព្យាបាលគ្រឿងញៀនរបស់កម្ពុជា បានអះអាងថា គោលការណ៍សិទ្ធិមនុស្សត្រូវបានបញ្ចូលដើម្បីឆ្លើយតបទៅនឹងបញ្ហាគ្រឿងញៀនរបស់កម្ពុជា។[18] ទោះបីជាយ៉ាងណាក៏ដោយ ឯកសារមួយផ្សេងទៀត អ.ជ.ប.គ.ញ បានធ្វើការពិពណ៌នាដោយចំៗអំពីមជ្ឈមណ្ឌលឃុំឃាំងគ្រឿងញៀនរបស់រដ្ឋាភិបាលកម្ពុជាដូចខាងក្រោមថា :-

> ជំរំតាមបែបយោធាដែលត្រូវបានប្រតិបត្តិដោយរដ្ឋាភិបាល គឺជាកន្លែងផ្តល់សេវាព្យាបាលបឋម សម្រាប់អ្នកប្រើប្រាស់គ្រឿងញៀនខុសច្បាប់ នៅក្នុងប្រទេសកម្ពុជា។ មជ្ឈមណ្ឌលភាគច្រើនផ្តល់ការអប់រំ និងសេវាសុខភាពនៅមានកម្រិត ដោយផ្តោតជាពិសេសលើការហាត់ប្រាណនិងវិន័យ។ មជ្ឈមណ្ឌលព្យាបាលភាគច្រើន ត្រូវបានប្រតិបត្តិដោយនគរបាល

[16] មជ្ឈមណ្ឌលព័ត៌មានគ្រឿងញៀន, អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន, "របាយការណ៍សង្ខេបស្តីពីទិន្នន័យគ្រឿងញៀន ឆ្នាំ២០០៨,"ភ្នំពេញ ខែ មេសា ឆ្នាំ២០០៩, មិនផ្សព្វផ្សាយ (ច្បាប់ចម្លងរក្សាទុកនៅអង្គការឃ្លាំមើលសិទ្ធិមនុស្ស)

[17] សូមកត់សំគាល់ថាក្រសួងសុខាភិបាល ពុំពាក់ព័ន្ធក្នុងទិដ្ឋភាពណាមួយរបស់មជ្ឈមណ្ឌលឃុំឃាំងគ្រឿងញៀនប្រទេសកម្ពុជាទេ។

[18] អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន " ផែនការជាតិ៥ឆ្នាំស្តីពីការគ្រប់គ្រងគ្រឿងញៀន ២០០៥-២០១០" ខែធ្នូ ២០០៤ ទំព័រ១៨

ស៊ីវិល ឬកងរាជអាវុធហត្ថ។ មជ្ឈមណ្ឌលមួយចំនួនតូចផ្សេងទៀត គ្រប់គ្រងដោយក្រសួងសង្គមកិច្ច ឬរដ្ឋបាលខេត្ត។[19]

ថ្វីបើមានមជ្ឈមណ្ឌលខ្លះបានកើតមានច្រើនឆ្នាំមកហើយក្តី គម្រោង និយតកម្មសម្រាប់មជ្ឈមណ្ឌលឃុំឃាំងនៅប្រទេសកម្ពុជា ត្រូវបានបង្កើតឡើងនៅឆ្នាំ២០០៦។ នៅក្នុងខែតុលា ឆ្នាំ២០០៦ លោកនាយករដ្ឋមន្ត្រីបានចេញសារាចរស្តីពី "អនុវត្តនីតិវិស័យអប់រំ វិធានការការព្យាបាល និងស្តារនីតិសម្បទាសម្រាប់អ្នកញៀនគ្រឿងញៀន"។ សារាចរផ្តល់សិទ្ធិដល់ខេត្តក្រុងក្នុងប្រទេសកម្ពុជា "ជាពិសេសបណ្តាខេត្តក្រុងដែលមានអ្នកញៀនគ្រឿងញៀនច្រើន ដើម្បីស្វែងរកទីតាំងណាមួយរៀបចំមជ្ឈមណ្ឌលព្យាបាលអ្នកញៀនគ្រឿងញៀន និងស្តារនីតិសម្បទា ដោយធ្វើកិច្ចសហប្រតិបត្តិការជាមួយក្រសួងនិងភ្នាក់ងារពាក់ព័ន្ធ"។[20] សារាចរក៏អំពាវនាវដល់ក្រសួងមហាផ្ទៃ ក្រសួងការពារជាតិ និងក្រសួងយុត្តិធម៌(តែគ្មានក្រសួងសុខាភិបាល) ដើម្បីរៀបចំបង្កើតទីកន្លែង "ដើម្បីប្រមូលអ្នកញៀនថ្នាំ និងផ្តល់ការព្យាបាលនិងអប់រំដល់ពួកគេ ដើម្បីឱ្យពួកគេក្លាយជាប្រជាពលរដ្ឋល្អម្តងទៀតនៅក្នុងសង្គម"។[21]

បញ្ជីឈ្មោះមជ្ឈមណ្ឌលដែលបានបោះពុម្ពផ្សាយដោយរដ្ឋាភិបាល គឺមិនស៊ីគ្នាទេ។[22] ដោយពិនិត្យផ្ទៀងផ្ទាត់ជាមួយបញ្ជីផ្សេងៗទៀត រួមផ្សំនឹងចុះពិនិត្យមើលទីតាំងមជ្ឈមណ្ឌលមួយចំនួន

---

19 អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន, "របាយការណ៍ស្តីពីលទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀនក្នុងប្រទេសកម្ពុជា ឆ្នាំ២០០៧" ខែមិថុនា ឆ្នាំ២០០៨, ទំព័រទី៧៤

20 សូមមើលសារាចរលេខ០៣ ស.រ រាជរដ្ឋាភិបាលកម្ពុជា - ភ្នំពេញ ទី២៣ ខែតុលា ២០០៦

21 សារាចរដដែលបានបញ្ជាក់ថា "ក្រសួងសុខាភិបាលត្រូវបង្កើតផ្នែកព្យាបាលសម្រាប់អ្នកញៀនគ្រឿងញៀនថ្នាក់ជាតិនៅភ្នំពេញ រៀបចំសេវាពិគ្រោះយោបល់នៅមន្ទីរពេទ្យបង្អែកស្រុកខេត្តក្រុង ដើម្បីផ្តល់ប្រឹក្សានិងព្យាបាលអ្នកញៀនគ្រឿងញៀន ដែលបានបញ្ជូនទៅកាន់មន្ទីរពេទ្យដោយឪពុកម្តាយរបស់ខ្លួន បង្កើតបទដ្ឋានបច្ចេកទេស ដើម្បីគ្រប់គ្រងសេវាព្យាបាលគ្រឿងញៀននៅក្នុងមណ្ឌលសហគមន៍ និងលុបបំបាត់ទីកន្លែងព្យាបាល ដែលមិនបានអនុញ្ញាតដោយប្រសួងសុខាភិបាល"។ សកម្មភាពទាំងនេះមិនបានបំពេញទេ ហើយក្រសួងសុខាភិបាលក៏ពុំបានបិទមជ្ឈមណ្ឌលដែលគ្មានការអនុញ្ញាតពីខ្លួនដែរ។

22 ឧទាហរណ៍របាយការណ៍របស់ អ.ជ.ប.គ.ញ ឆ្នាំ២០០៧, "របាយការណ៍ស្តីពីលទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀនក្នុងប្រទេសកម្ពុជា ឆ្នាំ២០០៧" ចុះបញ្ជីមជ្ឈមណ្ឌលឃុំឃាំងគ្រឿងញៀនរបស់រដ្ឋាភិបាល១៣កន្លែង (ទោះបីបញ្ជីទាំងនេះយ៉ាងហោចណាស់មានមជ្ឈមណ្ឌលមួយដែលប្រកាសថា គ្រប់គ្រងដោយអង្គការក្រៅរដ្ឋាភិបាល។ ខណៈពេលដែលរបាយការណ៍ប្រចាំឆ្នាំ២០០៨ របស់ អ.ជ.ប.គ.ញចុះបញ្ជីមជ្ឈមណ្ឌលចំនួន១០។ បញ្ជីឆ្នាំ២០០៧ មិនបានរាប់បញ្ចូល"មជ្ឈមណ្ឌលស្តារយុវនីតិសម្បទា" ក្នុងខេត្តកណ្តាលទេ ដែលមានក្នុងបញ្ជីឆ្នាំ២០០៨ របស់ អ.ជ.ប.គ.ញ (តាមការពិត ទោះបីមជ្ឈមណ្ឌលនេះដំណើរការក្នុងអំឡុងពេលសរសេររបាយការណ៍២០០៧ក៏ដោយ)។ ទោះជាយ៉ាងណាក៏ដោយ បញ្ជីឆ្នាំ២០០៧ ពិតជាបញ្ចូលមជ្ឈមណ្ឌលកងរាជអាវុធហត្ថនៅខេត្តព្រះសីហនុ ដែលឈ្មោះមជ្ឈមណ្ឌលនេះអវត្តមានពីបញ្ជីឆ្នាំ២០០៨ របស់ អ.ជ.ប.គ.ញ ទោះបីពុំមានការបញ្ជាក់ការឈប់ដំណើរការរបស់មជ្ឈមណ្ឌលក៏ដោយ។ សូមមើលរបាយការណ៍របស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

បញ្ជីឈ្មោះត្រឹមត្រូវនៃមណ្ឌលឃុំឃាំងគ្រឿងញៀនបច្ចុប្បន្នរបស់រដ្ឋាភិបាល សម្រាប់ការញៀនគ្រឿងញៀន ត្រូវបានបង្កើតសារជាថ្មីដូចខាងក្រោម :-

| ល.រ | ឈ្មោះមណ្ឌល | ខេត្ត | ដំណើរការដោយ | ចំណុះ |
|---|---|---|---|---|
| ១ | ឱកាសខ្ញុំ | ភ្នំពេញ | សាលាក្រុងភ្នំពេញ | ប្រហែល. ២០០ |
| ២ | ចោមចៅ មជ្ឈមណ្ឌលយុវនីតិសម្បទា | ភ្នំពេញ | សង្គមកិច្ច | ប្រហែល. ១០០ |
| ៣ | មជ្ឈមណ្ឌលស្តារនីតិសម្បទា កងរាជអាវុធហត្ថ | បាត់ដំបង | កងរាជអាវុធហត្ថ | ប្រហែល. ១០០ |
| ៤ | មជ្ឈមណ្ឌលស្តារនីតិសម្បទា ស្រុកបវេល នគរបាលខេត្ត | បាត់ដំបង | នគរបាលស៊ីវិល | ប្រហែល. ២០០ |
| ៥ | មជ្ឈមណ្ឌលជីវិតថ្មី ភ្នំបាក់ | បន្ទាយមានជ័យ | សង្គមកិច្ច | ប្រហែល. ១២០ |
| ៦ | មជ្ឈមណ្ឌលស្តារនីតិសម្បទា កងរាជអាវុធហត្ថ | បន្ទាយមានជ័យ | កងរាជអាវុធហត្ថ | ប្រហែល. ២០០ |
| ៧ | មជ្ឈមណ្ឌលស្តារនីតិសម្បទា ស្នងការនគរបាល | សៀមរាប | នគរបាលស៊ីវិល | ប្រហែល.២០០ |
| ៨ | មជ្ឈមណ្ឌលស្តារនីតិសម្បទា កងរាជអាវុធហត្ថ | កោះកុង | កងរាជអាវុធហត្ថ | ប្រហែល. ៣០ |
| ៩ | មជ្ឈមណ្ឌលស្តារនីតិសម្បទា កងរាជអាវុធហត្ថ | ព្រះសីហនុ | កងរាជអាវុធហត្ថ | ប្រហែល. ៤០ |
| ១០ | មជ្ឈមណ្ឌលស្តារនីតិសម្បទា | កំពង់ចាម | កងរាជអាវុធហត្ថ | ប្រហែល. ២០ |

---

"របាយការណ៏ស្តីពីលទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀនក្នុងប្រទេសកម្ពុជា ឆ្នាំ២០០៨" ខែវិច្ឆិកា ឆ្នាំ២០០៨ ទំព័រ១២-១៣។ "របាយការណ៏ស្តីពីលទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀន ក្នុងប្រទេសកម្ពុជា ឆ្នាំ២០០៧" ខែមិថុនា ឆ្នាំ២០០៨ ទំព័រ៧៤-៧៥។

| | | | | |
|---|---|---|---|---|
| | កងរាជអាវុធហត្ថ | | | |
| ១១ | មជ្ឈមណ្ឌលសយុវនីតិសម្បទា ជីវិតថ្មី កំពង់កន្ទួត | កណ្ដាល | សង្គមកិច្ច | មិនដឹង |

មជ្ឈមណ្ឌលដែលនៅក្នុងបញ្ជីនេះ គឺសម្រាប់គោលបំណងព្យាបាលគ្រឿងញៀន និង ស្ដារនីតិសម្បទា។[23] ទោះជាយ៉ាងណាក៏ដោយ វានាំឱ្យខុសដោយចាត់ទុកបញ្ជីខាងលើនេះថាពេញលេញល្អិតល្អន់។ ការប្រើប្រាស់គ្រឿងញៀនគឺជាទោសឧក្រិដ្ឋដែលអាចដាក់ទណ្ឌកម្ម ដោយដាក់ពន្ធនាគារ និង (ដែលមានការពិភាក្សាដូចខាងក្រោម) អ្នកប្រើប្រាស់គ្រឿងញៀនខ្លះ មិនត្រូវបានបញ្ជូនទៅមជ្ឈមណ្ឌលទាំងនេះទេ ក៏ប៉ុន្តែពួកគេត្រូវបានកាត់ទោសឱ្យជាប់ពន្ធនាគារ ពីបទល្មើសប្រើប្រាស់គ្រឿងញៀន។ ជាងនេះទៅទៀត តាមការសិក្សាស្រាវជ្រាវរបស់យើងខ្ញុំ រកឃើញថាក្រៅពីមជ្ឈមណ្ឌលដែលបានចុះបញ្ជីខាងលើ មានមជ្ឈមណ្ឌលមួយបន្ថែមទៀតគ្រប់គ្រងដោយសង្គមកិច្ច (គឺមណ្ឌលព្រៃស្ពឺក្បែរភ្នំពេញ) ជាទូទៅតែងតែឃុំឃាំងអ្នកប្រើប្រាស់គ្រឿងញៀន(ព្រមទាំងបណ្ដាក្រុមដទៃទៀត "ដែលសង្គមមិនរាប់អាន" ដូចអ្នកគ្មានលំនៅឋាន អ្នកសុំទាន កុមាររស់តាមចិញ្ចើមថ្នល់ ស្ត្រីរកស៊ីផ្លូវភេទ អ្នកជំងឺផ្លូវចិត្តជាដើម។ នៅពេលសរសេររបាយការណ៍នេះ មជ្ឈមណ្ឌលសង្គមកិច្ចនៅព្រៃស្ពឺកំពុងដំណើរការ។[24] នៅប្រទេសកម្ពុជា ក៏មានមជ្ឈមណ្ឌលព្យាបាលគ្រឿងញៀនមួយចំនួនតូច ដែលគ្រប់គ្រងដោយឯកជនផងដែរ។[25]

---

[23] សូមមើលមជ្ឈមណ្ឌលព័ត៌មានគ្រឿងញៀន, អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន "បញ្ជីមជ្ឈមណ្ឌលព្យាបាលគ្រឿងញៀន" ខែកក្កដាឆ្នាំ២០០៩ មិនផ្សព្វផ្សាយ (ច្បាប់ចម្លងរក្សាទុកជាឯកសារនៅអង្គការឃ្លាំមើលសិទ្ធិមនុស្ស)។ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន "របាយការណ៍ស្ដីពីលទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀន ក្នុងប្រទេសកម្ពុជា ឆ្នាំ២០០៨" ខែវិច្ឆិកា ឆ្នាំ២០០៨ ទំព័រ១២-១៣។ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន "របាយការណ៍ស្ដីពីលទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀន ក្នុងប្រទេសកម្ពុជា ឆ្នាំ២០០៧" ខែមិថុនា ឆ្នាំ២០០៨ ទំព័រ៧៤-៧៥។

[24] អ្នកប្រើប្រាស់គ្រឿងញៀនមួយចំនួន បានរាយការណ៍ដែរថាត្រូវបានឃុំឃាំងនៅមជ្ឈមណ្ឌលសង្គមកិច្ចកោះគ (ដែលគេស្គាល់ថាជាកោះរំដួល)នៅក្នុងរយៈពេលធ្វើរបាយការណ៍នេះ។ ក្នុងពេលបច្ចុប្បន្នមជ្ឈមណ្ឌលនេះ មិនមានសកម្មភាពទេ បន្ទាប់ពីមានបទអន្តរាគមន៍របស់អង្គការសិទ្ធិមនុស្សក្នុងពាក់កណ្ដាលឆ្នាំ២០០៨។ ទោះបីយ៉ាងណាក៏ដោយ មជ្ឈមណ្ឌលត្រូវបានបិទជាផ្លូវការ ហើយអង្គការក្រៅរដ្ឋាភិបាលខ្លាចក្រែងអ្នកប្រើប្រាស់គ្រឿងញៀន អ្នកគ្មានផ្ទះសម្បែង និងប្រជាពលរដ្ឋ "ដែលសង្គមមិនរាប់អាន" ឯទៀត នឹងអាចត្រូវរងការឃុំឃាំងម្ដងទៀតនៅទីនោះ។ ដូចបានធ្វើការកត់សំគាល់ខាងលើ ការផ្ដល់សាក្ខីភាពពីអ្នកជាប់ឃុំឃាំងនៅកោះគពុំបានដាក់បញ្ចូល ក្នុងរបាយការណ៍នេះទេ។

[25] វាមិនមានតម្លៃទាល់តែសោះដែលថា មន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀតដែលគ្រប់គ្រងដោយរដ្ឋាភិបាលនៅទីក្រុងភ្នំពេញ នឹងដំណើរការជាគ្លីនិកស្ដារនីតិសម្បទាគ្រឿងញៀន ក្នុងពេលឆាប់ៗនឹងត្រៀមរៀបចំបើកទទួលការព្យាបាលអ្នកប្រើប្រាស់គ្រឿងញៀន ដោយប្រើថ្នាំមេតាដូន ជាសារធាតុជំនួស។

មានការបញ្ជាក់ថា ចំនួនមជ្ឈមណ្ឌលឃុំឃាំងគ្រឿងញៀនរបស់រដ្ឋាភិបាលក្នុងប្រទេសកម្ពុជា នឹងកើនឡើងក្នុងពេលអនាគតដ៏ខ្លីខាងមុខនេះ។ របាយការណ៍ប្រចាំឆ្នាំ២០០៨ ស្តីពីលទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀនរបស់អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ លើកឡើងថា :-

> ខេត្តក្រុងណា ដែលពុំទាន់បង្កើនមណ្ឌលសម្រាប់ព្យាបាលអ្នកប្រើប្រាស់គ្រឿងញៀន គួរពិចារណារកកន្លែងណាមួយដើម្បីរក្សាទុកដាក់ (អ្នកញៀនគ្រឿងញៀន) ក្នុងគោលបំណងលើកកម្ពស់សុខមាលភាពរបស់ជនរងគ្រោះ និងសំដៅរក្សាសន្តិសុខ សណ្តាប់ធ្នាប់សង្គម និងសុវត្ថិភាពនៅក្នុងខេត្តក្រុង ។[26]

តាមពិតទៅ មានអត្ថបទសារព័ត៌មានមួយក្នុងឆ្នាំ២០០៩ថ្មីៗនេះ បានរាយការណ៍ថា "ឯកឧត្តមឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាអតីតប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ស ខេង បានក្រើនរំឭកថា ខេត្ត-ក្រុង ខ្លះដែលមានអ្នកប្រើប្រាស់គ្រឿងញៀនលើសពី៥០នាក់ ត្រូវតែបង្កើតមណ្ឌលបន្សាបគ្រឿងញៀន"។[27] អំឡុងពេលថ្លែងសុន្ទរកថាប្រារព្ធទិវាអន្តរជាតិប្រឆាំងនឹងការរំលោភប្រើប្រាស់គ្រឿងញៀន និងការធ្វើចរាចរគ្រឿងញៀនខុសច្បាប់នៅថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០០៩ លោកនាយករដ្ឋមន្ត្រីហ៊ុន សែន បានស្នើសុំការរួមវិភាគទានថវិកាដើម្បីអនុញ្ញាតសាងសង់មណ្ឌលស្តារនីតិសម្បទាគ្រឿងញៀនថ្មីមួយ ក្នុងខេត្តកំពង់ស្ពឺ ។[28]

មានការបញ្ជាក់ដែលថា កិច្ចសហប្រតិបត្តិការអន្តរជាតិប្រហែលដើរតួនាទីក្នុងការពង្រីកមជ្ឈមណ្ឌលឃុំឃាំងគ្រឿងញៀនរបស់ប្រទេសកម្ពុជា។ ភាគីដែលមានសក្តានុពលមួយគឺប្រទេស

---

26 អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន, "របាយការណ៍ស្តីពីលទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀនក្នុងប្រទេសកម្ពុជា ឆ្នាំ២០០៨" ខែ វិច្ឆិកា ២០០៨, ទំព័រទី៤

27 ម៉េង ហួរ "ខេត្តដែលមានអ្នកប្រើគ្រឿងញៀនលើសពី៥០នាក់ ត្រូវបង្កើតមជ្ឈមណ្ឌលបន្សាប" *រស្មីកម្ពុជា ឆ្នាំ១៧ លេខ ៤៧៨៧ ថ្ងៃទី៦ ខែមករា ២០០៩* (ការបកប្រែដោយអង្គការឃ្លាំមើលសិទ្ធិមនុស្ស ច្បាប់ថតចម្លងរក្សាទុកជាឯកសារនៅអង្គការឃ្លាំមើលសិទ្ធិមនុស្ស)

28 ឃួន លក្ខិណា និង គ្រីស្តូហ្វើ សាយ "ផែនការបង្កើតមជ្ឈមណ្ឌលគ្រឿងញៀនថ្មីជួបប្រទះនឹងការឆ្លើយតបច្របល់គ្នា" *កាសែតភ្នំពេញប៉ុស្តិ៍* ថ្ងៃទី២៥ខែ មិថុនា ២០០៩។

វៀតណាម។ បញ្ហានេះថ្មីបើប្រព័ន្ធព្យាបាលគ្រឿងញៀនដោយបង្ខិតបង្ខំរបស់វៀតណាម ត្រូវរងការរិះគន់ចំពោះកង្វះខាត ដោយសារការគោរពបន្តិចបន្តួចលើការព្យាបាលត្រឹមត្រូវតាមវេជ្ជសាស្ត្រ ឬគោលការណ៍សិទ្ធិមនុស្ស ដែលជាមគ្គុទ្ទេសក៏សម្រាប់ការព្យាបាលគ្រឿងញៀន។[29] ការពិនិត្យមើលឡើងវិញដោយឯករាជ្យ បានរកឃើញថាវាពុំមានប្រសិទ្ធិភាពទេ ហើយអត្រាដែលលាប់ឡើងវិញដោយប្រើប្រាស់គ្រឿងញៀនរបស់អតីតអ្នកជាប់ឃុំឃាំងមានប្រហែល៩០ភាគរយ ។[30]

របាយការណ៍ប្រចាំឆ្នាំ២០០៨ ស្តីពីបញ្ហាគ្រឿងញៀនរបស់អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានរំពឹងទុកថា អ.ជ.ប.គ.ញ "ត្រៀមទទួលគណៈប្រតិភូវៀតណាមមកកម្ពុជា ដើម្បីពិភាក្សាលើលទ្ធភាព(របស់វៀតណាម) ផ្តល់មជ្ឈមណ្ឌលស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនដល់កម្ពុជា"។[31] មិនមានផែនការសម្រាប់ការជំនួយនេះ ត្រូវបានបង្ហាញនៅក្នុងរបាយការណ៍ទេ។ ទោះបីជាយ៉ាងណាក៏ដោយនៅក្នុងខែមិថុនាឆ្នាំ២០០៩ មន្ត្រីអ.ជ.ប.គ.ញ បានបំពេញទស្សនកិច្ចនៅទីក្រុងហូជីមិញ ប្រទេសវៀតណាម។ យោងតាមសេចក្តីរាយការណ៍សារព័ត៌មាន គោលបំណងនៃទស្សនកិច្ចគឺដើម្បីពិភាក្សាពីរបៀបដែលប្រទេសពីរ អាចផ្តល់ឱ្យគ្នាទៅវិញទៅមកនូវជំនួយទៀតទាត់ក្នុងការត្រួតពិនិត្យគ្រឿងញៀន ទីកន្លែងបន្សាបគ្រឿងញៀន និងស្តារនីតិសម្បទា និងការគ្រប់គ្រងអតីតអ្នកញៀនគ្រឿងញៀន។[32] នៅពេលលោកឧបនាយករដ្ឋមន្ត្រីវៀតណាមបានធ្វើទស្សនកិច្ចនៅប្រទេសកម្ពុជាក្នុងខែកញ្ញា ឆ្នាំ២០០៩ នាយករដ្ឋមន្ត្រីកម្ពុជាលោក ហ៊ុន សែន បានស្នើសុំជំនួយការសាងសង់មណ្ឌលស្តារនីតិសម្បទា។[33]

---

[29] សូមមើលឧទាហរណ៍ អង្គការសុខភាពពិភពលោកតំបន់ប៉ាស៊ីហ្វិចខាងលិច "ការវាយតម្លៃអំពីការព្យាបាលអ្នកប្រើប្រាស់គ្រឿងញៀនដោយបង្ខំក្នុងប្រទេសកម្ពុជា ចិន ម៉ាឡេស៊ី និងវៀតណាម : ការអនុវត្តគោលការណ៍សិទ្ធិមនុស្សដោយជ្រើសរើស" ឆ្នាំ ២០០៩ ទំព័រ ៣០-៣៤

[30] ការស្តារនីតិសម្បទាប្រទេសវៀតណាមស្ថិតក្នុងការងារដែលបិទជិត" ឌុក ត. ត្រាន បទបង្ហាញអំពីការកាត់បន្ថយគ្រោះថ្នាក់ ២០០៩ ទីក្រុងបាងកក ថ្ងៃទី២១ មេសា ឆ្នាំ២០០៩។ អ្នកស្រាវជ្រាវអង្គការឃ្លាំមើលសិទ្ធិមនុស្ស បានចូលរួមផ្ទាល់។

[31] អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន "របាយការណ៍ស្តីពីលទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀន ក្នុងប្រទេសកម្ពុជា ឆ្នាំ២០០៨" ខែវិច្ឆិកា ឆ្នាំ២០០៨ ទំព័រ២០

[32] "វៀតណាម-កម្ពុជារួមគ្នាប្រយុទ្ធប្រឆាំងគ្រឿងញៀន" ភ្នាក់ងារសារព័ត៌មានវៀតណាម ថ្ងៃទី១០ ខែធ្នូ ២០០៩។

[33] "កម្ពុជា-វៀតណាម សហការគ្នាប្រយុទ្ធនឹងចរាចរគ្រឿងញៀន" ភ្នាក់ងារសារព័ត៌មានស៊ីនហួរ ថ្ងៃទី២១ ខែកញ្ញា ២០០៩

## របាយការណ៍មុនៗអំពីការរំលោភបំពាននៅក្នុងមណ្ឌលសង្គមកិច្ច

ប៉ុន្មានឆ្នាំកន្លងទៅថ្មីៗនេះ មានការរិះគន់ជាច្រើនលើមជ្ឈមណ្ឌល "ស្តារនីតិសម្បទា" ជាក់លាក់ពីរកន្លែងរបស់សង្គមកិច្ច។ អង្គការសិទ្ធិមនុស្ស បានចងក្រងឯកសារនិងរាយការណ៍អំពីការរំលោភបំពានយ៉ាងធ្ងន់ធ្ងរ ដែលបានកើតមានឡើងនៅក្នុងមណ្ឌលសង្គមកិច្ចនៅព្រៃស្ពឺនិងកោះ គ។[34] ថ្វីបើមិនចុះបញ្ជីឈ្មោះជាផ្លូវការដោយរដ្ឋាភិបាលថាជាមជ្ឈមណ្ឌលឃុំឃាំងគ្រឿងញៀនក៏ដោយអតីតអ្នកប្រើប្រាស់គ្រឿងញៀនដែលត្រូវបានសម្ភាសដោយអង្គការឃ្លាំមើលសិទ្ធិមនុស្ស បានរាយការណ៍អំពីការឃុំឃាំងខុសច្បាប់នៅមជ្ឈមណ្ឌលទាំងនោះ។

របាយការណ៍ឆ្នាំ២០០៩អង្គការសម្ព័ន្ធជំរឿននិងការពារសិទ្ធិមនុស្សលីកាដូ ដាក់ជូនក្រុមប្រឹក្សាសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ សម្រាប់ដំណើរការពិនិត្យតាមកាលកំណត់ជាសកលផ្តល់សេចក្តីសង្ខេបខ្លីហើយច្បាស់ៗអំពីស្ថានភាពរំលោភសិទ្ធិមនុស្ស ដោយរងការចោទប្រកាន់ថាបានប្រព្រឹត្តនៅក្នុងមណ្ឌលទាំងពីរនេះ ហើយមានកង្វះខាតការការស៊ើបអង្កេតរបស់រដ្ឋាភិបាល ឱ្យបានហ្មត់ចត់ទៅលើសេចក្តីរាយការណ៍ស្តីពីការរំលោភបំពានបែបនេះ :-

> ស្ថានភាពនៅមណ្ឌលទាំងពីរ (ព្រៃស្ពឺនិងកោះគ) គឺអាក្រក់ហួស- អាក្រក់ជាងអ្វីដែលកើតមាននៅក្នុងពន្ធនាគារប្រទេសកម្ពុជាទៅទៀត និងមានចំនួនមនុស្សកកកុញច្រើននិងខ្វះអាហារដែលគួរទទួលយកបាន ខ្វះទឹកស្អាតសម្រាប់បរិភោគ និងខ្វះការថែទាំសុខភាព។ នៅក្នុងខែមិថុនា២០០៨ អង្គការលីកាដូបានចូលដល់ក្នុងមជ្ឈមណ្ឌលកោះគ ទោះបីមានការព្យាយាមរារាំងដោយបុគ្គលិកនៅទីនោះក៏

---

[34] ឧទាហរណ៍ សូមមើលអង្គការសម្ព័ន្ធជំរឿននិងការពារសិទ្ធិមនុស្ស(លីកាដូ) "សេចក្តីប្រកាសព័ត៌មាន :- ការចាប់ខ្លួនខុសច្បាប់ និងមជ្ឈមណ្ឌលសង្គមកិច្ច :- ពេលសម្រាប់រដ្ឋាភិបាលចាត់វិធានការ មិនមែនពេលសម្រាប់បដិសេធនោះទេ "ថ្ងៃទី៩ វិច្ឆិកា ២០០៨ សូមចូលមើលគេហទំព័រ http://www.licadho-cambodia. org/press/files/193LICADHOPRActionNotDenials08.pdf ។ គណៈកម្មាធិការសិទ្ធិមនុស្សអាស៊ី "ស្ថានភាពសិទ្ធិមនុស្សនៅក្នុងប្រជាជាតិអាស៊ីទាំង១១-២០០៨" — ខែធ្នូ-ឆ្នាំ២០០៨ទំព័រ៨៧-៨៨សូមចូលទៅគេហទំព័រ http://www.ahrchk.net/pub/pdf/TheStateofHRin11AsianNations2008.pdf ។ សូមមើលផងដែរការិយាល័យសហប្រជាជាតិឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា *អំពីតួនាទីនិងសមិទ្ធិផលរបស់ឧត្តមស្នងការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ក្នុងការជួយរដ្ឋាភិបាល និងប្រជាជនកម្ពុជា ក្នុងការជំរឿននិងការកាពារសិទ្ធិមនុស្ស* - A/HRC/12/41– ថ្ងៃទី៥ ខែសីហា ២០០៩ កថាខណ្ឌ២៨។

ដោយ ហើយបានថតរូបភាពបុរស ស្ត្រីនិងកុមារដែលស្រេកឃ្លានដែលជាប់ឃុំឃាំងនៅក្នុងបន្ទប់ ដែលបានចាក់សោរជាប់ ។ អ្នកទាំងនោះរួមមានកុមារា អាយុបួនឆ្នាំម្នាក់ ស្ត្រីមានផ្ទៃពោះ៩ខែម្នាក់ និងស្ត្រីចំណាស់ម្នាក់ដែលភ្លឹកលែងដឹងខ្លួន ដែលគាត់បានស្លាប់នៅក្នុងបន្ទប់ដែលចាក់សោរនោះ ។

នៅមណ្ឌលព្រៃស្ពឺ អ្នកជាប់ឃុំឃាំងបានទទួលរងអំពើហិង្សាដែលបានប្រព្រឹត្តជាការសប្បាយជាប្រចាំ ។ យោងទៅតាមសម្តីអតីតអ្នកជាប់ឃុំឃាំង ដែលអង្គការលីកាដូបានសម្ភាស ឆ្មាំបានចាប់រំលោភទណ្ឌិតស្ត្រី និងវាយអ្នកជាប់ឃុំឃាំងយ៉ាងធ្ងន់ធ្ងរដោយសារពួកគេព្យាយាមរត់គេច ឬដោយសារពួកគេប្តឹងអំពីស្ថានភាពរស់នៅទីនោះ ។ យោងតាមការស៊ើបអង្កេតរបស់អង្គការលីកាដូ យ៉ាងហោចណាស់ មានអ្នកជាប់ឃុំឃាំងបីនាក់ ឬមានច្រើនជាងនេះ ដែលត្រូវបានវាយដំរហូតដល់បាត់បង់ជីវិតដោយសារឆ្មាំមណ្ឌលព្រៃស្ពឺក្នុងអំឡុងឆ្នាំ ២០០៦-២០០៨ និងអ្នកជាប់ឃុំឃាំង ៥នាក់ទៀត ឮថាបានធ្វើអត្តឃាតកម្ម ។

ក្នុងពាក់កណ្តាលឆ្នាំ២០០៨ អង្គការលីកាដូបានធ្វើពាក្យបណ្តឹងទៅរដ្ឋាភិបាល ដោយនាំឱ្យមានការដោះលែងអ្នកជាប់ឃុំឃាំងនៅកោះគនិងនៅព្រៃស្ពឺ ។ ទោះជាយ៉ាងណាក្តី ក្រសួងសង្គមកិច្ចបានបដិសេធការអំពាវនាវសុំឱ្យបិទមណ្ឌលទាំងនោះជាស្ថាពរ ហើយអង្គការលីកាដូ ព្រួយបារម្ភថា ការឃុំខ្លួនខុសច្បាប់អាចនឹងបន្តនៅកន្លែងឃុំមួយ ឬក៏ទាំងពីរនៅគ្រប់ពេលវេលា ។ គ្មានការស៊ើបអង្កេតដោយមធ្យ័តរបស់រដ្ឋាភិបាលអំពីការរំលោភបំពាននៅមណ្ឌលទាំងនោះទេ និងគ្មានការកាត់ទោសអ្នកប្រព្រឹត្តបទឧក្រិដ្ឋឡើយ ។ បុគ្គលិកនៅមណ្ឌលព្រៃស្ពឺ ដែលតាមរាយកាណ៍ថាជាអ្នកបានប្រព្រឹត្តបទរំលោភសេពសន្ថវៈ និងមនុស្សឃាត និងដែលអង្គការលីការដូបានស្នើសុំដល់រដ្ឋាភិបាល ដើម្បីព្យួការងារពួកគេ ដោយរង់

ចាំការស៊ើបអង្កេតពេញលេញមួយ-ពួកគេនៅតែបន្តធ្វើការនៅទីនោះ។[35] (ប្រភពបញ្ជាក់ត្រូវបានលុបចោល)

## ច្បាប់គ្រឿងញៀនប្រទេសកម្ពុជា

ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនប្រទេសកម្ពុជាដែលបានអនុម័តក្នុងឆ្នាំ១៩៩៦ និងបានធ្វើវិសោធនកម្មក្នុងឆ្នាំ២០០៥ ចែងថាការប្រើប្រាស់គ្រឿងញៀនខុសច្បាប់ គឺជាការប្រព្រឹត្តបទឧក្រិដ្ឋ ត្រូវទទួលទោសដោយការដាក់ពន្ធនាគារពី៧ថ្ងៃដល់១ ខែ និងទោសពិន័យជាប្រាក់ពី ២៥,០០០ ដល់ ១០០,០០០ រៀល(ប្រហែលជាពី ៦ដុល្លា ទៅ ២៤ ដុល្លាអាមេរិក)។[36] ច្បាប់ដដែលនេះដែរក៏បានអនុញ្ញាតឱ្យព្រះរាជអាជ្ញា ឬតុលាការ"អាចឱ្យជនល្មើសរួចខ្លួនពីបទចោទ ឬគ្រាន់តែព្រមានបុគ្គលនោះ" បើសិនបុគ្គលនោះប្រព្រឹត្តក្នុងក្របខ័ណ្ឌទទួលទានតាមទម្លាប់ និងពាក់ព័ន្ធក្នុងការប្រព្រឹត្ត"ដែលមានចំនួនតិចតួចបំផុត"។[37]

ច្បាប់គ្រឿងញៀនចែងថា ថ្លៃព្យាបាលសម្រាប់ការញៀនគ្រឿងញៀននៅក្នុងមន្ទីរពេទ្យក្រសួងឯកទេស ឬគិលានដ្ឋានរបស់រដ្ឋត្រូវជា "បន្ទុកទាំងស្រុងរបស់រដ្ឋ"។[38]

ថ្នាំមេតាដូននិងប៊ូប្រេណ័រហ្វីន គឺជាឱសថសារធាតុជំនួសប្រើប្រាស់សម្រាប់ការព្យាបាល (OST) ជនដែលញៀនហេរ៉ូអ៊ីន ឬសារធាតុប្លែងពីអាភៀន។[39] ច្បាប់គ្រឿងញៀនពេលបច្ចុប្បន្ន ចុះ

---

[35] លីកាដូ "របាយការណ៍ដាក់ជូនអង្គការសហប្រជាជាតិដើម្បីការពិនិត្យតាមការកំណត់ជាសកល — កម្ពុជា" -ថ្ងៃទី១០ ខែមេសា ឆ្នាំ២០០៩ ទំព័រ៣។ សូមមើលផងដែរ អង្គការឃ្លាំមើលសិទ្ធិមនុស្ស "របាយការណ៍ដាក់ជូនសម្រាប់ការពិនិត្យតាមការកំណត់ជាសកល :- កម្ពុជា" មេសា ឆ្នាំ២០០៩ ទំព័រ២។

[36] ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន, លេខ ១៩៧/០១ ថ្ងៃទី៩ ខែធ្នូ ឆ្នាំ១៩៩៦, មាត្រាទី៩៨ កថាខណ្ឌទី៤។ សូមកត់សំគាល់ថាយោងតាម UNOCDG អនុសញ្ញាឆ្នាំ១៩៨៨ តម្រូវឱ្យមានការហាមប្រាមចំពោះសារធាតុដែលគ្រប់គ្រងខុសច្បាប់ ប៉ុន្តែមិនតម្រូវឱ្យមានការកាត់ទោសបទឧក្រិដ្ឋសម្រាប់ចំនួនតិចតួច សូមមើល UNODC "របាយការណ៍គ្រឿងញៀនពិភពលោក ឆ្នាំ២០០៩" -ទំព័រ ១៦៦-១៦៩។

37 ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន, មាត្រា៨៩, កថាខណ្ឌទី៤

[38] ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន, មាត្រា៨៩, កថាខណ្ឌទី១។

39 អង្គការសុខភាពពិភពលោក បញ្ចូលថ្នាំមេតាដូន និងប៊ូប្រេណ័រហ្វីនទៅក្នុងបញ្ជីគំរូរបស់ខ្លួនស្តីពីថ្នាំសំខាន់ៗ។ បញ្ជីគំរូស្តីពីថ្នាំសំខាន់ៗនេះ គឺមានបំណងសម្រាប់ចង្អុលបង្ហាញដល់អ្នកធ្វើគោលនយោបាយ ឱ្យដឹងអ្វីដែលចាំបាច់ដើម្បីធានានូវសុខភាពប្រជាពលរដ្ឋរបស់ខ្លួន។ សូមមើលអង្គការសុខភាពពិភពលោក - បញ្ជីគំរូស្តីពីឱសថសំខាន់ៗរបស់អង្គការសុខភាពពិភពលោក ដែលបានកែតម្រូវឡើងវិញនៅឆ្នាំ២០០៥- គេហទំព័រ [http://mednet3.who.int/EMLib/index.aspx].

បញ្ជីថ្នាំប្រភេទទាំងពីរថ្មីៗនេះ ថាជាសារធាតុដែលមិនអាចរកបាននៅក្នុងប្រទេសកម្ពុជា (ទោះបីនៅពេលសរសេររបាយការណ៍នេះ មានគម្រោងចាប់ផ្តើមធ្វើពិសោធន៍សាកល្បងនូវកម្មវិធីមេតាដូនក៏ដោយ)។[40]

ច្បាប់គ្រឿងញៀនបច្ចុប្បន្នកំណត់ថា បុគ្គលម្នាក់អាចត្រូវបានបង្គាប់បញ្ជាឱ្យព្យាបាលដោយយន្តការទូលំទូលាយផ្សេងៗគ្នា។ ព្រះរាជអាជ្ញាអាចចេញដីកាកោះហៅបុគ្គលនោះ ដើម្បីចូល "គ្រឹះស្ថានបន្សាបគ្រឿងញៀនណាមួយ" បន្ទាប់ពីមានការកោះហៅជននោះ ឱ្យចូលខ្លួនមកកាន់តុលាការនៅពេលចោទប្រកាន់ពីបទល្មើសការប្រើប្រាស់គ្រឿងញៀនខុសច្បាប់។ តាមផ្លូវច្បាប់បញ្ញត្តិនេះតម្រូវឱ្យចេញទាំងពីរគឺដីកាកោះហៅដំបូងដែលចេញដោយតុលាការ និងដីកាបង្គាប់ឱ្យព្យាបាលពីព្រះរាជអាជ្ញា។ បើសិនបុគ្គលនោះអនុវត្តតាមបញ្ជានេះ តុលាការខ្លួនឯងនិងមិនដាក់ទោសអ្នកប្រព្រឹត្តបទល្មើសឡើយ។[41]

នៅពេលអ្នកណាម្នាក់ ត្រូវបានចោទប្រកាន់ពីបទល្មើសប្រើប្រាស់គ្រឿងញៀនខុសច្បាប់ តុលាការខ្លួនឯងផ្ទាល់អាចបញ្ជាឱ្យជនជាប់ចោទ "ដើម្បីទទួលការព្យាបាលសមស្រប អាស្រ័យតាមស្ថានភាពសុខភាពរបស់ខ្លួន"។ ប្រសិនបុគ្គលនោះ ប្រតិបត្តិតាមបញ្ជាឱ្យព្យាបាល តុលាការមានអំណាចចេញសេចក្តីព្រមាន។[42] ស្រដៀងគ្នានេះដែរ បន្ទាប់ពីការកាត់ទោសរួចបុគ្គល ដែលត្រូវបានកាត់ឱ្យជាប់ទោសពីបទប្រើប្រាស់គ្រឿងញៀនខុសច្បាប់ អាចស្នើសុំ "ការព្យាបាលដោយវេជ្ជសាស្ត្រអាស្រ័យតាមស្ថានភាពសុខភាពរបស់ពួកគេរៀងៗខ្លួន" ជាការជំនួសការទទួលទោសវិញ។[43]

ប្តីប្រពន្ធ ឪពុកម្តាយ សាច់ញាតិ ឬអយ្យការក៏អាចស្នើសុំទៅតុលាការស៊ីវិល បញ្ជាទៅអ្នកណាម្នាក់ឱ្យទទួលការព្យាបាលការញៀនគ្រឿងញៀន។ ក្នុងករណីនេះ តុលាការស៊ីវិល ត្រូវ

---

[40] ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន តារាង២ និងតារាង៣

[41] ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន មាត្រា៩១

[42] ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន មាត្រា៩២

[43] ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន មាត្រា៩៣

ទទួលបានការធានាថាបុគ្គលនោះពិតជាញៀនគ្រឿងញៀន ហើយត្រូវបានគេ"ដឹងឮថានឹងបង្កគ្រោះថ្នាក់ដល់អ្នកដទៃទៀត"។[44]

ថ្វីបើច្បាប់នៅប្រទេសកម្ពុជា កំពុងតែត្រូវបានគេប្រើប្រាស់ជាមូលដ្ឋានសម្រាប់ឃុំឃាំងអ្នកប្រើប្រាស់គ្រឿងញៀន — ដែលវាពុំដូច្នោះ ការឃុំឃាំងដ៏ច្រើនលើសលុប- អង្គការឃ្លាំមើលសិទ្ធិមនុស្សបានពិចារណាឃើញថា បទប្បញ្ញត្តិច្រើននៃបទប្បញ្ញត្តិទាំងនេះ មានលក្ខណៈទូលំទូលាយពេក ដោយមានការការពារខ្លះឬគ្មានការការពារតាមនីតិវិធីសោះ ប្រឆាំងនឹងការរំលោភបំពានរបស់យន្តការទាំងនេះ។ យន្តការទាំងនេះក៏អាចរំលោភបំពាន បទដ្ឋានសិទ្ធិមនុស្សផងដែរ ដោយសារពួកគេតម្រូវឱ្យបុគ្គលម្នាក់ទទួលការព្យាបាល ដោយគ្មានការយល់ព្រមពីសាម៉ីខ្លួន ដោយមិនគិតថាតើការព្យាបាលស្ថិតក្នុងផលប្រយោជន៍ល្អបំផុត ដល់អ្នកជំងឺឬអត់ ហើយខកខានមិនបានកំណត់រយៈពេលព្យាបាល ខកខានផ្តល់ការពិនិត្យមើល ឬការត្រួតមើលបទបញ្ជានៃការព្យាបាល។ មនុស្សជាច្រើនដែលប្រើប្រាស់គ្រឿងញៀន តាមពិតអាចមិនត្រូវការការព្យាបាលទេ ដោយសារតែពួកគេមិនញៀនគ្រឿងញៀន។

អង្គការឃ្លាំមើលសិទ្ធិមនុស្សមានការព្រួយបារម្ភជាពិសេសដែលថា បទប្បញ្ញត្តិដែលអនុញ្ញាតឱ្យប្តីប្រពន្ធ ឪពុកម្តាយ ញាតិសណ្តាន ឬអយ្យការ ស្នើសុំឃុំខ្លួនបុគ្គលម្នាក់ដែលញៀនគ្រឿងញៀន គឺបើកចំហឱ្យមានការរំលោភបំពានពីសមាជិកគ្រួសារ ឬអ្នកដទៃ ដែលគ្មានហេតុផលស្របតាមផលប្រយោជន៍ដ៏ល្អបំផុតរបស់អ្នកញៀនគ្រឿងញៀន ក្រៅពីការធ្វើឱ្យអាម៉ាស់ និង/ឬបំណងចង់ឱ្យសមាជិកគ្រួសាររបស់ពួកគេ ឃ្លៀតឆ្ងាយពីជីវិតរបស់ពួកគេមួយរយៈ។ បទប្បញ្ញត្តិក៏ផ្តល់នូវការព្រួយបារម្ភផងដែរថាមជ្ឈមណ្ឌលមិនបានផ្តល់ការព្យាបាល ការញៀនគ្រឿងញៀនតាមវេជ្ជសាស្ត្រ ឬអនុវត្តតាមបទដ្ឋានអន្តរជាតិឡើយ។

---

[44] ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន មាត្រា៩៥

ដោយមានជំនួយពីអ.ស.ប ប្រទេសកម្ពុជាកំពុងតែព្រាងបញ្ចប់ច្បាប់ថ្មីស្តីពីការត្រួតពិនិត្យគ្រឿងញៀន។ បទបញ្ញត្តិភាគច្រើនដែលមានស្រាប់ស្តីពីវិធានការព្យាបាល ត្រូវបានបង្កើតឡើងវិញនៅក្នុងទម្រង់ស្រដៀងគ្នាមែនទែន។[45] ឧទាហរណ៍ មាត្រាទី៧២(១) ស្តីពី "ការព្យាបាលដោយបង្ខំ" ចម្លងពីមាត្រា៩៥បច្ចុប្បន្ន (ដែលអនុញ្ញាតឱ្យដាក់កាតព្វកិច្ចស៊ីវិល សម្រាប់ព្យាបាលអ្នកប្រើប្រាស់គ្រឿងញៀន ទៅតាមការស្នើរបស់សមាជិកគ្រួសារ ឬអយ្យការ)។ *ពង្រាងច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន* ផ្តល់អំណាចទូលំទូលាយផងដែរដល់តុលាការ ដើម្បីបង្ខំបុគ្គលណាម្នាក់ឱ្យទទួលយកការព្យាបាលគ្រឿងញៀន ដែលស្រដៀងទៅនឹងច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនបច្ចុប្បន្ន។

អង្គការឃ្លាំមើលសិទ្ធិមនុស្សពិចារណាឃើញថា គ្មានបុគ្គលណាម្នាក់ ត្រូវទទួលរងការឃុំឃាំងសម្រាប់ការព្យាបាលគ្រឿងញៀនដោយបង្ខិតបង្ខំទេ លើកលែងស្ថិតក្នុងស្ថានភាពក្នុងកម្រិតធ្ងន់ធ្ងរបំផុត។ គន្លឹះក្នុងចំណោមល័ក្ខខ័ណ្ឌទាំងនេះ គឺនៅត្រង់ថាការឃុំខ្លួន មិនត្រូវធ្វើចំពោះបុគ្គលណាម្នាក់ដែលញៀនគ្រឿងញៀន ដោយមិនមានការបញ្ជាក់ពីគ្រូពេទ្យអាជីពដែលមានគុណសម្បត្តិខាងការថែទាំសុខភាពថា បុគ្គលម្នាក់នោះខ្វះសមត្ថភាពផ្តល់ ការយល់ព្រមដោយខ្លួនឯង ឬក៏បុគ្គលនោះស្ថិតក្រោមគំរាមកំហែងគ្រោះថ្នាក់ភ្លាមៗដល់ខ្លួនពួកគេ ដោយសារការញៀនគ្រឿងញៀន។ ការឃុំឃាំងមិនត្រូវមានរយៈពេលវែងហួសពីការចាំបាច់ ក្នុងការព្យាបាលពិតៗ ដើម្បីធ្វើឱ្យបុគ្គលម្នាក់វិលត្រឡប់មកគ្រប់គ្រងខ្លួនឯងដែលអាចសម្រេចចិត្តពីសុខាមាលភាពផ្ទាល់ខ្លួនឯង។ បន្ថែមលើសនេះទៀតការឃុំឃាំងណាមួយត្រូវតែធ្វើទៅតាមល័ក្ខខ័ណ្ឌ ពេលវេលាដែលបានបញ្ញត្តិតាមច្បាប់ ដើម្បីពិនិត្យមើលភាពចាំបាច់ដែលត្រូវបន្ត។ អ្នកដែលត្រូវទទួលការព្យាបាលដោយបង្ខំ (ឬតំណាងផ្លូវច្បាប់របស់ពួកគេ) ត្រូវមានសិទ្ធិតវ៉ាប្រឆាំងនឹងការឃុំឃាំង នៅចំពោះមុខអង្គភាពឯករាជ្យរបស់ជំនាញខាងការញៀនគ្រឿងញៀន។ បន្ថែមពីនេះទៀត ការព្យាបាលដែលគេផ្តល់នោះត្រូវតែជាផែនការដែលធ្វើឡើងសមស្របតាមវេជ្ជសាស្ត្រសម្រាប់បុគ្គលម្នាក់ៗ ដែលត្រូវមានការ

[45] សូមមើលគណៈកម្មាធិការពង្រាងច្បាប់ រាជរដ្ឋាភិបាលកម្ពុជា "ពង្រាងច្បាប់បញ្ចប់ លើច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន" ភ្នំពេញ ថ្ងៃទី២៣ មីនា ២០០៩ ទំព័រ៣៥-៣៧ (ច្បាប់ចំលងមានទុកជាឯកសារនៅអង្គការឃ្លាំមើលសិទ្ធិមនុស្ស)

ពិនិត្យជាប្រចាំ ស្របទៅតាមបទដ្ឋានអន្តរជាតិ។ នៅក្នុងកាលៈទេសៈណាក៏ដោយ គ្មានបុគ្គលណាម្នាក់រងការឃុំឃាំងសម្រាប់ការព្យាបាលដោយបង្ខំក្នុងក្នុងទម្រង់ព្យាបាលពិសោធន៏ឡើយ។[46]

[46] មាត្រា៧ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ចែងថាៈ- "គ្មានជនណាម្នាក់ត្រូវរងទារុណកម្មឬប្រព្រឹត្តកម្ម ឬទណ្ឌកម្មដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាបឡើយ។ ជាពិសេស ហាមយកជនណាម្នាក់មកធ្វើការពិសោធន៏ខាងវេជ្ជសាស្ត្រ ឬវិទ្យាសាស្ត្រ ដោយគ្មានការយល់ព្រមដោយសេរីពីសាមីខ្លួនឡើយ"។

## V. លទ្ធផលរកឃើញ

អង្គការឃ្លាំមើលសិទ្ធិមនុស្ស ត្រូវបានគេប្រាប់ឱ្យដឹងអំពីការរំលោភបំពានអំឡុងពេលចាប់ខ្លួន ដូចជាទារុណកម្មលើរាងកាយដោយនគរបាល ដើម្បីបង្ខំឱ្យសារភាព ឬទម្លាយឱ្យដឹងព័ត៌មាន។ អង្គការឃ្លាំមើលសិទ្ធិមនុស្ស ត្រូវបានគេប្រាប់ផងដែរថា នគរបាលបានទាមទារប្រាក់ ឬបើពុំនោះទេការរួមភេទជាថ្នូរនឹងការដោះលែងពីការឃុំឃាំងរបស់ខ្លួន។

មណ្ឌលឃុំឃាំងគ្រឿងញៀនប្រទេសកម្ពុជាឃុំឃាំងអ្នកប្រើប្រាស់គ្រឿងញៀន អ្នកដែលមានប្រវត្តិធ្លាប់ប្រើប្រាស់គ្រឿងញៀន (ប៉ុន្តែមិនកំពុងប្រើគ្រឿងញៀនទេ) និងអ្នកមិនដែលប្រើប្រាស់គ្រឿងញៀនទាល់តែសោះ។ ការឃុំឃាំង គឺមិនមែនសម្រាប់ការព្យាបាល ផ្តាច់គ្រឿងញៀនទេ។ អ្នកដែលមិនត្រូវតាមលក្ខណៈវិនិច្ឆ័យផ្ទាល់របស់អ.ជ.ប.គ.៣ ចំពោះការញៀនគ្រឿងញៀនក៏ត្រូវគេឃុំឃាំងនៅក្នុងមជ្ឈមណ្ឌលឃុំឃាំងគ្រឿងញៀនដែរ។

ស្ថិតក្រោមការឃុំឃាំងនោះ អតីតអ្នកជាប់ឃុំឃាំងបានរាយការណ៍ថាពួកគេត្រូវបានឆក់ដំបងមានចរន្តអគ្គិសនី វាយនឹងខ្សែភ្លើងវេញចូលគ្នា វាយដំ បង្ខំឱ្យហាត់ប្រាណយ៉ាងឈឺចាប់ ដូចជារមៀលនៅលើដី ហើយត្រូវបានចងជាប់នឹងច្រវាក់ឱ្យឈរកណ្តាលថ្ងៃ។ អតីតអ្នកជាប់ឃុំឃាំង បានរាយការណ៍ពីការរំលោភផ្លូវភេទដោយបុគ្គលិកមណ្ឌល។ បុគ្គលិកផ្តល់សិទ្ធិឱ្យអ្នកជាប់ឃុំដទៃទៀតដាក់វិន័យនិងទណ្ឌកម្មលើអ្នកជាប់ឃុំឃាំងដទៃទៀត។ ជាផលវិបាក អំពើឃោរឃៅលើរាងកាយដ៏ធ្ងន់ធ្ងរ ដែលបានប្រព្រឹត្តដោយអ្នកជាប់ឃុំឃាំងដូចគ្នា កើតឡើងជាទូទៅធម្មតា នៅក្នុងមជ្ឈមណ្ឌល។ អតីតអ្នកជាប់ឃុំឃាំងក៏បានរាយការណ៍ដែរថា ពួកគេត្រូវបានបង្ខំឱ្យបរិច្ចាគឈាមរបស់ខ្លួន។

អតីតអ្នកជាប់ឃុំឃាំង បាននិយាយត្អូញត្អែរប្រាប់អង្គការឃ្លាំមើលសិទ្ធិមនុស្សអំពីគុណភាពនិងបរិមាណអាហារដែលបានផ្តល់ឱ្យពួកគេ។ អ្នកជាប់ឃុំឃាំងបានរាយការណ៍អំពីរោគសញ្ញា ដែលស្របគ្នាទៅនឹងកង្វះខាតជីវជាតិអាហារ។

អំពើរំលោភជាច្រើន រួមមានការរៀបចំឆក់ខ្សែភ្លើង ការវាយដំ និងពលកម្មដោយបង្ខំ គឺត្រូវបានរាយការណ៍ដោយកុមារ។ កុមារទាំងនោះបាននិយាយថាពួកគេ ត្រូវបានបង្ខំឱ្យបរិច្ចាគឈាមរបស់ខ្លួន។ អង្គការឃ្លាំមើលសិទ្ធិមនុស្សក៏ធ្វើសម្ភាសអតីតអ្នកជាប់ឃុំឃាំងដែលបានរាយការណ៍អំពីហិង្សាលើរាងកាយដ៏រន្ធត់មកលើអ្នកជំងឺផ្លូវចិត្តនៅក្នុងមជ្ឈមណ្ឌល។

## ការរំលោភបំពានអំឡុងពេលចាប់ខ្លួន

> *រាជអាវុធហត្ថបានចាប់ខ្ញុំ...ពួកគេវាយដំខ្ញុំ ទាត់ធាក់ខ្ញុំ នៅពេលចាប់ខ្ញុំនៅក្នុងវត្តមួយ... បន្ទាប់ពួកគេវាយពួកខ្ញុំមក គេក៏បានបញ្ជូនពួកខ្ញុំទៅកាន់មន្ទីរឃុំឃាំងរបស់កងរាជអាវុធហត្ថ —ទន្លាប់បាននិយាយដូច្នេះ*[47]

របាយការណ៍ដែលបានប្រមូលចងក្រងដោយអង្គការឃ្លាំមើលសិទ្ធិមនុស្ស បង្ហាញថាផ្តើមពីការជួបគ្នាជាលើកដំបូងជាមួយនគរបាល រហូតដល់ការឃុំឃាំងនៅកន្លែងនគរបាល ការវាយដំដ៏ធ្ងន់ធ្ងរនិងអំពើហិង្សាជាច្រើនទម្រង់គឺកើតមានឡើងជាធម្មតា។ អតីតអ្នកជាប់ឃុំឃាំងនិយាយថានគរបាលប្រើប្រាស់ទារុណកម្មជាច្រើនទម្រង់រូបភាព ដូចជាការរៀបចំឆក់ចរន្តអគ្គិសនី ឬវាយនឹងស្ពាយកាំភ្លើង ដើម្បីបង្ខំឱ្យអ្នកទាំងនោះសារភាព ឬបង្ហាញព័ត៌មាន។[48] តាមធម្មតា នគរបាលធ្វើការជំរិតទារប្រាក់ពីអ្នកទាំងនោះបន្ទាប់ពីចាប់ខ្លួន។ ប្រជាពលរដ្ឋត្រូវបានគេចាប់ ខ្លួនជាញឹកញាប់ដោយគ្មានដីកាឬមូលហេតុសមស្របឡើយ ដោយមិនប្រាប់នូវហេតុផលចាប់ខ្លួនពួកគេ ឬត្រូវបានគេកុហកអំពីហេតុផលនៃការចាប់ខ្លួនពួកគេ។ ពួកគេមិនទទួលបានមេធាវី អំឡុងពេលស្ថិតក្រោមការឃុំឃាំងរបស់នគរបាល ឬអំឡុងពេលស្ថិតនៅក្នុងមជ្ឈមណ្ឌលឃុំឃាំងជាបន្ទាប់នោះ។ នគរបាលក្នុង

---

47 អង្គការឃ្លាំមើលសិទ្ធិមនុស្ស សម្ភាសទន្លាប់ - ខេត្តបន្ទាយមានជ័យ- ខែមិថុនាឆ្នាំ២០០៩

48 ការប្រើប្រាស់ទារុណកម្មដ៏រាលដាលរបស់នគរបាល ត្រូវបានកត់ត្រាទុកដោយអង្គការសិទ្ធិមនុស្សផ្សេងៗនៅក្នុងប្រទេសកម្ពុជា។ ឧទាហរណ៍ សូមមើលអង្គការលីកាដូ "ទារុណកម្មក្នុងការឃុំឃាំងរបស់នគរបាល" (២០០៣) ទំព័រទី៩ — គេហទំព័រ www.licadho-cambodia.org/reports/files/372003 percent20torture%20briefing%20paper.pdf ; LICADHO, "ស្ថានភាពពន្ធនាគារក្នុងប្រទេសកម្ពុជា ២០០៨ :ស្ត្រីភេទក្នុងពន្ធនាគារ" ២០០៨ www.licadho-cambodia.org/reports/files/129LICADHOPrisonWomen2008ENG.pdf.

ប្រទេសកម្ពុជាជាញឹកញយចាប់ខ្លួនអ្នកប្រើប្រាស់គ្រឿងញៀន តាមសំណូមពររបស់អាណាព្យាបាល ឬសាច់ញាតិដទៃទៀត។ ពុំមានការការពារណាដែលធានាកុំឱ្យសមាជិកគ្រួសារសម្តែងនូវភាពអាម៉ាស់និង/ឬបំណងប្រាថ្នា ដើម្បីធ្វើឱ្យសមាជិកគ្រួសារណាម្នាក់ ឱ្យឃ្លាតឆ្ងាយពីជីវិតរបស់ពួកគេក្នុងរយៈពេលមួយទេ។

ប្រជាពលរដ្ឋកម្ពុជាដែលប្រើប្រាស់គ្រឿងញៀន ត្រូវបានចាប់ខ្លួនដោយសារការប្រើប្រាស់គ្រឿងញៀននិងភាពអនាថា ប៉ុន្តែជាញឹកញាប់ត្រូវបានចាប់ខ្លួន ក្នុងការបោសសម្អាតតាមកាលកំណត់របស់នគរបាលចំពោះជនដែលត្រូវបានចាត់ទុកថាជាជនដែល"សង្គមមិនរាប់អាន"។ ការឡោមព័ទ្ធចាប់បែបនេះ បានកើតឡើងជាប្រចាំនៅក្នុងទីក្រុងភ្នំពេញជាច្រើនឆ្នាំ ដែលជាញឹកញាប់ធ្វើនៅមុនពេលពិធីបុណ្យជាតិឬកិច្ចប្រជុំអន្តរជាតិសំខាន់ៗ។ បុគ្គលិកមន្ទីរសង្គមកិច្ច រាជធានីភ្នំពេញជានិច្ចកាលសហការជាមួយនគរបាលក្រុងនិងខណ្ឌនិងអាជ្ញាធរស៊ីវិល ដឹកនាំឆ្មក់ចាប់ទាំងនេះ។ យោងតាមសេចក្តីរាយការណ៍សារព័ត៌មាន អភិបាលរងខណ្ឌម្នាក់របស់សាលាក្រុងភ្នំពេញ បានផ្តល់ហេតុផលអំពីការបោសសម្អាតតាមដងវិថីនៅក្នុងខែឧសភាឆ្នាំ២០០៩ ដោយថ្លែងថាអ្នកដែលត្រូវបានចាប់ដោយនគរបាលគឺជាជនដែល"ធ្វើឱ្យទីក្រុងកខ្វក់។ យើងប្រមូលពួកគេ ដើម្បីធ្វើការបោសសម្អាតទីក្រុង"។[49]

[49] អភិបាលរងខណ្ឌដូនពេញ ពេជ្រ សុជាតា ត្រូវបានដកស្រង់សម្តីក្នុងអត្ថបទរបស់ឆន ចាន់ស៊ុ និង Clancy McGilligan "អ្នកបម្រើផ្លូវភេទ អ្នកគ្មានផ្ទះសម្បែងត្រូវបានបោសសម្អាតពីខណ្ឌដូនពេញ" *ឌឹ ភែមបូឌា ដេលី*— ថ្ងៃទី២២ ឧសភា ឆ្នាំ២០០៩— ទំព័រទី១



ឡានរបស់សង្គមកិច្ចដែលប្រើសម្រាប់ឡោមព័ទ្ធចាប់ប្រជាពលរដ្ឋដែលចាត់ទុកថាជាជនដែល "សង្គមមិនរាប់អាន" ដើម្បីដឹកពួកគេទៅកាន់មជ្ឈមណ្ឌលសង្គមកិច្ចនានានៅជុំវិញភ្នំពេញ។© អង្គការលីកាដូ ឆ្នាំ២០០៨

ដោយរងនូវការប្រព្រឹត្តយ៉ាងមាក់ងាយ អ្នកប្រើប្រាស់គ្រឿងញៀន ត្រូវបានបដិសេធនូវសិទ្ធិជាមូលដ្ឋានជាទម្លាប់នៅពេលចាប់ខ្លួន។ ទៀបមានអាយុ១៤ឆ្នាំ បានរាយការណ៏អំពីការរងនូវការវាយដំនិងឆក់ចរន្តអគ្គិសនី នៅក្នុងការឃុំឃាំងរបស់នគរបាល ដើម្បីជម្រិតយកចម្លើយសារភាពៈ-

ខ្ញុំកំពុងដេកនៅក្នុងបរិវេណវត្តនៅកណ្តាលវាល... ប៉ូលិសបានសួរខ្ញុំថា "តើហ្វែងបានលួចកញ្ចក់ឡានគេទេ?" ។ ខ្ញុំបាននិយាយថា "ខ្ញុំមិនបានលួចទេ"។ បន្ទាប់មកពួក

គេបានចាប់ខ្ញុំ ហើយវាយខ្ញុំ។ ដោយសារតែពួកគេវាយខ្ញុំ ខ្ញុំបានកុហកហើយនិយាយថាខ្ញុំបានលួចកញ្ចក់នោះ។ ពួកគេបានឆក់ខ្ញុំដោយប្រើចរន្តអគ្គិសនី ហើយវាយខ្ញុំនឹង"ក្ដោ" (ប្រភេទដំបងរបស់នគរបាល)...។ ប៉ូលិសដែលឆក់ខ្ញុំនោះ មានរាងខ្ពស់ស្រឡះ សក្តិ៥ ហើយកាន់អាយកូម។ ដំបូងខ្ញុំបានប្រាប់គាត់ថាខ្ញុំអត់ដឹងអីទេ ហើយគាត់បាននិយាយស្រែកថា "អាក្មេងនេះក្បាលរឹងមែន" ហើយបានទាញយកដំបងឆក់។ ឃើញដូច្នេះ ខ្ញុំបាននិយាយថាខ្ញុំបានលួចកញ្ចក់ឡានមែន។ តាមពិតទៅខ្ញុំមិនបានលួចទេ។ ខ្ញុំខ្លាច...ពួកគាត់ឆក់ខ្ញុំម្ដងៗ។ នេះជាស្លាកស្នាមឆក់នៅលើកំភួនដៃខ្ញុំ។ ខ្ញុំដេកសន្លប់ ហើយគេចាក់ទឹកមកលើខ្ញុំឱ្យដឹងខ្លួនវិញ។ ខ្ញុំឃើញបែកផ្កាភ្លើងព្រាកៗ។ ឈឺណាស់។ ខ្ញុំឡើងញ័រខ្លួនអស់ហើយពេលឆក់ម្ដងៗ។[50]

ក្រញូង មានអាយុ១៨ឆ្នាំ បានពិពណ៌នាអំពីការទទួលរងទារុណកម្មពីសំណាក់រាជអាវុធហត្ថបន្ទាប់ពីខ្លួនជក់ "យ៉ាម៉ា" ជាមួយមិត្តម្នាក់ដើម្បីជម្រិតយកព័ត៌មានអំពីអ្នកផ្គត់ផ្គង់គ្រឿងញៀនឱ្យទៅគាត់ :-

គេបានយកពួកខ្ញុំទៅកន្លែងសួរចម្លើយមួយ គឺនៅក្នុងបន្ទាយប៉ែអឹម ហើយចាប់ផ្ដើមសួររក "តើអ្នកណាជាអ្នកលក់?"(អ្នកចែកចាយគ្រឿងញៀន)។ គឺនៅក្នុងបន្ទាយប៉ែអឹម។ គេបានសួរខ្ញុំអស់ពេលពីរម៉ោង... ខ្ញុំមិនបាននិយាយប្រាប់គេថាអ្នកណាជាអ្នកលក់ដូច្នេះគេវាយខ្ញុំ។ គេធាក់ខ្ញុំចំកណ្ដាលមុខប្រាំមួយដង និងពីក្រោយខ្នងនិងឆ្អឹងជំនី។ គេធាក់ខ្ញុំរហូតខ្ញុំដួល។ គេបានលើកខ្ញុំឡើងហើយវាយខ្ញុំនឹងស្ទ័យកាំភ្លើងអាកា។[51]

ដួងចែមមិនត្រូវបានគេប្រាប់ពីហេតុផលចាប់ខ្លួនគាត់ទេ និងមិនបានផ្ដល់សិទ្ធិឱ្យគាត់រកមេធាវីការពារដែរ។ គាត់បានពិពណ៌នាអំពីការវាយដំ ដែលគាត់បានទទួលពីនគរបាល និងចម្លើយសារភាពជាបន្តបន្ទាប់ដែលគេបានបង្ខំឱ្យគាត់ចុះហត្ថលេខា។

---

[50] អង្គការឃ្លាំមើលសិទ្ធិមនុស្ស សម្ភាសឡេប — កម្ពុជា ខែមិថុនា ឆ្នាំ២០០៩

[51] អង្គការឃ្លាំមើលសិទ្ធិមនុស្ស សម្ភាសក្រញូង — កម្ពុជា ខែមិថុនា ឆ្នាំ២០០៩

ប៉ូលិសបានសួរខ្ញុំថាខ្ញុំបានលួចរបស់ឬអត់។ ខ្ញុំឆ្លើយថា "ទេ ខ្ញុំគ្រាន់តែជាអ្នកប្រើគ្រឿងញៀនទេ។ ពួកគេនិយាយថា "ហ្អែងប្រើគ្រឿងញៀន តើបានលុយមកពីណា?"... គេទះកំផ្លៀងខ្ញុំ ហើយធាក់ខ្ញុំចំកណ្តាលពោះ និងឈូសស្មងជើងខ្ញុំជាមួយនឹងស្បែកជើងកវែង។ ស្បែកខ្ញុំចេញឈាម ហើយរលាត់ដាច់។ គេទាត់ខ្ញុំចំកណ្តាលពោះ។ គេវាយខ្ញុំឱ្យសារភាពថា ខ្ញុំលួចឥវ៉ាន់ពីផ្សារ។ ប៉ូលិសពីរនាក់បានវាយខ្ញុំនៅប៉ុស្តិ៍ប៉ូលិសក្នុងបន្ទប់សួរចម្លើយមួយ... ខ្ញុំមិនព្រមសារភាព ប៉ុន្តែប៉ូលិសចេះតែសរសេរ(ចម្លើយសារភាព)... ហើយនៅកន្លែងប៉ូលិស គេបានឱ្យខ្ញុំផ្តិតមេដៃនៅលើរបាយការណ៍នោះ។ ខ្ញុំធ្វើតាមគេទៅ។[52]

ជ្រលងបានរាយការណ៍អំពីការចាប់ខ្លួនគាត់ដោយគ្មានដីកា ឬមូលហេតុសមស្របដោយឆ្មាំសន្តិសុខម្នាក់នៅជិតវត្តភ្នំនៅភ្នំពេញ :-

ខ្ញុំកំពុងដើរពេលយប់ ហើយដើរចេញពីក្លឹបកំសាន្តរាត្រីមួយ។ ខ្ញុំកំពុងអង្គុយលេងជាមួយមិត្តស្រីខ្ញុំ... មិនមានផ្តល់ហេតុផលចាប់ខ្លួនពួកខ្ញុំទេ។ ពួកគេនិយាយថា "ពួកហ្អែងដើរលេងយប់។ ដើរលេងយប់អត់ល្អទេ"។ ឆ្មាំសន្តិសុខដែលចាប់ខ្ញុំ និយាយអញ្ចឹង... ខ្ញុំមិនមានមេធាវីការពារទេ"។[53]

ព័ត៌មានបានពីអតីតអ្នកជាប់ឃុំឃាំង ដែលធ្វើសម្ភាសដោយអង្គការឃ្លាំមើលសិទ្ធិមនុស្សបង្ហាញថា នគរបាលតែងតែបកស្រាយខុសនូវគោលបំណងចាប់ខ្លួន។ ឧទាហរណ៍ ឬស្សីបានពន្យល់ប្រាប់អំពីរូបគាត់ដែលត្រូវយកទៅឃុំឃាំងរបស់នគរបាល ដោយលេសមិនពិតនិងសន្យាថា នឹងត្រូវ

---

[52] អង្គការឃ្លាំមើលសិទ្ធិមនុស្ស សម្ភាសដួងចែម — កម្ពុជា ខែមិថុនា ឆ្នាំ២០០៩

[53] អង្គការឃ្លាំមើលសិទ្ធិមនុស្ស សម្ភាសជ្រលង — ភ្នំពេញ ខែកក្កដា ឆ្នាំ២០០៩

ដោះលែងភ្លាមៗ ទោះបីជារូបគាត់ត្រូវបានជាប់ឃុំឃាំងជាបន្តបន្ទាប់មក នៅក្នុងមជ្ឈមណ្ឌលឃុំឃាំងគ្រឿងញៀនយ៉ាងណាក៏ដោយ ។

> នៅម៉ោង១១ព្រឹក គេបានមកចាប់ខ្លួនខ្ញុំ។ មានប៉េអឹមពីរនាក់ម្នាក់រាងស្តើង ហើយម្នាក់ទៀតរាងធាត់។ ប៉េអឹមម្នាក់និយាយថា "អាល្អិត ហ្វែងបានរៃតប់គ្នា។ ឥឡូវអញសុំសួរហ្វែងនៅកន្លែងអញ។ ហើយអញនឹងឱ្យហ្វែងទៅវិញ"។ តែនៅពេលគេចាប់ខ្ញុំ គេបានបញ្ជូនខ្ញុំទៅ(កាន់មណ្ឌល) អត់មានដោះលែងខ្ញុំទេ។ គេបានកោរសក់ក្បាលខ្ញុំ... ខ្ញុំមិនដែលបានជួបមេធាវីទេ។[54]

អតីតអ្នកជាប់ឃុំឃាំងបាននិយាយប្រាប់អង្គការឃ្លាំមើលសិទ្ធិមនុស្សថា នគរបាលខ្លះទាមទារសំណូកជាថ្នូរនឹងការដោះលែងមនុស្សពីការឃុំឃាំងរបស់ខ្លួន។ តាមរយៈវិធីបែបនេះ អ្នកខ្លះមានលទ្ធភាពទិញទឹកចិត្តនគរបាលដើម្បីរួចខ្លួនពីការឃុំឃាំង (និងការឃុំឃាំងបន្ទាប់មកនៅក្នុងមជ្ឈមណ្ឌលឃុំឃាំងគ្រឿងញៀន)។ ឧទាហរណ៍ថោះបានពិពណ៌នាអំពីវិធីដែលគាត់ត្រូវបានដោះលែងពីការឃុំឃាំងរបស់នគរបាលបន្ទាប់ពីការចាប់ខ្លួនដោយសារការប្រើប្រាស់គ្រឿងញៀន :-

> គេបានបញ្ជូនខ្ញុំទៅកាន់ស្នងការនគរបាលខេត្ត។ គេបាននិយាយថាពួកយើងជាអ្នកប្រើប្រាស់គ្រឿងញៀន :- តាមពិតគឺមែន... គេបានទូរស័ព្ទហៅឪពុកម្តាយ។ ម្តាយរបស់ខ្ញុំនិងម្តាយពួកម៉ាកខ្ញុំ បានចូលលុយគ្នាសរុបគឺអស់២០០ដុល្លារសម្រាប់ដោះលែងមនុស្សប្រាំនាក់[55] ។

អតីតអ្នកជាប់ឃុំឃាំងផ្សេងៗទៀត បាននិយាយប្រាប់អង្គការឃ្លាំមើលសិទ្ធិមនុស្សអំពីវិធីដែលពួកគេគ្មានលទ្ធភាពទិញសេរីភាពរបស់ពួកគេទេ។ ពុទ្រាបាននិយាយថា រូបគាត់ត្រូវគេបាន

---

[54] អង្គការឃ្លាំមើលសិទ្ធិមនុស្ស សម្ភាសឫស្សី — ខេត្តបាត់ដំបង ខែមិថុនា ឆ្នាំ២០០៩

[55] អង្គការឃ្លាំមើលសិទ្ធិមនុស្ស សម្ភាសថោះ — កម្ពុជា ខែមិថុនា ឆ្នាំ២០០៩

បញ្ជូនទៅកាន់មជ្ឈមណ្ឌលឃុំឃាំងគ្រឿងញៀន ពីព្រោះគាត់គ្មានលទ្ធភាពបង់ប្រាក់ជំរិត ដើម្បីឱ្យគេដោះលែងរូបគាត់ចេញពីការឃុំខ្លួនរបស់នគរបាលទេ។ គាត់បានពន្យល់ដូច្នេះថា :-

> [នគរបាល] មិនបាននិយាយប្រាប់ខ្ញុំអំពីមូលហេតុដែលគេចាប់ខ្លួនខ្ញុំទេ។ ខ្ញុំមិនដែលជួបមេធាវីឡើយ... ខ្ញុំមិនញៀនគ្រឿងញៀនទេ។ ខ្ញុំមានការពិបាករកកន្លែងដេក និងគ្មានអាហារ... ថៅកែរបស់ខ្ញុំមិនអាច"ធានា"ខ្ញុំបាន(បង់ប្រាក់ជំរិត) ហេតុដូច្នេះគេបានចោទខ្ញុំពីបទលួច។[56]

តុលាបាននិយាយថាអ្នកចែកចាយគ្រឿងញៀនម្នាក់ ដែលត្រូវបានចាប់ខ្លួនជាមួយគាត់ មានលទ្ធភាពបង់ប្រាក់ដើម្បីដោះលែងរូបនាង។ ប៉ុន្តែគាត់មិនអាចបង់ប្រាក់ (ហើយបន្ទាប់មកត្រូវបានឃុំឃាំងនៅមណ្ឌលឱកាសខ្ញុំ:-

> គេបានដោះលែងស្ត្រីម្នាក់ដើម្បីប្រាក់៥០ដុល្លារ : ប៉ូលិសបានឱ្យនាងខ្ចីទូរស័ព្ទដៃដើម្បីហៅមិត្តភក្តិ... នៅពេលមិត្តភក្តិនាំយកប្រាក់មកដល់ ប៉ូលិសបានឱ្យគាត់ចេញទៅ។ គេមិនដោះលែងខ្ញុំទេ ពីព្រោះខ្ញុំគ្មានលុយ។[57]

អតីតអ្នកជាប់ឃុំឃាំងបាននិយាយប្រាប់អង្គការឃ្លាំមើលសិទ្ធិមនុស្សថាការចាប់ខ្លួនអ្នកប្រើប្រាស់គ្រឿងញៀនជាញឹកញាប់ធ្វើតាមការបង់ប្រាក់របស់ឪពុកម្តាយ ឬសាច់ញាតិ ឱ្យនគរបាលអនុវត្តការចាប់ខ្លួនពិតប្រាកដ ព្រមទាំងសម្រាប់ការឃុំឃាំងក្នុងរយៈពេលមួយបន្ទាប់មក។ សុក្រម អាយុ២៥ឆ្នាំ បានពន្យល់ថាម្តាយរបស់គាត់បានបង់ប្រាក់ឱ្យរាជអាវុធហត្ថនៅស៊ីសូផុន ដើម្បីធ្វើការចាប់ខ្លួនគាត់ :-

---

[56] អង្គការឃ្លាំមើលសិទ្ធិមនុស្ស សម្ភាសពុទ្រា — ភ្នំពេញ ខែឧសភា ឆ្នាំ២០០៩

[57] អង្គការឃ្លាំមើលសិទ្ធិមនុស្ស សម្ភាសតុលា— ភ្នំពេញ ខែឧសភា ឆ្នាំ២០០៩

ឪពុកម្តាយខ្ញុំបានហៅប៉េអឹមចាប់ខ្លួនខ្ញុំ។ គាត់ថាខ្ញុំជាអ្នកប្រើប្រាស់គ្រឿងញៀន ហើយបង្កបញ្ហាដល់ពួកគាត់។ ប៉េអឹមមកចាប់ខ្ញុំនៅក្នុងផ្ទះ នៅពេលខ្ញុំកំពុងដេក នៅប្រហែលម៉ោង១០យប់។ ខ្ញុំបានដឹងជាមុនថាគេនឹងមកចាប់ខ្ញុំ ហើយបញ្ជូនខ្ញុំទៅកាន់មណ្ឌលប៉េអឹម។ ម្តាយរបស់ខ្ញុំបានប្រាប់ខ្ញុំថាគាត់បានបង់ប្រាក់អស់ជាង ២០០ដុល្លារដើម្បីចាប់ខ្ញុំ។ ពួកគាត់បង់ប្រាក់៥០ដុល្លារក្នុងមួយខែ សម្រាប់ថ្លៃស្នាក់នៅក្នុងមណ្ឌល។ ខ្ញុំមិនដែលជួបមេធាវីទេ។ [អាវុធហត្ថ]បានវាយធ្វើបាបខ្ញុំពេលដែលខ្ញុំ រើបម្រះមិនព្រមទៅ។[58]

ស្រឡៅ អាយុ២៣ឆ្នាំ បានពន្យល់ប្រាប់ថានគរបាលបានចាប់ខ្លួនគាត់ ដែលសង្ស័យដោយស្មានៗថាបានលួចម៉ូតូ ក៏ប៉ុន្តែតាមពិតឪពុកម្តាយរបស់គាត់បានបង់ប្រាក់ដើម្បីចាប់ខ្លួនគាត់សោះ។ នៅពេលគាត់បានមកដល់មជ្ឈមណ្ឌល គេបានប្រាប់គាត់ថាឪពុកម្តាយរបស់គាត់បានបង់ប្រាក់អស់ ១,៥០០បាត(ប្រហែល ៤៥ ដុល្លារសហរដ្ឋ)សម្រាប់ថ្លៃចាប់ខ្លួន។[59] គុហា អាយុ ២៦ ឆ្នាំបានរាយការណ៍អំពីការចាប់ខ្លួនដោយកងរាជអាវុធហត្ថ នៅពេលម្តាយរបស់គាត់បានបង់ប្រាក់ឱ្យពួកគេធ្វើដូច្នេះ។ រាជអាវុធហត្ថនិយាយកុហកគាត់ពីមូលហេតុចាប់ខ្លួន តែពួកគេបានទម្លាយហេតុផលពិតនៅពេលដែលគាត់ស្ថិតក្រោមការឃុំខ្លួនរបស់រាជអាវុធហត្ថ នៅក្នុងមជ្ឈមណ្ឌលឃុំឃាំងគ្រឿងញៀន :-

ប៉េអឹមបួននាក់បានមកដល់ផ្ទះរបស់ខ្ញុំ។ ពួកគេនិយាយថា ពួកគេហៅខ្ញុំឱ្យទៅកាន់បន្ទាយអាវុធហត្ថ ដើម្បីបំភ្លឺបញ្ហាជម្លោះក្នុងភោជនីយដ្ឋានមួយ ដែលជាជម្លោះរវាងខ្ញុំនិងមិត្តភក្តិម្នាក់...ពួកគេបាននិយាយថាប្រសិនបើខ្ញុំមិនទៅតាមទេ គេនឹងវាយខ្នោះដៃ។ ខ្ញុំក៏បានទៅតាមពួកគេតាមសម្រួល។ ពួកគេបានគំរាមកំហែងខ្ញុំចង់ដាក់ខ្នោះដៃខ្ញុំ ប្រសិនបើខ្ញុំមិនព្រមទៅ។ ពួកគេអត់មានដីកាចាប់ខ្លួនទេ។

---

[58] អង្គការឃ្លាំមើលសិទ្ធិមនុស្ស សម្ភាសសុក្រម— ស៊ីសូផុន ខែមិថុនា ឆ្នាំ២០០៩

[59] អង្គការឃ្លាំមើលសិទ្ធិមនុស្ស សម្ភាសស្រឡៅ— បន្ទាយមានជ័យ ខែមិថុនា ឆ្នាំ២០០៩

ខ្ញុំមិនដែលបានជួបមេធាវីទេ...ពួកគេមិនបាននិយាយបាប់ខ្ញុំអ្វីទាំងអស់អំពីគ្រឿងញៀននៅផ្ទះ[របស់ខ្ញុំ] គឺនិយាយតែពីជម្លោះ។ [ក្រោយមក] ពេលកំពុងជិះនៅក្នុងឡាន ពួកគេបានចោទខ្ញុំថាបានប្រើគ្រឿងញៀន។ ពួកគេសួរខ្ញុំថា "តើហ្វែងប្រើគ្រឿងញៀនមែនទេ? ប្រាប់ត្រង់មក បើមិនអញ្ចឹងទេ អញនឹងវាយហ្វែង"។ ខ្ញុំបាននិយាយថាខ្ញុំបានប្រើមែន។ តាមពិតខ្ញុំបានឈប់ប្រើគ្រឿងញៀន អស់រយៈពេលបីខែហើយមុនពេលចាប់ខ្លួន.... ។[៦០]

បុគ្គលិកអង្គការក្រៅរដ្ឋាភិបាលម្នាក់ ដែលជំនាញខាងកិច្ចការគ្រឿងញៀននៅក្នុងប្រទេសកម្ពុជា បានពន្យល់ដល់អង្គការឃ្លាំមើលសិទ្ធិមនុស្សថា :-

ទោះបីខ្ញុំយល់ដឹងទាំងស្រុងអំពីទុក្ខកង្វល់របស់ក្រុមគ្រួសារក៏ដោយ ដោយសារខ្ញុំយល់ពីភាពរឹករវ...ការប្រើប្រាស់គ្រឿង....ដែលអាចបង្កដល់ក្រុមគ្រួសារ ប៉ុន្តែត្រង់នេះមិនមែនមានន័យថា ត្រូវតែគ្រួសារបញ្ជូនបុគ្គលនោះទៅទីកន្លែងឃុំឃាំងដោយគ្មាននីតិវិធីត្រឹមត្រូវនោះទេ។ ជាចាំបាច់ត្រូវមានយន្តការដើម្បីផ្តល់ការគាំទ្រដល់បណ្តាញក្រុមគ្រួសារទៅតាមសិទ្ធិស្មើគ្នាចំពោះមុខច្បាប់ ។[៦១]

## ការរំលោភលើស្ត្រីនិងកុមារី

នៅពេលបច្ចុប្បន្ននេះ ពុំមានទីកន្លែងឃុំឃាំងជាពិសេសសម្រាប់ស្ត្រីនិងកុមារីដែលប្រើប្រាស់គ្រឿងញៀនទេ។ មន្ត្រីរដ្ឋាភិបាលកម្ពុជាបាននិយាយប្រាប់ប្រព័ន្ធផ្សព្វផ្សាយសារព័ត៌មានថា ពួកគេ

---

60 អង្គការឃ្លាំមើលសិទ្ធិមនុស្ស សម្ភាសកុហា— កម្ពុជា ខែកក្កដា ឆ្នាំ២០០៩

61 អង្គការឃ្លាំមើលសិទ្ធិមនុស្ស សម្ភាសបុគ្គលិកអង្គការក្រៅរដ្ឋាភិបាលមួយ-ភ្នំពេញ ខែឧសភា ឆ្នាំ ២០០៩

មានផែនការបង្កើតគ្រឹះស្ថានជាពិសេសសម្រាប់ស្ត្រី។ [62] ក៏ប៉ុន្តែ នៅក្នុងបច្ចុប្បន្នកាល ស្ត្រីដែលប្រើប្រាស់គ្រឿងញៀនត្រូវបានចាប់ខ្លួនជាញឹកញាប់ ប៉ុន្តែកម្របញ្ជូនពួកគេទៅកាន់មជ្ឈមណ្ឌលឃុំឃាំងគ្រឿងញៀន។ ដូចបានធ្វើការកត់សម្គាល់ ក្នុងចំណោមមនុស្ស២៣៨២នាក់ដែលបានបញ្ជូលទៅក្នុងមជ្ឈមណ្ឌលដែលគ្រប់គ្រងដោយរដ្ឋាភិបាលក្នុងឆ្នាំ២០០៨ គឺមាន១៥នាក់គត់(ឬ0.៦ភាគរយ) គឺជាស្ត្រី។[63]

ទោះបីជាប់ឃុំឃាំងដោយកម្រនៅក្នុងមជ្ឈមណ្ឌលឃុំឃាំងគ្រឿងញៀនក៏ដោយ ស្ត្រីនិងកុមារីដែលប្រើប្រាស់គ្រឿងញៀន ត្រូវបានចាប់ខ្លួនជាញឹកញាប់ ហើយប្រឈមមុខនឹងការឃុំឃាំងនៅក្នុងមជ្ឈមណ្ឌល (ដូចជាមជ្ឈមណ្ឌលសង្គមកិច្ច ប៉ុន្តែមណ្ឌលទាំងនេះមិននៅដាច់ដោយឡែកទេ) ពីព្រោះពួកគេគឺជាជនគ្មានលំនៅឋាន អ្នកសុំទាន ស្ត្រីបម្រើផ្លូវភេទ ឬជាសមាជិកក្រុមផ្សេងៗដែល "សង្គមមិនរាប់អាន"។

ស្ត្រីដែលប្រើប្រាស់គ្រឿងញៀន នឹងអាចត្រូវគេបង្ខិតបង្ខំតាមរយៈសំណូក ឬការរួមភេទដើម្បីជាថ្នូរដោះលែងពីការឃុំឃាំងរបស់នគរបាល បន្ទាប់ពីការចាប់ខ្លួន។ ឧទាហរណ៍ រកាបានពិពណ៌នានូវវិធីដែលនាងត្រូវបានដោះលែងមកវិញបន្ទាប់ពីប្តីរបស់នាងបង់ប្រាក់សំណូកទៅឱ្យនគរបាល :-

> ខ្ញុំបានទៅទិញ "ស" (ហេរ៉ូអ៊ីន)។ ពេលខ្ញុំទិញហើយដើរចេញពីផ្ទះនោះ គេក៏ចាប់ខ្ញុំតែម្តង... ប៉ូលិសបាននិយាយថា "ប្រសិនបើមានលុយ ខ្ញុំឱ្យទៅ។ បើអត់លុយទេ

---

62 ឧទាហរណ៍ អភិបាលក្រុងភ្នំពេញ លោកកែប ជុតិមា ត្រូវបានដកស្រង់សម្តីក្នុងខែសីហា ឆ្នាំ២០០៩ ដោយបាននិយាយថា "យើងនឹងបង្កើតមជ្ឈមណ្ឌលស្តារនីតិសម្បទាគ្រឿងញៀនសម្រាប់ស្ត្រីនៅទីក្រុងភ្នំពេញ" : "សារធាតុញៀនជាង១០0.000 គ្រាប់ ត្រូវបានបំផ្លាញនៅកម្ពុជា" ភ្នាក់ងារសារព័ត៌មានស៊ីនហួរ — ថ្ងៃទី២0 ខែសីហា ឆ្នាំ២០០៩។ នៅពេលបច្ចុប្បន្ន សាលាក្រុងភ្នំពេញគ្រប់គ្រងមជ្ឈមណ្ឌលឱកាសខ្ញុំនៅជាយទីរាជធានីភ្នំពេញ។

63 របាយការណ៍ពី the National Residential Treatment Center Minimum Dataset: 2008," មជ្ឈមណ្ឌលព័ត៌មានគ្រឿងញៀន — អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន - បានធ្វើបទបង្ហាញនៅកិច្ចប្រជុំក្រុមការងារបច្ចេកទេសគ្រឿងញៀន/អេដស៍(DHA) នៅសណ្ឋាគារណាហ្គា នៅថ្ងៃទី៤ មិថុនា ឆ្នាំ ២០០៩ (ច្បាប់ថតចម្លងរក្សាទុកជាឯកសារនៅអង្គការឃ្លាំមើលសិទ្ធិមនុស្ស)។ ការបញ្ចូលពីខែកក្កដា-ធ្នូ ២៩៩៧ មាន១.១ ជាស្ត្រី។ ចំនួនមនុស្សដែលបានបញ្ចូលចាប់ពីខែកក្កដាដល់ខែធ្នូ ២០០៧ មាន៧៤0នាក់ :- អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន "របាយការណ៍ស្តីពីលទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀនក្នុងប្រទេសកម្ពុជា ឆ្នាំ២០០៧" ខែ មិថុនា ឆ្នាំ២០០៨ ទំព័រ ៧៥។

> ខ្ញុំបញ្ជូនទៅគុក" ។ ខ្ញុំបាននិយាយទៅវិញថា "ពូនិយាយជាមួយប្តីខ្ញុំសិនទៅម៉ោង ១២" ។ រឿងហ្នឹងកើតឡើងបីថ្ងៃមកហើយ ។ ប្តីរបស់ខ្ញុំបានទៅរកលុយបង់ឱ្យប៉ូលិស ១០ដុល្លារ ។ នៅម៉ោង៥ល្ងាច ពេលប្តីខ្ញុំត្រឡប់មកវិញ ហើយរកបាន ១០ដុល្លារ ។ ពួកគេក៏ដោះលែងខ្ញុំទៅ ។[64]

មីនាជាស្ត្រីម្នាក់ស្ថិតក្នុងវ័យពាក់កណ្តាល២០ឆ្នាំ និងជាអ្នកប្រើប្រាស់គ្រឿងញៀន ។ គាត់បានពន្យល់ប្រាប់អំពីនគរបាលពីរនាក់បានរំលោភសេពសន្ថវៈនាង ។

> [បន្ទាប់ពីចាប់ខ្លួន] ប៉ូលិសរុករកពេញខ្លួនរបស់ខ្ញុំ ។ ពួកគេយកលុយខ្ញុំ និងដកហូតគ្រឿងញៀនរបស់ខ្ញុំទុក... ពួកគេដឹងថាខ្ញុំអត់លុយ គេក៏មិនសុំឱ្យខ្ញុំបង់លុយដែរ [សម្រាប់សូក]... ពួកគេនិយាយថា "បើអត់លុយ ម៉េចមិនទៅដើរលេងជាមួយខ្ញុំទៅ? ចាំខ្ញុំដោះលែង" ។ រឿងនេះកើតឡើងតែម្តងចំពោះខ្ញុំ....ពួកគេ [នគរបាល] បានដឹកខ្ញុំទៅផ្ទះសំណាក់មួយ... តើខ្ញុំត្រូវបដិសេធមិនព្រមដេកជាមួយគាត់ម្តេចកើត ។ ខ្ញុំត្រូវតែធ្វើដូច្នេះ ។ មានមេប៉ូលិសពីរនាក់ [ដែលខ្ញុំបានរួមភេទជាមួយ] ម្នាក់ម្តងៗ ។ បន្ទាប់មកគេឱ្យខ្ញុំត្រឡប់ទៅផ្ទះវិញ ។[65]

## បទដ្ឋានអនុវត្តន៍

## ការឃាត់ខ្លួនតាមអំពើចិត្ត

ប្រទេសកម្ពុជាជាភាគីនៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដែលហាមឃាត់ការឃាត់ខ្លួន ឬការឃុំខ្លួនតាមអំពើចិត្ត ។[66] ការហាមការឃាត់ខ្លួន ឬការឃុំខ្លួន នេះមាន

---

64 អង្គការឃ្លាំមើលសិទ្ធិមនុស្ស សម្ភាសរកា-ភ្នំពេញ ខែឧសភា ឆ្នាំ ២០០៩

65 អង្គការឃ្លាំមើលសិទ្ធិមនុស្ស សម្ភាសមីនា-ភ្នំពេញ ខែឧសភា ឆ្នាំ ២០០៩

66 កតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ – អ.ស.ប ឯកសារ ក/៦៣១៦ (១៩៦៦) ចូលជាធរមាន ថ្ងៃទី២៣ មីនា ១៩៧៦ ផ្តល់សច្ចាប័នដោយកម្ពុជានៅថ្ងៃទី២៦ ឧសភា ១៩៩២ ។ ផ្នែកខ្លះនៃមាត្រាទី៩ចែងថាៈ- ១. ជនគ្រប់រូបមានសិទ្ធិមានសេរីភាព និងសន្តិសុខផ្ទាល់ខ្លួន ។ គ្មានជនណាម្នាក់ ត្រូវចាប់ខ្លួន ឬឃុំខ្លួនតាមអំពើចិត្ត ។ គ្មានជនណាម្នាក់ ត្រូវដកហូតសេរីភាពបានឡើយ លើកលែងតែមានហេតុផល និងស្របតាមនីតិវិធីដែលមានចែងនៅក្នុងច្បាប់ ។ ២. ជនណាដែលត្រូវបាន

ន័យថាការដកហូតសេរីភាព ទោះបីចែងដោយច្បាប់ក៏ដោយ គឺត្រូវតែចាំបាច់និងមានហេតុផល អាចព្យាករណ៍បាន និងសមាមាត្រទៅនឹងហេតុផលចាប់ខ្លួន។[67] កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ចែងបន្ថែមអំពីជនរងគ្រោះមានសិទ្ធិទាមទារសំណង ដោយសារការឃាត់ខ្លួន ឬឃុំខ្លួនខុសច្បាប់។[68]

ដើម្បីឱ្យការចាប់ឃាត់ខ្លួនមានលក្ខណៈសមហេតុផល ត្រូវមានភស្តុតាងនៅក្នុងដៃ ដើម្បីបង្ហាញដល់អ្នកសង្កេតការថាពិតជាមានមូលដ្ឋានសមហេតុសមផល ដើម្បីធ្វើឱ្យជឿបានថាជនសង្ស័យបានប្រព្រឹត្តបទឧក្រិដ្ឋមែន។[69] កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ តម្រូវឱ្យអាជ្ញាធរចាប់ខ្លួន ប្រាប់អ្នកជាប់ឃុំឱ្យដឹងភ្លាម១អំពីមូលហេតុនៃការចាប់ខ្លួន។[70] កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ បញ្ជាក់អំពីសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការប្រាប់ឱ្យដឹងអំពីបទចោទប្រកាន់ សិទ្ធិទទួលបានជំនួយផ្នែកច្បាប់ និងមិនចោទជាបទឧក្រិដ្ឋមកលើខ្លួន។[71]

---

ចាប់ខ្លួន ត្រូវមានសិទ្ធិឱ្យគេប្រាប់ឱ្យដឹងនៅពេលចាប់ខ្លួន អំពីមូលហេតុនៃការចាប់ខ្លួន និងត្រូវប្រាប់ឱ្យដឹងភ្លាមអំពីការចោទប្រកាន់។ ៣. ជនណាម្នាក់ដែលបានចាប់ខ្លួន ឬឃុំខ្លួនពីបទព្រហ្មទណ្ឌ នឹងត្រូវបាននាំខ្លួនទៅចំពោះមុខចៅក្រម ឬអាជ្ញាធរមួយផ្សេងទៀត ដែលអនុញ្ញាតដោយច្បាប់ឱ្យបំពេញមុខងារតុលាការ ក្នុងរយៈពេលយ៉ាងខ្លីបំផុត និងត្រូវបានជំនុំជំរះក្នុងរយៈពេលសមស្រប ឬត្រូវដោះលែង។

67 នៅក្នុងអត្ថាធិប្បាយរបស់គាត់លើកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ម៉ាន់ ហ្វ្រេត បានបញ្ចូលសារធាតុនៃភាពអយុត្តិធម៌ ភាពមិនអាចព្យាករណ៍ទុកបាន ភាពគ្មានសមហេតុសមផល វិសមិតភាព នៅក្នុងអត្ថន័យតាមអំពើចិត្ត។ ម៉ាន់ ហ្វ្រេត — កតិកាសញ្ញាសហប្រជាជាតិ ស្តីពី ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ :- អត្ថាធិប្បាយលើកតិកាសញ្ញាសហប្រជាជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (2nd rev. ed.)។ Kehl am Rhein: Engel (២០០៥) ទំព័រ២២៥។

68 កតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ – មាត្រាទី៩ (៥) កម្ពុជាបានផ្តល់សច្ចាប័នលើកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ នៅថ្ងៃទី២៦ ឧសភា ១៩៩២។

69 អង្គការសហប្រជាជាតិ — សិទ្ធិមនុស្សក្នុងរដ្ឋបាលយុត្តិធម៌ :-សៀវភៅណែនាំស្តីពីសិទ្ធិមនុស្សសម្រាប់ចៅក្រម ព្រះរាជអាជ្ញា និងមេធាវី (ទីក្រុងញូយ៉ក និងទីក្រុងហ្សឺណែវ :-អង្គការសហប្រជាជាតិ ឆ្នាំ២០០៣) វគ្គទី៥ :- "សិទ្ធិមនុស្ស និងការឃាត់ខ្លួន ការឃុំឃាំងបណ្តោះអាសន្ននិងការឃុំខ្លួនតាមរដ្ឋបាល" ទំព័រ១៧៤

70 កតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ – មាត្រាទី៩ (២)

71 កតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ – មាត្រាទី៩ (៣) និងមាត្រាទី១៤(៣)

ក្រមនីតិវិធីព្រហ្មទណ្ឌប្រទេសកម្ពុជាចែងថា ជនណាក៏ដោយអាចត្រូវចាប់ខ្លួនដោយគ្មានដីកា អំឡុងពេលប្រព្រឹត្តបទឧក្រិដ្ឋ ឬបន្ទាប់ពីប្រព្រឹត្តបទឧក្រិដ្ឋហើយភ្លាមៗ។ [72] បុគ្គលណាម្នាក់ដែលស្ថិតក្រោមការឃុំខ្លួនរបស់នគរបាល ត្រូវបានប្រាប់ឱ្យដឹងជាបន្ទាន់ អំពីមូលហេតុនៃសេចក្តីសម្រេចឃាត់ខ្លួន។[73] តែជាអកុសល ច្បាប់ចែងថាជនសង្ស័យនៃបទឧក្រិដ្ឋ អាចជួបសន្ទនាជាមួយមេធាវី ឬអ្នកផ្សេងទៀត ក្រោយពីការចាប់ខ្លួនបាណ ២៤ម៉ោងរួចមក - វាគឺជារយៈពេលដែលការធ្វើបាប ការរំលោភសេពសន្ថវៈ និងការជម្រិតទារប្រាក់កើតឡើង។[74]

---

[72] ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ — មាត្រា៨៧

[73] មាត្រា ៩៧

[74] មាត្រា ៩៨។ សូមកត់សំគាល់ថាបទបញ្ញត្តិជាបទដ្ឋានអប្បរិមាសម្រាប់គ្រប់គ្រងអ្នកទោស ចែងថា "ត្រូវអនុញ្ញាតឱ្យអ្នកទោស ដែលមិនទាន់បានទទួលការកាត់ទោស រកជំនួយផ្នែកតុលាការឥតគិតថ្លៃ ដូចជាអ្នកច្បាប់ ឬជាស្មាក្តីជាដើម ដើម្បីការពារខ្លួនគេ។ ហើយត្រូវអនុញ្ញាតទីប្រឹក្សាខាងច្បាប់ចូលជួបអ្នកទោសទាំងនោះ ក្នុងគោលដៅរៀបចំការការពារខ្លួន និងផ្តល់ការណែនាំជាសម្ងាត់ដល់អ្នកទោសនោះ"។ បទបញ្ញត្តិជាបទដ្ឋានអប្បរិមារបស់ អ.ស.ប សម្រាប់គ្រប់គ្រងអ្នកទោស ត្រូវបានអនុម័តដោយសមាជលើកដំបូងរបស់សហប្រជាជាតិ ស្តីពីការបង្ការទប់ស្កាត់ឧក្រិដ្ឋកម្ម និងការប្រព្រឹត្តរបស់ជនល្មើស ដែលធ្វើនៅទីក្រុងហ្សឺណែវ ឆ្នាំ១៩៥៥ និងទទួលយល់ព្រមដោយក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គម តាមសេចក្តីសម្រេចចិត្តលេខ (663 C (XXIV) ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ១៩៥៧, និងលេខ 2076 (LXII) ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ១៩៧៧ កថាខ័ណ្ឌ៩៣)។ សូមកត់សម្គាល់ថា មាត្រា១២.២ នៃក្រមអ៊ុនតាក់ (បទបញ្ញត្តិស្តីពីប្រព័ន្ធតុលាការ ច្បាប់ព្រហ្មទណ្ឌ និងនីតិវិធីព្រហ្មទណ្ឌសម្រាប់អនុវត្តនៅប្រទេសកម្ពុជាក្នុងសម័យអន្តរកាល — ថ្ងៃទី១០ ខែកញ្ញា ១៩៩២) បញ្ជាក់ថាការឃុំខ្លួនត្រូវអនុលោមតាមបទបញ្ញត្តិជាបទដ្ឋានអប្បរិមារបស់អ.ស.ប សម្រាប់គ្រប់គ្រងអ្នកទោស

## ទារុណកម្ម ការប្រព្រឹត្តដែលឃោរឃៅនិងអមនុស្សធម៌ និងការប្រើកម្លាំង ដោយមន្ត្រីប្រតិបត្តិច្បាប់

នគរបាលបានប្រព្រឹត្តបទរំលោភយ៉ាងធ្ងន់ធ្ងរមកលើអ្នកជាប់ឃុំឃាំង ដែលឈានឡើងយ៉ាងហោចណាស់ដល់កម្រិតនៃប្រព្រឹត្តកម្ម ឬទណ្ឌកម្មដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប ហើយធ្វើទារុណកម្មជាញឹកញាប់។[75] នគរបាលប្រើប្រាស់ទារុណកម្ម ដើម្បីបង្ខិតបង្ខំអ្នកជាប់ឃុំឃាំងឱ្យសារភាពនិងផ្តល់សក្ខីភាព។ នៅក្នុងការវាយតម្លៃការអះអាង ស្តីពីការរំលោភមាត្រា៧ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ គណៈកម្មាធិការសិទ្ធិមនុស្សបានកំណត់ថាការឆក់ចរន្តអគ្គិសនី គឺដូចគ្នាទៅនឹងទារុណកម្ម ដោយការឆក់ចរន្តអគ្គិសនីត្រូវបានប្រើសម្រាប់សម្រង់យកព័ត៌មាន ឬចម្លើយសារភាព។[76] ការរំលោភសេពសន្ថវៈ ពេលឃុំខ្លួនចាត់ទុកជាទារុណកម្ម។[77] រាល់ការប្រព្រឹត្តខុសទាំងអស់ មកលើអ្នកជាប់ឃុំឃាំង គឺរំលោភលើកាតព្វកិច្ចប្រទេសកម្ពុជាចំពោះកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ និងអនុសញ្ញាប្រឆាំងទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀតដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប។[78]

---

[75] មាត្រា ១ នៃអនុសញ្ញាប្រឆាំងទារុណកម្ម ពាក្យទារុណកម្មត្រូវបានឱ្យនិយមន័យថា "អំពើទាំងឡាយណាដែលនាំឱ្យមានការឈឺចាប់ ឬរងទុក្ខយ៉ាងខ្លាំង ទោះផ្លូវកាយ ឬផ្លូវចិត្តដែលបានបង្កឡើងដោយចេតនាទៅលើជនណាម្នាក់ ក្នុងគោលបំណងទាំងឡាយដូចជា ដោយការទាញយកព័ត៌មាន ឬចម្លើយសារភាពពីជននោះ ឬតតិយជនម្នាក់ ដាក់ទណ្ឌកម្មជននោះចំពោះអំពើណាមួយដែលជននោះ ឬតតិយជនណាម្នាក់បានប្រព្រឹត្ត ឬសង្ស័យថាបានប្រព្រឹត្ត ឬបំភិតបំភ័យ ឬបង្ខិតបង្ខំជននោះ ឬតតិយជនណាម្នាក់ ឬដោយមូលហេតុណាផ្សេងទៀតដោយផ្អែកលើការរើសអើងណាមួយ បើការឈឺចាប់ ឬការរងទុក្ខដោយសារតែតាមការញុះញង់ ឬការព្រមព្រៀង ឬការធ្វើមគំនិតរបស់មន្ត្រីសាធារណៈ ឬជនផ្សេងទៀតដែលបំពេញតួនាទីជាផ្លូវការ។ ពាក្យទារុណកម្មមិនរាប់បញ្ចូលការឈឺចាប់ ឬការរងទុក្ខដែលកើតជាប់ ឬម្តងម្កាលពីទណ្ឌកម្មត្រឹមត្រូវតាមច្បាប់ឡើយ"។ កម្ពុជាបានផ្តល់សច្ចាប័នអនុសញ្ញាប្រឆាំងទារុណកម្ម នៅថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៩២។

[76] ខូមីដូហ្វ វី. តាឃីគីស្ថាន (Khomidov v. Tajikistan) ទំនាក់ទំនងលេខ១១១៧/២០០២ — ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០០៤។ មូតេបា វ. ហ្សែរ (Muteba v. Zaire) ទំនាក់ទំនងលេខ ១២៤/១៩៨២-ថ្ងៃទី២៥ ខែមីនា ឆ្នាំ១៩៨៣។ អាហ្សូហ្គា វ. យូរ៉ាហ្គាយ (Arzuaga v. Uruguay) ទំនាក់ទំនងលេខ១៤៧/១៩៨៣-ថ្ងៃទី១ វិច្ឆិកា ១៩៨៥

[77] អ្នករាយការណ៍ពិសេសរបស់អ.ស.ប ស្តីពីទារុណកម្ម បានកត់សំគាល់ថា "ដោយសារតែច្បាស់ថា ការរំលោភសេពសន្ថវៈ ឬទម្រង់បទរំលោភសេពសន្ថវៈផ្សេងៗមកលើស្ត្រីភេទនៅក្នុងការឃុំខ្លួន គឺជាការរំលោភគួរឱ្យអាម៉ាស់លើសេចក្តីថ្លៃថ្នូរមានពីកំណើត និងសិទ្ធិបូរណភាពរាងកាយរបស់មនុស្សជាតិ ទាំងនេះត្រូវចាត់ទុកថាជាអំពើទារុណកម្មមួយ" សេចក្តីថ្លែងការណ៍របស់អ្នករាយការណ៍ពិសេសរបស់អ.ស.ប ស្តីពីទារុណកម្ម ថ្លែងចំពោះគណៈកម្មាធិការអ.ស.ប ទទួលបន្ទុកសិទ្ធិមនុស្ស។ អ.ស.ប ឯកសារ E/CN.4/1992/SR.21, ថ្ងៃទី២១ ខែកុម្ភៈ ១៩៩២ កថាខ័ណ្ឌ ៣៥។

[78] កតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ មាត្រាទី៧បញ្ជាក់ថា "គ្មានជនណាម្នាក់ត្រូវរងទារុណកម្ម ឬប្រព្រឹត្តកម្ម ឬទណ្ឌកម្មដែលឃោរឃៅ អមនុស្សធម៌ ឬបន្ទាបបន្ថោកឡើយ"។ ប្រទេសកម្ពុជាបានផ្តល់សច្ចាប័នអនុសញ្ញាប្រឆាំងទារុណកម្មនៅថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៩២។ ទារុណកម្មក្នុងការឃុំខ្លួនរបស់នគរបាល រួមមានការវាយដំយ៉ាងធ្ងន់ធ្ងរនិងការឆក់ចរន្តអគ្គិសនីដោយដំបងអគ្គិសនី ត្រូវបានកត់ត្រាដោយអង្គការសិទ្ធិមនុស្សប្រទេសកម្ពុជា អង្គការលីកាដូនៅក្នុង

ជាភាគីនៃអនុសញ្ញាស្តីពីការបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ កម្ពុជាមានកាតព្វកិច្ចដែលចងដោយច្បាប់ ដើម្បីការពារស្ត្រីភេទនិងកុមារីពីអំពើ ហិង្សាផ្លូវភេទ និងទម្រង់ទាំងឡាយនៃអំពើហិង្សាផ្អែកលើមូដ្ឋានយេនឌ័ ដែលបានប្រព្រឹត្តដោយភ្នាក់ងាររបស់រដ្ឋ និងផ្នែកឯកជនដូចគ្នា ។[79]

បន្ថែមលើបទប្បញ្ញត្តិភ្ជាប់កាតព្វកិច្ចច្បាប់អន្តរជាតិខាងលើ អ.ស.ប បានបង្កើតគោលការណ៍និងវិធានលំអិតស្តីពីការប្រើប្រាស់កម្លាំងនគរបាល ដើម្បីធានានូវការអនុវត្តន៍ស្របទៅតាមបទដ្ឋានអន្តរជាតិ។ បទវិន័យសម្រាប់មន្ត្រីប្រតិបត្តិច្បាប់របស់ អ.ស.ប កំណត់យ៉ាងជាក់លាក់នូវការប្រើប្រាស់កម្លាំង ដោយនគរបាលចំពោះស្ថានភាពដែល "ចាំបាច់ខ្លាំងបំផុត និងស្របតាមទំហំចាំបាច់សម្រាប់បំពេញភារកិច្ចរបស់ខ្លួន" ។[80] ស្រដៀងគ្នានេះដែរ គោលការណ៍ជាមូលដ្ឋានរបស់អ.ស.ប ស្តីពីការប្រើប្រាស់កម្លាំងនិង អាវុធដោយមន្ត្រីអនុវត្តន៍ច្បាប់បញ្ជាក់ថាមន្ត្រីប្រតិបត្តិច្បាប់ ដែលបំពេញភារកិច្ចរបស់ខ្លួន ត្រូវតែអនុវត្តមធ្យោបាយអហិង្សាតាមដែលអាចធ្វើទៅបានមុនជ្រើសរើសយកការប្រើប្រាស់កម្លាំង និងអាវុធ។[81] គោលការណ៍ជាមូលដ្ឋានចែងថា "រដ្ឋាភិបាលត្រូវធានាថាការប្រើប្រាស់កម្លាំង និងអាវុធដោយបំពាននិងតាមអំពើចិត្តដោយមន្ត្រី ប្រតិបត្តិច្បាប់ត្រូវដាក់ទោសជាបទល្មើសព្រហ្មទណ្ឌស្ថិតក្រោមច្បាប់របស់ខ្លួន" ។[82]

---

របាយការណ៍ "ការធ្វើទារុណកម្មនៅក្នុងកន្លែងឃុំឃាំងរបស់ប៉ូលិសនៅកម្ពុជា" ទំព័រ ៩ - សូមចូលមើលគេហទំព័រ: www.licadho-cambodia.org/reports/files/372003%20torture%20briefing%20paper.pdf ។ "ស្ថានភាពពន្ធនាគារនៅកម្ពុជា ឆ្នាំ២០០៨ : ស្ត្រីនៅក្នុងពន្ធនាគារ" ២០០៨ -សូមចូលមើលគេហទំព័រ www.licadho-cambodia.org/reports/files/129LICADHOPrisonWomen2008ENG.pdf ។ គណៈកម្មាធិការប្រឆាំងទារុណកម្ម អ.ស.ប (CAT) បានសម្តែងការព្រួយបារម្ភរបស់ខ្លួនចំពោះ "ការចោទប្រកាន់ដែលបន្តកើតឡើងយ៉ាងច្រើនដូចៗគ្នា នៃអំពើទារុណកម្ម និងប្រព្រឹត្តកម្ម ឬទណ្ឌកម្មដែលឃោរឃៅ អមនុស្សធម៌ ឬបន្ទាបបន្ថោក ដែលប្រព្រឹត្តដោយបុគ្គលិកអនុវត្តន៍ច្បាប់នៅទីកន្លែងនគរបាលនិងក្នុងពន្ធនាគារ" សេចក្តីសន្និដ្ឋាន និងអនុសាសន៍របស់គណៈកម្មាធិការ ប្រឆាំងទារុណកម្ម : កម្ពុជា ថ្ងៃទី២ ខែកុម្ភៈ ២០០៤ CAT/C/CR/៣១/៧ កថាខ័ណ្ឌ ៦

[79] អនុសញ្ញាស្តីពីការបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ (CEDAW), G.A. Res. 34/180, U.N. Doc. A/34/46 (ចូលជាធរមានថ្ងៃទី៣ ខែកញ្ញា ឆ្នាំ១៩៨១) ។ ប្រទេសកម្ពុជាផ្តល់សច្ចាប័នលើអនុសញ្ញានេះនៅថ្ងៃទី១៥ ខែតុលា ១៩៩២ — មាត្រា ២-១ ។

[80] អ.ស.ប- បទវិន័យសម្រាប់មន្ត្រីប្រតិបត្តិច្បាប់ - មាត្រាទី៣

[81] គោលការណ៍មូលដ្ឋានអ.ស.ប ស្តីពីការប្រើប្រាស់កម្លាំងនិងអាវុធដោយមន្ត្រីអនុវត្តន៍ច្បាប់ បទប្បញ្ញត្តិទូទៅ លេខ៤

[82] គោលការណ៍មូលដ្ឋានអ.ស.ប ស្តីពីការប្រើប្រាស់កម្លាំងនិងអាវុធដោយមន្ត្រីអនុវត្តន៍ច្បាប់ បទប្បញ្ញត្តិទូទៅ លេខ៧

## ការរំលោភបំពានអំឡុងពេលឃុំខ្លួន

## ការឃុំខ្លួនតាមអំពើចិត្ត

> *ខ្ញុំកំពុងជក់គ្រឿងញៀននៅក្នុងសួនច្បារមួយ... ហើយត្រូវបានចាប់ខ្លួន។ នគរបាល បានបញ្ជូនខ្ញុំទៅមន្ទីរសង្គមកិច្ចដែលនៅជិតវត្តមហាមន្ត្រី។ ខ្ញុំនៅទីនោះអស់មួយថ្ងៃមួយយប់។ គេមិននិយាយប្រាប់ខ្ញុំអ្វីទាំងអស់ តែគេយកខ្ញុំទៅឃុំឃាំង។ ខ្ញុំមិនបានជួបមេធាវីទេ...ស្អែកឡើងនៅម៉ោង៤ ល្ងាច គេបានបញ្ជូនខ្ញុំទៅមណ្ឌលឱកាសខ្ញុំ។ គេមិនសួរខ្ញុំ សូម្បីតែឈ្មោះរបស់ខ្ញុំ។ ខ្ញុំមិនហ៊ានសួរសំណួរទេព្រោះខ្លាចគេវាយ។.*
>
> *—មេសា[83]*

---

មជ្ឈមណ្ឌលឃុំឃាំងគ្រឿងញៀនប្រទេសកម្ពុជា ជាញឹកញាប់បង្ខាំងមនុស្ស ដែលមិនបំពេញទៅតាមលក្ខណៈវិនិច្ឆ័យរបស់ អ.ជ.ប.គ.ញ ចំពោះការញៀនគ្រឿងញៀនទេ។ បន្ថែមលើអ្នកប្រើប្រាស់គ្រឿងញៀន មជ្ឈមណ្ឌលឃុំឃាំងគ្រឿងញៀនធ្វើការឃុំឃាំងមនុស្សច្រើនប្រភេទផ្សេងៗគ្នាដូចជាកុមាររស់តាមចិញ្ចើមថ្នល់ អ្នកលេងល្បែង អ្នកញៀនស្រា និងអ្នកជំងឺផ្លូវចិត្ត។ ទោះជាមានការប្រាប់ហេតុផលសម្រាប់ការឃុំខ្លួនអ្នកទាំងនោះ ជាការបោសសំអាត"ជនដែលសង្គមមិនរាប់អាន"ចេញពីផ្លូវថ្នល់ក៏ដោយ ក៏នៅក្នុងតំបន់ផ្សេងៗក្នុងប្រទេសកម្ពុជា(ដូចជាទីរួមខេត្ត) ជនក្រីក្រដែលប្រើប្រាស់គ្រឿងញៀន ដែលទំនងត្រូវបានគេចាប់ខ្លួន ចោទប្រកាន់ និងបញ្ជូនទៅពន្ធនាគារ ជាជាងបញ្ជូនទៅកាន់មជ្ឈមណ្ឌលឃុំឃាំងគ្រឿងញៀន។ នៅក្នុងទីកន្លែងបែបនេះ មជ្ឈមណ្ឌលគ្រប់គ្រងជាបឋម ឬជាពិសេស ដាក់អ្នកជាប់ឃុំឃាំងទាំងនោះ ដែលមានឪពុកម្តាយ ឬសមាជិក គ្រួសារខ្លួនរបស់ពួកគេ បង់ប្រាក់សម្រាប់កន្លែងស្នាក់នៅក្នុង មជ្ឈមណ្ឌល។ ទោះបីជាច្បាប់ត្រួតពិនិត្យគ្រឿងញៀនចែងថា រដ្ឋជាអ្នកទទួលបង់ថ្លៃការព្យាបាលគ្រឿងញៀននៅក្នុងគ្រឹះ

---

[83] អង្គការឃ្លាំមើលសិទ្ធិមនុស្ស សម្ភាសមេសា— ភ្នំពេញ ខែឧសភា ឆ្នាំ២០០៩

ស្ថានដែលគ្រប់គ្រងដោយរដ្ឋាភិបាលក៏ដោយ។ រយៈពេលឃុំខ្លួនជាផ្លូវការ គឺខុសៗគ្នាពីមណ្ឌលមួយទៅមណ្ឌលមួយទៀត។ តាមការអនុវត្តន៍ជាក់ស្តែង រយៈពេលឃុំខ្លួនគឺស្រេចតែលើឆន្ទានុសិទ្ធិរបស់បុគ្គលិកមណ្ឌល ដែលអ្នកខ្លះគេអាចសូកសំណូកបាន ដើម្បីទទួលបានការដោះលែង។ ជាសង្ខេប លក្ខណៈនៃការឃុំខ្លួនអ្នកប្រើប្រាស់គ្រឿងញៀនក្នុងប្រទេសកម្ពុជា អាចកើតមានឡើងដោយចៃដន្យនិងមិនអាចព្យាករណ៍ទុកមុនបាន។

របៀបឃុំខ្លួនអ្នកប្រើប្រាស់គ្រឿងញៀនក្នុងប្រទេសកម្ពុជា ក៏មានលក្ខណៈខុសច្បាប់ផងដែរ។ ទោះបីមានការទាមទារឱ្យធ្វើតាមនីតិវិធីត្រឹមត្រូវដែលនៅខ្វះចន្លោះ ក្រោមច្បាប់គ្រឿងញៀន ដើម្បីអនុវត្តការឃុំឃាំងអ្នកញៀនគ្រឿងញៀនក៏ដោយ ក៏មិនត្រូវបានគេអើពើដែរក្នុងការអនុវត្តន៍ជាក់ស្តែង។ ការរៀបចំការចាប់ខ្លួនពួកគេ និងឃុំខ្លួនបន្តបន្ទាប់តាមបែបណាក៏ដោយ អ្នកជាប់ឃុំឃាំងបានរំលងផុតពីប្រព័ន្ធតុលាការ។ គ្មានដំណាក់កាលណាមួយដែលអ្នកជាប់ឃុំឃាំងទទួលបានសិទ្ធិតំណាងផ្លូវច្បាប់ឡើយ។ ពុំមានបញ្ជាពីព្រះរាជអាជ្ញាតាមដីកាកោះពីតុលាការទេ មិនមានការចោទប្រកាន់ពីនគរបាល តាមដីកាបង្គាប់ដែលចេញដោយតុលាការ ឬគ្មានការជំនុំជំរះរបស់តុលាការឡើយ។ ពុំមានស្ថាប័នតុលាការ ឬស្ថាប័នឯករាជ្យផ្សេងៗ ដែលអនុញ្ញាតការផ្តើមឃុំខ្លួន ឬពិនិត្យមើលឡើងអំពីភាពចាំបាច់នៃការបន្តឃុំខ្លួនទេ។ អ្នកជាប់ឃុំឃាំងពុំមានឱកាសដើម្បីឧទ្ធរចំពោះការឃុំខ្លួនរបស់ពួកគេឡើយ។ តាមរបៀបនេះ ប្រជាពលរដ្ឋត្រូវបានជាប់ឃុំឃាំងដោយគ្មានការពារទៅតាមនីតិវិធីត្រឹមត្រូវអ្វីទាំងអស់។

បន្ទាប់ពីការចាប់ខ្លួន តាមធម្មតាអ្នកទាំងនោះ ត្រូវបានគេឃុំខ្លួនមួយរយៈពេលខ្លី នៅកន្លែងនគរបាល នៅសាលាខណ្ឌ/ស្រុក ឬនៅមន្ទីរនាយកដ្ឋានសង្គមកិច្ចខេត្ត មុននឹងបញ្ជូនទៅកាន់មណ្ឌលឃុំឃាំងគ្រឿងញៀន។ មជ្ឈមណ្ឌលណា ដំណើរការដោយរាជអាវុធហត្ថ ឬនគរបាលស៊ីវិល ទីកន្លែងដែលត្រូវឃុំខ្លួនបន្តបន្ទាប់នោះ អាចស្ថិតនៅក្នុងបរិវេណនគរបាលដដែលដូចជាការិយាល័យ

នគរបាល ដែលជាកន្លែងដែលពួកគេត្រូវបានគេចាប់បញ្ជូនទៅ បន្ទាប់ពីការចាប់ខ្លួន ពួកគេត្រូវបានចុះឈ្មោះនិងបន្ទាប់មកត្រូវបានគេឃុំខ្លួន នៅផ្នែកមួយទៀតក្នុងបរិវេណនោះ។ សមាជិកបុគ្គលិកអង្គការមិនមែនរដ្ឋាភិបាលម្នាក់ ដែលមានបទពិសោធន៍ច្រើនក្នុងការងារគ្រឿងញៀនក្នុងប្រទេសកម្ពុជា បានធ្វើការពន្យល់យ៉ាងដូច្នេះថា :-

> គេអាចដាក់មនុស្សនៅក្នុងមណ្ឌលទាំងនោះ — ពួកគេមិនអាចចាកចេញបានទេ។ ពេលវេលាដែលពួកគេរស់នៅទីនោះ គឺជាឆន្ទានុសិទ្ធិទាំងស្រុងរបស់អ្នកក្តោបក្តាប់មណ្ឌល។ ភាគច្រើន អ្នកដែលជាប់ឃុំឃាំង មិនមានផ្លូវពឹងរកជំនួយផ្នែកច្បាប់អ្វីសោះឡើយ។[84]

តាមផ្លូវការ មជ្ឈមណ្ឌលសង្គមកិច្ច គឺផ្តល់សេវាស្តារនីតិសម្បទាដល់អ្នកដែលរស់នៅទីនោះតាមការស្ម័គ្រចិត្ត។ តាមការពិត ស្ថិតក្រោមច្បាប់ប្រទេសកម្ពុជា "មជ្ឈមណ្ឌលស្តារនីតិសម្បទា" សង្គមកិច្ចចោមចៅ គឺជាមណ្ឌលដែលត្រូវតែ"បើកចំហ"។[85] ម្នាស់មានអាយុ១៦ ឆ្នាំហើយត្រូវបានជាប់ឃុំឃាំងទីនោះក្នុងឆ្នាំ២០០៨។ គាត់បានពន្យល់អំពីភាពជាក់ស្តែងនូវអ្វីដែលសន្មត់ថាជាមណ្ឌល "បើកចំហ" ដូច្នេះថា :-

> ប្រសិនបើអ្នកណាម្នាក់ព្យាយាមរត់គេច គេត្រូវទទួលពិន័យទោស... អ្នកខ្លះរត់រួចខ្លួន ខ្លះទៀតរត់មិនរួច។ ភាគច្រើនអ្នកដែលទទួលការពិន័យពីការលួចរត់ គឺត្រូវវាយរហូតដល់លែងដឹងខ្លួន។ ការវាយបែបនេះកើតមានរាល់ថ្ងៃ"។[86]

---

84 អង្គការឃ្លាំមើលសិទ្ធិមនុស្ស សម្ភាសមន្ត្រីអង្គការក្រៅរដ្ឋាភិបាលម្នាក់ - ភ្នំពេញ ខែមិថុនា ឆ្នាំ២០០៩

85 ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា/ គណៈកម្មាធិការជាតិដោះស្រាយបញ្ហាជនអនាថា "សេចក្តីណែនាំស្តីពីគោលនយោបាយសម្រាប់ដោះស្រាយបញ្ហាជនអនាថា" ភ្នំពេញ ថ្ងៃទី៨ ខែសីហា ២០០៨ កថាខ័ណ្ឌ៦(២) ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា "សេចក្តីណែនាំស្តីពីល័ក្ខខ័ណ្ឌ និងនីតិវិធីសម្រាប់ការបញ្ចូលរដ្ឋបាល និងស្តារនីតិសម្បទា កុមារនិងកុមារដែលមានអាយុទទួលខុសត្រូវបទព្រហ្មទណ្ឌនៅមណ្ឌលយុវនីតិសម្បទាចោមចៅ" ភ្នំពេញ ថ្ងៃទី២៥ ខែសីហា ២០០៦ ចំណុច២(ច្បាប់ចំលងទុកជាឯកសារនៅអង្គការឃ្លាំមើលសិទ្ធិមនុស្ស)

86 អង្គការឃ្លាំមើលសិទ្ធិមនុស្ស សម្ភាសម្នាស់ - ភ្នំពេញ ខែមិថុនា ឆ្នាំ២០០៩

មនុស្សច្រើនប្រភេទ ត្រូវបានគេឃុំខ្លួននៅក្នុងមណ្ឌល។ ឧទាហរណ៍ កក្កដា អាយុ២៨ ឆ្នាំ បានពិពណ៌នាអំពីមិត្តភក្តិដែលជាអ្នកជាប់ឃុំឃាំងដូចគ្នានៅ"មណ្ឌលយុវនីតិសម្បទា"ចោមចៅ ដូច្នេះថា :-

> មានអ្នកហិតកាវ អ្នកចាក់គ្រឿងញៀន អ្នកលេងល្បែង អ្នកឈ្លោះវាយគ្នា ហើយ ត្រូវបានចាប់ខ្លួន អ្នកផឹកស្រា អ្នកជក់ម៉ា មនុស្សចាស់ កូនក្មេងដែលសុំទានតាមផ្លូវ មុន្នីវង្សនៅភ្នំពេញ។ ដេកតាមផ្លូវបង្កភាពគ្មានសណ្តាប់ធ្នាប់ នោះជាហេតុផល ដែលពួកគេត្រូវគេចាប់ខ្លួន។[87]

ប៉ុកបានពិពណ៌នាអំពីមិត្តភក្តិដែលជាប់ឃុំឃាំងនៅក្នុងមជ្ឈមណ្ឌលដែលគ្រប់គ្រងដោយ នគរបាលក្នុងស្រុកបវេល ខេត្តបាត់ដំបងដូច្នេះថា :-

> មានស្ត្រីពីរនាក់ ហើយក្រៅពីនោះគឺជាប្រុសទាំងអស់។ ស្ត្រីទាំងនោះគឺជាអ្នក ចម្រៀងក្នុងហាងខារ៉ាអូខេ ហើយពួកគេជាអ្នកប្រើប្រាស់គ្រឿងញៀនដែរ។ មាន មនុស្សឆ្កួតផងដែរ ពួកគេបាត់បង់ការចងចាំអស់ហើយ គឺមានពីរនាក់។ មានមនុស្ស ចាស់បីបួននាក់... គេនិយាយថាមនុស្សចាស់ទាំងអស់ហ្នឹង នឹងត្រូវរស់នៅទីនោះ អស់មួយជីវិត។ មានក្មេងពីរបីនាក់ដែរ ពួកគេមានអាយុប្រហែល១៥-១៦ឆ្នាំ។ ពួកវានៅទីនោះ ដោយសារមិនស្តាប់បង្គាប់ឪពុកម្តាយ ហើយជក់ម៉ា។ អ្នកជាប់ឃុំ ឃាំងខ្លះ ជាអ្នកជក់ម៉ា ហើយអ្នកជាប់ខ្លះទៀតប្រើអំពើហិង្សាក្នុងគ្រួសារ... អ្នក ដែលផឹកស្រា ឬប្រើអំពើហិង្សាក្នុងគ្រួសារ នឹងត្រូវដោះលែងក្នុងរយៈពេលពីរ ឬបី ខែក្រោយមក។[88]

---

87 អង្គការឃ្លាំមើលសិទ្ធិមនុស្ស សម្ភាសកក្កដា- ភ្នំពេញ ខែឧសភា ឆ្នាំ២០០៩

88 អង្គការឃ្លាំមើលសិទ្ធិមនុស្សសម្ភាសប៉ុក — កម្ពុជា ខែមិថុនា ឆ្នាំ២០០៩

ប្រធានបទខុសៗគ្នារបស់អ្នកជាប់ឃុំឃាំង មិនត្រូវបានកំណត់ចំពោះមជ្ឈមណ្ឌលសង្គមកិច្ចទេ។ មករាវាយការណ៍ថា នៅក្នុងមណ្ឌលឱកាសខ្ញុំ ដែលជាមណ្ឌលដ៏សំខាន់មួយនៅភ្នំពេញ "ក៏មានកុមាររស់តាមចិញ្ចើមថ្នល់ អ្នកចាក់គ្រឿងញៀន អ្នកជំងឺផ្លូវចិត្តដែរ"។[89] មមែ អាយុ១៥ឆ្នាំ ដែលជាក្មេងពិការរស់នៅតាមចិញ្ចើមថ្នល់ ប៉ុន្តែមិនដែលប្រើប្រាស់គ្រឿងញៀនសោះឡើយ ត្រូវបានជាប់ឃុំឃាំងនៅក្នុងមជ្ឈមណ្ឌលនៅស្នងការនគរបាលខេត្តសៀមរាប។[90] ត្រាច ដែលជាអតីតអ្នកជាប់ឃុំឃាំងនៅមជ្ឈមណ្ឌលដូចគ្នានៅខេត្តសៀមរាប បានពន្យល់ដូច្នេះថា :-

> មានអ្នកជក់ម៉ា ទឹកកក ខេ[ខេតាមីន] អ្នកហិតកាវ អ្នកជក់កញ្ឆា អ្នកប្រើថ្នាំមេតំហ្វេតាមីន... មានអ្នកជំងឺផ្លូវចិត្ត មនុស្សឆ្កួត អ្នករើសអេតចាយ អ្នកគ្មានផ្ទះសម្បែង អ្នកផឹកស្រា វាយធ្វើបាបកូនពេលស្រវឹងស្រា ក្មេងអនាថា។[91]

អាជ្ញាធរដឹងថា ការញៀនគ្រឿងញៀនពិតប្រាកដ គឺមិនមែនជាល័ក្ខខ័ណ្ឌសម្រាប់ចូលក្នុងមណ្ឌលឃុំឃាំងគ្រឿងញៀនរបស់រដ្ឋាភិបាលទេ។ មជ្ឈមណ្ឌលមួយចំនួនបង្ខិតបង្ខំអ្នកជាប់ឃុំឃាំងឱ្យធ្វើតេស្តរកសារធាតុញៀនមុនបញ្ចូលក្នុងមណ្ឌល ដែលមណ្ឌលភាគច្រើនមិនធ្វើដូច្នោះទេ។ យោងតាមរបាយការណ៍ពង្រាងមួយ ដែលជារបាយការណ៍រួមគ្នារបស់មជ្ឈមណ្ឌល ដែលបានធ្វើឡើងដោយអង្គការសុខភាពពិភពលោកនិងរដ្ឋាភិបាលកម្ពុជា ឧបករណ៍វាយតម្លៃដូចជា "ខ្នាតវង្វាស់កម្រិតញៀន" និងការពិនិត្យទឹកនោម មិនត្រូវបានប្រើប្រាស់ជាផ្នែកនៃការវិនិច្ឆ័យហាមចូលមជ្ឈមណ្ឌលទេ។[92]

---

89 អង្គការឃ្លាំមើលសិទ្ធិមនុស្សសម្ភាសមករា — ភ្នំពេញ ខែឧសភា ឆ្នាំ២០០៩

90 អង្គការឃ្លាំមើលសិទ្ធិមនុស្ស សម្ភាសមមែ — សៀមរាប ខែមិថុនា ឆ្នាំ២០០៩

91 អង្គការឃ្លាំមើលសិទ្ធិមនុស្ស សម្ភាសត្រាច — សៀមរាប ខែឧសភា ឆ្នាំ២០០៩

92 វ. ម៉ាកដូណល់ អែ. អាល លទ្ធផលរកឃើញជាសង្ខេប ដោយមជ្ឈមណ្ឌល — ការវាយតម្លៃជាបន្ទាន់ ស្តីពីមជ្ឈមណ្ឌលព្យាបាល និងស្តារនីតិសម្បទា ក្នុងប្រទេសកម្ពុជា WHO/NACD-SG/Ministry of Health/UNAIDS, ភ្នំពេញ ឆ្នាំ២០០៨ (មិនផ្សព្វផ្សាយ) ទំព័រ៩ (ច្បាប់ថតចម្លង រក្សាទុកជាឯកសារដោយអង្គការឃ្លាំមើលសិទ្ធិមនុស្ស)។ យោងតាមអ.ជ.ប.គ.ញ "ខ្នាតវាស់កម្រិតញៀន" គឺជាបញ្ជីសំណួរមាន៥ចំណុច ដែលចែងអំពីការពិន្ទុះចង្អុលបង្ហាញភាពធ្ងន់ធ្ងរនៃការញៀនគ្រឿងញៀន ដែលមានប្រភេទផ្សេងៗ។ ចំណុចនីមួយៗ ត្រូវឱ្យពិន្ទុះទៅលើខ្នាតវង្វាស់៤ចំណុច (០-៣)។ ពិន្ទុះសរុប ដែលទទួលបានពីការបូកបញ្ចូលគ្នា សម្រាប់បញ្ជីសំណួរទាំងប្រាំ។

" ខ្នាតវាស់កម្រិតញៀន"របស់ អ.ជ.ប.គ.ញ មិនជាទំនងជាអាចទុកចិត្តបានទេ សូម្បីតែពេលប្រើប្រាស់ក៏ដោយ ដោយហេតុថា ការវាយតំលៃគឺធ្វើឡើងចំពោះអ្នកមកដល់ថ្មី ដោយបុគ្គលិកដែលមានបទពិសោធន៍បន្តិចបន្តួច ឬគ្មានការបណ្តុះបណ្តាលផ្នែកសុខាភិបាលសោះ ចុះទំរាំការបណ្តុះបណ្តាលផ្នែកព្យាបាលការញៀនគ្រឿងញៀន នេះគឺមិនអាចទេ។[93] ទោះជាយ៉ាងណាក៏ដោយ ជនដែលមិនត្រូវតាមលក្ខណៈវិនិច្ឆ័យផ្ទាល់របស់ អ.ជ.ប.គ.ញ ត្រូវគេឃុំឃាំងសម្រាប់ការ"ព្យាបាល" ឬ"ស្តារនីតិសម្បទា"តាមការសន្មត់។ អ.ជ.ប.គ.ញ រាយការណ៏ថា ក្នុងឆ្នាំ២០០៨ បុគ្គល៧០០នាក់ស្ទើរតែទាំងអស់ ត្រូវបានគេឃុំខ្លួននៅក្នុងមណ្ឌលដែលគ្រប់គ្រងដោយរដ្ឋាភិបាល ដោយសារប្រើថ្នាំមេតំហ្វេតាមីនទឹកកក ទោះចំនួន ២៥ភាគរយក្នុងចំណោមអ្នកទាំងនោះមិនមែនជាអ្នក"ញៀនគ្រឿងញៀនក៏ដោយ" ។[94]

អតីតអ្នកជាប់ឃុំឃាំងគ្រឿងញៀនមួយចំនួន រាប់ទាំងអ្នកដែលបាននិយាយដោយស្មោះត្រង់អំពីការប្រើប្រាស់គ្រឿងញៀនរបស់ខ្លួន បាននិយាយប្រាប់អង្គការឃ្លាំមើលសិទ្ធិមនុស្សថា ពួកគេមិនកំពុងប្រើប្រាស់គ្រឿងញៀនទេ នៅពេលត្រូវបានចាប់ខ្លួន។ ឧទាហរណ៏ ស្វាយបាននិយាយថាគាត់ត្រូវជាប់ឃុំនៅមណ្ឌលឱកាសខ្ញុំអស់រយៈពេលបីខែ តាមការពិតទោះបីការធ្វើតេស្តទឹកនោមសម្រាប់ការបញ្ចូលក្នុងមណ្ឌលពុំបានបង្ហាញនូវការប្រើប្រាស់គ្រឿងញៀនជាមុនក៏ដោយ។

---

ពិន្ទុសរុបដែលខ្ពស់ជាងគេ មានន័យថាកម្រិតញៀននេះក៏ខ្ពស់។ សំណួរពាក់ព័ន្ធនឹងការគ្រប់គ្រងឱ្យអន់ថយក្នុងការទទួលគ្រឿងញៀន និងមានការបារម្ភអន្ទះសារចង់ប្រើប្រាស់គ្រឿងញៀន"។ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន "របាយការណ៏ស្តីពីលទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀនក្នុងប្រទេសកម្ពុជា ឆ្នាំ២០០៧" ខែ មិថុនា ឆ្នាំ២០០៨ ទំព័រ ៧៧។

93 អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន, "របាយការណ៏ស្តីពីលទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀនក្នុងប្រទេសកម្ពុជា ឆ្នាំ២០០៧" ខែ មិថុនា ២០០៨, ទំព័រទី ៧៧

94 របាយការណ៏ពី "the National Residential Treatment Center Minimum Dataset: 2008," មជ្ឈមណ្ឌលព័ត៌មាន គ្រឿងញៀន — អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន - បានធ្វើបទបង្ហាញនៅកិច្ចប្រជុំក្រុមការងារបច្ចេកទេសគ្រឿងញៀន/អេដស៏(DHA), នៅសណ្ឋាគារណោហ្គា នៅថ្ងៃទី៤ មិថុនា ឆ្នាំ ២០០៩ (ច្បាប់ថតចម្លងរក្សាទុកជាឯកសារនៅអង្គការឃ្លាំមើលសិទ្ធិមនុស្ស)។ ស្រដៀងគ្នាដែរ យោងតាមទិន្នន័យអ.ជ.ប.គ.ញ ចាប់ពីខែ កក្កដា-ធ្នូ ២០០៧ អ្នកប្រើប្រាស់ថ្នាំ "យ៉ាម៉ា" មានចំនួន ១០.៦ ភាគរយ អ្នកប្រើប្រាស់ថ្នាំមេតំហ្វេតាមីនទឹកកកមាន ១៦.២ ភាគរយ ហើយអ្នកចាក់ថ្នាំ ហេរ៉ូអ៊ីន មាន ១៥.៤ ភាគរយ ដែលបានបញ្ចូលក្នុងរយៈពេលនោះ មិនទាន់ឈានដល់កម្រិតញៀនគ្រឿងញៀននៅឡើយ។ អាជ្ញាធរជាតិប្រយុទ្ធ ប្រឆាំងគ្រឿងញៀន, "របាយការណ៏ស្តីពីលទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀនក្នុងប្រទេសកម្ពុជា ឆ្នាំ២០០៧" ខែមិថុនា ២០០៨ ទំព័រទី៧៧។

គាត់បានពន្យល់ដូច្នេះថា :- "គ្រូពេទ្យប្រចាំនៅមណ្ឌលបាននិយាយប្រាប់ខ្ញុំថា "អ្នកឯងអត់មានសារធាតុញៀនទេ... គេចាប់ទាំងអ្នកប្រើប្រាស់គ្រឿងញៀននិងអ្នកដែលមិនប្រើបាស់គ្រឿងញៀន" ។[95]

នៅតាមទីរួមខេត្តខ្លះក្នុងប្រទេសកម្ពុជា អតីតអ្នកជាប់ឃុំឃាំងបានជឿថា ទោះបីជនណាម្នាក់ត្រូវបានកាត់ទោសបទព្រហ្មទណ្ឌ ឬជាប់ឃុំឃាំងក្នុងមជ្ឈមណ្ឌលឃុំឃាំងគ្រឿងញៀន ក៏ដោយ គឺវាពឹងអាស្រ័យលើទ្រព្យសម្បត្តិរបស់ក្រុមគ្រួសារ ។ នៅផ្នែកទាំងនេះនៃប្រទេសកម្ពុជា អ្នកដែលក្រុមគ្រួសាររបស់ខ្លួន មិនមានលទ្ធភាពទិញកន្លែងនៅក្នុងមជ្ឈមណ្ឌលឃុំឃាំងគ្រឿងញៀន ត្រូវគេបញ្ជូនទៅកាន់ពន្ធនាគារ តែសម្រាប់អ្នកដែលមានប្រាក់ គឺអាចរំលងពន្ធនាគារ ទៅកាន់មជ្ឈមណ្ឌលឃុំឃាំងគ្រឿងញៀន។ មជ្ឈមណ្ឌលដាក់ឃុំអ្នកជាប់ឃុំឃាំងភាគច្រើនឬទាំងអស់ ដោយឪពុកម្តាយរបស់ពួកគេ បង់ប្រាក់ឱ្យមជ្ឈមណ្ឌលដើម្បីឃុំខ្លួនពួកគេ។ តម្លៃឃុំខ្លួន គឺចន្លោះ ៥០ ដុល្លារ និង ២០០ ដុល្លារក្នុងមួយខែ។ វាជាចំនួនដែលត្រូវបង់តាមធម្មតាដោយសមាជិកគ្រួសារទៅឱ្យមជ្ឈមណ្ឌល ។[96] ការអនុវត្តន៍បែបនេះ គឺផ្ទុយនឹងច្បាប់គ្រឿងញៀនប្រទេសកម្ពុជាដែលចែងថាថ្លៃសម្រាប់ព្យាបាលគ្រឿងញៀន"ត្រូវជាបន្ទុកទាំងស្រុងរបស់រដ្ឋ" ។[97]

ថោះត្រូវបានគេដាក់ពន្ធនាគារក្នុងឆ្នាំ២០០៩ ដោយសារបទឧក្រិដ្ឋប្រើប្រាស់គ្រឿងញៀន ទោះបីគាត់មិនដែលជាប់ឃុំឃាំងនៅក្នុងមជ្ឈមណ្ឌលឃុំឃាំងគ្រឿងញៀន នៅទីប្រជុំជនភាគខាងកើតប្រទេសកម្ពុជា ជាទីដែលគាត់កំពុងរស់នៅទីនោះក៏ដោយ ។

> មានមណ្ឌលស្តារនីតិសម្បទាមួយនៅក្នុងមូលដ្ឋានកងរាជអាវុធហត្ថ...ខ្ញុំមិនដឹងពីមូលហេតុដែលគេបញ្ជូនខ្ញុំទៅកាន់ទីនោះទេ។ ពួកគេនិយាយថា "ឯងមានកំហុស

---

[95] អង្គការឃ្លាំមើលសិទ្ធិមនុស្ស សម្ភាសស្វាយ — ភ្នំពេញ ខែឧសភា ឆ្នាំ២០០៩

[96] អង្គការសុខភាពពិភពលោកតំបន់ប៉ាស៊ីហ្វិចខាងលិច "ការវាយតម្លៃអំពីការព្យាបាលអ្នកប្រើប្រាស់គ្រឿងញៀន ដោយបង្ខំក្នុងប្រទេសកម្ពុជា ចិន ម៉ាឡេស៊ី និងវៀតណាម : ការអនុវត្តន៍គោលការណ៍សិទ្ធិមនុស្សដោយជ្រើសរើស" ឆ្នាំ ២០០៩ ទំព័រទី១០

[97] មាត្រាទី៨៩ កថាខ័ណ្ឌ១

ដូច្នេះឯងត្រូវតែជាប់គុក"។ អាវុធហត្ថមិនបានសួរខ្ញុំថាតើខ្ញុំចង់ទៅមណ្ឌលស្តារនីតិសម្បទា ឬយ៉ាងណានោះទេ។ គ្មានអ្នកណាម្នាក់ពីសហគមន៍ដ៏ក្រីក្រដែលនៅជិតនេះ] ធ្លាប់ទៅមជ្ឈមណ្ឌលផ្តាច់គ្រឿងញៀននេះទេ គឺគេបញ្ជូនត្រង់ទៅគុកតែម្តង។ មណ្ឌលកងរាជអាវុធហត្ថ គឺសម្រាប់តែគ្រួសារកូនអ្នកមានប៉ុណ្ណោះ។[98]

ចាបដែលជាអតីតអ្នកប្រើប្រាស់គ្រឿងញៀនមកពីសហគមន៍ដូចគ្នា យល់ស្របនឹងចំណុចនេះ "ការអនុវត្តន៍ច្បាប់មានពីរយ៉ាង :- គ្រួសារអ្នកមានប្តឹង ដើម្បីបញ្ជូនកូនទៅកាន់កងរាជអាវុធហត្ថ ប្រសិនប៉ូលិសចាប់ខ្លួនអ្នក[ដោយអត់លុយ] គេបញ្ជូនទៅគុក"។[99]

យោងតាមអតីតអ្នកជាប់ឃុំឃាំង អាជ្ញាធរដែលគ្រប់គ្រងមណ្ឌលទាំងនេះ ហាក់ដូចជាប្រឹងប្រែងលាក់បំពួនការពិតដែលថា ពួកគេឃុំឃាំងមនុស្ស ដរាបណាមានការលើកទឹកចិត្តខាងផ្នែកហិរញ្ញវត្ថុដើម្បីធ្វើដូច្នេះ។ ប៉ុកគឺជាអ្នកប្រើប្រាស់គ្រឿងញៀនក្នុងទីរួមខេត្ត ដែលមានមណ្ឌលឃុំឃាំងគ្រឿងញៀនគ្រប់គ្រងដោយរាជអាវុធហត្ថ។ គាត់ហិតការ ប៉ុន្តែ"ឈប់ប្រើប្រាស់យ៉ាម៉ា" ដោយសារថ្លៃ។ គាត់ដឹងយ៉ាងច្បាស់ពីមូលហេតុដែលគាត់មិនត្រូវបានឃុំឃាំងនៅក្នុងមណ្ឌលទីរួមខេត្ត ដែលគាត់រស់នៅទីនោះ និងមូលហេតុដែលគាត់ជាប់ឃុំឃាំងក្នុងរយៈពេលខ្លី (ដោយប្រៀបធៀបគ្នា):-

ពួកគេចាប់តែក្មេងណាដែលមានឪពុកម្តាយអាចមានលុយបង់ប្រាក់សម្រាប់ការឃុំឃាំង]។ ខ្ញុំគិតថាគេចាប់តែពួកខ្ញុំ[ដែលជាអ្នកហិតការ] ដើម្បីធ្វើឱ្យមជ្ឈមណ្ឌលមានប្រជាប្រិយភាពប៉ុណ្ណោះ សម្រាប់ពេលមន្ត្រីធំៗមកទស្សនា។ នៅក្នុងមណ្ឌល[មុនពួកខ្ញុំត្រូវចាប់ខ្លួន]មានអ្នកជក់ម៉ា ប៉ុន្តែអត់មានក្មេងហិតការទេ។ អញ្ចឹង

---

98 អង្គការឃ្លាំមើលសិទ្ធិមនុស្ស សម្ភាសចោះ — កម្ពុជា ខែមិថុនា ឆ្នាំ២០០៩

99 អង្គការឃ្លាំមើលសិទ្ធិមនុស្ស សម្ភាសជាមួយចាប — កម្ពុជា ខែមិថុនា ឆ្នាំ២០០៩

ហើយបានជាគេចាប់ពួកខ្ញុំ... គឺសម្រាប់តែអ្នកមកទស្សនាមណ្ឌលប៉ុណ្ណោះ ដូចជាភរិយារបស់លោកនាយករដ្ឋមន្ត្រីប៊ុន រ៉ានី។ គាត់បានមកទស្សនានៅពេលដែលខ្ញុំជាប់ឃុំនៅទីនោះ... គាត់បានចែកអំណោយ ហើយជួយគាំទ្រមណ្ឌល ដើម្បីពួកខ្ញុំមានអាហារគ្រប់គ្រាន់សម្រាប់ហូប។ គេបានដោះលែងខ្ញុំបន្ទាប់ពី១៥ថ្ងៃក្រោយមក។[100]

រយៈពេលផ្លូវការនៃការឃុំខ្លួន ពីមណ្ឌលមួយទៅមណ្ឌលមួយទៀត គឺខុសៗគ្នា —នៅទីកន្លែងខ្លះមានរយៈពេលបីខែ កន្លែងផ្សេងទៀតរយៈពេលពី៦ខែទៅ១ឆ្នាំ។ ជាក់ស្តែង រយៈពេលឃុំខ្លួនពិតប្រាកដ គឺស្រេចតែសិទ្ធិសម្រេចរបស់បុគ្គលិកមណ្ឌល។ ទន្ទាប់បានពិពណ៌នាអំពីរបៀបម្តាយគាត់ បង់ប្រាក់ទៅឱ្យមជ្ឈមណ្ឌលបន្ទាយរាជអាវុធហត្ថនៅស៊ីសូផុន ដើម្បីធានាដោះលែងគាត់បន្ទាប់ពីជាប់ឃុំឃាំងរយៈពេលពីរសប្តាហ៍។

[អាវុធហត្ថ]បាននិយាយថា"...ឯងដឹងទេ ពេលឪពុកម្តាយមក[ធានា] ឬបង់ប្រាក់]ឱ្យឯង គេនឹងដោះលែងឯងហើយ"។ [ចំពោះ]រូបខ្ញុំ រឿងនេះមានន័យថា ត្រូវបង់ប្រាក់។ មន្ត្រីម្នាក់បាននិយាយបែបនេះ ហើយគាត់និយាយទៅកាន់គ្រប់ៗគ្នាទាំងអស់។ ខ្ញុំនៅទីនោះអស់រយៈពេលប្រហែល២អាទិត្យ។ តាមពិត ពួកគេគួរដោះលែងខ្ញុំនៅថ្ងៃតែមួយ ប៉ុន្តែម្តាយរបស់ខ្ញុំមិនមានលុយគ្រប់ចំនួន។ ពួកគេបានទារ ១៥០.០០០រៀល[ប្រហែល៣៦ដុល្លារសហរដ្ឋអាមេរិក] ប៉ុន្តែគាត់មានតែ ១០០.០០០រៀល[ប្រហែល ២៤ដុល្លារសហរដ្ឋអាមេរិក]... គាត់បានបង់ឱ្យមេបញ្ជាការប៉េអឹមម្នាក់...។[101]

---

100 អង្គការឃ្លាំមើលសិទ្ធិមនុស្ស សម្ភាសប៊ុក— កម្ពុជា ខែមិថុនា ឆ្នាំ២០០៩

101 អង្គការឃ្លាំមើលសិទ្ធិមនុស្ស សម្ភាសទន្ទាប់ — បន្ទាយមានជ័យ ខែមិថុនា ឆ្នាំ២០០៩

## ការព្យាបាល

*គេបានដាក់ច្រវាក់ [ អ្នកជាប់ឃុំឃាំង ] ជាប់នឹងកជើង ហើយចងទៅនឹងដង ទង់ជាតិនៅចំកណ្តាលពន្លឺថ្ងៃ ។ ខ្ញុំបានឃើញពីរបីដងដែរ... ខ្ញុំបានឃើញម្នាក់ ដែលជាប់ច្រវាក់ដែលស្លៀកតែខោខ្លីក្នុង ។ វាជាទណ្ឌកម្មដោយសារលួចរត់ — ត្រាច* [102]

---

អំពើហិង្សាសម្រាប់បម្រើការសប្បាយលើទុក្ខអ្នកដទៃ ដែលកើតឡើងដោយឯកឯង និង ប្រកបដោយចរិតឆេវឆាវ គឺជាវិធីរួមគ្នាក្នុងការប្រតិបត្តិការនៃមណ្ឌលឃុំឃាំងគ្រឿងញៀន ។ ភាគ ច្រើនលើសលុបនៃអ្នកដែលបានសម្ភាសសម្រាប់របាយការណ៍នេះ ធ្លាប់ទទួលទទួលរងនូវអំពើ ប្រព្រឹត្តយ៉ាងឃោរឃៅ ឬអមនុស្សធម៌ដូចដែលពិពណ៌នាខាងក្រោម ឬបានឃើញដោយផ្ទាល់ភ្នែក ជាក់ស្តែង ។ អំពើឃោរឃៅ និងការប្រព្រឹត្តដោយអមនុស្សធម៌ ត្រូវបានរាយការណ៍ថាកើតមាន នៅក្នុងមណ្ឌលទាំងអស់ ដែលរាយការណ៍នៅក្នុងរបាយការណ៍នេះ ។ នៅពេលខ្លះ ការរំលោភ បំពានបានកើតឡើងជាទណ្ឌកម្មដែលអាចឃើញស្តែងៗ ដោយសារល្មើសបទបញ្ជាផ្ទៃក្នុងរបស់ មណ្ឌល ដូចជាការហាមជក់បារី ឈ្លោះប្រកែកគ្នា រវាងអ្នកជាប់ឃុំឃាំង និងលួចរត់ ។ តែទោះជា យ៉ាងណាក៏ដោយ អំពើប្រព្រឹត្តដោយឃោរឃៅ និងអមនុស្សធម៌ ជានិច្ចជាកាលត្រូវបានបញ្ជាឱ្យធ្វើ ដោយគ្មានការពន្យល់ ឬការផ្តល់ហេតុផលពិតប្រាកដឡើយ ។

ទុរេនបានរៀបរាប់អំពីការឆក់ចរន្តអគ្គិសនីមកលើខ្លួនគេ ដោយបុគ្គលិកម្តងម្កាល នៅពេល ដែលគេបានតាមទាន់គាត់លួចជក់បារីនៅក្នុងមជ្ឈមណ្ឌលឱកាសខ្ញុំ :-

---

[102] អង្គការឃ្លាំមើលសិទ្ធិមនុស្ស សម្ភាសត្រាច — សៀមរាប ខែមិថុនា ឆ្នាំ២០០៩

មានម្តងនោះគេបានឆក់ខ្ញុំនឹងដំបង[អគ្គីសនី]។ ខ្ញុំសន្លប់អស់មួយនាទី។ គឺបុគ្គលិក[ដែលជាអ្នកបានឆក់ខ្ញុំ]។ គាត់បាននិយាយថា "ហ្វៃងដឹងទេ គេមិនអនុញ្ញាតឱ្យជក់បារីទេ"។ មានអារម្មណ៍ក្តៅដូចភ្លើងអញ្ចឹង ឈឺខ្លាំងណាស់ ខ្ញុំឡើងញ័រពេញខ្លួន។ ខ្ញុំបានដួលនៅលើកម្រាលឥដ្ឋ... ខ្ញុំត្រូវបានគេឆក់បីបួនដង។ អ្នកដែលជក់បារីនិងឈ្លោះប្រកែកវាយគ្នា សុទ្ធតែត្រូវឆក់បែបនោះមិនខាន។ ពួកគេមានដំបងឆក់ពីរឬបី ដែលគេដាក់បញ្ចូលភ្លើងនៅលើជញ្ជាំង។[103]

តុលាបានរៀបរាប់អំពីការឆក់ខ្សែភ្លើង ដោយបានបញ្ជាឱ្យធ្វើទណ្ឌកម្មមកលើមិត្តភក្តិរបស់គាត់ដែលជាអ្នកជាប់ឃុំឃាំងនៅក្នុងមណ្ឌលឱកាសខ្ញុំ បន្ទាប់ពីព្យាយាមរត់គេចមិនបានសម្រេច។ បន្ទាប់មកត្រូវបានចាប់ខ្លួន :-

[អ្នកយាម] មិនទាន់ឆក់ [អ្នករត់គេច] ភ្លាមៗទេ។ នៅព្រឹកស្អែក ពួកគេសួរថា "តើអ្នកណារៀបចំផែនការនេះ?"។ បន្ទាប់មកពួកគេចាប់ផ្តើមសួររកអ្នកណាជាមេខ្លោង។ ពេលដែលពួកគេរកឃើញមេខ្លោងពីរនាក់ហើយ ពួកគេបានចាប់ផ្តើមឆក់តែម្តង។ ខ្ញុំមិនបានឃើញផ្ទាល់ភ្នែកទេ។ ប៉ុន្តែនៅពេលអ្នកទាំងពីរ ត្រឡប់មកបន្ទប់ដេកវិញ ខ្ញុំបានសួរថាមានរឿងអីកើតឡើងចំពោះពួកគេ។[ម្នាក់]បានបង្ហាញខ្ញុំនូវស្នាមយ៉ាងធំនៅលើពោះរបស់គាត់។ គាត់បាននិយាយថា គេឆក់គាត់... ហើយនិយាយថាគាត់ដួលលើឥដ្ឋ ហើយអស់កម្លាំង។ ស្បែកឡើងរលាកក្រហម ហើយឡើងពង។[104]

---

103 អង្គការឃ្លាំមើលសិទ្ធិមនុស្ស សម្ភាសទុរេន — ភ្នំពេញ ខែឧសភា ឆ្នាំ២០០៩

104 អង្គការឃ្លាំមើលសិទ្ធិមនុស្ស សម្ភាសតុលា — ភ្នំពេញ ខែឧសភា ឆ្នាំ២០០៩

ក្រញ្វងបានប្រាប់អំពីការឆក់ដំបងអគ្គិសនី នៅក្នុងមណ្ឌលគ្រប់គ្រងដោយស្នងការនគរបាលខេត្តសៀមរាប។ គេបានដាក់ទណ្ឌកម្មគាត់ដោយឆក់ចរន្តអគ្គិសនី ដោយសាររត់ចេញពីមណ្ឌលក្នុងគ្រាមុន។

> ពួកគេបានចាប់ខ្ញុំ[សារជាថ្មី]ហើយបានឆក់ខ្ញុំ... ពួកគេមិនហ៊ានឆក់ខ្ញុំនៅទីនេះទេ [នៅក្នុងក្រុង នៅពេលដែលខ្ញុំត្រូវបានចាប់សារជាថ្មី] ពីព្រោះខ្លាចអ្នកទេសចរមើលឃើញ... គឺជាប៉ូលិសម្នាក់[ដែលបានឆក់ខ្ញុំ]។ គាត់ឆក់ខ្ញុំនៅមុខបន្ទប់របស់ខ្ញុំ។ ដំបូងគាត់វាយខ្ញុំ បន្ទាប់មកឆក់ខ្ញុំរហូតសន្លប់ ហើយគេបានចាក់ទឹកមកលើខ្ញុំ និងរុញចូលក្នុងបន្ទប់វិញ។ គេបានដាល់ក្បាលរបស់ខ្ញុំឡើងពក។ នៅពេលគេឆក់ [អ្នកណាម្នាក់] អ្នកនោះនឹងអស់កម្លាំងនិងមិនអាចដើរបាន ធ្វើឱ្យវិលមុខ និងអស់កម្លាំង។ ប៉ូលិសនិយាយថា "មកពីហ្វៃងលួចរត់ "។[105]

បន្ថែមលើការឆក់ចរន្តអគ្គិសនី បុគ្គលិកក៏បានប្រើខ្សែតីដែលធ្វើពីខ្សែភ្លើងវេញចូលគ្នា។ កក្កដា អាយុ ២៨ ឆ្នាំ និយាយអំពីខ្លួនដែលត្រូវគេវាយនឹងខ្សែភ្លើងដែលវេញចូលគ្នា នៅក្នុង "មណ្ឌលស្តារនីតិសម្បទា"សង្គមកិច្ចចោមចៅដូច្នេះថា :-

> អ្នកយាមបានវាយខ្ញុំនឹងខ្សែ"អយ" ដែលធ្វើពីខ្សែភ្លើង៨ខ្សែវេញចូលគ្នា។ គាត់ឱ្យខ្ញុំលុតជង្គង់ចុះ ហើយឱ្យយកដៃគ្រប"អង្គជាតិ"ខ្ញុំ... បន្ទាប់មកគាត់ចាប់ផ្តើម វាត់ខ្ញុំពីក្រោយខ្នង ដោយខ្សែអយនោះ។ វាមានទំហំប្រហែលកដៃរបស់ខ្ញុំ។ គាត់វាយខ្ញុំជាច្រើនដង ប្រហែល១០ដង។ ខ្ញុំឈឺខ្លាំងណាស់។ នៅពេលខ្លះ ខ្ញុំលួចយំម្នាក់ឯងបន្ទាប់ពីគេវាយរួច ពីព្រោះវាឈឺណាស់។ ខ្ញុំមិនបានប្រព្រឹត្តកំហុសអ្វីផង :- ហេតុអី

---

105 អង្គការឃ្លាំមើលសិទ្ធិមនុស្ស សម្ភាសក្រញ្វង— កម្ពុជា ខែមិថុនា ឆ្នាំ២០០៩

> គេវាយខ្ញុំអញ្ចឹង? បន្ទាប់ពីវាយមក គាត់ទះកំផ្លៀងខ្ញុំចំកណ្ដាលមុខ។ មាត់ខ្ញុំចេញឈាម។ ខ្នងខ្ញុំចេញឈាម....[106]

ម្នាស់ជាអតីតអ្នកជាប់ឃុំឃាំងម្នាក់ អាយុ១៦ឆ្នាំ បានរៀបរាប់អំពីសាក្ខីភាពការវាយខ្សែភ្លើងនៅក្នុងមណ្ឌលសង្គមកិច្ចចោមចៅ :-

> [បុគ្គលិក]បានប្រើខ្សែអយសម្រាប់វាយ។ គាត់មានខ្សែអយបីប្រភេទ ដែលធ្វើពីខ្សែភ្លើងដែលគេបកសំបកផ្លាស្ទិកចេញ។ ខ្សែមួយមានទំហំតូចប៉ុនកូនម្រាមដៃ មួយទៀតប្រហែលប៉ុនមេដៃ ហើយមួយទៀតប៉ុនមេជើង។ គាត់សួរថាតើហ្វែងចង់រើសយកមួយណា។ វាត់មួយខ្វាប់ៗធ្វើឱ្យស្បែករបកដាច់ជាប់នឹងខ្សែភ្លើង[107]

បុគ្គលិកក៏វាយអ្នកជាប់ឃុំឃាំង ជាមួយឧបករណ៍ដទៃទៀតដែលមាននៅក្នុងដៃផងដែរ។ ទុរេនធ្លាប់ត្រូវរងការវាយ ដោយសារជក់បារីមួយដើមនៅក្នុងមជ្ឈមណ្ឌលឱកាសខ្ញុំ :-

> គេយកទុយយោទឹក ហើយបត់ចូលគ្នាជាពីរ មកវាយខ្ញុំ។ ពួកគេធ្វើបែបនេះ នៅពីក្រោយមណ្ឌល ដើម្បីកុំឱ្យគេមើលឃើញ។ ក្មេងៗស្ដាប់ឮតែសម្រែកទេ។ ពួកគេវាយខ្ញុំប្រហែល១០ដង នៅលើខ្នង។ វាជាទុយយោដែលគេប្រើសម្រាប់បាញ់ទឹកសម្អាតឡាន។ គេឱ្យខ្ញុំដោះអាវចេញ។ គឺអ្នកយាមជាអ្នកវាយ :- បីនាក់ទៀតឈរមើល ហើយសើចសប្បាយ ហើយម្នាក់...ជាអ្នកវាយ ។[108]

---

[106] អង្គការឃ្លាំមើលសិទ្ធិមនុស្ស សម្ភាសកក្កដា— ភ្នំពេញ ខែឧសភា ឆ្នាំ២០០៩

[107] អង្គការឃ្លាំមើលសិទ្ធិមនុស្ស សម្ភាសម្នាស់ — ភ្នំពេញ ខែមិថុនា ឆ្នាំ២០០៩

[108] អង្គការឃ្លាំមើលសិទ្ធិមនុស្ស សម្ភាសទុរេន — ភ្នំពេញ ខែ ឧសភា ឆ្នាំ២០០៩

គុហាបានរៀបរាប់អំពីការវាយមកលើខ្លួនគាត់ ដោយគ្រូបង្ហឹករាជអារុំធហត្ថ ដោយសារតែស្រវឹងស្រា "គាត់មានរំពាត់កាច់ពីមែកឈើ។ គាត់ដើរចូលក្នុងបន្ទប់ដេក ហើយវាយពួកយើងទាំងអស់គ្នា។ គាត់វាយខ្ញុំ និងពួកខ្ញុំទាំងអស់គ្នា។ ខ្ញុំដឹងថាគាត់ស្រវឹងស្រា ដោយសារមុខគាត់ឡើងក្រហម។[109] វិច្ឆិកាបានរៀបរាប់អំពីការវាយនៅក្នុងមណ្ឌលសង្គមកិច្ចព្រៃស្ពឺ ដែលគាត់បានឃើញដូច្នេះថាៈ-

> ខ្ញុំបានឃើញអ្នកយាមវាយអ្នកជាប់ឃុំឃាំង។ ខ្ញុំបានឃើញពួកគេវាយអ្នកដែលត្រូវចាប់បានមកវិញ បន្ទាប់ពីលួចរត់។ ដំបងធំប៉ុនដៃរបស់ខ្ញុំ។ ខ្ញុំបានឃើញពួកគេវាយបំបាក់ជើងបុរសម្នាក់។ ខ្ញុំឃើញអ្នកយាមលើកជើងនោះឡើងវា
> បាក់ទៅហើយ។[110]

អ្នកជាប់ឃុំឃាំងក្នុងមណ្ឌលក៏ត្រូវបានគេចាប់រំលោភសេពសន្ថវៈផងដែរ។ អតីតអ្នកជាប់ឃុំឃាំងភេទប្រុសម្នាក់ឈ្មោះក្រញូង អាយុ១៨ឆ្នាំ បានរាយការណ៍អំពីការបង្ខិតបង្ខំ ឱ្យខ្លួនគាត់រួមភេទតាមមាត់ ដោយមេបញ្ជាការមណ្ឌលកងរាជអាវុធហត្ថ ដែលជាកន្លែងដែលគាត់ជាប់ឃុំឃាំង ៈ-

> ដោយសារខ្ញុំជាអ្នកចូលថ្មី ខ្ញុំត្រូវតែធ្វើសរសៃឱ្យគេគ្រប់៧គ្នា។ នៅពេលខ្ញុំមកដល់អាទិត្យដំបូង ខ្ញុំមិនដែលបានដេកលក់ស្រួលទេ ពីព្រោះខ្ញុំត្រូវធ្វើសរសៃឱ្យប៉េអឹម ហើយពេលខ្លះធ្វើឱ្យមេបញ្ជាការ... គាត់ឱ្យខ្ញុំច្របាច់ដៃជើង និងឡើងជាន់លើគាត់យ៉ាងយូរ ទាញសក់ក្បាលរហូតដល់គាត់ដេកលក់។ គាត់ជាមេធំមណ្ឌលដែលធំជាងគេបង្អស់ ខ្ញុំត្រូវតែធ្វើសរសៃឱ្យកូនចៅគាត់ដែរ... បងដឹងទេធ្វើសរសៃធម្មតាផង និងរបៀបរួមភេទផង... ការធ្វើសរសៃខ្លះគឺជាការរួមភេទ។ ប្រសិនខ្ញុំមិនធ្វើតាមគាត់ គាត់នឹងវៃខ្ញុំ។ មេបញ្ជាការឱ្យខ្ញុំ "ស៊ីការ៉េម"[ការរួមភេទតាមមាត់]។ ខ្ញុំមិន

---

109 អង្គការឃ្លាំមើលសិទ្ធិមនុស្ស សម្ភាសគុហា — កម្ពុជា ខែកក្កដា ឆ្នាំ២០០៩

110 អង្គការឃ្លាំមើលសិទ្ធិមនុស្ស សម្ភាសវិច្ឆិកា — ភ្នំពេញ ខែឧសភា ឆ្នាំ២០០៩

ព្រម ហើយគាត់ទះកំផ្លៀងខ្ញុំ... ការរួមភេទតាមមាត់កើតឡើងជាញឹកញាប់ ខ្ញុំមិនធ្វើម៉េចនឹងកើត? ។[111]

អង្គការសិទ្ធិមនុស្សកម្ពុជាលីកាដូ បានកត់ត្រាការរំលោភសិទ្ធិមនុស្សយ៉ាងធ្ងន់ធ្ងរ រួមទាំងការរំលោភសេពសន្ថវៈដោយបុគ្គលិក ដែលតាមការចោទប្រកាន់បានកើតឡើងនៅក្នុងមណ្ឌលសង្គមកិច្ចព្រៃស្ពឺ ។[112] អតីតអ្នកជាប់ឃុំឃាំងធ្លាប់នៅព្រៃស្ពឺ ដែលត្រូវបានធ្វើសម្ភាសដោយអង្គការឃ្លាំមើលសិទ្ធិមនុស្ស បានបញ្ជាក់ពីភស្តុតាងពិតក្នុងរបាយការណ៍នេះ ។ ត្រាំបែក ដែលជាអ្នកប្រើប្រាស់គ្រឿងញៀន ហើយធ្លាប់ត្រូវបានឃុំខ្លួននៅក្នុងមណ្ឌលព្រៃស្ពឺ បានរាយការណ៍ថា ធ្លាប់ឃើញផ្ទាល់ភ្នែកនូវការរំលោភ "បូក" ដោយបុគ្គលិកមណ្ឌលជាច្រើនលើកច្រើនសារ :-

ខ្ញុំបានឃើញរឿងហ្នឹងផ្ទាល់ភ្នែក...ពួកវាបានយកស្រីចេញពីបន្ទប់ ។ ស្រីនោះមិនចេះនិយាយទេ...ពួកវាបាននាំក្មេងស្រីនោះចូលក្នុងថ្នាក់រៀន : អត់មានមនុស្សដេកនៅក្នុងថ្នាក់នោះទេ ។ ពួកគេបាននាំនាងនោះ[ចូលក្នុងបន្ទប់], ចាក់សោរបើកទ្វារបន្ទប់ ហើយចាក់សោរបិទបន្ទប់ឱ្យនាងនៅខាងក្នុង ។ ពួកវាចាប់រំលោភនាង... ខ្ញុំឃើញមានប្រុសបីនាក់... វាពិបាកនិយាយខ្លាំងណាស់ អាម៉ាស់មែនទែន ។ ក្មេងស្រីនោះស្រែករហូត ហើយមានការរើបំរះខ្លាំង... ពួកវាជាបុគ្គលិក ដែលធ្វើការនៅក្នុង

---

111 អង្គការឃ្លាំមើលសិទ្ធិមនុស្ស សម្ភាសក្រញូង — កម្ពុជា ខែមិថុនា ឆ្នាំ២០០៩

112 លីកាដូ "សេចក្តីប្រកាសព័ត៌មាន : ការចាប់ខ្លួនខុសច្បាប់ និងមជ្ឈមណ្ឌលសង្គកិច្ច : ពេលសម្រាប់រដ្ឋាភិបាលចាត់វិធានការ មិនមែនពេលសម្រាប់បដិសេធនោះទេ " ថ្ងៃទី៩ វិច្ឆិកា ២០០៨ សូមចូលមើលគេហទំព័រ http://www.licadhocambodia.org/press/files/193LICADHOPRActionNot_Denials08.pdf ។ ទោះបីរដ្ឋាភិបាលមិនចុះបញ្ជីជាផ្លូវការជាមជ្ឈមណ្ឌលស្តារនីតិសម្បទាក៏ដោយ អតីតអ្នកប្រើប្រាស់គ្រឿងញៀនពិតប្រាកដមួយចំនួន ត្រូវបានសម្ភាសដោយអង្គការឃ្លាំមើលសិទ្ធិមនុស្ស បានរាយការណ៍ថាធ្លាប់ជាប់ឃុំខ្លួនដោយខុសច្បាប់នៅមជ្ឈមណ្ឌលនេះ ។ ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា ក្នុងរបាយការណ៍របស់ខ្លួនជូនចំពោះក្រុមប្រឹក្សាសិទ្ធិមនុស្ស អ.ស.ប បានកត់ត្រាថា ប្រជាពលរដ្ឋដែលនៅក្នុងមជ្ឈមណ្ឌលឃុំឃាំងនៅភ្នំពេញ ជាពិសេសកោះគ (ដែលគេស្គាល់ថាជាកោះរំដួល) និងព្រៃស្ពឺ "ត្រូវបានឃុំឃាំងខុសច្បាប់ និងរងអំពើរំលោភអំណាចផ្សេងៗដោយបុគ្គលិក ដែលរួមមានស្ថានភាពការឃុំឃាំងដ៏អមនុស្សធម៌ ជីវិតទារប្រាក់ ការវាយដំ ការរំលោភសេពសន្ថវៈ ដែលពេលខ្លះបណ្តាលឱ្យស្លាប់ និងអត្តឃាតកម្ម"។ ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស នៅកម្ពុជា បានកត់សម្គាល់ឃើញថា "ខ្លួនបានចុះធ្វើទស្សនាកិច្ចមជ្ឈមណ្ឌលទាំងនោះ ហើយបានសង្កេតឃើញស្ថានភាពគួរឱ្យរន្ធត់ ដែលមនុស្សត្រូវជាប់នៅទីនោះ ។ "*អំពីតួនាទីនិងសមិទ្ធិផលរបស់ឧត្តមស្នងការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ក្នុងការជួយរដ្ឋាភិបាល និងប្រជាជនកម្ពុជា ក្នុងការជំរឿននិងការការពារសិទ្ធិមនុស្ស* - A/HRC/12/41- ថ្ងៃទី៥ ខែសីហា ២០០៩ កថាខ័ណ្ឌ២៨

មណ្ឌល [ដែលបានរំលោភនាង]ក្មេងស្រី"ធម្មតា" ក៏ត្រូវបានគេរំលោភផងដែរ។ អ្នកយាមបានយកលេសដើម្បីយកក្មេងស្រីចេញពីបន្ទប់ ដូចជាពួកវាធ្វើខុសអ្វីមួយ។ ពេលខ្លះពួកវាបានរំលោភស្ត្រីដដែលចំនួនប្រាំដងជាប់ៗគ្នា ដោយសារអត់មានអ្នកមកថ្មី។ ពេលខ្លះស្ត្រីទាំងនោះជាអ្នករកស៊ីផ្លូវភេទ ពេលខ្លះមិនមែនទេ។ ពួកវាបានរំលោភស្ត្រីគម្នាក់ប្រហែលប្រាំឬប្រាំមួយដង។ ខ្ញុំបានឃើញដោយផ្ទាល់ភ្នែក។ ពេលខ្លះទៀត ខ្ញុំបានឮសម្រែករបស់ស្រីនោះ... ខ្ញុំដឹងថា [នាង] ព្យាយាមធ្វើឱ្យមានសម្លេង : សម្លេងដែលខុសប្លែកពីធម្មតា។ បន្ទប់នោះគឺនៅជាប់នឹងបន្ទប់របស់ខ្ញុំ។ ជានិច្ចជាកាល គឺពួកវាជាអ្នកយាមបីនាក់នោះ[ដែលបានរំលោភស្រីៗ]។ ពេលខ្លះឃើញមានអ្នកក្រៅចូលរួមដែរ។[113]

លលកជាស្ត្រីអត់ផ្ទះសម្បែង ធ្លាប់ជាប់ឃុំឃាំងនៅក្នុងមណ្ឌលព្រៃស្ពឺ បានរាយការណ៍ថា :-

លោកដឹងទេ គេយកស្រីស្អាតៗទៅចាប់រំលោភ... បន្ទាប់ពីគេយកទៅ ស្រីៗទាំងនោះបាត់ខ្លួនលែងឃើញត្រឡប់មកវិញ។ ពួកគេមានអាយុប្រហែល១៩-២០ឆ្នាំ។ ខ្ញុំឃើញមានស្ត្រីពីរនាក់ ដែលបានយកចេញពីបន្ទប់របស់ខ្ញុំ...អ្នកយាមម្នាក់បាន [សួរអ្នកយាមម្នាក់ទៀត] "ម៉េច ហ្អា ស្រីស្អាតពីយប់មិញ?។ ហ្វែងធ្វើអីខ្លះ? [អ្នកយាមទីពីរបានឆ្លើយតប] ថា :- "មុនអញលែងវា អញស៊ីឆ្អែតហើយ" [គ្រាមភាសា ដែលមានន័យថារួមភេទ] [114]

អ្នកជាប់ឃុំឃាំង ក៏ទទួលរងការធ្វើទណ្ឌកម្មរាងកាយយ៉ាងឈឺចាប់ផងដែរ។ ទម្រង់ទូទៅនៃទណ្ឌកម្មលើរាងកាយ គឺជាទណ្ឌកម្មបែប"រមៀលធុងសាំង" ពោលគឺធ្វើឱ្យអ្នកជាប់ឃុំឃាំងរមៀល

---

[113] អង្គការឃ្លាំមើលសិទ្ធិមនុស្ស សម្ភាសត្របែក — ភ្នំពេញ ខែមិថុនា ឆ្នាំ២០០៩

[114] អង្គការឃ្លាំមើលសិទ្ធិមនុស្ស សម្ភាសលលក — សៀមរាប ខែមិថុនា ឆ្នាំ២០០៩

នៅលើដីទៅកាន់ចំងាយមួយជាក់លាក់។ ដុំថ្មដ៏រឹងមុតស្រួច ធ្វើឱ្យរាងកាយអ្នកជាប់ឃុំឃាំងទទួលរងការឈឺចាប់ខ្លាំងឡើង១។ ការឈឺចាប់នេះកាន់តែខ្លាំងឡើង ដោយសារតែដោះសម្លៀកបំពាក់ចេញ។ សៅបានធ្វើបង្ហាញនូវទណ្ឌកម្ម "រមៀលធុងសាំង" ដល់អង្គការឃ្លាំមើលសិទ្ធិមនុស្ស ដោយរមៀលដបទឹកសុទ្ធ នៅលើតុដែលកំពុងធ្វើសម្ភាស។ គាត់ពន្យល់ថាៈ-

> បន្ទាប់ពីវាយរួច ពួកគេបានបញ្ជាអ្នក[ដែលត្រូវទទួល]ទណ្ឌកម្មនោះឱ្យរមៀល "ធុងសាំង" នៅលើដុំថ្មតូច១។ អ្នកនោះត្រូវតែរមៀលទៅចំងាយប្រហែល៥០ម៉ែត្រ ហើយត្រូវរមៀលត្រឡប់មកវិញ... ដីនោះមិនរាបស្មើទេ ប៉ុន្តែជាប្រភេទដីក្រហូងដែលមានក្រួសច្រើន។ ដីនោះអាចធ្វើឱ្យឈឺជើងប្រសិនដើរអត់ពាក់ស្បែកជើង។ [បន្ទាប់ពីទណ្ឌកម្មបែបនេះមក] នៅលើខ្លួនមានស្នាមដាច់ មុត រលាត់ស្បែក។ មេធំ និងអ្នកយាមដែលឱ្យធ្វើបែបនេះ [បញ្ជាឱ្យធ្វើ] ។[115]

អាទិត្យបានរៀបរាប់អំពីទណ្ឌកម្មមកលើខ្លួនគាត់ ដោយតម្រូវឱ្យ "រមៀលធុងសាំង" និងធ្វើលំហាត់ប្រាណផ្សេង១ទៀត បន្ទាប់មកត្រូវរងការវាយដំ និងវាត់នឹងរំពាត់នៅក្នុងមជ្ឈមណ្ឌលឱកាសខ្ញុំ។

> បុគ្គលិកឱ្យខ្ញុំរមៀលនៅលើដី... ខ្ញុំត្រូវដោះខោអាវចេញ ហើយរមៀលធុងសាំង ។ ខ្ញុំត្រូវរមៀលខ្លួនចំងាយប្រហែល១០០ម៉ែត្រ ហើយរមៀលត្រឡប់មកវិញ១០០ ម៉ែត្រទៀត។ បន្ទាប់ពីរមៀលរួច ខ្ញុំក្រោកឈរឡើង តែដួលផ្កាប់មុខដោយសារវិលមុខពេក។ មានអារម្មណ៍ឈឺខ្លាំង។ ខ្ញុំប្រឡាក់ដីពេញខ្លួន។ ឈឺណាស់... មានស្នាមដាច់នៅលើខ្លួន ជាពិសេសកំភួនដៃ ដោយសារខ្ញុំយកដៃឱបការពារក្បាល។ ក្រោយមកគេឱ្យខ្ញុំលោតកង្កែបប្រហែល១០០ម៉ែត្រ [ទៅមុខ] ហើយ ១០០ ម៉ែត្រ

---

[115] អង្គការឃ្លាំមើលសិទ្ធិមនុស្ស សម្ភាសសៅ — ភ្នំពេញ ខែមេសា ឆ្នាំ២០០៩

ទៅត្រឡប់ក្រោយលើផ្លូវតែមួយ។ បន្ទាប់មកគេឱ្យខ្ញុំរមៀល "ស្វាដាំដូង" ១០០ ម៉ែត្រទៅមុខ ហើយមកក្រោយវិញ។ ខ្ញុំឈឺខ្លាំងណាស់។ ខ្ញុំមានអារម្មណ៍ថាគ្មានអ្វីទាំងអស់ ៖ ខ្ញុំធ្វើតាមតែបញ្ជាគេទេ។ គេយកដងរែកវៃគូទខ្ញុំ។ គេវាយខ្ញុំពីរដងរែកពេញទំហឹង។ មើលឃើញស្នាមឡើងក្រហម។ គេបានប្រើខ្សែភ្លើងបីបួនខ្សែរវេញចូលគ្នា។ ពួកគេបានវាយគូទខ្ញុំបីដង [ជាមួយខ្សែភ្លើង] វាឈឺជាងដងរែកទៅទៀត។ ខ្ញុំចេញឈាម... រឿងបានកើត ឡើងពីរដងមកលើខ្ញុំ៖- ម្តងនៅពេលឈ្លោះប្រកែកគ្នា ហើយម្តងទៀតជក់បារី។[116]

ស្រកានាគបានរៀបរាប់អំពីការធ្វើទណ្ឌកម្មមកលើខ្លួនគាត់នៅក្នុងមជ្ឈមណ្ឌល "ស្តារនីតិសម្បទា"សង្គមកិច្ចចោមចៅ។ បន្ទាប់ពីចាប់មកវិញដោយសារបំណងរត់គេចមិនបានសម្រេច ៖-

គេបានធ្វើទារុណកម្មមកលើខ្ញុំ... អ្នកយាមបានចេញបញ្ជាឱ្យលុតជង្គង់។ ខ្ញុំត្រូវដើរលើជង្គង់ប្រហែលចំងាយ ១៥ ម៉ែត្រ ចំនួន ៥០ ដង។ ធ្វើបែបនេះនៅពីមុខមណ្ឌលកន្លែងគេហាត់ប្រាណ។ ឈឺខ្លាំង។ ពេលដែលខ្ញុំធ្វើចប់ ខ្ញុំត្រូវធ្វើអ្វីផ្សេងៗទៀត។ ខ្ញុំបានធ្វើចំនួន២០ដងប៉ុណ្ណោះ។ [ក្បាលជង្គង់របស់ខ្ញុំ] ចេញឈាម ហើយរលាត់ស្បែក។ បន្ទាប់មកខ្ញុំ "រមៀលធុងសាំង" ៖ គឺយើងត្រូវរមៀលខ្លួននៅលើដីទៅមុខ និងរមៀលត្រឡប់ក្រោយវិញ ចំងាយប្រហែល ៥០ ទៅ ៧០ ម៉ែត្រ។ ខ្ញុំឈឺឆ្អឹងខ្នង និងស្មា។ មានដាច់ស្បែកចេញ និងរលាត់ស្បែក។ ខ្ញុំរមៀលតែម្តងទេ ទៅនិងត្រឡប់មកវិញ។ បន្ទាប់មកគេឱ្យខ្ញុំខាំថ្គាម ហើយគេបានទះកំផ្លៀងខ្ញុំនៅចំកណ្តាលមុខ។[117]

---

116 អង្គការឃ្លាំមើលសិទ្ធិមនុស្ស សម្ភាសអាទិត្យ — ភ្នំពេញ ខែមេសា ឆ្នាំ២០០៩

117 អង្គការឃ្លាំមើលសិទ្ធិមនុស្ស សម្ភាសស្រកានាគ — ភ្នំពេញ ខែមិថុនា ឆ្នាំ២០០៩

ក្រញូងបានរៀបរាប់អំពីទណ្ឌកម្មមកលើខ្លួនគាត់ នៅក្នុងមណ្ឌលស្នងការនគរបាលខេត្ត សៀមរាប ដោយឱ្យឈរកណ្តាលថ្ងៃ ជើងម្ខាងជាប់ច្រវាក់ ហើយបន្ទាប់មកត្រូវគេដាក់ខ្នោះ ។

> ខ្ញុំឈររហូតទាល់តែដួល ។ ថ្ងៃក្តៅខ្លាំងណាស់... ខ្ញុំត្រូវតែឈរជើងម្ខាង ហើយលាតត្រដាងដៃចេញ ៖ ប្រសិនបើហ៊ានទំលាក់ជើង គេនឹងវាយខ្ញុំ ។ ខ្ញុំមិនឈររាល់ថ្ងៃទេ ឈរតែរយៈពេលពីរម៉ោង ខ្ញុំទ្រាំលែងបាន ។ ក្រោយមកគេក៏វាយខ្ញុំ ។ បន្ទាប់ពីឈរ [បែបហ្នឹង] ។ ខ្ញុំឈឺខ្លួនមួយអាទិត្យ... គេបានដាក់ច្រវាក់កជើងទាំងពីរ របស់ខ្ញុំ គេបានមួលខ្នៅយ៉ាងណែន ។ ខ្ញុំជាប់ខ្នោះ អស់ប្រាំបួនថ្ងៃកន្លះ... [មិត្តខ្ញុំ] ។ ជាប់ខ្នោះប្រហែលពីរអាទិត្យ ។ នៅពេលពួកគេបើកទ្វារ ពួកខ្ញុំដើរដោយជើងជាប់ច្រវាក់ទៅផ្ទះបាយ ។ នៅក្នុងបន្ទប់ដេក ពួកខ្ញុំជាប់ខ្នោះផងដែរ ។[118]

## ការរំលោភដោយអ្នកជាប់ឃុំឃាំង

ការរំលោភជាច្រើនដែលកើតឡើងនៅក្នុងមជ្ឈមណ្ឌល ត្រូវបានប្រព្រឹត្តដោយអ្នកជាប់ឃុំឃាំង មកលើអ្នកជាប់ឃុំឃាំងដទៃទៀត ។ ទោះជាយ៉ាងណាក៏ដោយ ការរំលោភបំពានទាំងនេះមានលក្ខណៈជាអំពើដែលកើតឡើងដោយឯកឯងនៃអំពើហិង្សារវាងអ្នកជាប់ឃុំឃាំងដូចគ្នា ដែលនាំឱ្យខុសយ៉ាងធ្ងន់ធ្ងរ ។ បុគ្គលិកមណ្ឌល បានប្រគល់សិទ្ធិឱ្យអ្នកជាប់ឃុំឃាំងដែលទុកចិត្ត ។ អ្នកជាប់ឃុំឃាំងទាំងនេះ អនុវត្តការគ្រប់គ្រងប្រចាំថ្ងៃភាគច្រើនលើអ្នកជាប់ឃុំឃាំងដទៃទៀត ហើយអនុវត្តវិន័យមណ្ឌល ។ ប្រវីកបានពន្យល់ថា "ខ្ញុំកម្រឃើញអ្នកយាម [ពិតប្រាដ] ៖- អ្នកជាប់ឃុំឃាំងដែលរស់នៅយូរមុនខ្ញុំ ឡើងគ្រប់គ្រងទីកន្លែង" ។[119] អាជ្ញាធរបានផ្តល់សិទ្ធិ ទៅឱ្យអ្នកជាប់ឃុំឃាំងទាំងនេះ ដើម្បីពង្រីកអំណាចគ្រប់គ្រងដាក់វិន័យនិងដាក់ទណ្ឌកម្មអ្នក ជាប់ឃុំឃាំង ។ អំពើ

---

118 អង្គការឃ្លាំមើលសិទ្ធិមនុស្ស សម្ភាសក្រញូង — កម្ពុជា ខែមិថុនា ឆ្នាំ២០០៩

119 អង្គការឃ្លាំមើលសិទ្ធិមនុស្ស សម្ភាសប្រវីក — ភ្នំពេញ ខែមេសា ឆ្នាំ២០០៩

ឃោរឃៅលើរាងកាយយ៉ាងធ្ងន់ធ្ងរ គឺកើតឡើងជាធម្មតា នៅពេលខ្លះក្រោមបញ្ជាផ្ទាល់ពីបុគ្គលិកធម្មតា។

ពុធពន្យល់ថា អ្នកជាប់ឃុំឃាំងទាំងនោះ អនុវត្តវិន័យជាប្រចាំថ្ងៃយ៉ាងតឹងរឹង ក្នុងមណ្ឌល :-

> បងដឹងទេ ខ្ញុំត្រូវគេវាយពីរដងជាមួយនឹងបន្ទាត់... គឺមិនមែនប្រធានមណ្ឌល [ដែលជាអ្នកវាយទេ] ប៉ុន្តែគឺជាមេបន្ទប់មានសិទ្ធិវាយ។ ប្រសិនបើចូលខុសជួរ នៅពេលហូបបាយ ឬជជែកគ្នាឮពេកនៅក្នុងបន្ទប់ អ្នកនោះត្រូវគេវាយមិនខាន។[120]

នៅក្នុងមណ្ឌលសង្គមកិច្ច អ្នកជាប់ឃុំឃាំងដែលអនុវត្តវិន័យ គឺធម្មតាគេសំដៅទៅរក "ឆ្មា" ដែលមានភារកិច្ចចាំឃ្លាំមើល "កណ្ដុរ" (អ្នកជាប់ឃុំឃាំងផ្សេងទៀត)។ ដួងចែម អាយុ២០ ឆ្នាំ បានពន្យល់ដូច្នេះថា :- "យើង [អ្នកជាប់ឃុំឃាំង] ត្រូវបានគេចាត់ទុកថាជាកណ្ដុរ ហើយអ្នកយាមបន្ទប់គឺជាឆ្មា។ ប្រសិនបើកណ្ដុរលួចរត់ ឆ្មាត្រូវដេញចាប់... "ឆ្មា" និងបុគ្គលិកគឺជាមិត្តនឹងគ្នា"។[121] "ឆ្មា" មានភារកិច្ចរក្សាសណ្ដាប់ធ្នាប់ រាយការណ៍អំពីការប៉ុនប៉ងលួចរត់ ហើយដាក់ទណ្ឌកម្មចំពោះអ្នកដែលធ្វើខុសវិន័យ។ ម្នាស់ អាយុ ១៦ ឆ្នាំ អតីតជា "ឆ្មា" នៅពេលគាត់ជាប់ឃុំឃាំងថ្មីៗបំផុត។ គាត់បានពន្យល់តួនាទីរបស់គាត់ជា"ឆ្មា" ថា :-

> ខ្ញុំធ្លាប់ធ្វើ"ឆ្មា"។ "ឆ្មា" ទទួលខុសត្រូវអ្នកទោស។ ខ្ញុំមានសិទ្ធិវាយអ្នកណាម្នាក់ដែលមានកំហុស... មានឆ្មាបួននាក់ រួមទាំងខ្ញុំផង។ ខ្ញុំដេកខាងក្រៅ នៅចំពីមុខទ្វារបន្ទប់។ ឆ្មានីមួយៗមានសោរ... ពួកខ្ញុំមានរបបអាហារដាច់ពីអ្នកទោសផ្សេងៗទៀត :- ពួកខ្ញុំមានបាយពិសេសនិងសម្លម្ជូរដើមចេក។ ខ្ញុំទទួលខុសត្រូវបន្ទប់មួយ

---

[120] អង្គការឃ្លាំមើលសិទ្ធិមនុស្ស សម្ភាសពុធ — ភ្នំពេញ ខែមេសា ឆ្នាំ២០០៩

[121] អង្គការឃ្លាំមើលសិទ្ធិមនុស្ស សម្ភាសដួងចែម — កម្ពុជា ខែមិថុនា ឆ្នាំ២០០៩

ដែលមានគ្នា ២០ ទៅ ២១ នាក់ គឺធ្វើយ៉ាងណាមិនឱ្យអ្នកណាម្នាក់បាត់ខ្លួនទេ ប្រសិនអ្នកណាម្នាក់លួចរត់ ពួកខ្ញុំស្រែករហូតទាល់តែអ្នកនោះត្រូវចាប់មកវិញ... ខ្ញុំធ្លាប់ទះកំផ្លៀងអ្នកទោស។ ឧទាហរណ៍ ប្រសិនបើគេមិនចូលក្នុងជួរឱ្យបានត្រឹមត្រូវទេ ឬហាត់ប្រាណខុស ខ្ញុំទះកំផ្លៀងពួកគេ។ ប្រសិនបើកំហុសតិចតួច ត្រូវទះកំផ្លៀងពីរបីដង។ ប្រសិនខុសធ្ងន់ ត្រូវវាយដោយអ្នកនៅក្នុងបន្ទប់ទាំងអស់គ្នាពីរឬបីដង...[122]

នៅក្នុងមជ្ឈមណ្ឌលដទៃទៀត (ពោលគឺគ្រប់គ្រងដោយសាលាក្រុងភ្នំពេញ រាជអាវុធហត្ថ ឬនគរបាលស៊ីវិល) ឋានានុក្រមខាងវិន័យកាន់តែមានភាពស្មុគ្រស្មាញ។ បន្ទប់ដេករួមនីមួយៗ នៅក្នុងមជ្ឈមណ្ឌលកំណត់ឱ្យមាន [មេកង ឬមេបន្ទប់ម្នាក់] និងអនុកងម្នាក់ឬពីរនាក់។ អ្នកជាប់ឃុំឃាំងត្រូវបានគេចែកជាក្រុម (ដែលមួយក្រុមៗមានគ្នា ១០ នាក់) ដែលក្រុមនីមួយៗមានមេក្រុមម្នាក់និងអនុក្រុមម្នាក់។ ទុរនេនអតីតអ្នកជាប់ឃុំឃាំងម្នាក់ក្នុងវ័យពាក់កណ្តាល ៣០ ឆ្នាំ បានពន្យល់ប្រាប់អង្គការឃ្លាំមើលសិទ្ធិមនុស្ស អំពីមូលហេតុដែលគេជ្រើសរើសគាត់ ឱ្យធ្វើជាមេកង និងកិច្ចការដែលគាត់ត្រូវធ្វើដូច្នេះថា :-

ខ្ញុំធ្លាប់ធ្វើមេកង ដោយសារមាឌ និងសាច់ដុំរបស់ខ្ញុំ។ ខ្ញុំអាចសម្លុតមនុស្សច្រើន។ នៅពេលហូបបាយ ខ្ញុំស្រែកថា "ប្រុង!" ប្រសិនគេមិនធ្វើតាមទេ ខ្ញុំដើរទៅរកហើយទះកំផ្លៀង ឬយកទៅមុជទឹកនិងដាល់ ឬយកទៅបន្ទប់ហើយដាល់... ខ្ញុំចូលទៅក្នុងបន្ទប់ ពិនិត្យមើលតើពួកគេស្អាត ឬអត់។ ខ្ញុំធ្វើការងាររបស់បុគ្គលិក... [បុគ្គលិក] និយាយថា "ត្រូវធ្វើឱ្យល្អគ្រប់យ៉ាង ឱ្យពួកវាធ្វើឱ្យត្រឹមត្រូវ"។ ពួកគេប្រាប់ឱ្យគោរពបញ្ជា ហាមជក់បារី បន្ទប់ត្រូវតែស្អាត ហើយអ្នកជាប់ឃុំឃាំង ត្រូវធ្វើការទាំងអស់គ្នា។ ពួកគេនិយាយថា "ត្រួតពិនិត្យមើលពួកវា ហើយវាយពួកវា"។

---

[122] អង្គការឃ្លាំមើលសិទ្ធិមនុស្ស សម្ភាសម្នាស់ — ភ្នំពេញ ខែមិថុនា ឆ្នាំ២០០៩

> មេកងអាចប្រើដៃ ឬរំពាត់តាមចិត្តចង់ និងស្រេចតែចិត្ត។ អត់មានវិន័យអ្វីទេ។ [ធ្វើជាមេកង], គេបានហូបអាហារឆ្ងាញ់ៗ ហើយមានអ្នកធ្វើសរសៃឱ្យទៀត ប្រសិនបើមិនស្រួលខ្លួន មេកងអាចហៅមនុស្សពីរបីនាក់មកធ្វើសរសៃឱ្យ។ មានអ្នកចងមុងឱ្យដេកស្រាប់ៗ... នៅពេលឪពុកម្តាយកូនអ្នកមាន យកអាហារមកឱ្យកូនគេ មេកងទទួលបានពាក់កណ្តាល។ ធ្វើជាមេកងគឺដូចជាស្តេចអញ្ចឹង។[123]

តាមវិធីបែបនេះ អ្នកជាប់ឃុំឃាំងត្រូវបានប្រើប្រាស់ដោយបុគ្គលិក ឱ្យអនុវត្តនូវការរំលោភលើរាងកាយនិងវិធានការដាក់វិន័យផ្សេងៗទៀត មកលើអ្នកជាប់ឃុំឃាំងដទៃទៀត។ នៅពេលខ្លះបុគ្គលិកធ្វើទណ្ឌកម្មលើអ្នកជាប់ឃុំឃាំងដោយខ្លួនឯង ហើយបន្ទប់មក បញ្ជាឱ្យធ្វើទណ្ឌកម្មបន្ថែមប្រហែលតាមទម្រង់វាយដំដ៏ធ្ងន់ធ្ងរ ប្រព្រឹត្តដោយអ្នកជាប់ឃុំឃាំងផ្សេងទៀត។ នៅពេលខ្លះទៀតអ្នកជាប់ឃុំឃាំងត្រូវបានបញ្ជាឱ្យអនុវត្តរាល់ការដាក់ទណ្ឌកម្មទាំងអស់ដោយខ្លួនឯង។

អង្គការឃ្លាំមើលសិទ្ធិមនុស្ស បានទទួលរបាយការណ៍មួយចំនួនស្តីពីបុគ្គលិក ដែលបញ្ជាឱ្យអ្នកជាប់ឃុំឃាំងដ៏ច្រើន ឱ្យវាយដំអ្នកជាប់ឃុំឃាំងជាក់លាក់ណាម្នាក់ ដែលជាញឹកញាប់ ក្រោមការគ្រប់គ្រងរបស់អ្នកជាប់ឃុំឃាំង។ ការវាយដំនេះ ហាក់ដូចជាកើតឡើងតាមធម្មតា ភ្លាមៗបន្ទាប់ពីអ្នកជាប់ឃុំឃាំងថ្មីណាម្នាក់ទើបនឹងមកដល់។ អ្នកជាប់ឃុំឃាំងមកដល់ថ្មី ត្រូវបានណែនាំឱ្យស្គាល់របបវិន័យរបស់មណ្ឌល ដោយការវាយ"ស្វាគមន៍" ហើយការបញ្ជាឱ្យអ្នកជាប់ឃុំឃាំងទាំងអស់អនុវត្តការវាយដំទាំងនេះគឺធ្វើឡើងដើម្បីធ្វើឱ្យស្គាល់ និងពង្រឹងឋានានុក្រមវិន័យនៅក្នុងមណ្ឌលក្នុងចំណោមអ្នកជាប់ឃុំឃាំងទាំងអស់។ សាក្ខីភាពរបស់ដួងចែមគឺជាតំណាងនៃការអនុវត្តបែបនេះ :-

> [បន្ទាប់ពីមកដល់ភ្លាមៗ] ខ្ញុំសន្លប់លែងដឹងខ្លួន។ អ្នកជាប់ឃុំឃាំងបានវាយខ្ញុំ។ ខ្ញុំមិនដឹងថាមានប៉ុន្មាននាក់ទេ។ ពួកវាយកភួយមកគ្របលើខ្ញុំ ហើយវាយធ្វើបាបខ្ញុំ។

---

[123] អង្គការឃ្លាំមើលសិទ្ធិមនុស្ស សម្ភាសទុរេន — ភ្នំពេញ ខែឧសភា ឆ្នាំ២០០៩

ពួកវាវាយខ្ញុំចំកណ្ដាលមុខ ដើមទ្រូង ចំហៀងខ្លួន។ ខ្ញុំមិនដឹងថាគេវាយអស់រយៈពេលប៉ុណ្ណាទេ ប៉ុន្តែគេវាយខ្ញុំនៅក្នុងបន្ទប់ដែលខ្ញុំដេកនោះ។ បុគ្គលិកបានបញ្ជាឱ្យអ្នកជាប់ឃុំជាមួយគ្នាវាយខ្ញុំ។ បុគ្គលិកបាននិយាយថា "មាន់ថ្មីមកដល់ហើយវើយ ដកស្លាបវាស៊ីទៅ!"។ គឺបុគ្គលិក ជាអ្នកនិយាយ... គាត់បណ្ដើរខ្ញុំចូលក្នុងបន្ទប់ [ហើយចេញបញ្ជា]... គាត់ចាក់សោរទ្វារ ហើយក្មេងៗចាប់ផ្ដើមវាយធ្វើបាបខ្ញុំ។[124]

ត្របែកបានរៀបរាប់អ្វីដែលឃើញផ្ទាល់ភ្នែក នូវទម្រង់ទណ្ឌកម្មដ៏ឃោរឃៅមួយ ដោយសារជក់បារី ដែលហៅថា "ស៊ុស្លា" ។

ក្នុងមណ្ឌលឱកាសខ្ញុំ ពួកគេឱ្យអ្នកជាប់ឃុំឃាំងជក់បារី ហើយឱ្យរត់បុកជញ្ជាំងរហូតបាក់ធ្មេញ... មានម្នាក់លួចជក់បារី ហើយគេចាប់បាន។ គេឱ្យគាត់ជក់បារី ហើយរត់បុកនឹងជញ្ជាំង។ ប៉ុន្តែគាត់បានឈប់ង៉ក់នៅមុខជញ្ជាំង។ មេកងបាននិយាយថា "ស្អី ហ្អែងមិនចេះរត់បុកជញ្ជាំងទេ?" ហើយបានចាប់ក្បាលរុញបុកនឹងជញ្ជាំងរហូតដល់គាត់សន្លប់លែងដឹងខ្លួន។[125]

ត្របែកបានធ្វើការកត់សម្គាល់ថា រឿងដែលឈឺចាប់ចំពោះការធ្វើទណ្ឌកម្មនេះគឺថាមេកងខ្លួនឯង គឺជាអ្នកលួចលក់បារីឱ្យអ្នកជាប់ឃុំឃាំង ដោយទទួលប្រាក់ចំណេញយ៉ាងច្រើន។

ទំនាក់ទំនងដ៏ជិតស្និទ្ធរវាងបុគ្គលិកពិតប្រាកដ និងអ្នកជាប់ឃុំឃាំងដែលអនុវត្តវិន័យ ធ្វើឱ្យអ្នកជាប់ឃុំផ្សេងៗ មិនអាចរាយការណ៍អំពីការរំលោភបានទេ។ ពួកគេទទួលបាននិទណ្ឌភាពដែលមានកម្រិតស្មើគ្នានឹងបុគ្គលិកដែរ។ ប្រវឹកបាននិយាយថា គាត់រងការវាយដំដោយអ្នកជាប់

---

[124] អង្គការឃ្លាំមើលសិទ្ធិមនុស្ស សម្ភាសដួងថៃម — កម្ពុជា ខែមិថុនា ឆ្នាំ២០០៩

[125] អង្គការឃ្លាំមើលសិទ្ធិមនុស្ស សម្ភាសត្របែក — ភ្នំពេញ ខែមិថុនា ឆ្នាំ២០០៩

ឃុំឃាំងនៅពេលមកដល់មណ្ឌល គាត់បានពន្យល់ថា "ប្រសិនបើអ្នកណាម្នាក់ហ៊ានរាយការណ៍ប្រាប់អ្នកយាម អ្នកនោះពិតជាពិបាកហើយ។ គេមិនអាចនិយាយប្រាប់អ្នកយាមទេ ពីព្រោះ [ប្រសិនបើនិយាយប្រាប់] នៅពេលទ្វារបិទ អ្នកនោះនឹងត្រូវគេវាយម្តងទៀត"។[126] ទុរេន ដែលខ្លួនគាត់ជាអតីតមេកងម្នាក់ បានពន្យល់ថា "[អ្នកជាប់ឃុំឃាំងដទៃទៀត] មិនអាចប្តឹង [អំពីការ រំលោភរបស់អ្នកជាប់ឃុំឃាំងដូចគ្នាបានទេ] ៖ ប្រសិនបើគេហ៊ានប្តឹង ពួកគេនឹងត្រូវគេវាយម្តងទៀត។ ពួកគេមិនប្តឹងទេ។ គេក៏ដឹងថាមិនត្រូវប្តឹងទេ"។[127]

មានភាពដូចគ្នាមែនទែនរវាងសាក្សីកម្មរបស់អតីតអ្នកជាប់ឃុំឃាំងនៅមជ្ឈមណ្ឌលឃុំឃាំងគ្រឿងញៀន ដោយបានប្រមូលដោយអង្គការឃ្លាំមើលសិទ្ធិមនុស្ស ហើយអតីតអ្នកទោសដែលជាប់នៅក្នុងពន្ធនាគារប្រទេសកម្ពុជា។ អ្នកទោសពន្ធនាគាររៀបរាប់អំពីប្រព័ន្ធគ្រប់គ្រងដែលប្រហាក់ប្រហែលគ្នាច្រើននៅក្នុងពន្ធនាគារ ៖ អ្នកទោសមួយចំនួន ត្រូវបានផ្តល់តួនាទី អំណាច (ដូចជាប្រធានបន្ទប់ ឬប្រធានអាគារជាដើម) ទៅលើអ្នកទោសដូចគ្នា។ អំពើហិង្សា ត្រូវបានបញ្ជាឱ្យធ្វើតាមការណែនាំរបស់ឆ្មាំគុក ទៅលើអ្នកទោសដែលចោទថាបានល្មើសនឹងវិន័យពន្ធនាគារ ឬព្យាយាមរត់។ នៅក្នុងពន្ធនាគារមួយចំនួនទៀត អ្នកទោសចូលថ្មីតាមដែលរាយការណ៍ថា ត្រូវបានទទួល "ស្វាគមន៍" ដោយការវាយដំដោយអ្នកទោសដូចគ្នា។ ភាពស្រដៀងគ្នាទាំងនេះ ផ្តល់នូវភស្តុតាងកាន់តែច្រើនថា ការធ្វើទារុណកម្ម គឺមិនមែនការព្យាបាលនិងស្តារនីតិសម្បទាទេ ដែលជាគោលបំណងដ៏សំខាន់ របស់មជ្ឈមណ្ឌលឃុំឃាំងគ្រឿងញៀន។[128]

---

126 អង្គការឃ្លាំមើលសិទ្ធិមនុស្ស សម្ភាសប្រវឹក — ភ្នំពេញ ខែមេសា ឆ្នាំ២០០៩

127 អង្គការឃ្លាំមើលសិទ្ធិមនុស្ស សម្ភាសទុរេន — ភ្នំពេញ ខែឧសភា ឆ្នាំ២០០៩

128 សម្រាប់ព័ត៌មានបន្ថែមស្តីពីបញ្ហាពន្ធនាគារ រួមមានការប្រើប្រាស់អ្នកទោសឱ្យធ្វើទណ្ឌកម្មនិងរក្សាវិន័យ សូមមើលរបាយការណ៍ផ្សេងៗរបស់អង្គការលីកាដូ ដែលរួមមានរបាយការណ៍ "ស្ថានភាពពន្ធនាគារនៅកម្ពុជា ឆ្នាំ២០០២ និង២០០៣" ខែតុលា ២០០៤។ គេហទំព័រ ៖ http://www.licadho-cambodia.org/reports/files/63Prison%20Conditions%20Report%202002%20and%202003%20-%2011%20Oct%202004.pdf ។

"របាយការណ៍ដាក់ជូនអង្គការសហប្រជាជាតិដើម្បីការពិនិត្យតាមការកំណត់ជាសកល — កម្ពុជា" -ថ្ងៃទី១០ ខែមេសា ឆ្នាំ២០០៩ ទំព័រ៣។ គេហទំព័រ www.licadho-cambodia.org/reports/files/133LICADHOUPRSubmissionCambodia.pdf និងរបាយការណ៍របស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា "ដំណើរឆ្ពោះទៅកាន់គោលនយោបាយពន្ធនាគារប្រកបដោយមនុស្សធម៌សម្រាប់កម្ពុជា" ខែវិច្ឆិកា ឆ្នាំ២០០២។ គេហទំព័រ http://cambodia.ohchr.org/download.aspx?ep_id=229.

## ការបរិច្ចាគឈាមដោយបង្ខិតបង្ខំ

អតីតអ្នកជាប់ឃុំឃាំងមួយចំនួន បានរាយការណ៍អំពីការបរិច្ចាគឈាមខណៈពេលឃុំខ្លួន។ ការអនុវត្តន៍បែបនេះត្រូវបានគេលាក់កំបាំង ដោយបានណែនាំឱ្យអ្នកជាប់ឃុំឃាំង មិនឱ្យនិយាយអំពីការបរិច្ចាគឈាម ប្រាប់អ្នកជាប់ឃុំឃាំងដទៃទៀត។ តាមសម្តីរបស់សារិកា អាយុ១៥ :-

> ខ្ញុំធ្លាប់ឃើញបុគ្គលិកជ្រើសរើសក្មេងដែលធាត់ៗនិងសុខភាពល្អ ចេញទៅក្រៅមណ្ឌលប្រហែល១០នាក់។ ប៉ុន្តែខ្ញុំមិនដឹងពីមូលហេតុទេ។ ប្រសិនពួកខ្ញុំហ៊ានសួរ គេនឹងវាយ គេថា "ហ្អែងចង់ដឹងស្អី?"។ គេយកក្មេងទាំងនោះចេញក្រៅមណ្ឌលអស់កន្លះថ្ងៃ។ ខ្ញុំមិនដែលសួរគេទៅណាទេ។ ពួកគេនិយាយថាជាការសម្ងាត់។ ទាំងបុគ្គលិកនិងក្មេងទាំងនោះនិយាយដូចគ្នា... បុគ្គលិកបានមកបន្ទប់ហើយចង្អុលក្មេងទាំងនោះ [ដើម្បីហៅពួកគេ] ពីព្រោះពួកគេអាចធ្វើអ្វីក៏បានដែរនៅកន្លែងនោះ។ អ្នកជាប់ផ្សេងទៀតមិនដែលនិយាយប្រាប់ខ្ញុំថាមានរឿងអីទេ។ គេបានប្រាប់ពួកវាមិនឱ្យនិយាយប្រាប់អ្នកជាប់ផ្សេងទៀតពេលត្រឡប់មកវិញ។ នៅពេលត្រឡប់មកវិញ ពួកគេមានបង់រុំចងជាប់នឹងដៃ។ ពួកគេដើរត្បៀតដូចនេះអញ្ចឹង [ដៃម្ខាងបត់ជាប់នឹងដើមទ្រូង] ម្នាក់ៗមុខឡើងស្លេកៗ។[129]

ការបរិច្ចាគឈាមដោយបង្ខិតបង្ខំ ត្រូវបានរាយការណ៍ដោយអតីតអ្នកជាប់ឃុំឃាំងនៅមណ្ឌល "យុវនីតិសម្បទា" សង្គមកិច្ចចោមចៅ និងមណ្ឌលរាជអារុំធហត្ថនៅខេត្តបន្ទាយមានជ័យ។ ដោយផ្អែកលើបទសម្ភាសន៍ជាមួយអតីតអ្នកជាប់ឃុំឃាំង ការអនុវត្តន៍ការបរិច្ចាគឈាមនៅក្នុងមណ្ឌល ហាក់ដូចបីដូចជាទាក់ទងនឹងឡានមួយដែលប្រដាប់ដោយបុគ្គលិកពេទ្យ ដែលមកកាន់

---

[129] អង្គការឃ្លាំមើលសិទ្ធិមនុស្ស សម្ភាសសារិកា— កម្ពុជា ខែមិថុនា ឆ្នាំ២០០៩

មណ្ឌលពីមន្ទីរពេទ្យ ឬគ្លីនិកព្យាបាលដែលនៅជិតៗនោះ ឬ បុគ្គលិកមណ្ឌលយកអ្នកជាប់ឃុំឃាំងទៅកាន់មន្ទីរពេទ្យ។ អ្នកជាប់ឃុំឃាំងមួយចំនួន បានរាយការណ៍ថាការអនុវត្តន៍នេះគឺជាការស្ម័គ្រចិត្ត ហើយនិយាយថា ពួកគេទទួលបានប្រាក់សម្រាប់ការបរិច្ចាគឈាមរបស់ខ្លួន។ ទោះជាយ៉ាងណាក៏ដោយ អ្នកជាប់ឃុំឃាំងមួយចំនួន បានរាយការណ៍ប្រាប់អង្គការឃ្លាំមើលសិទ្ធិមនុស្សថា ពួកគេត្រូវបានគេបង្ខំឱ្យបរិច្ចាគឈាម។ ការបង្ខិតបង្ខំមានទម្រង់ជាការគំរាមកំហែង ឱ្យបរិច្ចាគឈាមដោយសារខ្លាចអំពើសងសឹកពីបុគ្គលិក និង ព្រមទាំងបរិច្ចាគឈាមដើម្បីទទួលបានការដោះលែងពីមណ្ឌល។

ម៉ូឌ មានអាយុ១៦ឆ្នាំ បានរាយការណ៍ថាគាត់ត្រូវបានគេបង្ខំឱ្យបរិច្ចាគឈាមរបស់គាត់ :-

> [បុគ្គលិក] បាននិយាយថា "ជួយសង្គ្រោះអ្នកដែលមានគ្រោះថ្នាក់ចរាចរ"។ [បុគ្គលិក] បណ្តើរខ្ញុំទៅកន្លែងបូមឈាម។ ពួកគេបាននិយាយថា "ប្អូនតូច ខ្ញុំចង់និយាយប្រាប់ឯងថា មន្ទីរពេទ្យត្រូវការមណ្ឌលស្តារនីតិសម្បទារបស់យើងឱ្យបរិច្ចាគឈាម ពីព្រោះមន្ទីរពេទ្យត្រូវការឈាមប្រភេទអានិងបេ។ ឈាមរបស់ឯងដូចគ្នា ហើយពួកគេខ្វះឈាមប្រភេទនេះ"។ ខ្ញុំថា "អត់ទេ ខ្ញុំខ្លាចបូមឈាម"។ គាត់បាននិយាយថា "អត់អីទេ" ហើយបណ្តើរខ្ញុំទៅឡាន។ ខ្ញុំមានអារម្មណ៍ខ្លាច។ ពួកគេបានបង្ខំខ្ញុំ។
>
> គាត់បានពន្យល់ដូច្នេះថា :-

ពួកខ្ញុំបីនាក់បានឱ្យគេបូមឈាមនៅក្នុងឡានធំមួយ ដែលមានម៉ាស៊ីនច្រើន។ គេឱ្យពួកខ្ញុំដេកហើយលាតដៃចេញ ហើយគេប្រើបង់សម្រាប់រុំដៃ ហើយចាប់ផ្តើមបូម ។[130]

ដួងចែមពន្យល់ថាគាត់បានបរិច្ចាគឈាមដោយសារបុគ្គលិកបានគំរាមកំហែងគាត់ :-

[បុគ្គលិក] បាននិយាយមកខ្ញុំពីរបីថ្ងៃមុន [គ្រូពេទ្យមកដល់មណ្ឌល]...គាត់បាននិយាយថា "ប្រសិនបើហ្អែងបរិច្ចាគឈាម និងមិនចង់ឱ្យអ្នកជាប់វាយ ខ្ញុំអាចជួយបាន"។ គាត់និយាយបែបនេះគឺមានន័យ។ ខ្ញុំបានគិតថាគាត់គំរាមកំហែង។ ខ្ញុំខ្លាចគេវាយ និងខ្លាចបុគ្គលិកផ្សេងទៀត។ គាត់បាននិយាយថា "ម៉េចហើយអាល្អិត បើមិនចង់ឱ្យគេវាយធ្វើបាបទៅបរិច្ចាគឈាមទៅ ចាំខ្ញុំប្រាប់គេកុំឱ្យធ្វើបាប"។

នៅពេលគ្រូពេទ្យបានមកដល់មណ្ឌល ដើម្បីយកការបរិច្ចាគឈាមរយៈពេលពីរបីថ្ងៃក្រោយមក ដួងចែមរៀបរាប់អំពីវត្តមានបុគ្គលិកទាំងនោះ ដោយបានដាក់សម្ពាធមកលើអ្នកជាប់ឃុំឃាំងឱ្យបរិច្ចាគឈាមៈ-

ក្មេងទាំងនោះ [ដែលបរិច្ចាគឈាម] មានអារម្មណ៍ខ្លាច[បុគ្គលិក]ដែលនៅទីនោះ :- គាត់វាយខ្សែភ្លើងសាហាវណាស់។ គាត់មិនហៅឱ្យបរិច្ចាគឈាមទេ ប៉ុន្តែគាត់ឈរនៅពីក្រោយខ្នងក្មេងៗ។ ក្មេងៗតក់ស្លុតភ័យខ្លាំង។ មានបុគ្គលិកពីរនាក់នៅទីនោះ...នៅពេលក្មេងៗឃើញ [បុគ្គលិកទាំងនោះ]មកដល់ គឺដូចឃើញខ្លាអញ្ចឹង។ ពួកគេឡើងញ័រខ្លួនអស់ហើយ។ មានតែខ្ញុំទេដែលបានស្ម័គ្រចិត្តមែន។ ក្រៅពីនោះពួកវាភ័យខ្លាច ហើយសុខចិត្តបរិច្ចាគឈាម ។[131]

---

130 អង្គការឃ្លាំមើលសិទ្ធិមនុស្ស សម្ភាសម្លិះ — កម្ពុជា ខែមិថុនា ឆ្នាំ២០០៩

131 អង្គការឃ្លាំមើលសិទ្ធិមនុស្ស សម្ភាសដួងចែម — កម្ពុជា ខែមិថុនា ឆ្នាំ២០០៩

ទៀប អាយុ១៨ឆ្នាំ ពន្យល់ថាគាត់បានបរិច្ចាគឈាមដើម្បីទទួលបានប្រាក់ និងការដោះលែងចេញពីមណ្ឌល។ ឡានមួយបានមកដល់មណ្ឌល ដើម្បីបូមឈាមពីអ្នកជាប់ឃុំឃាំងៈ-

មានមនុស្សប្រាំនាក់ដែលបានបរិច្ចាគឈាម។ សម្រាប់ខ្ញុំ ខ្ញុំក្មេងជាងគេ ក្រៅពីនោះសុទ្ធតែមនុស្សធំៗ។ កាលនោះខ្ញុំអាយុ១៣ឆ្នាំ... ពួកគេថាមិនមែនបង្ខំទេ គឺដោយស្ម័គ្រចិត្ត។ ពួកគេនិយាយថាម្នាក់ៗនឹងទទួលបាន២០ដុល្លារ ហើយត្រូវដោះលែងវិញ។ ដោយសារខ្ញុំចង់ចេញពីមណ្ឌល ខ្ញុំបានបរិច្ចាគឈាម។ ពួកគេថាបើបរិច្ចាគឈាមនឹងបានលុយ ហើយដើរចេញពីមណ្ឌលទៀត។ ខ្ញុំទទួលបាន២០ដុល្លារ។ ខ្ញុំជិះម៉ូតូឌុបមក[ទីប្រជុំជនដែលនៅជិតនោះ] ។[132]

បេងបានរាយការណ៍ផងដែរថា គាត់បានបរិច្ចាគឈាមនៅមន្ទីរពេទ្យពីរផ្សេងគ្នា ដើម្បីទទួលបានប្រាក់និងដើម្បីទទួលបានការដោះលែងពីមណ្ឌលវិញ។ គាត់បានរាយការណ៍ថាបានបរិច្ចាគឈាមសរុបប្រហែលចំនួនដប់ដង ហើយបានដោះលែងពីមណ្ឌលបីដង ៈ-

[ប្រធានមណ្ឌល] បាននិយាយថា "បូមឈាមទៅ ខ្ញុំឱ្យលុយ"។ ខ្ញុំទទួលបាន១០ដុល្លារពីប្រធាន[មន្ទីរពេទ្យទីមួយ] ។ [ប្រធានមណ្ឌល]និយាយថា "ខ្ញុំនឹងឱ្យលុយហើយដោះលែង"... [នៅមន្ទីរពេទ្យទី២] ខ្ញុំបានទទួលលុយចំនួនដូចគ្នា... ខ្ញុំទទួលបាន១០ដុល្លារ ប្រធានមណ្ឌលទទួលបាន៥០ដុល្លារ។ ខ្ញុំឈរនៅខាងក្រៅហើយឃើញគ្រូពេទ្យហុចលុយឱ្យគាត់។ គឺជាគ្រូពេទ្យស្រីដែលឱ្យលុយនោះ។ ខ្ញុំឃើញចំនួន៥០ដុល្លារ... នៅក្នុង[មន្ទីរពេទ្យទី១] ៈ ខ្ញុំបានឈរពីក្រោយ [ប្រធាន

132 អង្គការឃ្លាំមើលសិទ្ធិមនុស្ស សម្ភាសទៀប — កម្ពុជា ខែមិថុនា ឆ្នាំ២០០៩

មណ្ឌល ខ្ញុំឃើញគាត់។ គ្រូពេទ្យបានឱ្យលុយគាត់[ប្រធានមណ្ឌល]ចំនួន៥០ ដុល្លារ ។[133]

## បទដ្ឋានអនុវត្តន៍

## ការឃុំខ្លួនតាមអំពើចិត្ត

អង្គការឃ្លាំមើលសិទ្ធិមនុស្សចាត់ទុកថាមជ្ឈមណ្ឌលឃុំឃាំងគ្រឿងញៀននៅប្រទេសកម្ពុជាធ្វើការឃុំឃាំងមនុស្សជាប្រចាំដោយរំលោភច្បាប់ប្រទេសកម្ពុជានិងច្បាប់អន្តរជាតិ។ មាត្រា៩(១) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយប្រកាសថា "គ្មានជនណាម្នាក់ត្រូវចាប់ខ្លួន ឬ ឃុំខ្លួនតាមអំពើចិត្តបានឡើយ [ឬ] គ្មានជនណាម្នាក់ត្រូវដកហូតសេរីភាពបានឡើយ លើកលែងតែមានហេតុផល និងស្របតាមនីតិវិធីដែលមានចែងនៅក្នុងច្បាប់"។[134] ការឃុំខ្លួនត្រូវបានចាត់ទុកថា"តាមអំពើចិត្ត" ប្រសិនបើមិនអនុលោមទៅតាមច្បាប់ទេនោះ។ វាក៏ជាការធ្វើតាមអំពើចិត្តផងដែរ នៅពេលធ្វើដោយព្រាវៗ ចិត្តឆុងឆាំង ឬមិនស្របតាមនីតិវិធីត្រឹមត្រូវតាមផ្លូវច្បាប់ ។[135] ច្បាប់អន្តរជាតិផ្តល់សិទ្ធិឱ្យអ្នកជាប់ឃុំឃាំងជំទាស់តវ៉ានឹងភាពមិនស្របច្បាប់ចំពោះការឃុំខ្លួនរបស់គាត់ ដោយដាក់ពាក្យបណ្តឹងទៅអាជ្ញាធរតុលាការដែលសមស្រប

---

133 អង្គការឃ្លាំមើលសិទ្ធិមនុស្ស សម្ភាសបេង— ភ្នំពេញ ខែមិថុនា ឆ្នាំ២០០៩

134 កម្ពុជាបានផ្តល់សច្ចាប័ន លើកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ នៅថ្ងៃទី២៦ ខែឧសភា ឆ្នាំ១៩៩២

135 ការឃុំខ្លួនតាមអំពើចិត្ត រួមមានការឃុំខ្លួនដែលគ្មានមូលដ្ឋានក្នុងច្បាប់ ឬមិនបានអនុវត្តន៍ស្របតាមច្បាប់ ប៉ុន្តែក៏រាប់បញ្ចូលនូវ ការឃុំខ្លួន ដែលមាន "ធាតុផ្សំនៃភាពមិនសមស្រប អយុត្តិធម៌ ខ្វះភាពជឿទុកចិត្ត និងនីតិវិធីត្រឹមត្រូវ។ សូមមើល សេចក្តីឆ្លើយឆ្លងលេខ No. 458/1991, A. W. Mukong v. Cameroon (យោបល់ដែលបានអនុម័តនៅថ្ងៃទី ២១ ខែកក្កដា ឆ្នាំ១៩៩៤), ក្នុងឯកសារអង្គការសហប្រជាជាតិលេខ GAOR, A/49/40 (vol. II), ទំព័រ១៨១ កថាខ័ណ្ឌ ៩.៨. ។

ដើម្បីពិនិត្យមើលថាតើមូលដ្ឋាននៃការឃុំខ្លួននោះត្រឹមត្រូវតាមច្បាប់ មានហេតុផល និងចាំបាច់ដែរ ឬទេ ។[136]

គណៈកម្មាធិការសិទ្ធិមនុស្សរបស់ អ.ស.ប បានបញ្ជាក់ថាមាត្រា៩(១) "គឺអនុវត្តចំពោះ រាល់ការដកហូតសេរីភាព ទោះបីក្នុងករណីព្រហ្មទណ្ឌ ឬករណីផ្សេងៗទៀត ឧទាហរណ៍ដូចជាជំងឺផ្លូវចិត្ត ភាពអនាថា *ការញៀនគ្រឿងញៀន* គោលបំណងអប់រំ ការគ្រប់គ្រងអន្តោប្រវេសន៍ ។ល។[137] [សេចក្តីបញ្ជាក់បន្ថែម] ។

មាត្រា ១៤ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ចែងអំពីសិទ្ធិជំនុំជំរះក្តីដោយសមធម៌ រួមមានការសន្មត់ជាមុនថាជាជនគ្មានទោស មានសិទ្ធិទទួលបានសវនាការជាសាធារណៈ និងសុំឱ្យពិនិត្យមើលឡើងវិញលើករណីកាត់ឱ្យជាប់ពិរុទ្ធបទល្មើសព្រហ្មទណ្ឌ "ដោយសាលាក្តីជាន់ខ្ពស់"។[138] ក្រុមការងាររបស់ អ.ស.ប ស្តីពីការឃុំខ្លួនតាមអំពើចិត្តបានធ្វើការកត់សម្គាល់ពីលើកមុនមកថា ក្រុមការងារបាន

> ទទួលព័ត៌មានពីប្រភពមួយចំនួនថានៅក្នុងប្រទេសខ្លះជនពិការ អ្នកញៀនគ្រឿងញៀន និងអ្នកដែលរស់នៅជាមួយជំងឺអេដស៍ ត្រូវបានឃុំខ្លួននៅក្នុងទីកន្លែងដែលមិនស្របគ្នាទៅនឹងស្ថានភាពសុខភាពរបស់ខ្លួន ពេលខ្លះគ្មានការព្យាបាល និងមិនបានបង្កើតឱ្យមានការព្យាបាលដោយថា ការឃុំខ្លួនរបស់ពួកគេ

136 កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ មាត្រាទី៩(៤)

137 គណៈកម្មាធិកាសិទ្ធិមនុស្ស "អត្ថាធិប្បាយទូទៅទី ៨ : សិទ្ធិសេរីភាព និងសន្តិសុខផ្ទាល់ខ្លួន (មាត្រា ៩) ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ១៩៨២ កថាខ័ណ្ឌ ១ ។

138 កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ មាត្រា ១៤(១)(២)(៥)។ ស្ថាប័នអ.ស.ប ស្តីពីគោលការណ៍សម្រាប់ការពារបុគ្គលទាំងអស់ ដែលស្ថិតក្រោមទម្រង់នៃការឃុំខ្លួន ទាមទារឱ្យរាល់បុគ្គលទាំងអស់ "មិនត្រូវឃុំខ្លួន ដោយគ្មានការផ្តល់ឱកាសទទួលសវនាការភ្លាមៗដោយតុលាការ ឬអាជ្ញាធរដទៃទៀត។ បុគ្គលម្នាក់ដែលត្រូវឃុំខ្លួន ត្រូវតែមានសិទ្ធិការពារខ្លួន ឬទទួលជំនួយដោយប្រឹក្សាយោបល់ ដែលបានចែងដោយច្បាប់"។ "ស្ថាប័នគោលការណ៍ ដើម្បីការពារបុគ្គលទាំងអស់ស្ថិតក្រោមទម្រង់នៃការឃុំខ្លួន ឬជាប់ពន្ធនាគារ" គោលការណ៍ ១១(១) - សេចក្តីសម្រេចចិត្តលេខ៤៣/១៧៣ (១៩៨៨) របស់មហាសន្និបាតអ.ស.ប

គឺត្រឹមត្រូវតាមមូលដ្ឋានវិជ្ជសាស្ត្រ ឬសុខភាពសាធារណៈ។ ក្រុមការងារ អ.ស.ប ព្រួយបារម្ភដោយ សារមានការពាក់ព័ន្ធនឹងជនដែលងាយរងគ្រោះ ប្រជាពលរដ្ឋដែលត្រូវរងការមាក់ងាយពីគំនិតខុសឆ្គងរបស់សង្គមជាញឹកញាប់ ប៉ុន្តែការព្រួយបារម្ភលើសពីនោះទៀតនោះគឺ ការឃុំខ្លួនតាមរដ្ឋបាលបែបនោះមិនត្រូវបានពិនិត្យមើលដោយតុលាការឡើយ... ចំពោះជនដែលត្រូវគេដកហូតសេរីភាពរបស់ខ្លួនផ្អែកលើមូលដ្ឋានសុខភាព ក្រុមការងារអ.ស.ប ចាត់ទុកថានៅក្នុងករណីណាក៏ដោយ ជនគ្រប់រូបដែលទទួលរងប៉ះពាល់ដោយវិធានការបែបនេះត្រូវតែមានមធ្យោបាយប្តឹងតបនឹងការឃុំខ្លួនរបស់ពួកគេតាមផ្លូវតុលាការ។[139]

ច្បាប់សិទ្ធិមនុស្សអន្តរជាតិ តម្រូវឱ្យរដ្ឋផ្តល់សិទ្ធិទទួលបានសំណង សម្រាប់ការរំលោភសិទ្ធិសេរីភាពបុគ្គល និងសន្តិសុខបុគ្គល។[140]

រដ្ឋធម្មនុញ្ញប្រទេសកម្ពុជាចែងថា "ការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬការឃុំខ្លួនជនណាម្នាក់នឹងអាចធ្វើទៅកើត លុះត្រាតែអនុវត្តត្រឹមត្រូវតាមបញ្ញត្តិច្បាប់។[141] ការចាប់ខ្លួន ឬឃុំខ្លួន ឬបង្ខាំងខ្លួនមនុស្សដោយខុសច្បាប់ ត្រូវដាក់គុកពី១០ឆ្នាំ បើការបង្ខាំងខ្លួន ឬការឃុំខ្លួននោះមានពេលលើសពីមួយខែ។[142] រដ្ឋមន្ត្រីសង្គមកិច្ច អតីតយុទ្ធជន យុវនីតិសម្បទា បានចេញសេចក្តីណែនាំមួយនៅក្នុងខែសីហាឆ្នាំ២០០៨ ដោយហាមឃាត់ "ការប្រមូល ឬគ្រប់គ្រងជនអនាថា" ដោយ

---

139 ក្រុមការងារអ.ស.ប ស្តីពីការឃុំខ្លួនតាមអំពើចិត្ត "របាយការណ៍របស់ក្រុមការងារ ស្តីពីការឃុំខ្លួនតាមអំពើចិត្ត" ថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០០៣- ឯកសារអ.ស.ប លេខ E/CN.4/2004/3 កថាខ័ណ្ឌ ៧៤ និង ៨៧

140 កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ចែងថា "ជនណាដែលបានរងគ្រោះដោយសារការឃាត់ខ្លួន ឬឃុំខ្លួនខុសច្បាប់មានសិទ្ធិទាមទារសំណង" មាត្រា ៩ (៥)

141 រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា — ថ្ងៃទី ២១ ខែកញ្ញា ១៩៩៣ — មាត្រា ៣៨

142 បទបញ្ញត្តិស្តីពីប្រព័ន្ធតុលាការ ច្បាប់ព្រហ្មទណ្ឌ និងនីតិព្រហ្មទណ្ឌសម្រាប់អនុវត្តនៅក្នុងប្រទេសកម្ពុជាក្នុងសម័យអន្តរកាល ("ច្បាប់ព្រហ្មទណ្ឌអ៊ុនតាក់") ថ្ងៃទី១០ ខែកញ្ញាឆ្នាំ១៩៩២ — មាត្រា ៣៥។ បទបញ្ញត្តិដែលស្រដៀងគ្នានេះដែរ ឃើញមាននៅក្នុងសេចក្តីពង្រាងក្រមព្រហ្មទណ្ឌ (មាត្រា ២៥៣)។ ក្រោមសេចក្តីពង្រាងក្រមព្រហ្មទណ្ឌ រយៈពេលដាក់ទណ្ឌកម្ម រវាង ១៥ ទៅ ៣០ឆ្នាំ បើការឃុំខ្លួនទាក់ទងនឹង "ទារុណកម្មឬអំពើព្រៃផ្សៃ" ឬបើការចាប់ខ្លួន ឬការឃុំខ្លួនត្រូវបានអនុវត្ត "ដោយបំណងជំរិតទារប្រាក់" (មាត្រា ២៥៤)

បង្ខំនៅក្នុងមណ្ឌលសង្គមកិច្ច។ លោករដ្ឋមន្ត្រីដដែល បានចេញសេចក្តីណែនាំនៅខែសីហាឆ្នាំ ២០០៦ ឱ្យបង្កើតមណ្ឌលសង្គមកិច្ចចោមចៅគឺជា "មណ្ឌលដែលបើកចំហ" ដោយចង់មានន័យថា មិនត្រូវឃុំឃាំងមនុស្សនៅទីនោះដោយផ្ទុយពីឆន្ទៈរបស់ពួកគេឡើយ។[143]

អង្គការឃ្លាំមើលសិទ្ធិមនុស្សពិចារណាឃើញថាបទបញ្ញត្តិនៅក្នុងច្បាប់គ្រឿងញៀនរបស់ប្រទេសកម្ពុជា មានលក្ខណៈទូលំទូលាយពេក ហើយបើកឱ្យមានការរំលោភបំពាន។[144] ស្ថិតក្រោម *ច្បាប់ត្រួតពិនិត្យគ្រឿងញៀន* បុគ្គលម្នាក់ត្រូវបានបង្គាប់ឱ្យព្យាបាលតាមរយៈយន្តការផ្សេងៗគ្នាជាច្រើន។ ទោះជាយ៉ាងណាក៏ដោយ យន្តការទាំងអស់នោះ តម្រូវឱ្យ ៈ-

- ព្រះរាជអាជ្ញាបង្គាប់ឱ្យព្យាបាល (បន្ទាប់ពីចេញលិខិតកោះហៅរបស់តុលាការ)[145]
- បង្គាប់ឱ្យព្យាបាលដោយតុលាការព្រហ្មទណ្ឌ (មុនការកាត់ទោស នៅពេលសាម៉ីជនណាម្នាក់ត្រូវជាប់ចោទ ឬពេលផ្តន្ទាទោស ពេលកាត់ឱ្យជាប់ទោស)[146] ឬ
- ការបង្គាប់ដោយតុលាការរដ្ឋប្បវេណី (បណ្តឹងពីសហព័ទ្ធ ឪពុកម្តាយ សាច់ញាតិ ឬព្រះរាជអាជ្ញា ប្រសិនបើតុលាការដឹងថាសាម៉ីជនដែលញៀនជាតិពុលនោះជាមនុស្សដែលគេស្គាល់ថាមានគ្រោះថ្នាក់ដល់អ្នកដទៃ)[147]

ដូចបានកត់សំគាល់ការពិភាក្សាអំពីច្បាប់គ្រឿងញៀនប្រទេសកម្ពុជា ការតម្រូវជាអប្បរិមា មិនគ្រប់គ្រាន់សម្រាប់ការពារសិទ្ធិមនុស្សរបស់អ្នកប្រើប្រាស់គ្រឿងញៀនក្នុងប្រទេសកម្ពុជាទេ។

---

143 ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា/ គណៈកម្មាធិការជាតិដោះស្រាយបញ្ហាជនអនាថា "សេចក្តីណែនាំស្តីពីគោលនយោបាយសម្រាប់ដោះស្រាយបញ្ហាជនអនាថា" ភ្នំពេញ ថ្ងៃទី៨ ខែសីហា ២០០៨ កថាខ័ណ្ឌ៦(២) ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា "សេចក្តីណែនាំស្តីពីល័ក្ខខ័ណ្ឌ និងនីតិវិធីសម្រាប់ការបញ្ចូល រដ្ឋបាលនិងស្តារនីតិសម្បទា និងកុមារដែលមានអាយុទទួលខុសត្រូវបទព្រហ្មទណ្ឌនៅមណ្ឌលយុវនីតិសម្បទាចោមចៅ" ភ្នំពេញ ថ្ងៃទី២៥ ខែសីហា ២០០៦ ចំណុច ២ (ច្បាប់ចម្លងទុកជាឯកសារនៅអង្គការឃ្លាំមើលសិទ្ធិមនុស្ស)

144 សូមមើល "ប្រវត្តិ ៈ ច្បាប់គ្រឿងញៀនប្រទេសកម្ពុជា"

145 មាត្រា៩១

146 មាត្រា៩២-៩៣

147 មាត្រា៩៥

ទោះជាយ៉ាងណាក៏ដោយ តាមការជាក់ស្តែង សូម្បីតែវិធានការទាំងនេះក៏មិនត្រូវបានគេអនុវត្តបានផង។ ពុំមានអំណាចរបស់តុលាការបង្គាប់ឱ្យឃុំខ្លួនឡើយ ហើយពុំមានការពិនិត្យមើលលើការឃុំខ្លួន ឬមានឱកាសសម្រាប់ពិនិត្យមើលដែរ។

## ទារុណកម្មនិងប្រព្រឹត្តកម្មដែលឃោរឃៅនិងអមនុស្សធម៌

យោងតាមកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ "ជនណាដែលត្រូវបានដកហូតសេរីភាព ត្រូវទទួលបានការប្រព្រឹត្តមកលើខ្លួន តាមលក្ខណៈមនុស្សធម៌ និងការគោរពចំពោះសេចក្តីថ្លៃថ្នូរពីកំណើតរបស់មនុស្ស"[148] និង "គ្មានជនណាម្នាក់ត្រូវរងទារុណកម្ម ឬប្រព្រឹត្តកម្ម ឬទណ្ឌកម្ម ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាបឡើយ"។ [149] អនុសញ្ញាប្រឆាំងការធ្វើទារុណកម្ម ដែលប្រទេសកម្ពុជាជាភាគីនៅក្នុងខែតុលាឆ្នាំ១៩៩២ មានការហាមឃាត់ជាដាច់ខាតលើការប្រើប្រាស់ទារុណកម្ម។ បទបញ្ញត្តិជាបទដ្ឋានអប្បបរមារបស់ អ.ស.ប សម្រាប់គ្រប់គ្រងអ្នកទោស ចែងថា "ទណ្ឌកម្មលើរាងកាយ... និងទណ្ឌកម្មណាដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប ត្រូវហាមឃាត់ជាដាច់ខាតមិនឱ្យប្រើជាទណ្ឌកម្មសម្រាប់ការប្រព្រឹត្តល្មើសនឹងបទវិន័យឡើយ"។[150] អង្គការសុខភាពពិភពលោក និង ការិយាល័យគ្រឿងញៀននិងឧក្រិដ្ឋកម្មនៃអង្គការសហប្រជាជាតិ ធ្វើការកត់សំគាល់ថា "ការអនុវត្តន៍ដោយអមនុស្សធម៌ និងបន្ថោកបន្ទាប ពុំមែនជាផ្នែកនៃការព្យាបាលការញៀនគ្រឿងញៀនឡើយ"។[151] រដ្ឋធម្មនុញ្ញនៃប្រទេសកម្ពុជា ចែងថា "ការបង្ខិតបង្ខំ ការធ្វើបាបលើរូបរាងកាយ

---

[148] កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ មាត្រា ១០

[149] កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ មាត្រា ៧

[150] បញ្ញត្តិជាបទដ្ឋានអប្បរិមារបស់ អ.ស.ប សម្រាប់គ្រប់គ្រងអ្នកទោស កថាខ័ណ្ឌ ៣១

[151] ការិយាល័យគ្រឿងញៀននិងឧក្រិដ្ឋកម្មនៃអង្គការសហប្រជាជាតិ/អង្គការសុខភាពពិភពលោក- "គោលការណ៍សម្រាប់ការព្យាបាលនៃការញៀនគ្រឿងញៀន" : ឯកសារពិគ្រោះ ឆ្នាំ២០០៨ ទំព័រ៩

ឬប្រព្រឹត្តិកម្មណាមួយ ដែលបន្ថែមទម្ងន់ទណ្ឌកម្មអនុវត្តចំពោះជនជាប់ឃុំឃាំង ឬជាប់ពន្ធនាគារ ត្រូវហាមឃាត់មិនឱ្យធ្វើឡើយ។ ជនដៃដល់ អ្នកចូលរួមប្រព្រឹត្ត និងអ្នកសមគំនិត ត្រូវទទួលទោសតាមច្បាប់"។[152] ផ្នែកខ្លះនៃ ច្បាប់ព្រហ្មទណ្ឌចែងថា "គ្មានជនជាប់ឃុំឃាំងណាម្នាក់ ត្រូវរងការប្រព្រឹត្ត ឬទណ្ឌកម្ម ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាបឡើយ រងការវាយដំ ឬធ្វើទារុណកម្មឡើយ"។[153]

រាល់ទម្រង់នៃការប្រព្រឹត្តធ្វើបាបទាំងអស់ ដែលបានពិពណ៌នានៅក្នុងរបាយការណ៍នេះ ត្រូវបានហាមឃាត់ជាដាច់ខាតនៅក្នុងច្បាប់អន្តរជាតិ។ ឧទាហរណ៍ លំហាត់ប្រាណដ៏ឈឺចាប់ ឬការដាក់ខ្នោះឱ្យឈរកណ្ដាលថ្ងៃ គឺរំលោភលើការហាមឃាត់ការធ្វើទារុណកម្ម និងការប្រព្រឹត្ត ឬទណ្ឌកម្មដែលឃោរឃៅ និងអមនុស្សធម៌។ ការធ្វើទុក្ខបុកម្នេញខ្លះ ត្រូវចាត់ទុកជាទារុណកម្មដោយមិនបាច់សង្ស័យ។ ឧទាហរណ៍ ការរៀបចំឆក់ចរន្តអគ្គិសនី និងការវាយដំ (រួមការវាត់ និងវាយសំពងដោយប្រើស្វ័យកាំភ្លើង ឬដំបង) ត្រូវបានចាត់ទុកថាជាទម្រង់ទារុណកម្មដោយអ្នករាយការណ៍ពិសេសស្ដីពីទារុណកម្ម។[154] ការកើតមានឡើងនូវបទរំលោភសេពសន្ថវៈមួយចំនួនដោយបុគ្គលិក ដែលបានកត់ត្រានៅក្នុងរបាយការណ៍នេះ គឺពាក់ព័ន្ធជាមួយបុគ្គលិកដែលប្រើកម្លាំង ការគំរាមប្រើកម្លាំង ឬមធ្យោបាយបង្ខិតបង្ខំផ្សេងៗទៀត ដែលបង្ខំអ្នកជាប់ឃុំឃាំងឱ្យចូលរួមក្នុងសកម្មភាពសេពសន្ថវៈ។ ការរំលោភដោយប្រើអំណាចផ្ដាច់ការ ត្រូវបានកំណត់ថាជា "ការរំលោភលើរាងកាយ ដោយមានចរិតផ្លូវភេទ ដែលប្រព្រឹត្តលើបុគ្គលណាម្នាក់

---

[152] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា — ថ្ងៃទី២១ ខែកញ្ញា ១៩៩៣ — មាត្រា ៣៨

[153] ក្រមព្រហ្មទណ្ឌអ៊ុនតាក់ មាត្រា ១២។ ពង្រាងក្រមព្រហ្មទណ្ឌ ចែងថា "ទារុណកម្មនិងអំពើឃោរឃៅ" ត្រូវទទួលទោសជាប់ពន្ធនាគារពី ៧ ទៅ ១៥ ឆ្នាំ។ ប្រសិនបើបានប្រព្រឹត្តមកលើ "ពិសេសបុគ្គលងាយរងគ្រោះ ដោយសារអាយុរបស់ខ្លួន" ឬ "ជាពិសេសបុគ្គលងាយរងគ្រោះ ដោយសារមានជំងឺ ឬពិការភាព ខណៈដែលស្ថានភាពរបស់ខ្លួន ត្រូវបានគេដឹងថាជាជនល្មើស" ដូច្នេះ ការមានទោសជាប់ពន្ធនាគារ ពី ១០ ទៅ ២០ ឆ្នាំ : មាត្រា ២១០ និង ២១១។

[154] របាយការណ៍របស់អ្នករាយការណ៍ពិសេស ស្ដីពីទារុណកម្ម (១៩៨៦) **E/CN.4/1986/15** កថាខ័ណ្ឌ១១៩

នៅក្រោមកាលៈទេសៈបង្ខិតបង្ខំ" ។[155] ការរំលោភសេពសន្ថវៈ និងទម្រង់នៃការរំលោភផ្លូវភេទផ្សេងទៀតនៅ ក្នុងការឃុំខ្លួន គឺជាការធ្វើទារុណកម្ម ។[156]

ប្រទេសកម្ពុជាមានកាតព្វកិច្ចស៊ើបអង្កេតរាល់ការចោទប្រកាន់ដែលអាចទុកចិត្តបាន លើការធ្វើទារុណកម្ម និងការប្រព្រឹត្ត ឬទណ្ឌកម្មដែលឃោរឃៅ និងអមនុស្សធម៌ ។ អនុសញ្ញាប្រឆាំងទារុណកម្ម តម្រូវឱ្យរដ្ឋធ្វើការស៊ើបអង្កេត នៅពេលដែលមានមូលដ្ឋានសមស្របគួរឱ្យជឿបានថាពិតជាមានអំពើនៃការធ្វើទុក្ខបុកម្នេញ ទោះបីជនរងគ្រោះមិនបានផ្តើមគំនិតប្តឹងក៏ដោយ ។[157]

155 ការវិនិច្ឆ័យតុលាការឧក្រិដ្ឋកម្មអន្តរជាតិ រ៉ូវ៉ាន់ដា (ICTR) ព្រះរាជអាជ្ញា ហ្សង់ ប៉ូល អាកាយេស៊ូ (v. Jean-Paul Akayesu,) ករណីសំណុំរឿងលេខ ICTR-96-4-T (ថ្ងៃទី២ ខែកញ្ញា ឆ្នាំ១៩៩៨) កថាខ័ណ្ឌ៣៨ (ចាប់ពីនេះតទៅជាការវិនិច្ឆ័យរបស់អាកាយេស៊ូ) ។ សាលាជំនុំជំរះរបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិរ៉ូវ៉ាន់ដា (ICTR) ក្នុងការវិនិច្ឆ័យរបស់អាកាយេស៊ូ បានឱ្យនិយមន័យរំលោភសេពសន្ថវៈថាជា "ការរំលោភលើរាងកាយដោយមានចរិតផ្លូវភេទ ដោយបានប្រព្រឹត្តមកលើបុគ្គលណាម្នាក់ស្ថិតក្រោមកាលៈទេសៈបង្ខិតបង្ខំ" ។ នៅក្នុងការវិនិច្ឆ័យរបស់អាកាយេស៊ូ ដែលពាក់ព័ន្ធនឹងមន្ត្រីប្រទេសរ៉ូវ៉ាន់ដាម្នាក់ដែលបានលើកទឹកចិត្តដល់ការរំលោភសេពសន្ថវៈលើស្ត្រីជនជាតិតូស៊ី (Tutsi) អំឡុងពេលប្រល័យពូជសាសន៍ តុលាការបានបន្ថែមកស្រាយពន្យល់ថា "កាលៈទេសៈដែលបង្ខិតបង្ខំ មិនចាំបាច់បង្ហាញភស្តុតាង ដោយការបង្ហាញនូវកម្លាំងរាងកាយនោះទេ ។ ការគំរាមកំហែង ការបំភិតបំភ័យ ការជំរិត និងទម្រង់បង្ខិតបង្ខំដទៃទៀត ដែលធ្វើឱ្យភ័យខ្លាច ឬភាពអស់សង្ឃឹម អាចចាត់ទុកជាការបង្ខំ" ។ បញ្ហាមួយក្នុងសេចក្តីសម្រេចចិត្តរបស់ព្រះរាជអាជ្ញា v. Dragoljub Kunarac, Radomir Kovac and Zoran Vukovic, ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០១ (សាលាជំនុំជំរះ) ថាតើការរួមភេទតាមមាត់អាចត្រូវបានចាត់ទុកថាជាការរំលោភដោយប្រឆាំងនឹងទម្រង់នៃការរំលោភផ្លូវភេទដែលស្រាលជាងឬទេ ។ ពួកគេរកឃើញថាការបញ្ចូលតាមមាត់ដោយបង្ខំ គឺជាបទល្មើសផ្លូវភេទដ៏ធ្ងន់ធ្ងរ ដូច្នេះហើយត្រូវចំណាត់ថ្នាក់ជាបទរំលោភសេពសន្ថវៈ ។ សូមមើលសេចក្តីសម្រេចចិត្តរបស់ព្រះរាជអាជ្ញា v. Dragoljub Kunarac, Radomir Kovac and Zoran Vukovic, ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០១ (សាលាជំនុំជំរះ) កថាខ័ណ្ឌ ១៨៣ ។

156 អ្នករាយការណ៍ពិសេសអ.ស.បស្តីពីទារុណកម្ម បានបញ្ជាក់ថា "បទរំលោភសេពសន្ថវៈ និងទម្រង់បៀតបៀនផ្លូវភេទដទៃទៀតនៅក្នុងការឃុំខ្លួន គឺជាការរំលោភគួរឱ្យស្អប់ទៅលើសេចក្តីថ្លៃថ្នូរដែលមានពីកំណើត និង សិទ្ធិបូរណភាពរាងកាយរបស់មនុស្សជាតិគ្រប់រូប ដូច្នេះចាត់ទុកជាអំពើទារុណកម្ម" ។ អ្នករាយការណ៍ពិសេសអ.ស.បស្តីពីទារុណកម្ម កំណត់ត្រាសង្ខេបស្តីពីការប្រជុំលើកទី២១ អ.ស.ប ESCOR, Comm'n Hum. Rts, 48th Sess., ¶ 35, U.N. Doc. E/CN.4/1992/SR.21 (1992) ។ តុលាការអន្តរជាតិ និងអង្គការផ្សេងទៀត បានទទួលយកថាបទរំលោភសេពសន្ថវៈ ត្រូវបានការពារដោយការហាមឃាត់ដោយ អន្តរជាតិ ចំពោះទារុណកម្ម ប្រព្រឹត្តកម្ម ឬទណ្ឌកម្មឯទៀតដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប ។ សូមមើល ឧទាហរណ៍ Aydin v. Turkey, Eur. Ct. of H.R., វិនិច្ឆ័យ ថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ១៩៩៧ កថាខ័ណ្ឌ៦២-៨៨ ព្រះរាជអាជ្ញា V. Furundija, ICTY, សំណុំរឿងលេខ IT-95-17/1-T, វិនិច្ឆ័យ ថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៩៨ កថាខ័ណ្ឌ ១៦៣-៨៦ ។

157 មាត្រា១២ អនុសញ្ញាសហប្រជាជាតិប្រឆាំងការធ្វើទារុណកម្ម និង ការប្រព្រឹត្តមកលើខ្លួន ឬ ទណ្ឌកម្មឯទៀតដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប (CAT), ១៤៦៥ U.N.T.S. ៨៥ ចូលជាធរមានថ្ងៃទី២៦ ខែមិថុនា ឆ្នាំ១៩៨៧ ផ្តល់សច្ចាប័នដោយកម្ពុជានៅថ្ងៃ១៥ តុលា ឆ្នាំ១៩៩២ ។ មាត្រា១៦(១) ចែងថាចំពោះតែទារុណកម្ម រដ្ឋភាគីត្រូវសន្យាហាមឃាត់ក្នុងដែនដីស្ថិតក្រោមសមត្ថកិច្ចរបស់ខ្លួន នូវអំពើផ្សេងៗទៀតនៃការប្រព្រឹត្តទៅលើបុគ្គល ឬទណ្ឌកម្មឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប ដែលមិនចាត់ជាទារុណកម្មដូចមាត្រា១នៃអនុសញ្ញានេះ បើអំពើទាំងនេះត្រូវបានប្រព្រឹត្តតាមការញុះញង់ ឬការព្រមព្រៀង ឬការផ្តើមគំនិតរបស់មន្ត្រីសាធារណៈ ឬជនផ្សេងទៀតដែលបំពេញមុខងារជាផ្លូវការ ។ មាត្រា១៦បានចែងថាកាតព្វកិច្ចដែលមានចែងក្នុងមាត្រា១០ មាត្រា១១ មាត្រា១២ និងមាត្រា១៣ ត្រូវអនុវត្តដោយយកសេចក្តីយោងពាក់ព័ន្ធនិងទម្រង់ផ្សេងទៀតនៃការប្រព្រឹត្តទៅលើបុគ្គល ឬទណ្ឌកម្មឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប ទៅជំនួសសេចក្តីយោងពាក់ព័ន្ធនឹងទារុណកម្ម ។ មាត្រា១០ ទាក់ទងទៅនឹងការបណ្តុះបណ្តាលបុគ្គលិកពាក់ព័ន្ធ ដែលអាចដាក់ឱ្យអន្តរាគមន៍ក្នុងការឃុំខ្លួន ការសួចម្លើយ ឬការប្រព្រឹត្តទៅលើបុគ្គលណាដែលស្ថិតក្រោមការចាប់ខ្លួន ឃុំខ្លួន ឬការដាក់ពន្ធនាគារ តាមបែបណាមួយ ។ មាត្រា១១ និយាយដល់ការធានាអំពីវិធានសួរចម្លើយ សេចក្តីបង្គាប់ វិធី និងការអនុវត្តន៏

## ការរំលោភដោយអ្នកជាប់ឃុំឃាំង

ក្នុងការឱ្យនិយមន័យទារុណកម្ម ការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀតដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប អនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្មរាប់បញ្ចូលមិនត្រឹមតែអំពើទាំងឡាយដែលបានប្រព្រឹត្ត*ដោយ*មន្ត្រីសាធារណៈប៉ុណ្ណោះទេ ក៏ប៉ុន្តែរួមទាំងអំពើដែលបានប្រព្រឹត្តដោយមាន "ការសុខចិត្ត" របស់ខ្លួនផងដែរ ។[158]

បទបញ្ញត្តិជាបទដ្ឋានអប្បរិមារបស់អ.ស.ប សម្រាប់គ្រប់គ្រងអ្នកទោសចែងថា "ក្នុងសេវាកម្មរបស់មន្ទីរឃុំឃាំង មិនត្រូវជួលអ្នកទោសណាម្នាក់ឱ្យបំពេញមុខងារណាមួយ ក្នុងសមត្ថកិច្ចរក្សាបទវិន័យឡើយ" ។[159] បទបញ្ញត្តិជាបទដ្ឋានអប្បរិមា ត្រូវបានគេបញ្ចូលយ៉ាងជាក់លាក់ទៅក្នុងក្រមព្រហ្មទណ្ឌប្រទេសកម្ពុជា ។[160]

## ការបរិច្ចាគឈាមដោយបង្ខំ

---

ព្រមទាំងរបៀបឃុំ និងការប្រព្រឹត្តទៅលើជនដែលត្រូវចាប់ខ្លួន ឃុំខ្លួន ឬជាប់ពន្ធនាគារ ក្នុងដែនដីក្រោមដែនសមត្ថកិច្ចរបស់ខ្លួនក្រោមការពិនិត្យឡើងវិញហ្មត់ចត់ ដើម្បីជៀសវាងរាល់ករណីទារុណកម្ម ។ មាត្រា១២ តម្រូវឱ្យរដ្ឋភាគីស៊ើបអង្កេតជាបន្ទាន់មិនលំអៀង នៅពេលមានមូលហេតុសមស្របគួរឱ្យជឿបានថា អំពើទារុណកម្មត្រូវបានប្រព្រឹត្តមែន ។ មាត្រា១៣តម្រូវថារដ្ឋភាគីនីមួយៗត្រូវធានាថាបុគ្គលណាដែលអះអាងថាបានទទួលរងទារុណកម្ម មានសិទ្ធិប្តឹង និងដាក់ករណីរបស់ខ្លួនទៅអាជ្ញាធរមានសមត្ថកិច្ច ឱ្យចាត់ការពិនិត្យជាបន្ទាន់ និងឥតលំអៀងនូវរឿងហេតុរបស់ជននោះ ។ គោលការណ៍អ.ស.ប ស្តីពីការស៊ើបអង្កេតដោយប្រសិទ្ធិភាព និងកំណត់ត្រាអំពីការធ្វើទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀតដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប (២00១ ) និយាយយ៉ាងច្បាស់ថាទោះជារបាយការណ៍អំពីទារុណកម្មឥតមានភស្តុតាងក៏ដោយ ក៏ត្រូវតែមានការស៊ើបអង្កេតដែរ ។

158 អនុសញ្ញាប្រឆាំងការធ្វើទារុណកម្ម - មាត្រា ១(១) និង មាត្រា ១៦(១)

159 បទបញ្ញត្តិជាបទដ្ឋានអប្បរិមារបស់ អ.ស.ប សម្រាប់គ្រប់គ្រងអ្នកទោស — កថាខ័ណ្ឌ ២៨ (១)

160 មាត្រា១២(២) នៃក្រមព្រហ្មទណ្ឌអ៊ុនតាក់ (បទបញ្ញត្តិដែលទាក់ទងទៅនឹងច្បាប់និងនីតិវិធីព្រហ្មទណ្ឌនិង និង តុលាការសម្រាប់អនុវត្តន៍នៅប្រទេសកម្ពុជាក្នុងសម័យអន្តរកាល ថ្ងៃទី១០ កញ្ញា ឆ្នាំ១៩៩២) បញ្ជាក់ថាការឃុំខ្លួន ត្រូវតែគោរពតាមបញ្ញត្តិជាបទដ្ឋានអប្បរិមា អ.ស.ប សម្រាប់គ្រប់គ្រងអ្នកទោស

ដោយសារចរិតរំលោភលើការបរិច្ចាគឈាមដោយបង្ខំ ការអនុវត្តន៍បែបនេះរំលោភលើសិទ្ធិបូរណភាពរាងកាយរបស់បុគ្គល។ [161] ការបង់ប្រាក់សម្រាប់ការបរិច្ចាគក៏ផ្ទុយនឹងច្បាប់ប្រទេសកម្ពុជាផងដែរ។[162]

អង្គការសុខភាពពិភពលោក ផ្តល់អនុសាសន៍ថា ការបរិច្ចាគឈាម គួរធ្វើដោយស្ម័គ្រចិត្ត និងមិនបង់ប្រាក់។ យោងតាមអង្គការសុខភាពពិភពលោក :-

> បន្ទុកជំងឺនៅលើពិភពលោក ដោយសារការបញ្ចូលឈាមដែលគ្មានសុវត្ថិភាព អាចត្រូវបានលុបបំបាត់ ឬកាត់បន្ថយបានយ៉ាងច្រើន តាមរយៈយុទ្ធសាស្រ្តបញ្ចូលគ្នាសម្រាប់សុវត្ថិភាពឈាម ដែលរួមទាំង... ការប្រមូលឈាមណាដែលបានពីអ្នកបរិច្ចាគឈាមដែលមិនគិតកម្រៃនិងដោយស្ម័គ្រចិត្ត ពីចំណោមប្រជាពលរដ្ឋ ដែលប្រឈមនឹងគ្រោះថ្នាក់ទាប...។[163]

ការយកឈាមពីប្រជាពលរដ្ឋ ដែលប្រឈមនឹងគ្រោះថ្នាក់ខ្ពស់ ចំពោះការឆ្លងមេរោគអេដស៍ ដូចជាអ្នកប្រើប្រាស់គ្រឿងញៀននោះ គឺនឹងធ្វើឱ្យគ្រោះថ្នាក់ដល់សុវត្ថិភាពនៃប្រព័ន្ធបញ្ចូលឈាមរបស់ប្រទេសកម្ពុជា។ យោងតាមទិន្នន័យខែវិច្ឆិកា ឆ្នាំ២០០៨ មាន៣ភាគរយនៃឯកតា

---

161 សូមមើលឧទាហរណ៍ មាត្រា១៧ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ

162 ក្រសួងសុខាភិបាលបានចេញសេចក្តីប្រកាសមួយ "ស្តីពីការគ្រប់គ្រង និងសុវត្ថិភាពឈាម" ក្នុងឆ្នាំ១៩៩៤ ដែលចាត់ទុកការបរិច្ចាគឈាមដែលគិតថ្លៃ គឺខុសច្បាប់។ មាត្រា៧ ចែងថា "ឈាមដែលមន្ទីរពេទ្យទាំងអស់ ទទួលឈាមពីមជ្ឈមណ្ឌលផ្តល់ឈាម ឬពីសប្បុរសជន គឺធ្វើឡើងដោយឥតគិតថ្លៃ ហើយការផ្តល់ឈាមដល់ជនរងគ្រោះវិញ ក៏ពុំគិតថ្លៃដែរ" ។ មាត្រា៨ ចែងថា "ជនណាដែលបានប្រព្រឹត្តផ្ទុយនិងប្រការ ៤, ៥ និង៧ នៃប្រកាសនេះ ឬប្រើមធ្យោបាយផ្សេងៗ និងល្បិចកល់ដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួន ត្រូវផ្តន្ទាទោសតាមច្បាប់ " (ការបកប្រែដោយអង្គការឃ្លាំមើលសិទ្ធិមនុស្ស។ ច្បាប់ថតចម្លងរក្សាទុកជាឯកសារនៅអង្គការឃ្លាំមើលសិទ្ធិមនុស្ស)

163 អង្គការសុខភាពពិភពលោក "សុវត្ថិភាពឈាម : កំណត់ហេតុសង្ខេបសម្រាប់កម្មវិធីឈាមថ្នាក់ជាតិ" **WHO/BCT/02.03, 2002**។ សូមកត់សំគាល់ថា សង្គមអន្តរជាតិដើម្បីការបញ្ចូលឈាម (**International Society for Blood Transfusion's**) "ក្រមសីលធមិសម្រាប់ការបរិច្ចាគឈាម និងការបញ្ចូលឈាម" បញ្ជាក់ថា :- "ការបរិច្ចាគឈាម ត្រូវតែធ្វើដោយស្ម័គ្រចិត្ត និងឥតគិតថ្លៃនៅគ្រប់កាលៈទេសៈ មិនត្រូវបង្ខំមកលើអ្នកធ្វើបរិច្ចាគ។ ការបរិច្ចាគឈាមដែលត្រូវបានចាត់ទុកថាស្ម័គ្រចិត្តនិងបង់ប្រាក់ ប្រសិនបើបុគ្គលនោះផ្តល់ឈាមរបស់ខ្លួន... ដោយឆន្ទៈសេរីរបស់ខ្លួន ហើយមិនទទួលការបង់ថ្លៃណាមួយសម្រាប់ការបរិច្ចាគនោះ ទោះជាប្រាក់ក្តី ឬរបស់ដែលអាចជំនួសប្រាក់ក្តី... អ្នកធ្វើបរិច្ចាគត្រូវព្រមព្រៀងផ្តល់សិទ្ធិសម្រាប់ការបរិច្ចាគឈាម..." អនុម័តដោយមហាសន្និបាតសង្គមអន្តរជាតិសម្រាប់ការបញ្ចូលឈាម — ថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០០០

ឈាមដែលបានបរិច្ចាគនោះ មិនត្រូវបានឆ្លងកាត់ការពិនិត្យរកមេរោគអេដស៍ " តាមលក្ខណៈធានាពីគុណភាព" ទេ។[164] នៅក្នុងឆ្នាំ២០០៦ របាយការណ៍មួយដែល គាំទ្រដោយអង្គការសហប្រជាជាតិប្រយុទ្ធនឹងជំងឺអេដស៍ (UNAIDS) បានទទួលស្គាល់ថា :-

> ការបរិច្ចាគ[ឈាម]ភាគច្រើន គឺបានមកពីអ្នកបរិច្ចាគ ជំនួសហើយប្រព័ន្ធនេះបន្តធ្វើដោយមានការជ្រៀតចូលពីអ្នកបរិច្ចាគដែលគិតថ្លៃ។ រដ្ឋាភិបាលបានកម្រិតថវិកាសម្រាប់ធានាសុវត្ថិភាពឈាម ដែលនៅតែជារឿងធ្ងន់ធ្ងរ។ សេចក្តីរាយការណ៍ស្តីពីការពិនិត្យឈាម មានការប្រែប្រួល ហើយមិនមានបទដ្ឋានកំណត់ ឬនីតិវិធីសម្រាប់ធានាគុណភាពឡើយ។[165]

## ការព្យាបាលគ្រឿងញៀន និងស្ថានភាពរស់នៅ

### ការបដិសេធការព្យាបាលការញៀនគ្រឿងញៀន

> *ពួកគេបានឱ្យខ្ញុំហាត់ប្រាណ... ខ្ញុំក្អួត។ ខ្ញុំមានអារម្មណ៍ថា គេកេងចំណេញពីខ្ញុំ។ ខ្ញុំចង់ចាកចេញពី[ចមចៅ]... បើខ្ញុំនឿយហត់ ហើយមិនអាចហាត់ប្រាណបាន មេបន្ទប់មកវាយខ្ញុំ— ស្រកានាគ អាយុ២២ឆ្នាំ*[166]

ចំពោះបទដ្ឋានសីលធម៌ ដែលអនុវត្តចំពោះការព្យាបាល អង្គការសុខភាពពិភពលោក និងការិយាល័យគ្រឿងញៀននិងឧក្រិដ្ឋកម្មរបស់ អ.ស.ប ផ្តល់ជាយោបល់ថាការការ

[164] អង្គការសុខភាពពិភពលោក/អង្គការសហប្រជាជាតិស្តីពីកម្មវិធីអេដស៍/យូនីសែហ្វ "ខិត្តប័ណ្ណព័ត៌មាន ស្តីពីមេរោគអេដស៍ និងជំងឺអេដស៍ :ប្រទេសកម្ពុជា ២០០៨ ធ្វើបច្ចុប្បន្នភាព " ខែធ្នូ ឆ្នាំ២០០៨ ទំព័រ១៤

[165] អង្គការសហប្រជាជាតិប្រយុទ្ធនឹងជំងឺអេដស៍ UNAIDS, "ការប្រែក្លាយកំណើនៈ ការឆ្លើយតបរបស់ប្រទេសកម្ពុជា ចំពោះមេរោគអេដស៍ និងជំងឺអេដស៍ ១៩៩១-២០០៥" ខែសីហា ឆ្នាំ២០០៦ ទំព័រ៦៦

[166] អង្គការឃ្លាំមើលសិទ្ធិមនុស្ស សម្ភាសស្រកានាគ — ភ្នំពេញ ខែមិថុនា ឆ្នាំ២០០៩

ញៀនគ្រឿងញៀន គួរតែត្រូវបានចាត់ទុកថាជាស្ថានភាពថែទាំសុខភាពដទៃទៀត។[167] គោលការណ៍សំខាន់ៗមួយចំនួន ដែលផ្សារភ្ជាប់នឹងការព្យាបាលប្រកបដោយលទ្ធផលវិជ្ជមាន រួមមាន :-

- ការញៀនគ្រឿងញៀន គឺជាជំងឺរ៉ាំរ៉ៃនិងដែលលាប់ធ្ងន់ធ្ងរ
- មិនមានការព្យាបាលតែមួយ សមស្របសម្រាប់បុគ្គលគ្រប់ៗគ្នាឡើយ
- ការព្យាបាលរបស់បុគ្គលម្នាក់ និងផែនការផ្តល់សេវា ត្រូវតែធ្វើការវាយតម្លៃជាបន្តបន្ទាប់ និងផ្លាស់ប្តូជាចាំបាច់ ដើម្បីធានាថាការព្យាបាលនោះត្រូវនឹងសេចក្តីត្រូវការផ្លាស់ប្តូររបស់គាត់។
- ឱសថគឺជាសារធាតុដ៏សំខាន់មួយនៃការព្យាបាលដល់អ្នកជំងឺជាច្រើន ជាពិសេសពេលដែលបញ្ចូលគ្នាជាមួយការប្រឹក្សាយោបល់ និងការព្យាបាលឥរិយាបទផ្សេងទៀត។
- ការបន្សាបគ្រឿងញៀន គឺជាដំណាក់កាលបឋមនៃការព្យាបាលភាពញៀន និងការបន្សាបនេះជួយបានបន្តិចបន្តួច ដើម្បីផ្លាស់ប្តូរការបំពានគ្រឿងញៀនរយៈពេលវែងហើយ
- ការព្យាបាល ត្រូវតែជួយយកចិត្តទុកដាក់ដល់តម្រូវការចម្រុះគ្នារបស់អ្នកជំងឺ (ជាញឹកញាប់រួមបញ្ចូលបញ្ហាសុខភាពផ្លូវចិត្ត)[168]

ដូចដែលអង្គការសុខភាពពិភពលោក និងការិយាល័យគ្រឿងញៀននិងឧក្រិដ្ឋកម្ម របស់ អ.ស.ប កត់សម្គាល់ថា "ការឃុំខ្លួនក្តី ឬពលកម្មដោយបង្ខិតបង្ខំក្តី មិនត្រូវបានទទួលស្គាល់តាមវិទ្យាសាស្ត្រថាជាការព្យាបាលដំណើរវិបល្លាសនៃការប្រើប្រាស់គ្រឿងញៀនទេ"។ [169]

---

[167] អង្គការសុខភាពពិភពលោក/ការិយាល័យគ្រឿងញៀន និងឧក្រិដ្ឋកម្មអ.ស.ប "គោលការណ៍នៃការព្យាបាលការញៀនគ្រឿងញៀន" ខែមីនា ២០០៨ ទំព័រ៩—សូមមើលគេហទំព័រ www.who.int/substance_abuse/publications/principles_drug_dependence_treatment.pdf.

[168] វិទ្យាស្ថានជាតិស្តីពីការបំពានគ្រឿងញៀនរបស់ [ស.រ.អ] (NIDA) បង្កើតគោលការណ៍១៣ អំពីការព្យាបាលការញៀនគ្រឿងញៀនដោយប្រសិទ្ធិភាព។ សូមមើល NIDA "គោលការណ៍ព្យាបាលការញៀនគ្រឿងញៀន : មគ្គុទេសន៏សម្រាប់មូលដ្ឋានស្រាវជ្រាវ"

[169] អង្គការសុខភាពពិភពលោក/ការិយាល័យគ្រឿងញៀន និងឧក្រិដ្ឋកម្មអ.ស.ប "គោលការណ៍នៃការព្យាបាលការពឹងអាស្រ័យលើគ្រឿងញៀន" ទំព័រ១៤

គោលការណ៍សិទ្ធិមនុស្ស ដែលអនុវត្តចំពោះការព្យាបាលការញៀនគ្រឿងញៀនដែលប្រសិទ្ធិភាព នឹងពិភាក្សាល្អិតល្អន់ខាងក្រោម។

អង្គការឃ្លាំមើលសិទ្ធិមនុស្សបានរកឃើញថា ផ្នែកសំខាន់នៃការព្យាបាលក្នុងមជ្ឈមណ្ឌលឃុំឃាំងគ្រឿងញៀនប្រទេសកម្ពុជា គឺការហាត់ប្រាណនិងពលកម្មដោយបង្ខំ។ អ្នកដែលទទួលខុសត្រូវមជ្ឈមណ្ឌល បានប្តេជ្ញាខិតខំធ្វើឱ្យអ្នកជាប់ឃុំឃាំងបែកញើស ដោយបញ្ជាក់ពីបំណងបញ្ចេញសារធាតុញៀនចេញពីខ្លួន។ តាមពិត ការបញ្ចេញញើស ខណៈពេលហាត់ប្រាណឬពលកម្ម គឺហាក់ដូចជាមធ្យោបាយចម្បងសម្រាប់ការព្យាបាលការញៀនគ្រឿងញៀន នៅក្នុងមជ្ឈមណ្ឌលទាំងនោះ។ ក្នុងមជ្ឈមណ្ឌលមួយចំនួន របបនៃការហាត់ប្រាណនេះ ត្រូវបានបន្ថែមពីលើដោយការហ្វឹកហ្វឺនយោធា សកម្មភាពថ្នាក់បង្រៀនជាក្រុមដែលរៀនពីបញ្ហាគ្រឿងញៀន និងការបណ្តុះបណ្តាលវិជ្ជាជីវៈតាមការសន្មត់នោះ។ ដោយសារសកម្មភាពទាំងអស់នេះមាននៅក្នុងមជ្ឈមណ្ឌល ការចូលរួមជាញឹកញាប់ត្រូវបានអនុវត្តដោយអំពើឃោរឃៅ ដែលជាផ្នែកមួយរបស់បុគ្គលិកមជ្ឈមណ្ឌល និងអ្នកជាប់ឃុំឃាំង។

អ.ជ.ប.គ.ញរបស់ប្រទេសកម្ពុជាខ្លួនឯង និយាយភ្ញាក់ផ្អើលដោយត្រង់ៗ អំពីគុណភាពព្យាបាលការញៀនគ្រឿងញៀនដែលគេសន្មត់ក្នុងមជ្ឈមណ្ឌលដូច្នេះថា :-

> មណ្ឌលស្ទើរទាំងអស់ ផ្តល់ការអប់រំនិងសេវាសុខភាពមានកម្រិត ហើយផ្តោតជាពិសេសលើការហាត់ប្រាណនិងវិន័យទាំងស្រុង... ក្នុងករណីភាគច្រើន ពុំមានការវាយតម្លៃអំពីស្ថានភាពសុខភាពផ្លូវកាយនិងចិត្តរបស់អ្នកចូលរួម ដើម្បីបញ្ចូលទៅក្នុងមណ្ឌលទេ។ ពុំមានមណ្ឌលមួយណា ដែលផ្តល់សេវាបន្សាបគ្រឿងញៀនដែលធ្វើទៅតាមទម្រង់នោះទេ ហើយពុំមានការប្រើប្រាស់ថ្នាំដើម្បីធ្វើឱ្យស្ថេរភាពដល់អ្នកជំងឺក្នុងស្ថានភាពដែលមានទុក្ខព្រួយធ្ងន់ធ្ងរ (ពីការផ្តាច់គ្រឿងញៀន)ទេ។

> មណ្ឌលផ្ដោតទៅលើការស្ដារនីតិសម្បទារបស់អ្នកប្រើប្រាស់គ្រឿងញៀន។ ជាទូទៅ មជ្ឈមណ្ឌលគ្រឿងញៀន ពាក់ព័ន្ធនឹងសកម្មភាពដូចជាការហាត់ប្រាណ បណ្ដុះបណ្ដាលវិជ្ជាជីវៈ មានដូចជាកាត់សក់ ដាំដំណាំ ការផ្ដល់ប្រឹក្សាអំពីសីលធម៌ ឬសាសនា និងវគ្គពិគ្រោះយោបល់ជាក្រុម។[170]

អ្នកជំនាញមិនយល់ស្របទេដែលថា គោលនយោបាយនៃការឃុំខ្លួន ដោយបង្ខំនៅមជ្ឈមណ្ឌលទាំងនេះ ដំណើរការ។ គ្រូពេទ្យវិជ្ជាជីវៈខាងសុខភាពជនជាតិកម្ពុជាម្នាក់ បានធ្វើការវាយតម្លៃផ្ទាល់ខ្លួនអំពីប្រព័ន្ធព្យាបាលគ្រឿងញៀនដោយបង្ខំដូច្នេះថា :-

> តាមគំនិតផ្ទាល់ខ្លួនរបស់ខ្ញុំ គឺវាមិនអាចដំណើរការទៅរួចទេ។ នៅពេលពួកគេត្រូវបានដោះលែងមកវិញដោយគ្មានកញ្ចប់ព្យាបាលល្អ រួមទាំងការពិគ្រោះយោបល់ ការគាំទ្រចិត្តសាស្ត្រ ជម្រើសរបស់ពួកគេ នៅពេលត្រូវបានគេដោះលែងដើម្បីមានជម្រក — នោះពួកគេនឹងវិលត្រឡប់ទៅរកការញៀនថ្នាំវិញ។ ពុំមានសេវាសង្គម ដើម្បីជួយពួកគេឱ្យរកផ្លូវចេញផុតពីគ្រឿងញៀនបាន... [អ្នកទាំងនោះដែលទទួលខុសត្រូវមណ្ឌល] មិនបានគិតដល់បញ្ហាទាំងអស់នេះទេ... ពួកគេមើលឃើញថា [ការព្យាបាល] ដែលជា[ការឃុំខ្លួន]រយៈពេលបីខែនេះ ធ្វើឱ្យសារធាតុញៀនចេញពីខ្លួនបាន ដូច្នេះពួកគេបាន"ជាសះស្បើយ"។ ក៏ប៉ុន្តែ វាមិនដំណើរការទេ :- [អតីតអ្នកជាប់ឃុំឃាំង] លាប់ឡើងវិញ!។ ពួកគេគ្រាន់តែយកអ្នកទាំងនេះចេញ ហើយនិយាយថា "លែងមានអ្នកប្រើប្រាស់គ្រឿងញៀននៅតាមផ្លូវថ្នល់ទៀតហើយ"។ ក៏ប៉ុន្តែ វាមិនដំណើរការទេ។[171]

---

170 អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន "របាយការណ៍ស្ដីពីលទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀន ក្នុងប្រទេសកម្ពុជា ឆ្នាំ២០០៧" ខែមិថុនា ឆ្នាំ២០០៨ ទំព័រ៧៤

171 អង្គការឃ្លាំមើលសិទ្ធិមនុស្ស សម្ភាសគ្រូពេទ្យវិជ្ជាជីវៈកម្ពុជាម្នាក់ - ភ្នំពេញ ខែឧសភា ឆ្នាំ២០០៩

ក្នុងនាមជាបុគ្គលិកអង្គការក្រៅរដ្ឋាភិបាលដែលមានបទពិសោធន៍គួរឱ្យចាប់អារម្មណ៍ ដែលបម្រើការផ្នែកបញ្ហាគ្រឿងញៀនក្នុងប្រទេសកម្ពុជា គាត់បានពន្យល់ដូច្នេះថា :-

> វិធានការនៃ[ការព្យាបាលការញៀនគ្រឿងញៀនក្នុងប្រទេសកម្ពុជា] គឺមើលថាតើ...រាងកាយរបស់ជនណាម្នាក់នឹងលែងមានគ្រឿងញៀន នៅពេលដែលពួកគេឈានចេញពីរបងទ្វារ[របស់មជ្ឈមណ្ឌលមួយ]។ ពុំមានការតាមដានពុំមានជម្រើសជាយុទ្ធសាស្ត្រក្នុងការប្រកបរបរចិញ្ចឹមជីវិត ... ហើយពុំមានកិច្ចសហការជាមួយភ្នាក់ងារឬស្ថាប័នណា ដែលអាចផ្តល់យុទ្ធសាស្ត្រជាជម្រើសឡើយ។ នេះមានន័យថា អតីតអ្នកប្រើប្រាស់គ្រឿងញៀនមិនមានជម្រើសអ្វីក្រៅពីវិលត្រឡប់ទៅរកកន្លែងដែលមានកត្តាផ្សារភ្ជាប់ទៅនឹងការ ប្រើប្រាស់គ្រឿងញៀនរបស់ពួកគេកាលពីលើកមុនឡើយ។[172]

## លំហាត់ប្រាណដោយបង្ខំ

តាមមជ្ឈមណ្ឌលទាំងឡាយដែលបានរាយការណ៍ក្នុងរបាយការណ៍នេះ អតីតអ្នកជាប់ឃុំឃាំងបានរាយការណ៍ថា មានការឱ្យអនុវត្តលំហាត់ប្រាណយ៉ាងធ្ងន់ធ្ងរជាប្រចាំ។ ជាញឹកញាប់វគ្គនេះចាប់ផ្តើមពេលព្រឹកព្រលឹមនៅម៉ោង ៦ ឬ ៧ ហើយបន្ទាប់មកមានវគ្គរៀនសូត្រដែលធ្វើឱ្យនឿយហត់ខ្លាំងស្មើគ្នាក្រោយពេលរសៀល។ លំហាត់អាចជាការរត់ ការហាត់ប្រាណនិងលំហាត់ហ្វឹកហ្វឺនដូចជាដៃច្រត់ដីរុញដងខ្លួនជាដើម។ គោលដៅនៃការហាត់បែបនេះ ត្រូវបានគេប្រកាសថាដើម្បីធ្វើឱ្យអ្នកជាប់ឃុំឃាំង "បញ្ចេញឱ្យអស់"សារធាតុញៀនពីខ្លួន ដើម្បីធ្វើឱ្យពួកគេ

172 អង្គការឃ្លាំមើលសិទ្ធិមនុស្ស សម្ភាសបុគ្គលិកអង្គការក្រៅរដ្ឋាភិបាលម្នាក់ - ភ្នំពេញ ខែ ឧសភា ឆ្នាំ ២០០៩

"ជាសះស្បើយ"ពីការញៀន។ ប្រធានមជ្ឈមណ្ឌលរាជអាវុធហត្ថនៅស៊ីសូផុន បានពន្យល់នូវរបៀបដោះស្រាយបែបនេះនៅក្នុងអត្ថបទសារព័ត៌មានកម្ពុជាមួយដូច្នេះថា :- "នៅទីនេះ យើងបង្វឹកពួកគេដូចគ្នានឹងកងរាជអាវុធហត្ថដែរ ធ្វើឱ្យពួកគេមានសុខភាពល្អ ធ្វើឱ្យពួកគេបែកញើសចេញសារធាតុអាក្រក់"។[173]

យោងតាមសម្តីរបស់ឬស្សី អាយុ១៧ឆ្នាំ និងជាអតីតអ្នកជាប់ឃុំឃាំងនៅមជ្ឈមណ្ឌលកងរាជអាវុធហត្ថខេត្តបាត់ដំបង :-

[ការហាត់ប្រាណប្រចាំថ្ងៃមានដូចជា] ធ្វើសរសៃក្បាលពោះ ដៃច្រត់ដីរុញដងខ្លួន ធ្វើចលនាដៃជើង [ការហាត់ធ្វើចលនាមួយដែលហៅថា]"លោតកង្កែប"។ គឺដើម្បីសុខភាពរបស់ពួកខ្ញុំ :- ដើម្បីឱ្យរឹងឆ្លាតនិងខ្លាំង។ មេបញ្ជាការប៉េអឹមបាននិយាយមុនពេលហាត់ប្រាណថា "នៅពេលអ្នកហាត់ប្រាណ អ្នកនឹងបែកញើស ហើយបញ្ចេញជាតិញៀនតាមញើស"។ បន្ទាប់ពីគាត់និយាយរួច ពួកខ្ញុំបានចាប់ផ្តើមហាត់ប្រាណ។[174]

ម្ចាស់មានអាយុ១៦ឆ្នាំ បានពន្យល់អំពីការហាត់ប្រាណនៅក្នុង"មជ្ឈមណ្ឌលយុវនីតិ សម្បទា" សង្គមកិច្ចចោមចៅដូច្នេះថា :-

ការហាត់ប្រាណមាន១២របៀប មានដូចជា"ដៃច្រត់ដីរុញដងខ្លួន"។ [ក្នុងវគ្គនីមួយៗ] ពួកខ្ញុំត្រូវយក"ដៃច្រត់ដីរុញដងខ្លួន" ពី៥០ ទៅ ១០០ ដង។ បើហ៊ានឈប់សម្រាកលើដី គេឱ្យធ្វើបន្ថែម២០ដងទៀត។ បើធ្វើមិនបាន គេនឹង

---

[173] យន់ សាមៀន និង ហ៊ើហ្គល់ ឃ្វីន "ស្ទេហាតឹងរឹង សម្រាប់អ្នកបង្កបញ្ហាវ័យក្មេងដែលមានទ្រព្យសម្បត្តិ" ឌឹ ឃែមបូឌៀ ដេលី — ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៨

[174] អង្គការឃ្លាំមើលសិទ្ធិមនុស្ស សម្ភាសឬស្សី — ខេត្តបាត់ដំបង ខែមិថុនា ឆ្នាំ២០០៩

> វាយ។ ពួកខ្ញុំត្រូវតែបត់ជើងដែរ និងធ្វើកាយវិកាដៃ អង្គុយចុះ លើកដៃឡើងលើ និងចុះក្រោមឱ្យប៉ះដី ឈរជើងម្ខាង ហើយលាតដៃត្រង់ទៅមុខ... [ការហាត់ប្រាណ] មានរយៈពេលមួយម៉ោង ម្តងក្នុងមួយថ្ងៃ ហើយពេលខ្លះតិចជាងនេះ។ ពួកខ្ញុំហាត់ ៥ថ្ងៃក្នុងមួយអាទិត្យ។ គេនិយាយថាគឺដើម្បីបន្សាបសារធាតុញៀន។ មេធំ [មណ្ឌល] និយាយថា... "ហាត់ប្រាណធ្វើឱ្យបែកញើស ហើយជាតិញៀននឹងហូរតាមញើសចេញមកក្រៅ"។[175]

អតីតអ្នកជាប់ឃុំឃាំង វាយការណ៍ថាលំហាត់ប្រាណ បានធ្វើឱ្យនឿយហត់យ៉ាងខ្លាំង។ យោងតាមសម្តីរបស់គុហានិយាយថា "ខ្ញុំមានអារម្មណ៍វេទនា [ពេលកំពុងហាត់ប្រាណ]។ ពីមុនខ្ញុំមិនធ្លាប់ហាត់បែបនេះសោះ"។[176] ទោះបីតម្រូវឱ្យមានការហាត់ប្រាណបែបនេះក្តី អតីតអ្នកជាប់ឃុំឃាំងរាយការណ៍ថាត្រូវគេវាយធ្វើបាប ប្រសិនបើពួកគេមិនអាចបញ្ចប់ ឬមានកំហុសពេលហាត់ប្រាណ។ តាមសម្តីរបស់វ៉ារី : "គេវាយខ្ញុំ នៅពេលដែលខ្ញុំធ្វើខុស ដូចជាហាត់ខុស ឬ ចូលជួរមិនត្រង់... នៅពេលខ្លះគេប្រើបន្ទះរនៀតគ្រែ ឬមែកឈើ"។[177]

## ពលកម្មដោយបង្ខំ

អ្នករស់នៅក្នុងមណ្ឌល ធ្វើឱ្យពេលវេលាពួកគេយ៉ាងច្រើនកន្លងទៅដោយការជម្រះស្មៅ ដាំបន្លែ ឬមើលថែទាំសត្វនៅក្នុងមណ្ឌល។ ការមិនធ្វើពលកម្មទាំងនោះ នឹងបង្កផលវិបាកយ៉ាងធ្ងន់ធ្ងរ។ នេះគឺជាករណីយ៉ាងចម្លែកសម្រាប់អ្នកជាប់ឃុំឃាំងដែលរាយការណ៍អំពីការមានជំងឺនៅ

---

[175] អង្គការឃ្លាំមើលសិទ្ធិមនុស្ស សម្ភាសម្ចាស់ — ភ្នំពេញ ខែមិថុនា ឆ្នាំ២០០៩

[176] អង្គការឃ្លាំមើលសិទ្ធិមនុស្ស សម្ភាសគុហា — កម្ពុជា ខែកក្កដា ឆ្នាំ២០០៩

[177] អង្គការឃ្លាំមើលសិទ្ធិមនុស្ស សម្ភាសវ៉ារី — ភ្នំពេញ ខែកក្កដា ឆ្នាំ២០០៩

ក្នុងមណ្ឌល។ មេសាមានអាយុ២៨ឆ្នាំ បានរៀបរាប់អំពីការឆក់ដោយដំបងដែលមានចរន្តអគ្គិសនីមកលើខ្លួនគាត់ដោយបុគ្គលិកនៅមណ្ឌលឱកាសខ្ញុំ ដើម្បីបង្ខំគាត់ឱ្យធ្វើការ នៅពេលគាត់មានជំងឺ :-

> ថ្ងៃមួយខ្ញុំដេកដណ្តប់ភួយ ដោយសារក្តៅខ្លួន និងឈឺក្បាល ហើយអស់កម្លាំង។ ខ្ញុំដេកញ័រនៅលើឥដ្ឋ... មេក្រុមបានមកដល់តាមបញ្ជារបស់មេកង ឱ្យហៅខ្ញុំចេញក្រៅពីរដង។ ខ្ញុំបាននិយាយប្រាប់មេក្រុមថា ខ្ញុំទៅមិនរួចទេ។ ក្រោយមក [បុគ្គលិកម្នាក់] គាត់ជាគ្រូបង្វឹកប៉េអឹម បាននិយាយថា "ទុកឱ្យអញទៅមើលអាអ្នកឈឺមើល!"។ គាត់ចូលមកដោយកាន់ដំបងឆក់ចរន្តអគ្គិសនី ហើយបានឆក់ខ្ញុំ [178]

អ្នកញៀនគ្រឿងញៀន មានបទពិសោធន៍រោគសញ្ញាពីការផ្តាច់គ្រឿងញៀនបន្ទាប់ពីពួកគេឈប់ប្រើគ្រឿងញៀន ដូចជាចុកពោះ ចង់ក្អួត ក្អួតចង្អោរ ឈឺឆ្អឹងនិង សាច់ដុំ ដេកមិនលក់ និងអារម្មណ៍អន្ទះសារ។ [179] បុគ្គលិកក៏បង្ខំឱ្យអ្នកជាប់ឃុំឃាំងធ្វើការនៅពេលជំងឺរបស់ពួកគេ ទាក់ទងទៅនឹងការផ្តាច់ពីគ្រឿងញៀន។ តាមពិតទៅ ការធ្វើពលកម្មនៅក្នុងទីវាលត្រូវបានគេអះអាងថាជាការព្យាបាលមួយ :- បុគ្គលិកពន្យល់ថា ការហាត់ប្រាណនឹងធ្វើឱ្យសារធាតុញៀនចេញពីខ្លួន។ កុម្ភៈបានពន្យល់ថា :-

> [បន្ទាប់ពីចូលមណ្ឌលឱកាសខ្ញុំ] ខ្ញុំឈឺអស់រយៈពេលប្រហែលពីរអាទិត្យ ប៉ុន្តែគេឱ្យខ្ញុំឈប់សម្រាកតែបីថ្ងៃប៉ុណ្ណោះ។ ខ្ញុំចង់បានច្បាប់ឈប់សម្រាកឱ្យបានយូរបន្តិច

---

178 អង្គការឃ្លាំមើលសិទ្ធិមនុស្ស សម្ភាសមេសា — ភ្នំពេញ ខែឧសភា ឆ្នាំ២០០៩

179 ជំងឺធ្លាក់កម្លាំងកាយចិត្តកើតឡើង នៅពេលជនណាម្នាក់ឈប់ទទួលសារធាតុដែលចិត្តសកម្ម។ យោងតាមអង្គការសុខភាពពិភពលោក "ពេលចាប់ផ្តើមធ្វើទុក្ខ និងខួបនៃរោគសញ្ញាធ្លាក់កម្លាំងកាយចិត្តមានពេលកំណត់ ហើយទាក់ទងទៅនឹងប្រភេទសារធាតុថ្នាំនិងកំរិតដូសរបស់វា ត្រូវតែលេបជាបន្ទាន់មុននឹងបញ្ឈប់ ឬបន្ថយការប្រើ... ការផ្តាច់គ្រឿងញៀនប្រភេទអាភៀន គឺកើតមានជាមួយនឹងការហៀរសំបោរ ការហៀរទឹកភ្នែកច្រើន ឈឺសាច់ដុំ រងាញាក់ ឡើងព្រឺសម្បុរ ហើយបន្ទាប់ពីរយៈ២៤ម៉ោងទៅ៤៨ម៉ោងក្រោយមក ធ្វើឱ្យរមួលសាច់ដុំ និងរមួលពោះ... ការផ្តាច់គ្រឿងញៀនប្រភេទកម្រើក រំញោច គឺមានរោគសញ្ញាកើតតិចជាងរោគសញ្ញាដែលមានពីការផ្តាច់ពីសារធាតុដែលប៉ះពាល់លើប្រព័ន្ធសរសៃប្រសាទ។ ជំងឺធ្លាក់កម្លាំងកាយចិត្តគឺមើលឃើញយ៉ាងងាយ និងកើតព្រមគ្នាជាមួយនឹងដំណើររសាប់រសល់ ភាពគ្មានកម្លាំង និងអស្ថេរភាព" អង្គការសុខភាព ពិភពលោក "សទ្ទានុក្រមនៃពាក្យគ្រឿងញៀននិងគ្រឿងស្រវឹង" ១៩៩៩ [www.who.int/substance_abuse/terminology/who_lexicon/en/].

តែគេមិនព្រម។ បុគ្គលិកមណ្ឌលម្នាក់និយាយថា "បើមិនធ្វើការឱ្យបែកញើសទេ ជាតិញៀននៅយូរណាស់។ ធ្វើពលកម្មគឺដើម្បីបញ្ចេញញើសឱ្យជាតិញៀនចេញ ឯងនឹងជាវិញ"។ ខ្ញុំបានជឿថាបើខ្ញុំខំធ្វើពលកម្ម ជាតិញៀននឹងហូរតាមញើស ចេញមកអស់។ វាពិបាកធ្វើការណាស់ តែចេះតែទ្រាំទៅ។ ខ្ញុំអស់កម្លាំង ពីខ្លួនពេលកំពុងធ្វើការ។ សន្លាក់ដៃជើងឡើងឈឺអស់ហើយ។ ខ្ញុំអស់កម្លាំង វិលមុខ ហើយក្អួត។ ខ្ញុំត្រូវតែកាប់ដីធ្វើស្រះចិញ្ចឹមត្រី។ ពួកខ្ញុំដាំបន្លែដែរ។[180]

ពុធបានរៀបរាប់អំពីដំណើរការពលកម្មដោយបង្ខំដែលគាត់ធ្វើក្នុងពេលផ្តាច់ចេញពីគ្រឿងញៀននៅមណ្ឌលឱកាសខ្ញុំ ដូច្នេះថា ៖-

ខ្ញុំមានជំងឺរាគ ឈឺពោះ។ ព្រឹកស្អែកឡើង [បន្ទាប់ពីចូលមណ្ឌលឱកាសខ្ញុំ] ខ្ញុំក្រោកលែងរួច។ គេប្រាប់ឱ្យខ្ញុំចេញទៅកាប់ដីដើម្បីបែកញើសបញ្ចេញជាតិញៀន។ អ្នកយាមប្រាប់មេបន្ទប់ឱ្យបញ្ជូនខ្ញុំទៅកាប់ដីដើម្បីព្យាបាលគ្រឿងញៀន។ ខ្ញុំប្រាប់ពួកគេថាខ្ញុំធ្វើមិនរួចទេ។ គេឱ្យខ្ញុំទៅជួបគ្រូពេទ្យក្នុងមណ្ឌលដើម្បីយកថ្នាំលេប... គ្រូពេទ្យនិយាយថាថ្នាំរាគនិងឈឺពោះ... [គ្រូពេទ្យឱ្យខ្ញុំ] បួនប្រាំគ្រាប់ ប៉ុន្តែមិនបាត់ទេ។ ខ្ញុំអស់កម្លាំងពីខ្លួន។ បន្ទាប់មក មេបន្ទប់វាយខ្ញុំនឹងរំពាត់... ខ្ញុំបានប្រាប់គាត់ថាខ្ញុំត្រូវការសម្រាក ប៉ុន្តែគាត់ថាខ្ញុំធ្វើពុតឈឺ។ គាត់និយាយថា "ហ្អែងនៅដើរបានតើ..."។[181]

---

[180] អង្គការឃ្លាំមើលសិទ្ធិមនុស្ស សម្ភាសកុម្ភៈ — ភ្នំពេញ ខែឧសភា ឆ្នាំ២០០៩

[181] អង្គការឃ្លាំមើលសិទ្ធិមនុស្ស សម្ភាសពុធ — ភ្នំពេញ ខែមេសា ឆ្នាំ២០០៩

តាមសម្តីរបស់ទុរេន ដែលបានជាប់នៅមណ្ឌលឱកាសខ្ញុំ "ពេលឈប់ប្រើគ្រឿងញៀន មានអារម្មណ៍រកកល់ចង់ស្លាប់។ នៅពេលយើងត្រូវធ្វើការពេលឈឺនោះ វាដូចជាទារុណកម្ម អញ្ចឹង"។[182]

បន្ថែមលើពលកម្មដោយបង្ខំនៅក្នុងមជ្ឈមណ្ឌល អង្គការឃ្លាំមើលសិទ្ធិមនុស្ស បានទទួលរបាយការណ៍អំពីក្រុមអ្នកជាប់ឃុំឃាំង ដែលចេញធ្វើពលកម្មនៅខាងក្រៅមណ្ឌល។ ផែនការពលកម្មទាំងនេះ ហាក់ដូចជាមានទ្រង់ទ្រាយតូចតាចទេ ហើយខុសគ្នាពីមណ្ឌលមួយទៅមណ្ឌលមួយទៀត។ ការងារនេះមានដូចជាសម្អាតផ្លូវថ្នល់ និងសួនសាធារណៈ។ នៅក្នុងសេចក្តីថ្លែងការណ៍មួយក្នុងខែឧសភា ឆ្នាំ២០០៩ លោកនាយករដ្ឋមន្ត្រី បានអំពាវនាវឱ្យអ.ជ.ប.គ.ញ បង្កើតមណ្ឌលព្យាបាលគ្រឿងញៀនបន្ថែម ដោយមានប្រសាសន៍បន្ថែមថា "ត្រូវប្រមូលផ្តុំ (អ្នកញៀនគ្រឿងញៀន)ឱ្យជួយកិច្ចការសង្គម ដើម្បីឱ្យពួកគេសងមកវិញនូវទង្វើមិនសមរម្យរបស់ខ្លួន... ពួកគេត្រូវតែបោសសម្អាតទីធ្លាសាធារណៈ ផ្លូវ សួនច្បារ ថែទាំលូទឹក និងស្តារប្រឡាយទឹក"។[183]

នៅពេលផ្សេងទៀត ការងារក្រោមណ្ឌលអាចធ្វើនៅការដ្ឋានសំណង់ ពេលខ្លះសាងសង់អាគារដែលជាកម្មសិទ្ធរបស់បុគ្គលិកមណ្ឌល ឬជាកម្មសិទ្ធឯកជន។ ក៏ប៉ុន្តែអ្នកជាប់ឃុំឃាំងមួយចំនួន ទទួលបានប្រាក់កម្រៃបន្តិចបន្តួចសម្រាប់ការងារពលកម្មធ្វើសំណង់នោះ ឯអ្នកផ្សេងទៀតមិនទទួលបានប្រាក់ទេ។ ការពន្យល់រៀបរាប់របស់អ្នកជាប់ឃុំឃាំង ដែលបានទទួលដោយ

---

182 អង្គការឃ្លាំមើលសិទ្ធិមនុស្ស សម្ភាសទុរេន — ភ្នំពេញ ខែឧសភា ឆ្នាំ២០០៩

183 ហ៊ុន សែន ថ្លែងក្នុងពិធីចូលកាន់ដំណែងរបស់ប្រធានថ្មីនៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ថ្ងៃ១៩ ឧសភា ២០០៩ (ច្បាប់ចម្លងរក្សាទុកជាឯកសារនៅអង្គការឃ្លាំមើលសិទ្ធិមនុស្ស)

អង្គការឃ្លាំមើលសិទ្ធិមនុស្ស បញ្ជាក់ថាការងារសំណង់បែបនេះ គឺបុគ្គលិករបស់មណ្ឌលជាអ្នកចាំទទួលផលចំណេញ មិនមែនបានមកអ្នកជាប់ឃុំឃាំងខ្លួនឯងនោះទេ។

សុក្រមពិពណ៌នាអំពីការងារសំណង់ដែលមានម្ដងម្កាល ដែលគាត់ធ្វើខណៈដែលបានជាប់ឃុំនៅមណ្ឌលកងរាជអាវុធហត្ថក្នុងខេត្តបន្ទាយមានជ័យ ដូច្នេះថា :-

> ពួកខ្ញុំធ្វើការដូចជាវាយបំបែកថ្ម រែកដី លាបថ្នាំជញ្ជាំងផ្ទះ... នៅពេលខ្លះប៉ុណ្ណោះ នៅពេលគេត្រូវការកម្លាំងប្រុស។ ឧទាហរណ៍ អ្នកណាត្រូវការធ្វើសំណង់ គេត្រូវការពួកខ្ញុំឱ្យធ្វើរួចរាល់ក្នុងរយៈពេលពីរអាទិត្យឬមួយខែ។ ខ្ញុំមិនដែលទទួលបានលុយទេ អ្នកផ្សេងក៏ដូចគ្នាដែរ ។[184]

ដួងចែមបានរាយការណ៍អំពីការងារសំណង់ដែលគាត់ធ្វើនៅការដ្ឋានឯកជនមួយ ដែលនៅជុំវិញមណ្ឌលដែលគាត់ត្រូវបានឃុំឃាំងនោះ។ គាត់ក៏រាយការណ៍ដែរថា ត្រូវគេវាយដើម្បីឱ្យគាត់ធ្វើការ។ [185] វ៉ារី អាយុ២៣ឆ្នាំ និងជាអតីតអ្នកជាប់ឃុំឃាំងនៅមណ្ឌលចោមចៅដែលគ្រប់គ្រងដោយសង្គមកិច្ច បានពិពណ៌នាអំពីការជួយសាងសង់អាគារមួយដែលជាកម្មសិទ្ធរបស់បុគ្គលិក :-

> មានការងារសំណង់ សាងសង់ផ្ទះឱ្យបុគ្គលិក។ ពេលម្ដងៗ គាត់យកមនុស្សពីរបីនាក់ [ពីមណ្ឌល]ឱ្យទៅធ្វើការ។ គឺនៅចំពីមុខមណ្ឌល។ យើងធ្វើជាកម្មករលីសែងលីបាវស៊ីម៉ង់។ បន្ទាប់ពីធ្វើការ ពួកខ្ញុំត្រឡប់មក[មណ្ឌល]វិញ។ ខ្ញុំលីតែស៊ីម៉ង់។ ពួកខ្ញុំធ្វើការរហូតដល់ផ្ទះនោះធ្វើរួចរាល់។ ខ្ញុំធ្វើការរាល់ថ្ងៃអស់រយៈពេលបីខែ គឺធ្វើការចាប់ពីម៉ោង៧ព្រឹក រហូតបាយម៉ោងបាយថ្ងៃត្រង់។ សម្រាកហូបបាយពីម៉ោង១១ដល់ម៉ោង១។ ហើយចាប់ផ្ដើមវិញនៅម៉ោង១ រហូតដល់ម៉ោង៥កន្លះ។

---

184 អង្គការឃ្លាំមើលសិទ្ធិមនុស្ស សម្ភាសសុក្រម — ខេត្តបន្ទាយមានជ័យ ខែមិថុនា ឆ្នាំ២០០៩

185 អង្គការឃ្លាំមើលសិទ្ធិមនុស្ស សម្ភាសដួងចែម — កម្ពុជា ខែមិថុនា ឆ្នាំ២០០៩

មានតែមនុស្សបីបួននាក់ប៉ុណ្ណោះ [ដែលបានធ្វើការនៅអាគារនោះ] ។ [បុគ្គលិក] បានឱ្យលុយពួកខ្ញុំ១០០០ ទៅ ២០០០រៀល[ប្រហែល ០.២៥ ឬ០.៥០ ដុល្លារ] ក្នុងមួយថ្ងៃ ។[186]

បន្ថែមលើពលកម្មដោយបង្ខំ គឺមានសកម្មភាព "បណ្តុះបណ្តាលវិជ្ជាជីវៈ" នៅក្នុងមណ្ឌលមួយចំនួន ។ ឧទាហរណ៍មានដូចជាជំនាញកាត់សក់ ជួសជុលម៉ូតូ ឬជាងឈើជាដើម ។ មណ្ឌលខ្លះមានថ្នាក់រៀនភាសាខ្មែរ ឬភាសាអង់គ្លេសផងដែរ ។ ទោះជាយ៉ាងណាក្តី ក្នុងករណីសិក្សាមួយខាងក្រោមនេះ អ្នកជាប់ឃុំឃាំងម្នាក់ បានរៀនជំនាញជាងឈើ ។ ដូចគ្នាទៅនឹងពលកម្មដោយបង្ខំនៃការងារសំណង់ខាងលើដែរ ការបណ្តុះបណ្តាលវិជ្ជាជីវៈនៅក្នុងករណីនេះ គឺជាការកេងប្រវ័ញ្ចកម្លាំងពលកម្មរបស់អ្នកជាប់ឃុំឃាំង ដើម្បីផលប្រយោជន៍របស់បុគ្គលិកមណ្ឌល ។

**"ស្នាដៃជនរងគ្រោះ" : ករណីសិក្សាមួយអំពី "ការបណ្តុះបណ្តាលវិជ្ជាជីវៈ"**

វិច្ឆិកាជាអតីតអ្នកជាប់ឃុំឃាំងម្នាក់នៅមណ្ឌលឱកាសខ្ញុំ បានរៀបរាប់ការងារជាងឈើដូច្នេះថា :-

ខ្ញុំរៀនជំនាញជាងឈើ ធ្វើកៅអីឈើ... ពួកខ្ញុំបានកែច្នៃធ្វើធុងសម្រាមនិងថូផ្កា ដោយយកសំបកកង់ឡានចាស់ៗដែលគេបោះចោល... ខ្ញុំឃើញរបស់ទាំងនោះនៅក្រៅមណ្ឌល មានមនុស្សច្រើនណាស់បានទិញរបស់ទាំងនោះ ។ ពួកគេក៏បានទិញកៅអីដែរ... កៅអីមួយមានតម្លៃប្រហែល ១៥ដុល្លារ - ឪពុកម្តាយបានទិញរបស់ទាំងនោះ ។ [ឪពុកម្តាយ]ខ្លះទិញកៅអី ហើយបរិច្ចាគឱ្យមណ្ឌលវិញ... ពួកខ្ញុំបានសរសេរឈ្មោះពួកគាត់នៅលើកៅអី ។ គ្រូគឺជាអ្នកទុកលុយ... អ្នកខ្លះមកមណ្ឌលដើម្បីបញ្ជាឱ្យធ្វើកៅអី : ឪពុកម្តាយខ្លះទៀតបញ្ជាទិញ៥កៅអី ខ្លះ១០ ហើយពួកគាត់យកទៅផ្ទះ ។ កៅអីនីមួយៗមានតម្លៃ៥០០០០រៀល ប្រហែល១២ដុល្លារ ។ ចំណែក

186 អង្គការឃ្លាំមើលសិទ្ធិមនុស្ស សម្ភាសវារី — ភ្នំពេញ ខែកក្កដា ឆ្នាំ២០០៩

ធុងសម្រាមគឺ១៥ដុល្លារ ថូផ្កាគឺ១០ដុល្លារ។ ធុងសម្រាមលក់ដាច់ណាស់ : ឪពុកម្តាយទិញយកទៅដាក់នៅខាងមុខផ្ទះ។ ពួកខ្ញុំបាញ់ថ្នាំពិណសលើធុងសម្រាមថា "ស្នាដៃជនរងគ្រោះ" [187]

នៅពេលសួរថាតើគាត់យកជំនាញទាំងនេះទៅប្រើនៅក្រៅមណ្ឌលឱកាសខ្ញុំទេ វិច្ឆិកាឆ្លើយថា :- "ខ្ញុំអត់មានលុយបើកធ្វើនៅខាងក្រៅមណ្ឌលឱកាសខ្ញុំទេ។ ខ្ញុំគ្មានមធ្យោបាយធ្វើដំណើរ ដើម្បីដើររកអតិថិជន។ ខ្ញុំត្រូវការលុយធ្វើដើមទុន ដើម្បីទិញឧបករណ៍សម្ភារៈ ទំនាក់ទំនងជាមួយអតិថិជន។ ពួកគេមិនបានឱ្យខ្ញុំការគាំទ្រផងទេ នៅពេលដែលខ្ញុំបានចេញពីមណ្ឌល" ។[188]

[187] អង្គការឃ្លាំមើលសិទ្ធិមនុស្ស សម្ភាសវិច្ឆិកា — ភ្នំពេញ ខែឧសភា ឆ្នាំ២០០៩

[188] អង្គការឃ្លាំមើលសិទ្ធិមនុស្ស សម្ភាសវិច្ឆិកា — ភ្នំពេញ ខែឧសភា ឆ្នាំ២០០៩




"ពួកខ្ញុំបាញ់ថ្នាំពណ៌លើធុងសម្រាមថា "ស្នាដៃជនរងគ្រោះ" ©អង្គការឃ្លាំមើលសិទ្ធិមនុស្ស ២០០៩

## ហ្វឹកហ្វឺនយោធាដោយបង្ខំ

បន្ថែមលើរបបហាត់ប្រាណដ៏តឹងរឹងនិងពលកម្ម អតីតអ្នកជាប់ឃុំឃាំងក៏រាយការណ៍ផង ដែរថា ពួកគេបានហ្វឹកហ្វឺនដើរជាក្បួនយោធា។ ម្ចាស់អាយុ១៦ឆ្នាំ បានរៀបរាប់អំពីការហ្វឹកហ្វឺន យោធានៅមណ្ឌល"ស្តារនីតិសម្បទា"សង្គមកិច្ចចោមចៅ ដូច្នេះថា :-

> យើងដើរក្បួន និងធ្វើដៃដូចជាយើងកាន់កាំភ្លើងដែរ។ ចលនានីមួយៗត្រូវឱ្យស្របគ្នា ដើរបណ្តើរ ច្រៀងចម្រៀងជាតិបណ្តើរ។ [ការហាត់ប្រាណ]គឺដូចជាកាន់កាំភ្លើង ដូចដើរក្បួនទ័ពអញ្ចឹង។ គេនិយាយដូចជា "បាទ! ទទួលបញ្ជា!"។ វាដូចជាការ ហាត់ប្រាណដែរ គឺធ្វើឱ្យបែកញើស... គេស្រែក"មួយ ពីរ មួយ ពីរ"។ ពេលគេ ស្រែកថា មួយ ត្រូវលើកជើងឆ្វេង បើស្រែកពីរ ត្រូវលើកជើងស្តាំ។ គេត្រូវធ្វើ ឱ្យព្រមគ្នាគ្រប់ជំហានទាំងអស់ ទាំងអ្នកខាងមុខនិងអ្នកខាងក្រោយ។ គេអត់ប្រាប់ ពួកខ្ញុំថាធ្វើ[ដើម្បីអ្វីផង]។[189]

ពុធបានរៀបរាប់អំពីលំហាត់យោធានៅក្នុងមណ្ឌលឱកាសខ្ញុំ ដូច្នេះថា :-

> យើងត្រូវឈរប្រុង នៅស្ងៀម បត់ឆ្វេង បត់ស្តាំ និងដើរជាក្បួន គោរពមេ។ ប្រសិនបើបត់ខុស គេនឹងទះកំផ្លៀងចំមុខ... ឬ ប្រសិនបើគេស្រែកថា"ប្រុង" ហើយយើងបត់ខ្លួននោះ ពិតជាត្រូវកំផ្លៀងហើយ [190]

---

[189] អង្គការឃ្លាំមើលសិទ្ធិមនុស្ស សម្ភាសម្ចាស់ — ភ្នំពេញ ខែមិថុនា ឆ្នាំ២០០៩

[190] អង្គការឃ្លាំមើលសិទ្ធិមនុស្ស សម្ភាសពុធ — ភ្នំពេញ ខែមេសា ឆ្នាំ២០០៩

អតីតអ្នកជាប់ឃុំឃាំង មានជំនឿច្បាស់ថា ការហ្វឹកហ្វឺនតាមបែបយោធានេះ គឺជារឿងអត់ប្រយោជន៍។ តាមសម្តីរបស់អង្គារ : "ពួកខ្ញុំត្រូវតែហ្វឹកហ្វឺនយោធា... វាជាការបង់ខាតពេលវេលា... ខ្ញុំធ្វើតាមតែគេប្រាប់ឱ្យធ្វើ ដូចជាឱ្យបត់ឆ្វេង បត់ស្តាំ បត់ក្រោយ ឈរប្រុង..."[191]

ដោយសារការហាត់ប្រាណមានជាប្រចាំថ្ងៃ ការចូលរួមនិងការអនុវត្តន៍ឱ្យបានត្រឹមត្រូវនៃការហ្វឹកហ្វឺនត្រូវបានពង្រឹងដោយការវាយដំ។

## ថ្នាក់រៀនជាក្រុម

អ្នកជាប់ឃុំឃាំងក៏ត្រូវចូលរួមក្នុងថ្នាក់រៀនជាក្រុមផងដែរ :- នៅក្នុងមណ្ឌលមួយចំនួនមានបង្រៀនក្នុងថ្នាក់ម្តងក្នុងមួយថ្ងៃ នៅមណ្ឌលផ្សេងទៀតប្រហែលពីរដងដែលគេហៅថា (អរុណសួស្តី និង សាយ័ន្តសួស្តី) ចំណែកនៅមណ្ឌលផ្សេងទៀត សកម្មភាពថ្នាក់រៀនមិនសូវទៀងទាត់ទេ។ ថ្នាក់បង្រៀនអំពីបញ្ហាគ្រឿងញៀន ការបង្រៀនទាមទារឱ្យអ្នកជាប់ឃុំឃាំងត្រូវផ្លាស់ប្តូរឥរិយាបទខ្លួន និងធ្វើការតិទៀនខ្លួនឯងផង និងតិទៀនអ្នកដទៃផង។

គុហា ជាអតីតអ្នកជាប់ឃុំឃាំងម្នាក់នៅមណ្ឌលកងរាជអាវុធហត្ថ រៀបរាប់សកម្មភាពថ្នាក់រៀនប្រចាំថ្ងៃរបស់ខ្លួនថា :-

> កងរាជអាវុធហត្ថម្នាក់គឺជាគ្រូបង្រៀន។ ពេលគាត់រវល់ ពួកខ្ញុំអត់បានរៀនទេ។ ចាប់រៀនពីម៉ោង២ដល់ម៉ោង៤ល្ងាច... ខ្ញុំចេះមាត្រាខ្លះ [ស្តីពីច្បាប់គ្រឿងញៀន] គ្រឿងញៀនបង្កឱ្យមានផលប៉ះពាល់លើស្មារតី រាងកាយ ផ្លូវចិត្ត។ វាបង្កផលប៉ះពាល់ដល់ថ្លើម វាបង្កឱ្យខូចប្រព័ន្ធសរសៃប្រាសាទ"។ ពួកខ្ញុំរៀនពី[បុគ្គលិក]។ គាត់

---

[191] អង្គការឃ្លាំមើលសិទ្ធិមនុស្ស សម្ភាសអង្គារ — ភ្នំពេញ ខែមេសា ឆ្នាំ២០០៩

លើកឡើងអំពីច្បាប់ថា ប្រសិនបើអ្នកណាម្នាក់បង្ករបួសស្នាមដល់អ្នកដទៃ ត្រូវជាប់ពន្ធនាគារពី១ទៅ៣ឆ្នាំ។ គាត់បានពន្យល់ដែរ អំពីផលប៉ះពាល់នៃការប្រើគ្រឿងញៀន ។[192]

កញ្ញារៀបរាប់អំពីការចូលថ្នាក់រៀននៅក្នុងមណ្ឌលឱកាសខ្ញុំ។ ថ្នាក់រៀន"អរុណសួស្តី" គឺដឹកនាំដោយមេបន្ទប់។ ពួកគេជជែកអំពីឥទ្ធិពលគ្រឿងញៀន និងអ្នកជាប់ឃុំឃាំងចាំបាច់ត្រូវ"កែប្រែ"ខ្លួនៈ-

> នៅក្នុងថ្នាក់ "ហ្គូតម័រនីញ" មេបន្ទប់និយាយប្រាប់អ្នកដែលចូលថ្មីពីព័ត៌មានដដែល១ដូចនៅក្នុងថ្នាក់ "អរុណសួរស្តី"ដែរ] ប្រសិនបើអ្នកណាម្នាក់នៅស្ងៀម ហើយខំស្តាប់អ្វីដែលគាត់និយាយ គឺមិនអីទេ។ ប្រសិនបើអ្នកណាម្នាក់ មិនយកចិត្តទុកដាក់ស្តាប់ គឺត្រូវគេវាយ។ [មេបន្ទប់]ថាឡើងវិញដដែលតាមអ្វីដែល[បុគ្គលិក]បាននិយាយហើយ ដូចជា"នៅខាងក្រៅ មិត្តប្រើគ្រឿងញៀន តែឥឡូវត្រូវឈប់ប្រើវា។ មិត្តត្រូវរកការងារធ្វើ និងមិនត្រូវវាយគ្រួសារ"។ គាត់និយាយដដែល១រាល់ថ្ងៃ... អ្នកដែលមិនស្តាប់ គឺត្រូវគេវាយ ។[193]

## អាហារ

អតីតអ្នកជាប់ឃុំឃាំង បាននិយាយប្រាប់អង្គការឃ្លាំមើលសិទ្ធិមនុស្ស អំពីគុណភាពនិងបរិមាណអាហារដែលបានផ្តល់ឱ្យពួកគេ។ ជាទូទៅអ្នកជាប់ឃុំឃាំង ទទួលបានរបបអាហារបីដងក្នុងមួយថ្ងៃ ប៉ុន្តែអ្នកជាប់ឃុំឃាំងជាច្រើន បានរាយការណ៍ថាពួកគេទទួលបានចំនួនអាហារមិនគ្រប់គ្រាន់ទេ ហើយថាពួកគេស្រេកឃ្លានជាញឹកញាប់។ អាហារដែលផ្តល់នោះ ច្រើនតែខូចនិងមានសត្វ

---

[192] អង្គការឃ្លាំមើលសិទ្ធិមនុស្ស សម្ភាសគុហា — កម្ពុជា ខែកក្កដា ឆ្នាំ២០០៩

[193] អង្គការឃ្លាំមើលសិទ្ធិមនុស្ស សម្ភាសកញ្ញា — ភ្នំពេញ ខែឧសភា ឆ្នាំ២០០៩

ល្អិតជាប់ជាមួយ។ វាហាក់ដូចជាមានកង្វះខាតកាឡូរីនិងជីវជាតិយ៉ាងច្រើន ជាពិសេសដោយសារលំហាត់ប្រាណ និងរបបពលកម្មនៅក្នុងមជ្ឈមណ្ឌល។ ការរាយការណ៍ពីរបបអាហារមិនគ្រប់គ្រាន់មានជាទូទៅចំពោះអ្នកជាប់ឃុំ ដែលគ្មានឪពុកម្ដាយបង់ប្រាក់សម្រាប់ការចាប់ខ្លួន និងការឃុំខ្លួន។ អ្នកជាប់ឃុំឃាំងបានរាយការណ៍អំពីរោគសញ្ញាដូចជាស្ពឹកនិងហើម ដែលស្របគ្នាទៅនឹងជំងឺបណ្ដាលមកពីកង្វះជីវជាតិអាហារ។

សារិកាបានរៀបរាប់អំពីអាហារថា "គ្មានជាតិ។ ពួកខ្ញុំហូបបបរពេលព្រឹក មានពងរុយ និងដង្កូវ...។"[194] តាមសម្ដីរបស់ស្រកានាគ បាននិយាយថា :-

> ម្ដងឬពីរដងក្នុងមួយអាទិត្យ គេដាំបបរ [សម្រាប់អាហារពេលព្រឹក]។ ក្រោយមកមានបាយនិងសម្ល... សម្រាប់បាយថ្ងៃត្រង់និងពេលល្ងាច។ អត់មានជាតិទេ សុទ្ធតែទឹក ហើយអត់បន្លែ។ ខ្ញុំមិនដែលបានហូបឆ្អែតទេ គឺឆ្អែតតែមួយភ្លែតហើយចាប់ឃ្លានទៀត។[195]

ចំពោះអ្នកជាប់ឃុំឃាំងណាដែលមានឪពុកម្ដាយយកចិត្តទុកដាក់ ពួកគេជួយបំពេញបន្ថែមរបបអាហារឱ្យ ដោយឱ្យមណ្ឌលចំអិន។ តាមសម្ដីរបស់ពុទ្រា :-

> សម្លដូចបាយជ្រូកអញ្ចឹង។ នៅពេលព្រឹក ពួកខ្ញុំហូបបបរជាមួយសៀង។ ពួកខ្ញុំឃ្លានអង្គុយក្នុងបន្ទប់។ ពេលថ្ងៃត្រង់យើងហូបបាយនិងសម្ល... បន្លែនៅក្នុងសម្លគឺពិបាកនិយាយ។ យើងហូបបន្លែដែលដាំខ្លួនឯង មានត្រកួន និងសណ្ដែកកួរ។ បន្លែមិនល្អ ពេលខ្លះមានដង្កូវអណ្ដែកក្នុងសម្ល។ អាហារពេលល្ងាចគឺដូចគ្នា...ចំណែក

194 អង្គការឃ្លាំមើលសិទ្ធិមនុស្ស សម្ភាសសារិកា — ភ្នំពេញ ខែមិថុនា ឆ្នាំ២០០៩

195 អង្គការឃ្លាំមើលសិទ្ធិមនុស្ស សម្ភាសស្រកានាគ — ភ្នំពេញ ខែមិថុនា ឆ្នាំ២០០៩

កូនអ្នកមានហូបអាហារផ្សេង :- ពួកគេមានត្រីងៀត មី សាច់គោ សាច់មាន់។ ឪពុកម្តាយគេបានទិញសាច់នៅពីក្រៅ និងឱ្យទៅចុងភៅក្នុងមណ្ឌលចំអិនឱ្យ។ ឪពុកម្តាយទាំងនោះចេញលុយសម្រាប់ចំអិនអាហារនោះ។[196]

ឪពុកម្តាយរបស់មករា បានផ្ញើរបបអាហារឱ្យគាត់អំឡុងពេលជាប់ឃុំឃាំង។ គាត់បាននិយាយថាអ្នកដែលជាប់ឃុំឃាំងដែលហូបតែអាហារផ្តល់ដោយមណ្ឌលនោះ បានមកសុំពីគាត់:-

ពួកគេទាំងនោះ[អ្នកជាប់ឃុំឃាំង] ដែលគ្មានឪពុកម្តាយ គឺពិបាកហើយ។ ពួកវាមើលខ្ញុំហូបបាយ។ របបអាហារនៅមណ្ឌលឱកាសខ្ញុំមិនគ្រប់គ្រាន់ទេ :- ពួកគេហូបអត់គ្រប់គ្រាន់ទេ។ អ្នកដែលមានឪពុកម្តាយ មានមី ស្ករគ្រាប់ នំសម្រាប់ អាហារបន្ថែម... ចំណែកអ្នកផ្សេង ស្រេកឃ្លានពេលដែលឃើញកូនអ្នកមានហូបអាហារ។ អ្នកដែលត្រូវចាប់ខ្លួន អង្គុយសម្លឹងមើលខ្ញុំហូបហើយខ្ញុំក៏ចែក[អាហាររបស់ខ្ញុំ]ឱ្យ។ ពួកគេថា"ខ្ញុំសុំហូបផងបានទេ?" ខ្ញុំក៏ហុចឱ្យគេទៅ។[197]

អ្នកជាប់ឃុំឃាំងមួយចំនួន បាននិយាយដល់រោគសញ្ញា"ស្លឹកនិងហើម" ក្នុងចំណោមអ្នកជាប់ឃុំឃាំង។ អាទិត្យបានពន្យល់អំពីសភាពនោះនៅមណ្ឌលឱកាសខ្ញុំ ដូច្នេះថា :-

ជើងរបស់ខ្ញុំឡើងហើម ខ្លួនហើមពេញទាំងអស់រហូតដល់មុខ។ គឺដោយសារតែអាហារគ្មានជាតិ។ អ្នកដែលមានគ្រួសារយកអាហារមកឱ្យ គេអត់ហើមទេ។ ប៉ុន្តែបើគ្មានគ្រួសារយកមកឱ្យទេ គេហើម... អាហារគឺសម្លបន្លែរាល់ថ្ងៃ... ពីព្រោះខ្ញុំគ្មានអាហារផ្សេងទៀត[ពីឪពុកម្តាយខ្ញុំ] ខ្ញុំហូបតែសម្លមួយមុខគត់។ អ្នកផ្សេង

---

196 អង្គការឃ្លាំមើលសិទ្ធិមនុស្ស សម្ភាសពុទ្រា — ភ្នំពេញ ខែឧសភា ឆ្នាំ២០០៩

197 អង្គការឃ្លាំមើលសិទ្ធិមនុស្ស សម្ភាសមករា — ភ្នំពេញ ខែឧសភា ឆ្នាំ២០០៩

ទៀតជាច្រើនហើមដូចខ្ញុំដែរ ។ ដោយសារហើមខ្លាំងពេក ខ្ញុំដើរលែងរួច ហើយ នឿយហត់ ។[198]

ប៉ុកបានរាយការណ៍រោគសញ្ញាដែលស្រដៀងគ្នា ខណៈពេលជាប់ឃុំឃាំងនៅមណ្ឌលគ្រប់គ្រងដោយស្នងការនគរបាលខេត្ត នៅស្រុកបវេល ដូច្នេះថា :-

ដំបូងខ្ញុំចាប់ផ្តើមស្ពឹកជើង ។ ខ្ញុំព្យាយាមក្រោកឈរតែមិនរួច ។ ពេលក្រោកឈរម្តងៗ ខ្ញុំប្រើដៃទាញបង្អួច ឬទ្វារ ។ ខ្ញុំនៅតែដើរមិនបាន... មានមនុស្សប្រហែល ២០ នាក់មានជំងឺនេះ[ពេលខ្ញុំជាប់នៅទីនោះ]... ។[199]

អង្គារ ដែលជាប់ឃុំឃាំងរយៈពេលពន្យាបន្ថែមនៅក្នុងឆ្នាំ២០០៨ នៅមណ្ឌលឱកាសខ្ញុំ បាន រាយការណ៍អំពីរោគសញ្ញាដូចគ្នា អំពីការស្ពឹកនិងហើម ក្នុងអំឡុងពេលឃុំខ្លួនរបស់គាត់ ។ នៅពេលអង្គការឃ្លាំមើលសិទ្ធិមនុស្សធ្វើសម្ភាស គាត់នៅដើរខ្ញើចនៅឡើយបន្ទាប់ពីត្រូវបានដោះលែងរយៈពេលពីរខែក្រោយមក ។ គាត់បានពន្យល់ថា :-

សម្លមិនកើតទេ ។ ចង្ក្រានកខ្វក់ ហើយអាហារគ្មានរស់ជាតិ ។ អត់មានត្រីនៅក្នុងសម្លទេ ហើយបាយក៏អាក្រក់ទៀត ។ ជើងខ្ញុំឡើងហើម... នៅក្នុងមណ្ឌល មានអ្នកជាច្រើនដែលហើមជើងដោយសារសម្លរស់ជាតិសាប ។ អាហារដែលគេចំអិន គឺពិបាកហូប ។ នៅក្រៅមណ្ឌល ប្រសិនបើយើងឃើញអាហារបែបហ្នឹង ក៏យើងមិនហូបដែរ... កខ្វក់ណាស់ មានម្នាក់ហើមទាំងជើង គឺហើមពេញខ្លួន ។ ហើម... ខ្ញុំកំរើកជើងលែងកើតហើយ ។ ខ្ញុំស្រកហើមវិញហើយ ប៉ុន្តែជើងនិងម្រាមជើងនៅស្ពឹកដដែល ។[200]

---

198 អង្គការឃ្លាំមើលសិទ្ធិមនុស្ស សម្ភាសអាទិត្យ — ភ្នំពេញ ខែមេសា ឆ្នាំ២០០៩

199 អង្គការឃ្លាំមើលសិទ្ធិមនុស្ស សម្ភាសប៉ុក — បាត់ដំបង ខែមិថុនា ឆ្នាំ២០០៩

ទ្រឹស្តីសន្និដ្ឋានមួយបង្ហាញថា រោគសញ្ញា "ស្ពឹកនិងហើម" ទាំងនេះគឺបញ្ជាក់អំពីករណីរោគស្ពឹក ។ រោគស្ពឹកគឺជារោគដែលធ្វើឱ្យប៉ះពាល់ដល់ប្រព័ន្ធសរសៃប្រសាទ ដែលបណ្តាលមកពីកង្វះខាតជាតិស៊ីយ៉ាមីន (thiamine) (វីតាមីន បេ១) ។ ករណីវិវឌ្ឍទៅមុខ នឹងអាចបង្កឱ្យស្លាប់បាន ។ វេជ្ជបណ្ឌិតដែលធ្វើការជាមួយភ្នាក់ងារអ.ស.ប បានចុះទស្សនៈកិច្ចមជ្ឈមណ្ឌលចំនួនបីនៅពាក់កណ្តាលឆ្នាំ២០០៨ ។ លោកវេជ្ជបណ្ឌិតរូបនោះ បាននិយាយថាអ្នកជាប់ឃុំឃាំងប្រហែល ១០-២៥ភាគរយ ក្នុងចំណោមមជ្ឈមណ្ឌលទាំងបីដែលគាត់បានចុះមើលនោះ បានរាយការណ៍ដោយផ្ទាល់អំពី "ការស្ពឹកនិងហើម" ដែលក្នុងករណីខ្លះធ្ងន់ធ្ងរខ្លាំងពេកធ្វើឱ្យរំខានដល់ការដើរនិងឈរឱ្យត្រង់ ។ វេជ្ជបណ្ឌិតបានឱ្យទ្រឹស្តីសន្និដ្ឋានថា ការស្ពឹកនិងហើមអាចជាជំងឺស្ពឹក ។ [201] ទោះបីការវិនិច្ឆ័យព្យាបាលជំងឺស្ពឹកមិនអាចធ្វើទៅបានក្នុងកាលៈទេសៈនោះក៏ដោយ គាត់បាននិយាយប្រាប់អង្គការឃ្លាំមើលសិទ្ធិមនុស្សថា :- "ខ្ញុំបានសង្កេតឃើញអត្រា "ស្ពឹកនិងហើម" ដែលគេរាយការណ៍នោះ ហាក់ដូចជាកើតស្របគ្នាទៅនឹងកង្វះជាតិស៊ីយ៉ាមីន ហើយជាបុព្វហេតុដែលអាចជឿបានថាមកពីការផ្តល់អាហារដ៏ខ្សត់ខ្សោយនៅក្នុងមជ្ឈមណ្ឌល" ។[202]

## បទដ្ឋានអនុវត្តន៍

## ការព្យាបាលគ្រឿងញៀន

---

[200] អង្គការឃ្លាំមើលសិទ្ធិមនុស្ស សម្ភាសអង្ការ — ភ្នំពេញ ខែមេសា ឆ្នាំ២០០៩

[201] រោគស្ពឹកដែលបណ្តាលមកពីកង្វះជីវជាតិអាហារ គឺជាជំងឺដ៏សាមញ្ញបំផុត ដែលមានយូរយារមកហើយនៅក្នុងពន្ធនាគារប្រទេសកម្ពុជា ។ ការស្ពឹកគឺជារោគសញ្ញាសំខាន់ដែលអ្នកជំងឺតែងតែរាយការណ៍ ។ សូមអានរបាយការណ៍អង្គការលីកាដូ "ស្ថានភាពពន្ធនាគារក្នុងប្រទេសកម្ពុជា ឆ្នាំ២០០៨ : ស្ត្រីនៅក្នុងពន្ធនាគារ " ឆ្នាំ២០០៨ ទំព័រ១៩ — គេហទំព័រ www.licadho-cambodia.org/reports/files/129LICADHOPrisonWomen2008ENG.pdf ។ អ្នកស្រាវជ្រាវបានកត់សម្គាល់ការផ្ទុះនៃរោគស្ពឹកនេះនៅក្នុងមជ្ឈមណ្ឌលឃុំឃាំងគ្រឿងញៀនមួយនៅប្រទេសម៉ាឡេស៊ី នៅ **Pusat Serenti Bukit Cabang, Perlis** ក្នុងខែកុម្ភៈ ២០០៤ ។ "ការផ្ទុះរោគនេះត្រូវបានកត់សម្គាល់ បន្ទាប់ពីបង្ហាញចំនួនអ្នកទោសដ៏ច្រើននៅមជ្ឈមណ្ឌលសុខភាពមួយ ដោយរោគសញ្ញាមានជាតិទឹកនៅក្រោមស្បែកកជើងដ៏មិនធម្មតា និងមានដង្ហើមខ្លី... ការផ្ទុះនេះអាចបណ្តាលមកពីកង្វះខាតអាហារជាតិស៊ីយ៉ាមីន ដែលទទួលដោយអ្នកទោស ដោយរួមផ្សំជាមួយនឹងសារធាតុប្រឆាំងនឹងវីតាមីនស៊ីយ៉ាមីន ដែលមាននៅក្នុងអាហាររបស់ពួកគេ" ហ្វូស៊ី អាមុី កាម៉ារៀ (**Fozi K, Azmi H, Kamariah H, Azwa MS**) "អត្រានៃកង្វះខាតជីវជាតិវីតាមីនប្រភេទស៊ីយ៉ាមីន នៅមជ្ឈមណ្ឌលស្តារនីតិសម្បទាគ្រឿងញៀនមួយក្នុងប្រទេសម៉ាឡេស៊ី" ***Med J Malaysia*, 61(5)** ( ធ្នូ ២០០៦) ទំព័រ ៥១៩-២៥

[202] អង្គការឃ្លាំមើលសិទ្ធិមនុស្ស សម្ភាសមន្ត្រីភ្នាក់ងារ អ.ស.ប — ខែមីនា ឆ្នាំ២០០៩

អង្គកាសុខភាពពិភពលោកចាត់ទុកថា ការញៀននឹងសារធាតុមិនមែនជាបរាជ័យផ្នែកឆន្ទៈ ឬកម្លាំងចរិតលក្ខណៈទេ ប៉ុន្តែវាជាស្ថានភាពវេជ្ជសាស្ត្រដែលលាប់ធ្ងន់ធ្ងរ ដោយមានមូលដ្ឋានសរីរវិទ្យានិងពន្ធុ ដែលអាចជះឥទ្ធិពលមកលើមនុស្សណាម្នាក់។[203] អង្គការសុខភាពពិភពលោក និងការិយាល័យគ្រឿងញៀន និងឧក្រិដ្ឋកម្មរបស់អ.ស.ប ធ្វើការកត់សម្គាល់ថា :-

> បទដ្ឋានដដែលអំពីការព្យាបាលប្រកបដោយក្រមសីលធម៌ គួរអនុវត្តសម្រាប់ការព្យាបាលនៃការញៀនគ្រឿងញៀនឱ្យដូចគ្នាទៅនឹងស្ថានភាពថែទាំងសុខភាពដទៃទៀតដែរ។ ទាំងនេះរួមមានសិទ្ធិស្វ័យភាពនិងសិទ្ធិស្វ័យសម្រេចលើផ្នែករបស់អ្នកជំងឺ និងកាតព្វកិច្ចធ្វើអំពើល្អជួយអ្នកដទៃ និងមិនធ្វើអំពើអាក្រក់ចំពោះអ្នកដទៃក្នុងនាមជាបុគ្គលិកព្យាបាល។[204]

ការបង្ខំមនុស្សឱ្យទទួលការព្យាបាល ជាធម្មតានិង*ជារួម* ពាក់ព័ន្ធនឹងការរំលោភសិទ្ធិមនុស្សយ៉ាងច្រើនមកលើអ្នកដែលទទួលរងនូវវិធានការទាំងអស់នេះ។

គណៈកម្មាធិការស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ បានបញ្ជាក់ថា គ្រឹះស្ថានសុខភាពរបស់រដ្ឋ ផលិតផល និងសេវាកម្ម ត្រូវតែអាចរកបាន អាចទទួលយកបាន អាចប្រើប្រាស់បានហើយមានគុណភាពល្អផង។[205] ទោះជាយ៉ាងណាក្តី អង្គការសុខភាពពិភពលោក

---

[203] អង្គការសុខភាពពិភពលោក "វិទ្យាសាស្ត្រសរសៃប្រសាទអំពីការប្រើនិងការញៀនសារធាតុចិត្តសកម្ម" www.who.int/substance_abuse/publications/en/Neuroscience_E.pdf· សូមមើលរបាយការណ៍របស់អង្គការសុខភាពពិភពលោក "ការគ្រប់គ្រងនៃការញៀនសារធាតុញៀន" ខិត្តប័ណ្ណព័ត៌មាន ២០០៣។ សូមមើលគេហទំព័រ **www.who.int/substance_abuse.**

[204] ការិយាល័យគ្រឿងញៀន និងឧក្រិដ្ឋកម្មអ.ស.ប/អង្គការសុខភាពពីភពលោក "គោលការណ៍នៃការព្យាបាលការញៀនគ្រឿងញៀន" ទំព័រ៩

[205] គណៈកម្មាធិការស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ គឺជាស្ថាប័នអ.ស.ប ដែលទទួលខុសត្រូវលើការពិនិត្យការអនុវត្តន៍តាមកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និវប្បធម៌ (G.A. res. 2200A (XXI), U.N. Doc. A/6316 (1966) ចូលជាធរមាននៅថ្ងៃទី៣ ខែមករា ១៩៧៦ ហើយកម្ពុជាបានផ្តល់សច្ចាប័ននៅថ្ងៃទី២៦ ខែឧសភា ឆ្នាំ១៩៩២។ គណៈកម្មាធិការស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌របស់អ.ស.ប បទអត្ថាធិប្បាយលេខ១៤ : សិទ្ធិទទួលបានបទដ្ឋានសុខភាពខ្ពស់បំផុត- ថ្ងៃទី៨ វិច្ឆិកា ២០០០ — កថាខ័ណ្ឌ១២

និងការិយាល័យគ្រឿងញៀននិងឧក្រិដ្ឋកម្មអ.ស.ប ធ្វើការកត់សម្គាល់ថា "ការឃុំខ្លួនក្តី ឬពលកម្មដោយបង្ខំក្តី មិនត្រូវបានគេទទួលស្គាល់ដោយវិទ្យាសាស្រ្តថាសម្រាប់ព្យាបាលដំណើរវិបល្លាសនៃការប្រើគ្រឿងញៀនទេ"។[206] ដូចគ្នានេះដែរ ការហាត់ប្រាណដោយបង្ខំក្តី ឬការហ្វឹកហ្វឺនយោធាក្តី ក៏មិនត្រូវបានគេទទួលស្គាល់ ដោយវិទ្យាសាស្រ្តថាជាទម្រង់សម្រាប់ព្យាបាលដែរ។ ការបង្ខំប្រជាពលរដ្ឋឱ្យធ្វើការ "ព្យាបាល" ដែលបានសន្មត់ដោយគ្មានផ្អែកលើភស្តុតាងនោះ អាចរំលោភលើល័ក្ខខ័ណ្ឌដែលតម្រូវឱ្យគ្រឹះស្ថានសុខភាព មានទំនិញ និងសេវាដែលអាចទទួលយកបានប្រកបដោយសីលធម៌និងវប្បធម៌ និងសមស្របតាមវិទ្យាសាស្រ្តនិងវេជ្ជសាស្រ្ត ហើយមានគុណភាពល្អ។

នៅពេល "ការព្យាបាល" និង "ស្តារនីតិសម្បទា" ដែលបានសន្មត់នោះពាក់ព័ន្ធក្នុងការឃុំខ្លួនប្រព័ន្ធបែបនេះ ក៏រំលោភលើសិទ្ធិផ្សេងៗមួយចំនួនទៀត ដូចជាសេរីភាពពីការឃុំខ្លួនតាមអំពើចិត្ត។ លើសពីនេះ នៅពេល "ការព្យាបាល" និង "ស្តារនីតិសម្បទា" ដែលបានសន្មត់ ពាក់ព័ន្ធក្នុងការងារពលកម្មដោយបង្ខំ ដែលមិនផ្តល់ផលប្រយោជន៍ដល់អ្នកជាប់ឃុំឃាំង ឬដែលមានលក្ខណៈរំលោភបំពាននោះ ប្រព័ន្ធបែបនេះក៏រំលោភលើការហាមឃាត់លើពលកម្មដោយបង្ខិតបង្ខំ ដោយបានដាក់តំកល់ក្នុងលិខិតុបករណ៍អន្តរជាតិស្តីពីសិទ្ធិមនុស្សផ្សេងៗ។[207]

ការហាមឃាត់លើពលកម្មដោយបង្ខិតបង្ខំ នៅក្នុងច្បាប់អន្តរជាតិ មិនរាប់បញ្ចូល "ការងារ ឬសេវាដែលគេតម្រូវពីជនណាម្នាក់ ដោយសារដាក់ទោសពីតុលាការ និងក្នុងល័ក្ខខ័ណ្ឌដែលថាការងារនោះ ឬសេវាកម្មនោះ បានអនុវត្តនៅក្រោមការត្រួតពិនិត្យ ឬឃ្លាំមើលពីអាជ្ញាធរសាធារណៈ និងឱ្យតែជននោះមិនត្រូវបានគេជួល ឬដាក់ឱ្យធ្វើការឱ្យបុគ្គលក្រុមហ៊ុន ឬ សមាគម

---

206 ការិយាល័យគ្រឿងញៀន និងឧក្រិដ្ឋកម្មអ.ស.ប/អង្គការសុខភាពពិភពលោក "គោលការណ៍នៃការព្យាបាលការញៀនគ្រឿងញៀន" ទំព័រ១៤

207 សូមមើលមាត្រា ៤ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងមាត្រា ៨ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ និងអនុសញ្ញាស្តីពីការងារដោយបង្ខំរបស់អង្គការពលកម្មអន្តរជាតិ ឆ្នាំ១៩៣០។ អនុសញ្ញាអង្គការពលកម្មអន្តរជាតិ លេខ២៩ (អនុសញ្ញាស្តីពីការងារដោយបង្ខំ) ឱ្យនិយមន័យការងារដោយបង្ខំ ថា "រាល់ការងារ ឬសេវាកម្មណា ដែលតម្រូវឱ្យជនណាម្នាក់ធ្វើដោយការគំរាមកំហែងថានឹងដាក់ទណ្ឌកម្មណាមួយ ហើយដែលជននោះមិនបានស្ម័គ្រចិត្តធ្វើដោយខ្លួនឯងផងទេ": អនុសញ្ញាស្តីពីការងារដោយបង្ខំ — ឆ្នាំ១៩៣០ មាត្រា ២(១)

ឯកជននានា"។ [208] តែទោះជាយ៉ាងណាក៏ដោយ អ្នកដែលត្រូវឃុំឃាំងនៅក្នុងមជ្ឈមណ្ឌលឃុំឃាំងគ្រឿងញៀនប្រទេសកម្ពុជា មិនត្រូវបានគេបញ្ជាឱ្យធ្វើពលកម្ម ដែលជាផ្នែកនៃការទទួលទោសរបស់ខ្លួនទេ។ លើសពីនេះទៀតនោះ អ្នកខ្លះរាយការណ៍អំពីការងារធ្វើនៅតាមគម្រោងរបស់ឯកជន ជាក់ស្តែងនៅជុំវិញទីក្រុងភ្នំពេញ ឬការដ្ឋានសំណង់ ដែលជាកម្មសិទ្ធរបស់បុគ្គលិក។

បទបញ្ញត្តិជាបទដ្ឋានអប្បរិមារបស់ អ.ស.ប សម្រាប់គ្រប់គ្រងអ្នកទោសចែងថា ការងារដែលដាក់ឱ្យធ្វើ ត្រូវធ្វើដើម្បីផលប្រយោជន៍របស់អ្នកទោស និងថាការងារនោះមិនត្រូវមានបំណងកេងចំណេញខាងហិរញ្ញវត្ថុ សម្រាប់ស្ថាប័នឡើយ។[209]

ស្ថិតក្រោមកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ រដ្ឋាភិបាលត្រូវផ្តល់"ការថែទាំងសុខភាពគ្រប់គ្រាន់អំឡុងពេលជាប់ឃុំឃាំង"។ [210] អតីតអ្នកជាប់ឃុំឃាំង បានរាយការណ៍ប្រាប់អង្គការឃ្លាំមើលសិទ្ធិមនុស្សថា ពួកគេត្រូវបានបង្ខំឱ្យអនុវត្តលំហាត់ប្រាណយ៉ាងហត់នឿយ ធ្វើការនិងដើរក្បួនយោធា។ ពួកគេក៏បានរាយការណ៍ដែរអំពីទណ្ឌកម្មដ៏ធ្ងន់ធ្ងរ ដោយសារមិនអាចបំពេញនូវភារកិច្ចទាំងនេះ។

ផ្នែកនៃ"ការព្យាបាល"និង"ស្តារនីតិសម្បទា" ដែលសន្មត់នោះក៏អាចចាត់ទុកថា

---

[208] អនុសញ្ញាស្តីពីការងារដោយបង្ខំ — ឆ្នាំ១៩៣០ មាត្រា២(១)(ឃ)។ កម្ពុជាបានផ្តល់សច្ចាប័នលើអនុសញ្ញានេះនៅថ្ងៃទី ២៤ ខែកុម្ភៈ ១៩៦៩។ សូមមើលកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ មាត្រា៨(៣)(គ)(i) ម៉ាន់ហ្វ្រេត ណូវ៉ាក់ (**Manfred Nowak, ICCPR Commentary, 2nd ed., (Kehl: NP Engel, 2005), p. 204-05**) បទអត្ថាធិប្បាយអំពីកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។

[209] បទបញ្ញត្តិជាបទដ្ឋានអប្បរិមារបស់ អ.ស.ប សម្រាប់គ្រប់គ្រងអ្នកទោស វិធាន ៧២ (២)។ បទបញ្ញត្តិជាបទដ្ឋានអប្បរិមា ត្រូវបានបញ្ចូលក្នុងក្រម ព្រហ្មទណ្ឌប្រទេសកម្ពុជា។ មាត្រា ១២.២ នៃក្រមព្រហ្មទណ្ឌអ៊ុនតាក់ (បទបញ្ញត្តិដែលទាក់ទងទៅនឹងប្រព័ន្ធតុលាការ ច្បាប់ព្រហ្មទណ្ឌ និងនីតិវិធីព្រហ្មទណ្ឌ សម្រាប់អនុវត្តន៍នៅកម្ពុជាក្នុងសម័យអន្តរកាល ថ្ងៃទី១០ ខែកញ្ញា ឆ្នាំ១៩៩២) បញ្ជាក់ថាការឃុំខ្លួន ត្រូវតែគោរពតាមបញ្ញត្តិជាបទដ្ឋានអប្បរិមារបស់ អ.ស.ប

[210] Pinto v. Trinidad and Tobago (Communication No. 232/1987) របាយការណ៍របស់គណៈកម្មាធិការសិទ្ធិមនុស្ស vol. 2, U.N. Doc A/45/40, p. 69.

ជាប្រព្រឹត្តកម្ម ឬទណ្ឌកម្មអមនុស្សធម៌ ឬបន្ថោកបន្ទាប។ ឧទាហរណ៍ អ្នករាយការណ៍ការពិសេសរបស់ អ.ស.ប ស្តីពីទារុណកម្ម បានបញ្ជាក់ថាការអប់រំឡើងវិញតាមរយៈប្រព័ន្ធពលកម្មនៅក្នុងប្រទេសចិន

> និងវិធីសាស្ត្រដូចគ្នាទៅនឹងការអប់រំឡើងវិញនៅក្នុងពន្ធនាគារ មជ្ឈមណ្ឌលឃុំឃាំងបណ្តោះអាសន្នមុនការកាត់ទោស និងស្ថាប័នរបស់ពួកគេ... អាចត្រូវបានចាត់ទុកថាជាទម្រង់មួយនៃប្រព្រឹត្តកម្ម ឬទណ្ឌកម្មដែលអមនុស្សធម៌ ឬបន្ថោកបន្ទាប ប្រសិនបើពុំមែនជាទារុណកម្មផ្លូវចិត្ត។[211]

ប្រព័ន្ធនៃការ"ព្យាបាល" និង "ស្តារនីតិសម្បទា"ដែលសន្មត់នោះ បង្ខំឱ្យមនុស្សចូលធ្វើការព្យាបាល ជាទម្រង់ការនិង*ជារួម* ប្រព័ន្ធបែបនេះរំលោភលើបទដ្ឋានអន្តរជាតិស្តីពីសិទ្ធិមនុស្ស ព្រោះថាការព្យាបាលតាមវេជ្ជសាស្ត្រ ត្រូវផ្អែកលើការព្រមព្រៀងគ្នានិងឥតគិតថ្លៃ។ អ្នករាយការណ៍ពិសេស បានបញ្ជាក់ថា :-

> ការព្រមព្រៀងគ្នា មិនគ្រាន់តែជាការទទួលយកបទអន្តរាគមន៍តាមវេជ្ជសាស្ត្រប៉ុណ្ណោះទេ ក៏ប៉ុន្តែវាជាការសម្រេចចិត្តដោយស្ម័គ្រចិត្ត ហើយប្រាប់ឱ្យដឹង សព្វគ្រប់ក្នុងការការពារសិទ្ធិអ្នកជំងឺដែលពាក់ព័ន្ធក្នុងការធ្វើសេចក្តីសម្រេចផ្នែក វេជ្ជសាស្ត្រ និងប្រគល់ភារកិច្ចផ្សារភ្ជាប់ និងកាតព្វកិច្ចដល់អ្នកផ្តល់សេវាថែទាំងសុខភាព។ យុត្តិកម្មខាងសីលធម៌និងទម្រង់ការច្បាប់ កើតឡើងចេញពីការធ្វើជំរឿននៃស្វ័យភាពរបស់អ្នកជំងឺ សិទ្ធិស្វ័យសម្រេច បូរណាភាពរាងកាយ និងសុខមាលភាព។[212]

---

[211] គណៈកម្មាធិការអ.ស.ប ស្តីពីសិទ្ធិមនុស្ស "របាយការណ៍របស់អ្នករាយការណ៍ពិសេស ស្តីពីទារុណកម្ម និងប្រព្រឹត្តកម្ម ឬទណ្ឌកម្មដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប :- បេសកកម្មទៅកាន់ប្រទេសចិន " E/CN.4/2006/6/Add.6, ថ្ងៃទី១០ ខែមីនា ២00៦ កថាខ័ណ្ឌ ៦៤ ៨២ (u).

[212] អ្នករាយការណ៍ពិសេស ស្តីពីសិទ្ធិទទួលបានសុខភាព "របាយការណ៍ ដាក់ជូនមហាសន្និបាត — ថ្ងៃទី១០ ខែសីហា ២00៩" A/64/272, កថាខ័ណ្ឌ៩

សិទ្ធិទទួលបានសុខភាព រួមមានគោលការណ៍ព្យាបាលបន្ទាប់ពីការព្រមព្រៀងគ្នា គណៈកម្មាធិការស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ បានបកស្រាយមាត្រា១២ ដើម្បីបញ្ចូល "សិទ្ធិមានសេរីភាពពី... ការព្យាបាលវេជ្ជសាស្ត្រដែលគ្មានការព្រមព្រៀងគ្នា និងធ្វើពិសោធន៍"[213]

តាមពិត ការស្រាវជ្រាវវេជ្ជសាស្ត្រពីបណ្តាប្រទេសផ្សេងៗ បានចោទជាសំណួរអំពីប្រសិទ្ធិភាពនៃការព្យាបាលគ្រឿងញៀនដោយបង្ខំ។ ការស្រាវជ្រាវខ្លះលើកឡើងថា ការខ្វះខាតឆន្ទៈខាងក្នុងរបស់អតិថិជនក្នុងការព្យាបាល អាចធ្វើឱ្យខូចលទ្ធផលជាវិជ្ជមាន។[214] ជាពិសេសទាក់ទងទៅនឹងការព្យាបាលការការញៀនថ្នាំមេតំហ្វេតាមីន ការស្រាវជ្រាវខ្លះបានបង្ហាញថា ការព្យាបាលដោយបង្ខិតបង្ខំ គឺមានអត្រាលាប់ឡើងវិញខ្ពស់ជាងអត្រាព្យាបាលដោយស្ម័គ្រចិត្ត។[215] ការពិនិត្យមើលដោយឯករាជ្យទៅលើប្រព័ន្ធព្យាបាលគ្រឿងញៀនដោយបង្ខិតបង្ខំរបស់ប្រទេសវៀតណាមបានរកឃើញថាវាគ្មានប្រសិទ្ធិភាពទេ ហើយថាអត្រាដែលលាប់ទៅរកការប្រើគ្រឿងញៀនឡើងវិញរបស់អតីតអ្នកជាប់ឃុំឃាំង គឺមានប្រហែល៩០ភាគរយ។[216]

គណៈកម្មាធិការស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ បានធ្វើការកត់សម្គាល់ថា កាតព្វកិច្ចរបស់រដ្ឋ ដែលត្រូវគោរពសិទ្ធិទទួលបានសុខភាព រួមមានកាតព្វកិច្ចត្រូវជៀសវាងការអនុវត្តន៍

---

213 បទអត្ថាធិប្បាយទូទៅ — លេខ១៤ កថាខ័ណ្ឌ៣៤

214 ធី វ៉ាយ អេ អាល (T. Wild et al) "ការបង្ខំដែលគេបានដឹងក្នុងចំណោមអតិថិជនដែលចូលព្យាបាលការរំលោភសារធាតុញៀន :- កត្តាកំណត់រចនាសម្ព័ន្ធនិងចិត្តសាស្ត្រ" *ឥរិយាបទញៀន* ២៣(១)(១៩៩៨) ទំព័រ៨១-៩៥។ ជេ អេ អាល (J. Platt et al) "ក្តីសង្ឃឹម និងការកំណត់ការព្យាបាលដោយបង្ខំ នៃការញៀនគ្រឿងញៀន" *ទស្សនាវដ្តីអំពីបញ្ហាគ្រឿងញៀន* ១៨(៤) (១៩៨៨) ទំព័រ៥០៥-៥២៥។ ស្ទីវិន អេ អាល (Stevens et al) "ការព្យាបាលដោយបង្ខំ ចំពោះអ្នកញៀនគ្រឿងញៀន :- ទស្សនៈអក្សរសាស្ត្រអន្តរជាតិ" ការប្រើសារធាតុនិងការប្រើខុស 40 (2005), p. 269–283.

215 អឹម អែល ប្រែក អេ អាល (M.–L. Brecht et al) "ការព្យាបាលដោយបង្ខំ ចំពោះការបំពានថ្នាំមេតំហ្វេតាមីន :- លក្ខណៈ និងលទ្ធផលខុសៗគ្នារបស់អ្នកជំងឺ" *ទស្សនាវដ្តីអាមេរិកាំង ស្តីពីការបំពានគ្រឿងស្រវឹង និងគ្រឿងញៀន* ៣១ (២០០៥) ទំព័រ ៣៣៧-៣៥៦

216 ឧទាហរណ៍សូមមើល អង្គការសុខភាពពិភពលោកតំបន់ប៉ាស៊ីហ្វិចខាងលិច "ការវាយតម្លៃអំពីការព្យាបាលអ្នកប្រើប្រាស់គ្រឿងញៀនដោយបង្ខំក្នុងប្រទេសកម្ពុជា ចិន ម៉ាឡេស៊ី និងវៀតណាម :- ការអនុវត្តន៍គោលការណ៍សិទ្ធិមនុស្សដោយជ្រើសរើស" ឆ្នាំ២០០៩ ទំព័រទី៣០-៣៤ និងសូមមើល "ការស្តារនីតិសម្បទាប្រទេសវៀតណាមស្ថិតក្នុងការងារដែលបិទជិត" ឌុក ត. ត្រាន បទបង្ហាញអំពីការកាត់បន្ថយគ្រោះថ្នាក់ ២០០៩ ទីក្រុងបាងកក ថ្ងៃទី២១ មេសា ឆ្នាំ២០០៩។ អ្នកស្រាវជ្រាវអង្គការឃ្លាំមើលសិទ្ធិមនុស្សបានចូលរួមផ្ទាល់។

ការព្យាបាលវេជ្ជសាស្ត្រដោយបង្ខំ លុះត្រាតែផ្អែកលើមូលដ្ឋានពិសេស សម្រាប់ការព្យាបាលជំងឺផ្លូវចិត្ត ឬបង្ការ និងការគ្រប់គ្រងជំងឺឆ្លង ។[217]

ករណីពិសេសបែបនេះ ត្រូវតែមានល័ក្ខខ័ណ្ឌកំណត់ជាក់លាក់ ដោយគោរពការអនុវត្តន៍ដ៏ប្រសើរបំផុត និងបទដ្ឋានអន្តរជាតិនៃការអនុវត្តន៍។ [218] ដូចដែលអង្គការសុខភាពពិភពលោក និងការិយាល័យប្រឆាំងគ្រឿងញៀន និងឧក្រិដ្ឋកម្មរបស់អ.ស.ប បានកត់សម្គាល់ថា "លើកលែងតែស្ថានភាពវិបត្តិដ៏ពិសេស ក្នុងការប្រឈមនឹងគ្រោះថ្នាក់ខ្ពស់ចំពោះខ្លួនឯងនិងអ្នកដទៃ ការព្យាបាលដោយបង្ខំត្រូវតែចាំបាច់សម្រាប់ល័ក្ខខ័ណ្ឌជាក់លាក់ និងរយៈពេលវេលាដែលបានបញ្ជាក់ទៅតាមច្បាប់" ។[219]

ក្នុងពេលមិនមានការផ្តល់យោបល់ព្យាបាលពីគ្រូពេទ្យមានវិជ្ជាជីវៈ ប្រព័ន្ធប្រទេសកម្ពុជាបង្ខំមនុស្សឱ្យទទួលយក"ព្យាលបាល" និង "ស្តារនីតិសម្បទា"ដែលសន្មត់នោះ ដោយមិនបានគិតដល់កង្វះខាតសមត្ថភាព ដែលយល់ព្រមពីបុគ្គលដែលទទួលការព្យាបាល។ ប្រព័ន្ធមិនអើពើចំពោះតម្រូវការរបស់បុគ្គល (ប្រសិនបើមាន) ដូច្នេះហើយគេមិនអាចធ្វើយុត្តិកម្មតាមរយៈផលប្រយោជន៍ជាក់ស្តែងពីអន្តរាគមន៍ដែលស្នើនោះបានឡើយ។ ប្រព័ន្ធបដិសេធចោលបុគ្គលពីឱកាសបញ្ឈប់ឬកែប្រែផែនការព្យាបាលរបស់ខ្លួន និងខកខានមិនបាន ពិនិត្យមើលតម្រូវការជាការចាំបាច់នៃការព្យាបាលបន្ត។ ដោយសារតែការខកខានទាំងនោះ បានជាពុំមានការធានាតាមនីតិវិធីដើម្បីបញ្ឈប់ការផ្តល់អន្តរាគមន៍ដោយបង្ខិតបង្ខំរយៈពេលយូរហួសពីភាពចាំបាច់។

ជាទម្រង់មួយផ្ទុយពីប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌនៅត្រង់កន្លែងដែលការប្រើប្រាស់ និង/ឬការកាន់កាប់គ្រឿងញៀនជាកម្មសិទ្ធរបស់ខ្លួន នៅតែជាបទល្មើសព្រហ្មទណ្ឌ ឬ រដ្ឋបាលមួយ

---

217 បទអត្ថាធិប្បាយទូទៅ — លេខ១៤ កថាខ័ណ្ឌ៣៤

218 ដូចជាគោលការណ៍សម្រាប់ការការពារអ្នកជំងឺផ្លូវចិត្ត និងការកែលំអនៃការថែទាំងសុខភាពផ្លូវចិត្ត

219 ការិយាល័យគ្រឿងញៀន និងឧក្រិដ្ឋកម្មអ.ស.ប/អង្គការសុខភាពពិភពលោក "គោលការណ៍នៃការព្យាបាលការញៀនគ្រឿងញៀន" ទំព័រ៩

ដូចដែលមានចែងនៅក្នុងច្បាប់គ្រឿងញៀនប្រទេសកម្ពុជា គេត្រូវតែយកចិត្តទុកដាក់ខ្ពស់បំផុតដើម្បីធានាដល់ការគោរពសិទ្ធិស្វ័យភាពរបស់បុគ្គល។ ដូចដែលអង្គការសុខភាពពិភពលោក និងការិយាល័យគ្រឿងញៀននិងឧក្រិដ្ឋកម្មរបស់អ.ស.ប ធ្វើការកត់សម្គាល់ថា "អ្នកជំងឺត្រូវមានសិទ្ធិបដិសេធនូវការព្យាបាល និងសិទ្ធិជ្រើសរើសយកទណ្ឌកម្មព្រហ្មទណ្ឌជំនួសវិញ។[220]

អង្គការសុខភាពពិភពលោក ធ្វើការកត់សម្គាល់ថា អំឡុងពេលផ្តាច់គ្រឿងញៀន :-

> ចាំបាច់ត្រូវមានការពិនិត្យគ្រប់គ្រងសមស្រប និងត្រូវមានសេវាព្យាបាលដែលអាចរកបាន ជាពិសេសស្ថិតក្នុងស្ថានភាពភាន់ច្រលំ ការផ្អាកដំណើការខួរក្បាល ឬគ្រោះថ្នាក់ ដែលជាផលវិបាកបណ្តាលមកពីស្ថានភាពកង្វះខាតជីវជាតិ។ ការត្រួតពិនិត្យដិតដល់មានផ្នែកសំខាន់មួយក្នុងការគ្រប់គ្រងលើស្ថានភាពផ្តាច់ចេញពីគ្រឿងញៀន។ ការព្យាបាលដោយឱសថសាស្ត្រ និងវិធីសាស្ត្រផ្សេងៗ... ដែលអាចយកមកប្រើប្រាស់សម្រាប់កាត់បន្ថយការឈឺចាប់ ភាពរំជើបរំជួល ជំងឺដេកមិនលក់ ឬរោគសញ្ញាផ្សេងៗទៀត។ គេអាចគ្រប់គ្រងការកាត់បន្ថយកម្រិតថ្នាំសារធាតុជំនួស ជាពិសេសនៅក្នុងករណី...ការញៀនថ្នាំញៀនប្រភេទអាភៀន។[221]

## ភាពមិនរើសអើងនៅក្នុងសេវាព្យាបាលគ្រឿងញៀន

ដូចបានកត់សម្គាល់ខាងលើ ពុំមានសេវាព្យាបាលគ្រឿងញៀនក្នុងប្រទេសកម្ពុជាសម្រាប់ស្ត្រីភេទនិងកុមារីទេ។ អង្គការឃ្លាំមើលសិទ្ធិមនុស្សមិនជឿថា ការបើកមជ្ឈមណ្ឌលឃុំឃាំងគ្រឿងញៀនសម្រាប់ស្ត្រីភេទ គឺជាគោលនយោបាយដ៏សមស្រប ដើម្បីឆ្លើយតបទៅនឹងកង្វះខាតសេវា

---

[220] ការិយាល័យប្រឆាំងគ្រឿងញៀន និងឧក្រិដ្ឋកម្មអ.ស.ប/អង្គការសុខភាពពិភពលោក "គោលការណ៍នៃការព្យាបាលការពឹងអាស្រ័យគ្រឿងញៀន" ទំព័រ៩

[221] គណៈកម្មាធិការអ្នកជំនាញការរបស់អង្គការសុខភាពពិភពលោក ស្តីពីការញៀនគ្រឿងញៀន —របាយការណ៍ទី៣០:- របាយការណ៍បច្ចេកទេសអង្គការសុខភាពពិភពលោក សេរី៨៧៣ ឆ្នាំ១៩៩៨ ទំព័រ៨— គេហទំព័រ [http://whqlibdoc.who.int/trs/WHO_TRS_873.pdf].

ព្យាបាលគ្រឿងញៀននោះទេ។ និយាយឱ្យចំទៅ ប្រទេសកម្ពុជាគួរត្រូវបានណែនាំដោយគោលជំហរគោលនយោបាយ ដោយប្រាប់ឱ្យដឹងនូវវិធីដែលប្រសើរបំផុតសម្រាប់បំពេញសេចក្តីត្រូវការរបស់ស្ត្រី ចំពោះសេវាព្យាបាលគ្រឿងញៀនដែលមានប្រសិទ្ធិភាព។

យោងតាមគណៈកម្មាធិការស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ រដ្ឋត្រូវយកចិត្តទុកដាក់ពិសេស ដោយធានាថាស្ត្រីនិងកុមារី ត្រូវមានសិទ្ធិស្មើគ្នាចំពោះការប្រើប្រាស់សេវាសុខភាព។[222] តម្រូវការព្យាបាលវេជ្ជសាស្ត្ររវាងបុរសនិងស្ត្រី អាចខុសគ្នាធំធេង។ ការិយាល័យគ្រឿងញៀននិងឧក្រិដ្ឋកម្មរបស់អ.ស.ប ចាត់ទុកថាកម្មវិធីផ្តល់សេវាពិសេសសម្រាប់ស្ត្រី គឺផ្សារភ្ជាប់ជាមួយលទ្ធផលព្យាបាលដែលប្រសើរជាងសម្រាប់ប្រជាពលរដ្ឋនេះ។[223] យោងតាមការិយាល័យគ្រឿងញៀននិងឧក្រិដ្ឋកម្មរបស់អ.ស.ប ការញៀនគ្រឿងញៀនចំពោះស្ត្រីភេទ អាចធ្វើឱ្យកាន់តែមានប្រសិទ្ធិភាពដោយការឆ្លើយតបទៅតាមកម្មវិធីខាងក្រោម ក្នុងចំណោមការឆ្លើយតបផ្សេងៗទៀត :-

- **ការបង្កើតកម្មវិធីយល់ដឹង** ដែលមិនសម្រាប់វិនិច្ឆ័យទោស និងសម្រាប់ដាក់ទណ្ឌកម្ម។ យកចិត្តទុកដាក់ចំពោះទំនាក់ទំនង ដំណើរប៉ះទង្គិចផ្លូវចិត្ត និងដំណើររំលោភបំពានដែលជាការសំខាន់សម្រាប់ផ្តល់សេវាប្រកបដោយជោគជ័យ។
- **ការផ្តល់សេវានៅមូលដ្ឋានសហគមន៍** គឺមានប្រសិទ្ធិភាព មិនរំលោភបំពាន និងផ្តល់ជម្រកដល់ស្ត្រី ដែលមានការលំបាកចូលទទួលសេវាតាមលំនៅឋាន។

---

222 បទអត្ថាធិប្បាយជាទូទៅ លេខ១៤ កថាខ័ណ្ឌ១២ (ក)-(ឃ)

223 ការិយាល័យគ្រឿងញៀន និងឧក្រិដ្ឋកម្មរបស់អ.ស.ប "ការបំពានគ្រឿងញៀន ការព្យាបាល និងថែទាំសម្រាប់ស្ត្រី (សង្ខេប)" **http://www.unodc.org/pdf/report_2004-08-30_1_summary.pdf.**

- **ផ្តល់គ្រឹះស្ថាននិងការថែទាំសម្រាប់ស្ត្រីមានផ្ទៃពោះនិងស្ត្រីចិញ្ចឹមបីបាច់កូន** ដែលជាពហុវិន័យទូលំទូលាយនិងទាន់ពេលវេលា ដែលបច្ច័យនាំឱ្យការថែទាំ និងលទ្ធផលសម្រាប់មាតា និងកូនទារកដែលទើបសម្រាលកាន់តែប្រសើរ ។

ការិយាល័យប្រឆាំងគ្រឿងញៀន និងឧក្រិដ្ឋកម្មរបស់អ.ស.ប ផ្តល់អនុសាសន៍ឱ្យមានសេវាព្យាបាលគួបផ្សំជាមួយសេវាថែទាំកុមារ និងសេវាសង្គម និងការគាំទ្រខាងសង្គម (ដូចជាជំនួយផ្នែកឱកាសរកការងារធ្វើ និងឱកាសបណ្តុះបណ្តាល ការព្យាបាលតាមគ្រួសារ និងជំនួយផ្ទះសុវត្ថិភាព) ។[224]

## អាហារ

មាត្រា១០នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ តម្រូវថាជនណាដែលត្រូវបានដកហូតសេរីភាព ត្រូវទទួលបានការប្រព្រឹត្តមកលើខ្លួន តាមលក្ខណៈមនុស្សធម៌ ដែលរួមមានការឃុំខ្លួនពួកគេទៅតាមស្ថានភាពមនុស្សធម៌ ។ ជាពិសេស ស្ថានភាពឃុំខ្លួនដែលឃោរឃៅ រួមទាំងការដកហូតអាហារ ត្រូវចាត់ទុកថាជាស្ថានភាពអមនុស្សធម៌ ដែលរំលោភលើកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ។[225]

បទបញ្ញត្តិជាបទដ្ឋានអប្បបរិមារបស់អ.ស.ប សម្រាប់គ្រប់គ្រងអ្នកទោសចែងថា :- "អ្នកទោសគ្រប់រូប ត្រូវតែទទួលបានម្ហូបអាហារ ដែលផ្តល់ឱ្យដោយរដ្ឋតាមពេលម៉ោងធម្មតា ។ ម្ហូប

---

224 ការិយាល័យគ្រឿងញៀន និងឧក្រិដ្ឋកម្មរបស់អ.ស.ប "ការបំពានគ្រឿងញៀន ការព្យាបាល និងថែទាំងសម្រាប់ស្ត្រី (សង្ខេប)" **http://www.unodc.org/pdf/report_2004-08-30_1_summary.pdf.**

225 ម៉ាន់ហ្វ្រេត ណូវ៉ាក់ (Manfred Nowak) កតិកាសញ្ញាអ.ស.ប ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ បទអត្ថាធិប្បាយ (បោះពុម្ពផ្សាយលើកទី២) (Khel: N.P. Engel, 2005) ទំព័រ ១៦៥ ១៧២ ២៤៤-៩ ។ សូមមើលឧទាហរណ៍សំណុំរឿងប្រឆាំងប្រទេស យូរ៉ាហ្គាយ ដូចជា Buffo Carball v. Uruguay លេខ៣៣/១៩៧៨ ។ Massiotti v. Uruguay លេខ២៥/១៩៧៨ ។ Madagascar: Marais v. Madagascar លេខ៤៩/១៩៧៩ ។ Wight v. Madagascar លេខ១១៥/១៩៨២ ។ Jamaica: Robinson v Jamaica លេខ៧៣១/១៩៩៦ ។ Pennant v Jamaica លេខ៦៤៧/១៩៩៥ ។ Russia: Lantsova v Russian Federation លេខ៧៦៣/១៩៩៧

អាហារនោះត្រូវមានគុណភាពនិងជីវជាតិអាហារគ្រប់គ្រាន់ដើម្បីសុខភាព និងកម្លាំងពលំ ដែលមានការដាំស្ល និងបំរើដោយយកចិត្តទុកដាក់"។[226] បទដ្ឋាននេះ ត្រូវបាននិយាយយោង ដោយមានការគាំទ្រដោយគណៈកម្មាធិការសិទ្ធិមនុស្សរបស់អ.ស.ប នៅពេលដែលការពិនិត្យ បទដ្ឋានអប្បរិមាតម្រូវថា រដ្ឋត្រូវតែសង្កេតមើលដោយគោរពចំពោះជនដែលត្រូវបានដកហូត សេរីភាព "ដោយមិនគិតដល់កម្រិតនៃការអភិវឌ្ឍន៍របស់រដ្ឋភាគី"។[227]

## ក្រុមប្រជាពលរដ្ឋជាក់លាក់

### កុមារ

> *បងដឹងទេ ក្មេងមានសិទ្ធិប្តឹងបញ្ហាហ្នឹងបាន! ខ្ញុំចង់ឱ្យក្មេងទាំងអស់ចាកចេញពី មជ្ឈមណ្ឌលទាំងអស់នោះ ដើម្បីឱ្យពួកគេមានសេរីភាពដូចខ្ញុំដែរ— ចំបក់ អាយុ១៧ឆ្នាំ ជាអតីតអ្នកជាប់ឃុំឃាំងនៅមជ្ឈមណ្ឌល "យុវនីតិសម្បទា" សង្គមកិច្ចចោមចៅ*[228]

មជ្ឈមណ្ឌលឃុំឃាំងគ្រឿងញៀនប្រទេសកម្ពុជា ក្តោបក្តាប់កុមារចំនួនយ៉ាងច្រើន។ តាម ការពិត មជ្ឈមណ្ឌលឃុំឃាំងគ្រឿងញៀនដែលបង្កើតឡើងនោះ — មជ្ឈមណ្ឌលសង្គមកិច្ច នៅចោមចៅ និងនៅខេត្តកណ្តាល — គឺមានតែឈ្មោះជាមជ្ឈមណ្ឌល"យុវនីតិសម្បទា"ប៉ុណ្ណោះ។ ដូចបានធ្វើការកត់សម្គាល់ខាងលើ នៅក្នុងឆ្នាំ២០០៨ អ្នកជាប់ឃុំឃាំងចំនួនតិចជាងមួយភាគបួន បន្តិចដែលរស់នៅក្នុងមជ្ឈមណ្ឌលឃុំឃាំងគ្រឿងញៀនរដ្ឋាភិបាល មានអាយុ១៨ឆ្នាំ ឬក្រោម១៨ឆ្នាំ។ ក្នុងចំណោមអ្នកទាំងនេះ មានកុមារ១០៤នាក់ ដែលមានអាយុតិចជាង១៥ឆ្នាំ។ ក្នុងឆ្នាំ២០០៨

---

[226] កថាខ័ណ្ឌ ២០(១)

[227] សូមមើល ម៉ូគង់ និង កាមេរ៉ូន (*Mukong v Cameroon)* លេខ៤៥៨ / ១៩៩១ កថាខ័ណ្ឌ ៩.៣

[228] អង្គការឃ្លាំមើលសិទ្ធិមនុស្ស សម្ភាសចំបក់ - ភ្នំពេញ ខែមិថុនា ឆ្នាំ២០០៩

អ្នកជាប់ឃុំឃាំងចំនួន១១៦នាក់ ត្រូវបានចំណាត់ថ្នាក់ជា"កុមាររស់តាមចិញ្ចើមថ្នល់"។ [229] កុមារទាំងនោះត្រូវបានចាប់ខ្លួន ហើយឃុំខ្លួនដោយគ្មានអំណាចផ្លូវច្បាប់ឡើយ។ កុមារទាំងនោះត្រូវបានឃុំខ្លួននៅក្នុងអាគារដេករួមជាមួយមនុស្សចាស់ដែរ។ ពុំមានការព្យាបាលដែលសមស្រប ការអប់រំ និងសេវាកម្សាន្តនៅក្នុងមជ្ឈមណ្ឌលទេ។ គេបាននិយាយប្រាប់អង្គការឃ្លាំមើលសិទ្ធិមនុស្សថា អ្នកជាប់ឃុំឃាំងនៅ"មជ្ឈមណ្ឌលយុវនីតិសម្បទា"ចោមចៅ ត្រូវបានគេឆក់ចរន្តអគ្គិសនី វាយដំនិងបង្ខិតបង្ខំដោយ"ឆ្មា"ដើម្បីឱ្យរាំស្រាត។

កុមារដែលរស់តាមចិញ្ចើមថ្នល់ជាច្រើន ត្រូវបានចាប់ខ្លួនដោយនគរបាល ឬអាជ្ញាធរផ្សេងៗទៀតនៅក្នុងការបោសសំអាតផ្លូវថ្នល់ ហើយត្រូវបាននាំទៅកាន់មជ្ឈមណ្ឌលឃុំឃាំងតែម្តង ដោយគ្មានអំណាចផ្លូវច្បាប់អ្វីទាំងអស់។ ចំបក់ អាយុ១៧ឆ្នាំ បានពន្យល់អំពីដំណើរការនៃការចាប់ខ្លួន និងឃុំខ្លួនគាត់ ដូច្នេះថា :-

> [អ្នកដែលចាប់ខ្ញុំនោះ]គឺបុគ្គលិកសង្គមកិច្ច... ពួកគេចាប់ខ្ញុំបោះចូលឡានទ្រុង។ ឡានមានទ្រុង។ មានសញ្ញាសង្គមកិច្ច[នៅលើឡាន]... ពួកម៉ាកខ្ញុំក៏នៅក្នុងឡានដែរ ដែលមានគ្នា៤-៥នាក់... គេចាប់ពួកខ្ញុំនៅម៉ោង ៤-៥ព្រឹក ហើយក្រោយមកយកពួកខ្ញុំត្រង់ទៅចោមចៅតែម្តង[មជ្ឈមណ្ឌលឃុំឃាំង]។ គេមិនបាននិយាយប្រាប់ពីហេតុផលចាប់ខ្លួនទេ :- ខ្ញុំឆ្ងល់ដែរ... ខ្ញុំមិនដែលជួបមេធាវីទេ។ គេដាក់ខ្ញុំក្នុងឡានយ៉ាងស្រួល ហើយខ្ញុំបានមកដល់[មណ្ឌល]ចោមចៅនៅម៉ោង៦ល្ងាច ។[230]

---

[229] សូមមើលមជ្ឈមណ្ឌលព័ត៌មានគ្រឿងញៀន, អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន "របាយការណ៍សង្ខេប ស្តីពីទិន្នន័យគ្រឿងញៀន ២០០៨" ភ្នំពេញ ខែមេសា ២០០៩ មិនបានផ្សព្វផ្សាយ (ច្បាប់ចម្លង រក្សាទុកជាឯកសារនៅអង្គការឃ្លាំមើលសិទ្ធិមនុស្ស)

[230] អង្គការឃ្លាំមើលសិទ្ធិមនុស្ស សម្ភាសចំបក់ - ភ្នំពេញ ខែមិថុនា ឆ្នាំ២០០៩

កុមារនិងមនុស្សចាស់ ត្រូវជាប់ឃុំខ្លួនជាមួយគ្នាជាធម្មតា។ នៅពេលធ្វើការស្រាវជ្រាវសម្រាប់របាយការណ៍នេះ អង្គការឃ្លាំមើលសិទ្ធិមនុស្ស បានសម្ភាសមនុស្សចាស់៦នាក់(ពោលគឺលើសអាយុ១៨ឆ្នាំ) ដែលជាប់ឃុំខ្លួននៅក្នុង"មជ្ឈមណ្ឌលយុវនីតិសម្បទា"សង្គមកិច្ចចោមចៅ។ មជ្ឈមណ្ឌលផ្សេងៗទៀត ក៏បង្ខាំងកុមារនិងមនុស្សចាស់រួមគ្នាដែរ។ យោងតាមសម្ដីរបស់សៅ អាយុ២៤ និងជាអតីតអ្នកជាប់ឃុំឃាំងនៅមណ្ឌលឱកាសខ្ញុំ :-

> ក្នុងបន្ទប់របស់ខ្ញុំ មានក្មេងបួននាក់ដែលមានអាយុ១៣-១៥ឆ្នាំ។ ពួកវានៅទីនោះដោយសារហិតការ។ គេចាប់ពួកវា។ ពួកវាធ្វើការដូចមនុស្សធំដូចពួកខ្ញុំដែរ។ ពួកវាហ្វឹកហ្វឺនយោធាដូចពួកខ្ញុំដែរ។ ពួកវាដេកក្នុងបន្ទប់ជាមួយមនុស្សធំ។[231]

ស្រដៀងគ្នានេះដែរ ត្រាច អាយុ២៧ឆ្នាំ បានរាយការណ៍ថានៅក្នុងមជ្ឈមណ្ឌលស្នងការនគរបាលខេត្តសៀមរាបពុំមានការបែងចែកកុមារពីមនុស្សធំទេ :-

> ក្មេងជាងគេបង្អស់[នៅក្នុងមណ្ឌល]មានអាយុ១២ឬ១៣ឆ្នាំ... ពួកវាជាអ្នកហិតការ។ មានក្មេងក្រោម១៨ឆ្នាំប្រហែល៧-៨នាក់។ ពួកវាដេកជាមួយពួកខ្ញុំដែរ។ ធម្មតាក្មេងៗដេកជាមួយមនុស្សឆ្កួត។[232]

កក្កដា អាយុ២៨ឆ្នាំ បានរៀបរាប់អំពីមជ្ឈមណ្ឌលសង្គមកិច្ចចោមចៅថាជា"មណ្ឌលដែលធ្វើបាបក្មេង"។ គាត់បានរាយការណ៍ថាកុមារនៅមជ្ឈមណ្ឌល ត្រូវបានគេឱ្យហ្វឹកហាត់យោធាដូចមនុស្សធំដែរ :-

---

231 អង្គការឃ្លាំមើលសិទ្ធិមនុស្ស សម្ភាសសៅ - ភ្នំពេញ ខែមេសា ឆ្នាំ២០០៩

232 អង្គការឃ្លាំមើលសិទ្ធិមនុស្ស សម្ភាសត្រាច - សៀមរាប ខែមេសា ឆ្នាំ២០០៩

មានក្មេងតូចៗ ហើយគេធ្វើបាបពួកវាដូចទាហានអញ្ចឹង។ គេវាយទះកំផ្លៀងពួកវា "ឆ្មា"និងអ្នកយាមជាអ្នកវាយ។ គេឱ្យពួកវាហាត់ដូចទាហាន។ ខ្ញុំអាណិតពួកវាណាស់ ពួកវាដូចប្អូនប្រុសខ្ញុំដែរ។ ពេលខ្លះខ្ញុំយំដោយសារអាណិត។ គេបង្ហាត់ពួកវាលុតដំខ្លួនប្រាណដូចជាទាហាន។ អ្នកយាមចេញបញ្ជាជាទាហានឱ្យបត់ឆ្វេង បត់ស្តាំ។ ការហាត់បែបនេះធ្វើឱ្យពួកវាខ្លាំង និងធ្វើឱ្យពួកវាដើរចេញពីគ្រឿងញៀន... បើពួកវារមៀលលើដីមិនត្រង់ជួរ អ្នកយាមទាត់ក្បាលពួកវា។ មានក្មេងម្នាក់បានរមៀលតែមិនត្រង់ជួរ អ្នកយាមស្រែកថា "អាក្មេងនេះ ហ្អែងមិនធ្វើទៅ"។ គាត់ឱ្យក្មេងនោះក្រោកឈរ ហើយទាត់ក្មេងនោះ។ ក្មេងនោះខ្ទាតទៅក្រោយពីរម៉ែត្រ។ អ្នកយាមនិយាយថា "បើហ្អែងហ៊ានយំ អញវាយថែម"។ ក្មេងនោះយំ។[233]

មករា អាយុ២៥ឆ្នាំ ជាអតីតអ្នកជាប់ឃុំឃាំងនៅមជ្ឈមណ្ឌលឱកាសខ្ញុំ បានពន្យល់ថា :-

[កុមារ] ទទួលរងការប្រព្រឹត្តដូចគ្នាទាំងអស់[ដូចអ្នកជាប់ឃុំឃាំងផ្សេងទៀត] :- [អ្នកជាប់ឃុំឃាំង] ត្រូវតែហ្វឹកហាត់ទាហានមួយរយភាគរយ ដើរក្បួនទាហាន គោរពបុគ្គលិក សម្អាតស្មៅ កាប់ដី សម្អាត បង្គន់ មើលគោ មើលទា...[234]

កញ្ញា អាយុ៣៥ឆ្នាំ ជាអតីតអ្នកជាប់ឃុំឃាំងនៅមជ្ឈមណ្ឌលឱកាសខ្ញុំ បានពន្យល់ថា :-

មានក្មេងៗ អាយុ១០ ១២ និង១៣ឆ្នាំ ប្រហែលមាន១០នាក់[នៅក្នុងមជ្ឈមណ្ឌលដែរ]... ខ្លះដេកបន្ទប់ផ្សេងគ្នា។ នៅក្នុងបន្ទប់របស់ខ្ញុំ ឃើញមានម្នាក់អាយុ១២ឆ្នាំ ហើយម្នាក់ទៀតមានអាយុ១៣ឆ្នាំ។ ពួកគេធ្វើការដូចគ្នា[ដូចអ្នកជាប់ឃុំឃាំង

233 អង្គការឃ្លាំមើលសិទ្ធិមនុស្ស សម្ភាសកក្កដា - ភ្នំពេញ ខែឧសភា ឆ្នាំ២០០៩
234 អង្គការឃ្លាំមើលសិទ្ធិមនុស្ស សម្ភាសមករា - ភ្នំពេញ ខែឧសភា ឆ្នាំ២០០៩

ផ្សេងទៀតដែរ] :- កាប់ដី ទៅថ្នាក់រៀន [អរុណសួស្តី] ហ្វឹកហ្វឺនយោធា។ ពេលខ្លះពួកវាត្រូវគេវាយ ប្រសិនបើធ្វើខុស[នឹងវិន័យក្នុងមណ្ឌល] ។ខ្ញុំឃើញគេវាយផ្ទាល់។ មិនគិតថាជាក្មេង ឬមនុស្សធំទេ ឱ្យតែពួកគេធ្វើខុស ពួកគេត្រូវរងការវាយដំហើយ ។[235]

ភាគច្រើនទារុណកម្មនិងការរំលោភលើរាងកាយដែលប្រព្រឹត្តដោយបុគ្គលិក ដែលបានពិពណ៌នាខាងលើ ត្រូវបានកុមាររាយការណ៍ប្រាប់អង្គការឃ្លាំមើលសិទ្ធិមនុស្ស។ អង្គការឃ្លាំមើលសិទ្ធិមនុស្ស បានធ្វើសម្ភាសកុមារដែលធ្លាប់ជាប់ឃុំខ្លួនពីមុននៅក្នុង"មជ្ឈមណ្ឌលយុវនីតិសម្បទា"សង្គមកិច្ចចោមចៅ បានរាយការណ៍ពីការប្រព្រឹត្តដ៏រន្ធត់ដោយសារស្នាដៃបុគ្គលិកនិងអ្នកជាប់ឃុំឃាំង។ ទោះបីមានឈ្មោះជាមជ្ឈមណ្ឌលស្តារនីតិសម្បទាសម្រាប់យុវជនក៏ដោយ អ្នកយាមបានប្រើប្រាស់ដំបងឆក់ដោយចរន្តអគ្គិសនី។ កក្កដា អាយុ២៨ឆ្នាំ និងជាអតីតអ្នកជាប់ឃុំឃាំងនៅ"មជ្ឈមណ្ឌលយុវនីតិសម្បទា"ចោមចៅ បានឃើញហេតុការណ៍ដែលអ្នកជាប់ឃុំឃាំងដូចគ្នាម្នាក់នៅក្នុងមជ្ឈមណ្ឌលនោះ ទទួលរងការឆក់ចរន្តអគ្គិសនី ដែលជាទណ្ឌកម្មសម្រាប់ការប៉ុនប៉ងរត់គេច :-

អ្នកយាមនៅខាងក្រោមជ្ឈមណ្ឌលមានដំបងឆក់។ នៅពេលអ្នកណាម្នាក់ព្យាយាមលួចរត់ ពួក"ឆ្មា"នាំគ្នាស្រែកហៅអ្នកយាមទាំងនោះ ដែលមានដំបងឆក់... មានម្នាក់នោះគាត់បានលួចរត់ ហើយអ្នកយាមបានឆក់គាត់ទាល់តែគាត់ដួលដេកដី។ គាត់សន្លប់... នៅកន្លែងហ្នឹងពួកគេគិតតែពីវាយធ្វើបាប ។[236]

ទន្លេ អាយុ១៦ឆ្នាំ ជាអតីតអ្នកជាប់ឃុំឃាំងនៅ"មជ្ឈមណ្ឌលយុវនីតិសម្បទា"សង្គមកិច្ចចោមចៅ បានពិពណ៌នាអំពីខ្លួនត្រូវពួក"ឆ្មា"បង្ខំឱ្យរាំស្រាត :-

---

235 អង្គការឃ្លាំមើលសិទ្ធិមនុស្ស សម្ភាសកញ្ញា - ភ្នំពេញ ខែឧសភា ឆ្នាំ២០០៩

236 អង្គការឃ្លាំមើលសិទ្ធិមនុស្ស សម្ភាសកក្កដា - ភ្នំពេញ ខែឧសភា ឆ្នាំ២០០៩

បងដឹងទេ ពេល"ឆ្មា"វាស្រវឹង ពួកវាឱ្យក្មេង៧ទាំងអស់ស្រាតខោអាវចេញហើយរាំឱ្យពួកវាមើល។ គឺមានរឿងបែបហ្នឹងម្តង។ ក្មេងទាំងអស់ត្រូវតែរាំនៅក្នុងបន្ទប់។ ពួកវាចាក់ចម្រៀងខារ៉ាអូខេនៅលើទូរស័ព្ទដៃ។ នៅប្រហែលម៉ោង៨-៩យប់។ ក្មេងជាងម្ភៃនាក់ ត្រូវដោះខោអាវអស់ហើយនាំគ្នារាំប្រហែលមួយម៉ោង។ បើមិនដោះខោអាវចេញទេ ពួកវានឹងវាយ ។[237]

ចំបក់ អាយុ១៧ឆ្នាំ បាននិយាយប្រាប់អំពីខ្លួនដែលគេបង្ខំឱ្យធ្វើការ ហើយត្រូវគេវាយនៅពេលឈឺ :-

[នៅក្នុងមជ្ឈមណ្ឌលចោមចៅ] ខ្ញុំចាំងសម្អាតស្មៅ។ បើអ្នកណាមិនធ្វើការត្រូវតែទៅជួបអ្នកយាម ហើយសុទ្ធតែត្រូវ "ក្តគោ"[ដំបងនគរបាល]បីដង។ ពួកគេវាយខ្ញុំពីរដងដោយសារខ្ញុំឈឺ។ ពួកគេនិយាយថា"អត់ទេ ទៅធ្វើការ!"។ ខ្ញុំញាក់ [កាលនោះ]ខ្ញុំមានជំងឺគ្រុនចាញ់ ។[238]

ខាល អាយុ១៦ ពិពណ៌នាអំពីការវាយជាប្រចាំថ្ងៃដោយ"ឆ្មា"នៅចោមចៅ :-

[ពួកឆ្មា]បានវាយស្វាគមន៍ខ្ញុំ តែបន្ទាប់ពីស្វាគមន៍ ពួកវានៅតែវាយខ្ញុំរាល់ថ្ងៃ ពួកវាប្រើដៃ។ ខ្ញុំអត់បានធ្វើអីខុសផង។ ពួកគេថាខ្ញុំជាក្មេងឈ្លើយ ហើយថាមុខខ្ញុំហ្នឹងមើលទៅឈ្លើយ។ ខ្ញុំមិនបានធ្វើអីខុសសោះ។ [ឆ្មាម្នាក់]បានដាល់ខ្ញុំចំកណ្តាលដើមទ្រូងអស់ច្រើនដៃ។ [ឆ្មា]បានបញ្ជាកូនចៅវាឱ្យវាយខ្ញុំ។ គ្មានអ្នកណាហ៊ាន

---

[237] អង្គការឃ្លាំមើលសិទ្ធិមនុស្ស សម្ភាសទន្លេ- ភ្នំពេញ ខែមិថុនា ឆ្នាំ២០០៩

[238] អង្គការឃ្លាំមើលសិទ្ធិមនុស្ស សម្ភាសចំបក់- ភ្នំពេញ ខែមិថុនា ឆ្នាំ២០០៩

និយាយប្រាប់អ្នកយាមទេ បើមិនអញ្ចឹងទេ ត្រូវគេវាយហើយ ។ ខ្ញុំមិនហ៊ានប្រាប់អ្នកយាមទេ ពីព្រោះខ្ញុំខ្លាចត្រូវគេវាយ ។[239]

[239] អង្គការឃ្លាំមើលសិទ្ធិមនុស្ស សម្ភាសខាល- ភ្នំពេញ ខែកក្កដា ឆ្នាំ២០០៩

**ការដកស្រង់ផ្នែកខ្លះៗពីបទចម្រៀងនៅក្នុង "មជ្ឈមណ្ឌលយុវនីតិសម្បទា"ចោមចៅ**

បទចម្រៀងនេះ ត្រូវបានបង្រៀនដល់អ្នកជាប់ឃុំឃាំង"មជ្ឈមណ្ឌលយុវនីតិសម្បទា"សង្គមកិច្ចចោមចៅ។ អ្នកជាប់ឃុំឃាំងបានរាយការណ៍ថាគេបង្ខំឱ្យច្រៀងចម្រៀងនេះនៅពេលព្រឹកពីរដងក្នុងមួយសប្តាហ៍។

*រាំវង់ក្នុងពេលរាត្រី*
*បងសុំចាប់ដៃ*
*ស្រីហ្អើយ កុំខឹង*
...

*ពីមុនបងរាងសង្ហា បងធ្វើទាហាន។*
*កែវអើយ ប្រាក់ខែបងមាន*
*កែវអើយ ប្រាក់ខែបងមាន*
*បងធ្វើទាហាន ប្រាក់ខែ២៥០០៛*[240]
...

*ជាប់គុកដំបូងស៊ីបីក្តគោ[រងការវាយនឹងដំបងបីដង] ជាការបាត់ប្រាណ។*
*អូនអើយ ពេលបងសុំលុយបាន*
*អូនហើយ ពេលបងសុំលុយបាន*
*បងនាំកល្យាណទៅលេងចោមចៅ។*

*ចោមចៅសប្បាយខ្លាំងណាស់*

240 ប្រហែល ០.៦០ដុល្លារសហរដ្ឋ

*មានប្រុសសង្ហា*

*អង្គុយបោចស្មៅ*

*កែវអើយ នេះគឺមណ្ឌលចោមចៅ*

*កែវអើយនេះគឺមណ្ឌលចោមចៅ*

*អង្គុយបោចស្មៅមួយអាទិត្យប្រាំពីរដង*

ការរំលោភលើកុមារ ត្រូវបានរាយការណ៍ប្រាប់អង្គការឃ្លាំមើលសិទ្ធិមនុស្សនៅក្នុងមជ្ឈមណ្ឌលដទៃទៀតក្រៅពីមជ្ឈមណ្ឌលសង្គមកិច្ចចោមចៅ។ អតីតអ្នកជាប់ឃុំឃាំងម្នាក់ឈ្មោះ ឬស្សី អាយុ១៧ឆ្នាំ បានពិពណ៌នាអំពីការវាយមកលើខ្លួនគាត់ ដោយកងរាជអាវុធហត្ថនៅក្នុងមជ្ឈមណ្ឌលទីរួមខេត្តបាត់ដំបង ដើម្បីធ្វើការដោះលែងគាត់ចេញពីមជ្ឈមណ្ឌល :-

> អាវុធហត្ថបានវាយខ្ញុំ។ ពួកគេប្រើ"ក្តគោ"ពណ៌ខ្មៅ[ដំបងប៉ូលិស]វាយកំប៉េះគូទខ្ញុំ... គ្រូបង្ហាត់និយាយថា"អាល្អិត ឯងត្រូវដោះលែងវិញនៅថ្ងៃនេះហើយ ទុកឱ្យខ្ញុំវាយឯងសិន"។ [គាត់សួរថា]"តើឯងកែខ្លួនហើយនៅ? តើឯងឈប់ប្រើប្រាស់គ្រឿងញៀនហើយនៅ? តើឯងរកការងារធ្វើនៅ?" បន្ទាប់មកគាត់វាយខ្ញុំម្តងទៀត ។[241]

ចំណោត អាយុ១៥ឆ្នាំ ជាកុមារីម្នាក់ក្នុងចំណោមកុមារីពីរបីនាក់ដែលបានសម្ភាសដោយអង្គការឃ្លាំមើលសិទ្ធិមនុស្ស ត្រូវឃុំខ្លួននៅក្នុងមជ្ឈមណ្ឌលមួយក្រៅពីមជ្ឈមណ្ឌលសង្គមកិច្ច។ ដូចគ្នាទៅនឹងអ្នកជាប់ឃុំឃាំងដែលជាមិត្តភក្តិរបស់គាត់ដែរ គាត់បានរាយការណ៍អំពីខ្លួនត្រូវគេវាយដូច្នេះថា :-

---

[241] អង្គការឃ្លាំមើលសិទ្ធិមនុស្ស សម្ភាសឬស្សី- បាត់ដំបង ខែមិថុនា ឆ្នាំ២០០៩

ខ្ញុំត្រូវហាត់ប្រាណ[ដូចប្រុសៗ]ដែរ ។ ខ្ញុំធ្វើការផ្នែកចំអិនអាហារ ។ ប្រសិនបើខ្ញុំធ្វើខុសតិចតួច គេនឹងវាយខ្ញុំ ។ ខ្ញុំធ្វើខុសដូចជាដាក់គ្រឿងខុសក្នុងសម្ល ។ មេចុងភៅដែលជាបុគ្គលិក បានវាយខ្ញុំ ។ គាត់យករំពាត់វាយបាតដៃខ្ញុំ ។[242]

## ជំងឺផ្លូវចិត្ត

*ពួកគេបានចាប់មនុស្សឆ្កួត... ពួកគេត្រូវបានចាប់ខ្លួនហើយបោះចូលឡាន ។ មានបួននាក់ [ មានជំងឺផ្លូវចិត្ត] នៅក្នុងមណ្ឌល... ពួកគេធ្វើការដូចជាជម្រះស្មៅ រែកទឹក និងស្រោចដំណាំ ។ ពួកគេនិយាយពិបាកទាក់ទងគ្នាណាស់ អញ្ចឹងបានជាគេវាយពួកគាត់ — កក្កដា អាយុ២៨ឆ្នាំ អតីតអ្នកជាប់ឃុំឃាំងនៅ "មជ្ឈមណ្ឌលយុវនីតិសម្បទា" សង្គមកិច្ចចោមចៅ*[243]

ជាក់ស្តែង មជ្ឈមណ្ឌលឃុំឃាំងគ្រឿងញៀនរបស់រដ្ឋាភិបាល ក៏មានមុខងារជាមធ្យោបាយដ៏សមស្របក្នុងការយកមនុស្សដែលមានជំងឺផ្លូវចិត្តពីសហគមន៍ផងដែរ ។ អង្គការឃ្លាំមើលសិទ្ធិមនុស្សបានសម្ភាសអតីតអ្នកជាប់ឃុំឃាំងដែលបានពិពណ៌នាពីអំពើហិង្សាលើរាងកាយ គួរឱ្យតក់ស្លុតមកលើអ្នកជំងឺផ្លូវចិត្តជាក់ស្តែង ។

សៅ ជាអតីតអ្នកជាប់ឃុំឃាំងនៅមជ្ឈមណ្ឌលឱកាសខ្ញុំ បានធ្វើការពន្យល់ថា មជ្ឈមណ្ឌលត្រូវបានប្រើប្រាស់ដើម្បីឃុំខ្លួនអ្នកដែលមានជំងឺផ្លូវចិត្ត ។

---

242 អង្គការឃ្លាំមើលសិទ្ធិមនុស្ស សម្ភាសចំណោត- ភ្នំពេញ ខែកក្កដា ឆ្នាំ២០០៩

243 អង្គការឃ្លាំមើលសិទ្ធិមនុស្ស សម្ភាសកក្កដា- ភ្នំពេញ ខែឧសភា ឆ្នាំ២០០៩

មានមនុស្សឆ្កួតជាប់ឃុំនៅទីនោះ។ ពួកគេមិនមែនជាអ្នកប្រើគ្រឿងញៀនទេ។ ពួកគេអត់ដឹងខុសត្រូវ។ ពួកគេនិយាយពេលយប់ ស៊ីលើដី។ ពួកគេដូចជាមនុស្សអត់ខួរក្បាល។ ពួកគេត្រូវគេវាយ ប្រសិនបើមិនព្រមធ្វើការ :- បន្ទាប់ពីវាយរួចពួកគេទៅធ្វើការ។ ពួកគេត្រូវបានគ្រួសារយកទៅដាក់នៅទីនោះ។ អ្នកខ្លះត្រូវបានគេចាប់ខ្លួនពេលកំពុងដើរតាមផ្សារ។[244]

យោងតាមរបាយការណ៍ពង្រាងមួយ ស្តីពីការវាយតម្លៃរួមគ្នា ស្តីពីមជ្ឈមណ្ឌល ដែលបានធ្វើរួមគ្នាដោយអង្គការសុខភាពពិភពលោកនិងរដ្ឋាភិបាលកម្ពុជា :-

ពុំមានការផ្តល់សេវាសុខភាពផ្លូវចិត្តនៅក្នុងមជ្ឈមណ្ឌលទេ។ មជ្ឈមណ្ឌលនៅខេត្តសៀមរាប កំពុងកាន់កាប់អ្នកជំងឺដែលមិនមែនជាអ្នកញៀនគ្រឿងញៀន។ វាហាក់ដូចជាមានអ្នកជំងឺខ្លះដែលមានជំងឺផ្លូវចិត្ត ដែលត្រូវបានគេដាក់នៅក្នុងមជ្ឈមណ្ឌលបន្ទាប់ពីត្រូវបាន"ប្រមូល"ដោយនគរបាលនិងអាជ្ញាធរផ្សេងៗ ហើយនាំទៅកាន់មជ្ឈមណ្ឌល... មជ្ឈមណ្ឌលមិនបានធ្វើការវាយតម្លៃឱ្យមានប្រសិទ្ធិភាពអំពីកម្រិតសុខភាពផ្លូវចិត្ត ដូច្នេះហើយគឺហាក់ដូចជាថា អ្នកដែលចូលរួមនោះមានបញ្ហាជំងឺផ្លូវចិត្ត។[245]

អង្គការឃ្លាំមើលសិទ្ធិមនុស្ស បានទទួលរបាយការណ៍ស្តីពីការប្រព្រឹត្តដ៏ឃោរឃៅ អមនុស្សធម៌ មកលើអ្នកជំងឺផ្លូវចិត្តជាក់ស្តែង។ កក្កដាបានមើលឃើញផ្ទាល់ អំពីបុរសម្នាក់ដែលមានជំងឺផ្លូវចិត្ត ដែលត្រូវគេវាយយ៉ាងធ្ងន់ធ្ងរ :-

---

244 អង្គការឃ្លាំមើលសិទ្ធិមនុស្ស សម្ភាសសៅ- ភ្នំពេញ ខែមេសា ឆ្នាំ២០០៩

245 វី ម៉ាកដូណល់ អេ អាល់ (V. **McDonald et al**) "របាយការណ៍សង្ខេបអំពីការរកឃើញ ដោយមជ្ឈមណ្ឌល ការវាយតម្លៃជាប្រញាប់ អំពីការព្យាបាល និងមជ្ឈមណ្ឌលស្តារនីតិសម្បទាក្នុងប្រទេសកម្ពុជា" អង្គការសុខភាពពិភពលោក/អ.ជ.ប.គ.ញ/ប្រសួងសុខាភិបាល/កម្មវិធីអេដស៍របស់អ.ស.ប- ភ្នំពេញ ២០០៨ (មិនផ្សព្វផ្សាយ) ទំព័រ៨-៩ (ច្បាប់ចម្លងរក្សាទុកជាឯកសារនៅអង្គការឃ្លាំមើលសិទ្ធិមនុស្ស)

[បុគ្គលិកនិងអ្នកជាប់ឃុំឃាំងដទៃទៀត] ទាត់ធាក់មនុស្សឆ្កួត ពីព្រោះគាត់មិនដឹងអ្វីទាំងអស់។ បុរសឆ្កួតម្នាក់ ត្រូវអ្នកយាមឱ្យគាត់យកឈើដងរែកទៅរែកទឹក ប៉ុន្តែគាត់បែរជាយកដងរែកនោះទៅវាយអ្នកផ្សេងវិញ ព្រោះគាត់មិនដឹងអីទេ។ អ្នកយាមឆក់ដងរែកពីគាត់ ហើយវាយគាត់រហូតដល់គាត់មានរបួសធ្ងន់។ ពួកខ្ញុំមិនអាចជួយមនុស្សឆ្កួតនោះបាន។ ប្រសិនបើយើងជួយគាត់ គេវាយពួកខ្ញុំ។ អ្នកយាមវាយគាត់ខ្លាំងពេកហើយ គឺនៅលើខ្នង វាយរហូតដល់ក្អួតឈាមចេញតាមមាត់។ គាត់វាយមនុស្សឆ្កួតនោះ រហូតដល់ដួលដេកដី និងបាក់ដងរែក...[246]

គុហាបាននិយាយប្រាប់ការវាយដំមកលើអ្នកជំងឺផ្លូវចិត្តម្នាក់ដោយមេបន្ទប់តាមបញ្ជាផ្ទាល់និងវត្តមានរបស់កងរាជអាវុធហត្ថ។

កងរាជអាវុធហត្ថបួននាក់ បានឈរមើលការវាយដំ [អ្នកជាប់ឃុំឃាំងម្នាក់]ដោយមេបន្ទប់។ ពួកគេនិយាយថា"មេកង វៃវាឱ្យខ្លាច! [អ្នកជាប់ឃុំឃាំងនោះ] ដោយសារតែគាត់មានបញ្ហាផ្លូវចិត្ត បានស៊ីសាប៊ូអស់កន្លះដុំ។ "វៃវាកុំឱ្យវាស៊ីសាប៊ូទៀត។ វៃវាឱ្យខ្លាក់ចេញ! [មេបញ្ជាកងរាជអាវុធហត្ថទីមួយ]ដែលមើលខុសត្រូវកិច្ចការនោះ និង[មេបញ្ជាការរង]មណ្ឌលគឺជាអ្នកនិយាយអញ្ចឹង។ បន្ទាប់មក មេកងបានវាយគាត់ ទាត់ធាក់ ដាល់ ដោយយកកែងជើងពុះចំកណ្ដាលឆ្អឹងខ្នងមនុស្សឆ្កួតនោះ។ ដំបូងកងរាជអាវុធហត្ថខឹង ក្រោយមកក៏នាំគ្នាសើចក្រេវៗ។[247]

---

[246] អង្គការឃ្លាំមើលសិទ្ធិមនុស្ស សម្ភាសកក្កដា — ភ្នំពេញ ខែឧសភា ឆ្នាំ២០០៩

[247] អង្គការឃ្លាំមើលសិទ្ធិមនុស្ស សម្ភាសគុហា — កម្ពុជា ខែកក្កដា ឆ្នាំ២០០៩

មេសាបាននិយាយថាគាត់បានឃើញដោយផ្ទាល់នូវការវាយដំលើបុរសម្នាក់ដែលជាក់ស្តែងមានជំងឺផ្លូវចិត្ត ៈ-

> [មេបន្ទប់] ម្នាក់វាយមនុស្សឆ្កួតម្នាក់... គាត់មានរំពាត់ពីរលាក់នៅក្បាលគ្រែ។ រំពាត់មួយធ្វើពីឈើ ហើយមួយទៀតជាឬស្សី។ គាត់ឱ្យគេដោះខោអាវមនុស្សឆ្កួតចេញ ហើយវាយគាត់។ គូទរបស់គាត់ឡើងក្រហម។ គាត់ពិតជាឆ្កួតមែន ព្រោះគាត់នៅតែឯង ស្ងាត់ស្ងៀម។ នៅខាងក្រៅមណ្ឌល គាត់ដូចជាធម្មតាសោះ តែដល់ចូលមណ្ឌល គាត់ប្រែជាឆ្កួត ៈ-ប្រហែលមកពីគេវាយគាត់ច្រើនពេក [248]

## បទដ្ឋានអនុវត្តន៍

## ការឃុំខ្លួនកុមារជាវិធានការជម្រើសចុងក្រោយ

អនុសញ្ញាអ.ស.បស្តីពីសិទ្ធិកុមារ — ដែលជាសន្ធិសញ្ញាអន្តរជាតិចងភ្ជាប់កាតព្វកិច្ចដល់ប្រទេសកម្ពុជាជាភាគី —ចែងថាការចាប់ខ្លួន ការឃុំខ្លួន ឬការដាក់ ពន្ធនាគារកុមារត្រូវធ្វើស្របតាមច្បាប់ និងត្រូវប្រើសម្រាប់តែវិធានជម្រើសចុងក្រោយ"។ [249] លើសពីនេះទៀត កុមារដែលត្រូវបានគេដកហូតសេរីភាព មានសិទ្ធិជំទាស់ភាពស្របច្បាប់នៃការឃុំខ្លួននៅចំពោះមុខតុលាការ ឬអាជ្ញាធរមានសមត្ថកិច្ចឯករាជ្យ និងមិនលំអៀង និងមានសិទ្ធិទទួលបានសេចក្តីសម្រេចយ៉ាងឆាប់លើបណ្តឹងបែបនេះ។ [250] នេះមានន័យថា ជាទូទៅកុមារមិនត្រូវឃុំខ្លួនទេ ប្រសិនបើមិនមានការជំនុំជំរះក្តីថាគាត់បានប្រព្រឹត្តអំពើហិង្សាមកលើអ្នកណាម្នាក់

248 អង្គការឃ្លាំមើលសិទ្ធិមនុស្ស សម្ភាសមេសា — ភ្នំពេញ ខែឧសភា ឆ្នាំ២០០៩

249 អនុសញ្ញាស្តីពីសិទ្ធិកុមារ មាត្រា ៣៧(ខ)

250 អនុសញ្ញាស្តីពីសិទ្ធិកុមារ មាត្រា ៣៧(ឃ)

ឬមិនព្រមលះបង់ការប្រព្រឹត្តបទល្មើសធ្ងន់ធ្ងរផ្សេងៗទៀត និងពុំមានការ ឆ្លើយតបសមស្របផ្សេងៗទៀត ។[251]

គណៈកម្មាធិការអ.ស.ប ស្តីពីសិទ្ធិកុមារ — ដែលជាស្ថាប័នមួយដែលមានអ្នកជំនាញការឯករាជ្យ ត្រូវបានផ្តល់អំណាចដើម្បីបកស្រាយអនុសញ្ញាស្តីពីសិទ្ធិកុមារ និងពិនិត្យមើលថាតើប្រទេសទាំងឡាយ ប្រព្រឹត្តតាមអនុសញ្ញាស្តីពីសិទ្ធិកុមារឬទេ — បានបំភ្លឺបញ្ជាក់អំពីតម្រូវការនៃជម្រើសផ្សេងៗជាច្រើន ដើម្បីជៀសវាងការដាក់កម្រិតលើសេរីភាពកុមារ ដែលប្រើប្រាស់គ្រឿងញៀន។[252] គណៈកម្មាធិការនេះ បានសម្តែងការព្រួយបារម្ភចំពោះការឆ្លើយតប ដែលមិនមែនព្រហ្មទណ្ឌ មកលើកុមារដែលប្រើប្រាស់គ្រឿងញៀន ដែលមានដូចជាការមាក់ងាយ ឬពាក់ព័ន្ធនឹងការដកហូតសិទ្ធិសេរីភាពកុមារ ឬសិទ្ធិពលរដ្ឋផ្សេងៗទៀត ដូចជាការដាក់កុមារឱ្យនៅក្នុងមជ្ឈមណ្ឌលនីតិសម្បទាដែលបិទជិត។ តាមការពិត គណៈកម្មាធិការនេះ បានស្វែងរកការគាំទ្រឱ្យមានការបង្កើតទម្រង់នៃព្យាបាលក្រៅស្ថាប័ន ដល់កុមារដែលប្រើគ្រឿងញៀន និងសម្រាប់ការដាក់កុមារនៅក្នុងគ្រឹះស្ថានមួយ ដែលជាវិធានការចុងក្រោយបង្អស់។ បន្ថែមពីនេះទៀត កុមារដែលរស់នៅក្នុងគ្រឹះស្ថានបែបនេះ គួរទទួលបានសេវាជាមូលដ្ឋានដូចជាសេវាសុខភាព អប់រំ និងសេវាសង្គមផ្សេងៗទៀត និងរក្សាទំនាក់ទំនងជាមួយគ្រួសាររបស់ពួកគេអំឡុងពេលការស្នាក់នៅរបស់ពួកគេ។ ជាអវសាន្ត គណៈកម្មាធិការនោះបានអំពាវនាវឱ្យបង្កើតបទដ្ឋានគ្រឹះស្ថានឱ្យបានច្បាស់ និងផ្តល់ការពិនិត្យតាមកាលកំណត់នៃការដាក់កុមារ ។[253]

---

251 បទប្បញ្ញត្តិជាបទដ្ឋានអប្បបរិមាអ.ស.ប សម្រាប់រដ្ឋបាលយុត្តិធម៌អនីតិជន (វិន័យក្រុងប៉េកាំង) ("Beijing Rules") អនុម័តដោយសេចក្តីសម្រេចរបស់មហាសន្និបាតលេខ៤០/៣៣ ថ្ងៃទី២៩ វិច្ឆិកា ឆ្នាំ១៩៨៥ — គេហទំព័រ http://www.un.org/documents/ga/res/40/a40r033.htm.

252 ឧទាហរណ៍ មានការលើកជាយោបល់ថា ប្រទេសឡាត់វៀ (Latvia) "អភិវឌ្ឍនិងអនុវត្តជម្រើសជាច្រើនក្រៅពីជ្រើសរើសយកការដកហូតសេរីភាព រួមមានការសាកល្បង ការធ្វើជាអាជ្ញាកណ្តាលសម្របសម្រួល សេវាសហគមន៍ ឬការព្យួរទោស និងវិធានការបង្ការដោយប្រសិទ្ធិភាព និងដោះស្រាយការប្រព្រឹត្តបទល្មើសដែលទាក់ទងគ្រឿងញៀននិង/ឬគ្រឿងស្រវឹង" ប្រទេសឡាត់វៀ CRC/C/LVA/CO/2,para. 62(d) at http://daccessdds.un.org/doc/UNDOC/GEN/G06/428/94/PDF/G0642894.pdf?OpenElement.

253 ប្រទេសប្រុយណេ ដារូសាឡែម (Brunei Darussalam) CRC/C/15/Add.219, កថាខ័ណ្ឌ៥៣ និង ៥៤ — សូមមើលគេហទំព័រ http://www.unhchr.ch/tbs/doc.nsf/898586b1dc7b4043c1256a450044f331/39be9d499b7a0157c1256df00031b980/$FILE/G0344676.pdf.

## កង្វះខាតកម្មវិធីដាក់លាក់តាមអាយុ ឬសេវា/គ្មានការបែងចែក មនុស្សចាស់ និងកុមារ

ការឃុំខ្លួនមនុស្សក្រោមអាយុ១៨ឆ្នាំ នៅក្នុងគ្រឹះស្ថានតែមួយដូចគ្នានឹងមនុស្សចាស់ ត្រូវបានហាមឃាត់នៅក្រោមច្បាប់អន្តរជាតិស្តីសិទ្ធិមនុស្ស។ [254] គណៈកម្មាធិការស្តីពីសិទ្ធិកុមារបានកត់សម្គាល់ថា កុមារដែលដាក់នៅក្នុងគ្រឹះស្ថាន ក្នុងគោលបំណងព្យាបាលគ្រឿងញៀន ត្រូវតែធានាយ៉ាងហោចណាស់ឱ្យដូចទៅនឹងបទដ្ឋានអតិប្បរិមា ដូចកុមារដែលត្រូវដកហូតសេរីភាពរបស់ខ្លួនដែរ។ [255] វិន័យពន្ធនាគារប្រទេសកម្ពុជា តម្រូវឱ្យធ្វើការបែងចែកពីគ្នារវាងអ្នកទោសជានីតិជននិងអ្នកទោសជាអនីតិជន។[256]

មជ្ឈមណ្ឌលឃុំឃាំងគួរិះរកតាមដាន និងព្យាបាលនូវសញ្ញានៃជំងឺផ្លូវចិត្ត ឬជំងឺផ្លូវកាយ ការបំពានសារធាតុញៀន ឬស្ថានភាពដទៃទៀតដែលអាចធ្វើឱ្យរាំងស្ទះដល់សាមាហរណកម្មកុមារចូលក្នុងសង្គមវិញ ហើយគួរអនុម័តកម្មវិធីឯកទេសបង្ការនិងស្តារនីតិសម្បទាគ្រឿងញៀន ដែលគ្រប់គ្រងដោយបុគ្គលិកប្រកបដោយវិជ្ជាជីវៈ។ កម្មវិធីទាំងនេះ គួរមានលំនាំតាមអាយុ ភេទ និងតម្រូវការផ្សេងទៀតរបស់អនីតិជនដែលពាក់ព័ន្ធ ហើយមជ្ឈមណ្ឌលបន្សាបនិងសេវាដែលផ្តតផ្តង់ដោយបុគ្គលិកដែលឆ្លងកាត់ការបណ្តុះបណ្តាល គួរតែមានសម្រាប់អនីតិជនដែលញៀនគ្រឿងញៀន ឬគ្រឿងស្រវឹង។[257]

---

[254] កតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ — មាត្រា ១០(២) និង១០(៣) និងអនុសញ្ញាស្តីពីសិទ្ធិកុមារ មាត្រា៣៧ (គ)

[255] គណៈកម្មាធិការអ.ស.ប ស្តីពីសិទ្ធិកុមារ "បទអត្ថាធិប្បាយទូទៅ លេខ១០ —សិទ្ធិកុមារ ក្នុងយុត្តិធមិអនីតិជន" (ថ្ងៃទី៩ ខែកុម្ភៈ ២០០៧) **U.N. Doc No CRC/C/GC/10 fn 1.**

[256] "នីតិវិធីពន្ធនាគារ លេខ៣ — ការបែងចែកអ្នកទោស" អគ្គលេខាធិការដ្ឋាននៃនាយកដ្ឋានរដ្ឋបាលពន្ធនាគារ — ក្រសួងមហាផ្ទៃ មាត្រា៣.២

[257] បទប្បញ្ញត្តិអ.ស.ប សម្រាប់ការការពារអនីតិជន ដែលត្រូវដកហូតសេរីភាពរបស់ខ្លួន បទប្បញ្ញត្តិ៥៣ និងបទប្បញ្ញត្តិ៥៤ — អនុម័តដោយសេចក្តីសម្រេចចិត្តមហាសន្និបាត លេខ៤៥/១១៣ ចុះថ្ងៃទី១៤ ខែធ្នូ ១៩៩០។ សូមមើលគេហទំព័រ **http://www.un.org/documents/ga/res/45/a45r113.htm.**

## ទារុណកម្មនិងប្រព្រឹត្តកម្មដែលឃោរឃៅ និងអមនុស្សធម៌

ដូចគ្នានឹងមនុស្សចាស់ដែរ កុមារទាំងអស់ដែលត្រូវឃុំខ្លួន ត្រូវបានប្រព្រឹត្តប្រកបដោយភាពថ្លៃថ្នូរ និងមានការហាមឃាត់ដាច់ខាតនូវការធ្វើទារុណកម្ម ឬប្រព្រឹត្តកម្ម ឬទណ្ឌកម្មឯទៀតដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាបមកលើកុមារឡើយ ។[258] អ្នករាយការណ៍ពិសេសស្តីពីទារុណកម្ម បានកត់សម្គាល់ថា ៈ-

> មិនដូចនឹងនីតិជនភាគច្រើនទេ អនីតិជនអាចត្រូវបានដកហូតសេរីភាពរបស់ពួកគេបាន ក្នុងទម្រង់មួយនៃស្ថានភាពខាងផ្លូវច្បាប់ លើកលែងតែជនទាំងឡាយណាដែលពាក់ព័ន្ធនឹងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ និងត្រូវបានគេរាយការណ៍ថានឹងងាយរងគ្រោះជាពិសេសចំពោះទម្រង់នៃទារុណកម្ម ឬការធ្វើទុក្ខបុកម្នេញនៅក្នុងបរិយាកាសក្នុងគ្រឹះស្ថាន... មិនដូចគ្នាទៅនឹងការឃុំខ្លួននៅក្នុងប្រព័ន្ធយុត្តិធម៌ ដែលមានករណីស្ទើរតែទាំងអស់ នឹងកើតឡើងសម្រាប់រយៈពេលដែលកំណត់ជាមុន នៅពេលខ្លះកុមារត្រូវបានជាប់នៅក្នុងគ្រឹះស្ថានបែបនោះ និងទទួលរងនូវការប្រព្រឹត្តដែលឃោរឃៅ អមនុស្សធម៌ ឬបន្ទាបបន្ថោកដោយគ្មានការកំណត់ពេលវេលា ឬការពិនិត្យតាមកាលកំណត់ ឬការពិនិត្យមើលដោយតុលាការលើការសម្រេចចិត្តដាក់បញ្ចូល ។ ការឃុំឃាំងគ្មានកំណត់ជាពិសេសនៅក្នុងគ្រឹះស្ថានដែលកម្រិតយ៉ាងតឹងរឹងមកលើសេរីភាពធ្វើដំណើររបស់ពួកគេ អាចចាត់ទុកថាជាការប្រព្រឹត្តដែលឃោរឃៅ ឬអមនុស្សធម៌ ។[259]

---

258 កតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ មាត្រា ៧ ។ អនុសញ្ញាស្តីពីសិទ្ធិកុមារ មាត្រា៣៧ (ក)

259 អ្នករាយការណ៍ពិសេស ស្តីពីទារុណកម្មនិងការប្រព្រឹត្តដទៃទៀតដែលឃោរឃៅ អមនុស្សធម៌ ឬបន្ទាបបន្ថោក —របាយការណ៍ដាក់ជូនមហាសន្និបាត ២០០០ A/55/290 កថាខ័ណ្ឌ១១ និង១២ ។ សូមមើលគេហទំព័រ http://www.un.org/documents/ga/docs/55/a55290.pdf.

ប្រព្រឹត្តកម្មដែលបន្ថោកបន្ទាប រួមមានប្រព្រឹត្តកម្មដែលទាក់ទងនឹងការធ្វើឱ្យជនគ្រោះរងភាពអាម៉ាស់ ឬមិនសមាមាត្រទៅនឹងកាលៈទេសៈនៃករណីកើតឡើងនោះ។ ឧទាហរណ៍ ដូចករណីខាងលើជាដើម ការបង្ខិតបង្ខំកុមារាឱ្យរាំស្រាត និងការដាក់ទណ្ឌកម្មដោយសាររំលោភលើវិន័យមជ្ឈមណ្ឌល គឺរំលោភលើកាតព្វកិច្ចប្រទេសកម្ពុជា ក្នុងការបង្ការប្រព្រឹត្តកម្មដែលឃោរឃៅអមនុស្សធម៌ និងបន្ថោកបន្ទាប។

ពង្រាងក្រមព្រហ្មទណ្ឌចែងថា "ទារុណកម្មនិងអំពើដែលឃោរឃៅ" ត្រូវតែមានទោសដោយដាក់ពន្ធនាគារពី៧ឆ្នាំទៅ១៥ឆ្នាំ។ ប្រសិនបើប្រព្រឹត្តមកលើ"ជាពិសេសជនដែលងាយរងគ្រោះទៅតាមអាយុខ្លួន" ឬ "ជាពិសេសមកលើជនដែលងាយគ្រោះដោយជំងឺ ឬពិការភាពរបស់ខ្លួន ខណៈពេលដែលស្ថានភាពត្រូវបានឃើញ ឬដឹងថាជាជនល្មើស" នោះការទទួលទោសជាប់ពន្ធនាគារគឺពី១០ទៅ២០ឆ្នាំ។[260]

## ជំងឺផ្លូវចិត្ត

នៅក្រោមច្បាប់អន្តរជាតិស្តីពីសិទ្ធិមនុស្ស អ្នកជំងឺផ្លូវចិត្ត ត្រូវបានការពារពីប្រព្រឹត្តកម្ម ឬទណ្ឌកម្មឯទៀតដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប។ ច្បាប់អន្តរជាតិស្តីពីសិទ្ធិមនុស្សក៏បានបញ្ជាក់ផងដែរ អំពីសិទ្ធិបែងចែកដាច់ពីគ្នាក្នុងការទទួលបានសុខភាព ដែលតម្រូវឱ្យមានការថែទាំសុខភាពផ្លូវចិត្តសមស្រប ទៅតាមកម្រិតដែលអាចធ្វើទៅបានសម្រាប់មនុស្សទាំងអស់ រួមទាំងសិទ្ធិទទួលបានការព្យាបាលត្រឹមត្រូវសម្រាប់ជំងឺផ្លូវចិត្ត។

"គោលការណ៍ សម្រាប់ការការពារនិងថែទាំងអ្នកជំងឺផ្លូវចិត្ត" របស់អង្គការសហប្រជាជាតិចែងថា ការព្យាបាលដោយមិនមានការស្ម័គ្រចិត្តកើតឡើងបានតែក្នុងករណីបំពេញតាមលក្ខណៈ

---

[260] មាត្រា២១០ និង២១១

វិនិច្ឆ័យដែលត្រឹមត្រូវប៉ុណ្ណោះ។ គោលការណ៍ចែងថា សិទ្ធិរបស់អ្នកជំងឺទទួលបានការព្យាបាលដោយវេជ្ជសាស្ត្រ អាចធ្វើទៅបានលុះត្រាតែមានការយល់ព្រមពេញលេញ "បន្ទាប់ពីសវនាការយុត្តិធម៌មួយប៉ុណ្ណោះ ដែលធ្វើឡើងដោយតុលាការឯករាជ្យនិងមិនលំអៀង បង្កើតដោយច្បាប់នៅក្នុងស្រុក"។ តុលាការ ត្រូវទទួលបានការពេញចិត្តដែលថា"អ្នកជំងឺខ្វះសមត្ថភាពក្នុងការផ្តល់ការយល់ព្រម ឬ បដិសេធការយល់ព្រមដែលបានដឹងឮចំពោះផែនការព្យាបាលដែលស្នើរនោះ ឬថា ដោយបានពិចារណាដល់សុវត្ថិភាពផ្ទាល់ខ្លួនរបស់អ្នកជំងឺ ឬសុវត្ថិភាពរបស់អ្នកដទៃ អ្នកជំងឺបានបដិសេធការយល់ព្រមដោយមិនសមហេតុសមផល" ឬថា ផែនការព្យាបាលដែលស្នើនោះស្ថិតក្នុង"ឧត្តមប្រយោជន៍ដ៏ល្អបំផុតនៃតម្រូវការចាំបាច់ផ្នែកសុខភាពរបស់អ្នកជំងឺ។ ការដាក់បញ្ចូលដែលមិនស្ម័គ្រចិត្ត ឬការបង្ខាំងទុក ជាបឋមត្រូវតែមានរយៈពេលខ្លី (ដូចដែលបញ្ជាក់ដោយច្បាប់ក្នុងស្រុក) សម្រាប់ធ្វើការសង្កេត និងការព្យាបាលជាបឋម ដោយរង់ចាំការពិនិត្យសារជាថ្មី។ ក្នុងករណីការព្យាបាលដែលមិនស្ម័គ្រចិត្ត ការព្យាបាលបែបនេះ មិនត្រូវពន្យាពេលឱ្យហួសពីរយៈពេលដែលចាំបាច់ច្បាស់លាស់ សម្រាប់គោលបំណងនោះទេ។ បន្ថែមពីនេះទៀត អ្នកជំងឺត្រូវមានសិទ្ធិទទួលបានការព្យាបាល ក្នុងបរិយាកាសដែលមានការដាក់កម្រិតតិចបំផុត ឬការព្យាបាលដែលសមរម្យ។[261]

---

261 អ.ស.ប "គោលការណ៍ សម្រាប់ការការពារអ្នកជំងឺផ្លូវចិត្ត និងការកែលំអ ការថែទាំសុខភាពផ្លូវចិត្ត" អនុម័តដោយសេចក្តីសម្រេចចិត្តរបស់មហាសន្និបាត លេខ ៤៦/១១៩ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ១៩៩១។

# VI. សេចក្តីសន្និដ្ឋាន

ពុំមានអ្វីគួរឱ្យសង្ស័យឡើយដែលថា ការប្រើប្រាស់គ្រឿងញៀនខុសច្បាប់ បង្ក បញ្ហាប្រឈមពិបាកស្មុគ្រស្មាញ សម្រាប់អ្នកធ្វើគោលនយោបាយសាធារណៈ។ តាមទំនៀមទម្លាប់ គោលនយោបាយរបស់រដ្ឋស្តីពីការប្រើប្រាស់គ្រឿងញៀន បានផ្តោតលើការកាត់បន្ថយការ ផ្គត់ផ្គង់ផង និងតម្រូវការគ្រឿងញៀនផង។ រដ្ឋកំពុងបញ្ចូល ទស្សនវិស័យលើផ្នែកសុខភាព សាធារណកាន់តែច្រើនឡើង ដើម្បីកាត់បន្ថយគ្រោះថ្នាក់ភ្លាមៗនៃការប្រើប្រាស់គ្រឿងញៀន ដូចជាការរីករាលដាលមេរោគអេដស៍ និងជំងឺឆ្លងតាមឈាមផ្សេងៗទៀត នៅក្នុងចំណោមអ្នកដែល ប្រើប្រាស់គ្រឿងញៀន។ ការកាត់បន្ថយតម្រូវការនិងការផ្គត់ផ្គង់ និងគ្រោះថ្នាក់ភ្លាមៗ ដែលផ្សារភ្ជាប់ជាមួយនឹងការប្រើប្រាស់គ្រឿងញៀនទាំងអស គឺជាធាតុនៃការបង្កើតគោល នយោបាយរបស់រដ្ឋស្តីពីគ្រឿងញៀន ដែលការប្រើប្រាស់គ្រឿងញៀន បង្កការគំរាមកំហែង ដ៏ធ្ងន់ធ្ងរដល់សុខភាពសាធារណៈ។ ក៏ប៉ុន្តែ ការថែទាំប្រកបដោយទេព្យកោសល្យ ត្រូវធ្វើឡើង ដើម្បីធ្វើឱ្យប្រាកដថា ចរិតនិងការអនុវត្តគោលនយោបាយកាត់បន្ថយការផ្គត់ផ្គង់និងតម្រូវការ មានដំណើរស្របទៅនឹងកាតព្វកិច្ចសិទ្ធិមនុស្សរបស់រដ្ឋ។

ការញៀនគ្រឿងញៀន គឺជាជំងឺដែលលាប់ធ្ងន់ធ្ងរ។ អ្នកប្រើប្រាស់គ្រឿងញៀន ដែលនៅក្រោមការឃុំខ្លួនក្តី ក្រៅឃុំខ្លួនក្តី ត្រូវមានសិទ្ធិទទួលបានការព្យាបាលការញៀន គ្រឿងញៀន ដែលត្រឹមត្រូវតាមវេជ្ជសាស្ត្រ និងស្របតាមបទដ្ឋានអន្តរជាតិ។ យោងតាមការិយាល័យប្រឆាំងគ្រឿងញៀននិងឧក្រិដ្ឋកម្ម អ.ស.ប និងអង្គការសុខភាពពិភពលោក " សិទ្ធិមនុស្សរបស់អ្នកញៀនគ្រឿងញៀន មិនត្រូវទទួលរងការដាក់កំហិតលើមូលដ្ឋាននៃការ ព្យាបាល និងការស្តារនីតិសម្បទាឡើយ"។[262] ទោះជាយ៉ាងណាក៏ដោយ នៅក្នុងប្រទេសកម្ពុជា

---

[262] ការិយាល័យគ្រឿងញៀន និងឧក្រិដ្ឋកម្មអ.ស.ប "គោលការណ៍ នៃការព្យាបាលការញៀនគ្រឿងញៀន" ២០០៨ ទំព័រ៩

អ្នកប្រើប្រាស់គ្រឿងញៀន ត្រូវបានប្រព្រឹត្តមកលើខ្លួន ហាក់បីដូចជាពួកគេត្រូវបានបាត់បង់សិទ្ធិមនុស្សរបស់ខ្លួន។

ពាក្យដូចជា"ស្តារនីតិសម្បទា" ឬ "ព្យាបាល"សម្រាប់ការញៀនគ្រឿងញៀនមជ្ឈមណ្ឌលបែបនេះ គឺជាភាពបរាជ័យ។ ដោយរួមផ្សំគ្នានឹងភាពគ្មានប្រសិទ្ធិភាពព្យាបាលរបស់មជ្ឈមណ្ឌលខ្លួនឯងផង អ្នកជាប់ឃុំឃាំងត្រូវបានគេបង្ខំឱ្យធ្វើសកម្មភាពនានា ដែលគ្មានភស្តុតាងវិទ្យាសាស្ត្រសម្រាប់ការព្យាបាលការការញៀនគ្រឿងញៀនឡើយ ដូចជាលំហាត់ប្រាណដោយបង្ខំ ពលកម្មដោយបង្ខំនិងការហ្វឹកហ្វឺនយោធាដោយបង្ខំជាដើម។ មន្ត្រីអង្គការក្រៅរដ្ឋាភិបាលម្នាក់ដែលមានបទពិសោធន៍ផ្នែកកិច្ចការគ្រឿងញៀនគួឱ្យចាប់អារម្មណ៍ក្នុងប្រទេសកម្ពុជា បានធ្វើការពន្យល់ដល់អង្គការឃ្លាំមើលសិទ្ធិមនុស្សថា "[ក្នុងមជ្ឈមណ្ឌល] មានការខ្វះខាតការយល់ដឹងទាំងស្រុងអំពីការញៀន ដែលវាជាដំណើរនៃបញ្ហាចិត្តសាស្ត្រសង្គមមួយ"។ [263] ពុំមានការបញ្ជាក់ទេថា ប្រព័ន្ធមជ្ឈមណ្ឌលឃុំឃាំងគ្រឿងញៀនដោយបង្ខំ ដែលកំពុងដំណើរការនោះកំពុងកាត់បន្ថយចំនួនប្រជាពលរដ្ឋកម្ពុជាដែលប្រើប្រាស់គ្រឿងញៀនទេ។

ផ្ទុយទៅវិញ វាស្តែងចេញឱ្យឃើញថា មជ្ឈមណ្ឌលព្យាបាលគ្រឿងញៀនហាក់ដូចជាត្រូវបានជំរុញដោយបុព្វហេតុនៃបញ្ហាគ្រប់គ្រងសណ្តាប់ធ្នាប់សង្គម ទណ្ឌកម្មដែលសមនឹងទទួលសម្រាប់ការប្រើប្រាស់គ្រឿងញៀនដែលគេយល់ឃើញថាជាភាពបរាជ័យខាងសីលធម៌ និងការរកផលកម្រៃ។ ចាប់ពីពេលដែលពួកគេត្រូវបានចាប់ខ្លួន រហូតដល់ពេលនៅទីបញ្ចប់ដែលត្រូវដោះលែងពីមជ្ឈមណ្ឌលវិញ អ្នកជាប់ឃុំឃាំងរងនូវអំពើហិង្សាសម្រាប់ជាការបម្រើការ សប្បាយលើទុក្ខអ្នកដទៃ។ អំពើហិង្សាដែលបានប្រព្រឹត្តមកលើអ្នកជាប់ឃុំឃាំងដោយឥតរើសមុខទោះជាកុមារ ឬជាអ្នកជំងឺវិកលចរិតក៏ដោយ។ បុគ្គលិករបស់មជ្ឈមណ្ឌល អាចប្រើដំបងឆក់

---

263 អង្គការឃ្លាំមើលសិទ្ធិមនុស្ស សម្ភាសមន្ត្រីអង្គការក្រៅរដ្ឋាភិបាលម្នាក់ - ភ្នំពេញ ខែឧសភា ឆ្នាំ២០០៩

ចរន្តអគ្គិសនី រំពាត់ ហើយវាយអ្នកជាប់ឃុំឃាំងដោយគ្មានទោស និងបញ្ជាឱ្យអ្នកជាបឃុំឃាំងឱ្យប្រព្រឹត្តមកលើអ្នកជាប់ឃុំឃាំងដូចគ្នាផ្សេងទៀត។ នៅក្នុងហេតុការជាច្រើនបុគ្គលិកមជ្ឈមណ្ឌលបានកេងប្រវ័ញ្ចមកលើអ្នកជាប់ឃុំឃាំងដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួន ទោះជាបង្ខំឱ្យអ្នកជាប់ឃុំឃាំងធ្វើពលកម្ម ឬបង្ខំពួកគេឱ្យបរិច្ចាគឈាមក្តី។ ការឃុំខ្លួនអ្នកដែលនៅក្នុងមជ្ឈមណ្ឌលទាំងនោះ និងការទទួលរងនូវ ការប្រព្រឹត្តមកលើខ្លួនបែបនោះ គឺជាការរំលោភលើបទដ្ឋានអន្តរជាតិទាំងអស់ ដែលកំពុងអនុវត្តន៍ជាធរមាន។

ដោយមើលឃើញការរំលោភដ៏រីករាលដាលមកលើអ្នកជាប់ឃុំឃាំងបែបនេះ រាជរដ្ឋាភិបាលកម្ពុជា គួរតែបិទមជ្ឈមណ្ឌលឃុំឃាំងគ្រឿងញៀនប្រទេសកម្ពុជាជាបន្ទាន់។ រាជរដ្ឋាភិបាលកម្ពុជាត្រូវតែស៊ើបអង្កេត និងចាត់វិធានការ(រួមទាំងការកាត់ទោសព្រហ្មទណ្ឌ) ចំពោះអ្នកប្រព្រឹត្តនូវការធ្វើទារុណកម្ម ការប្រព្រឹត្តដែលឃោរឃៅ និងអមនុស្សធម៌ ការឃុំខ្លួនតាមអំពើចិត្ត និងការរំលោភសិទ្ធិមនុស្សផ្សេងៗទៀត និងបទឧក្រិដ្ឋ នៅក្នុងមជ្ឈមណ្ឌលឃុំឃាំងគ្រឿងញៀនប្រទេសកម្ពុជា។ ប្រជាពលរដ្ឋដែលកំពុងឃុំខ្លួនដោយខុសច្បាប់ ត្រូវតែដោះលែងឱ្យមានសេរីភាព។ ការបន្តការឃុំខ្លួនពួកគេ មិនអាចធ្វើយុត្តិកម្ម ដោយផ្អែកលើមូលដ្ឋានច្បាប់ ឬវេជ្ជសាស្ត្របានទេ។ តម្រូវការការព្យាបាលគ្រឿងញៀននៅមូលដ្ឋានសហគមន៍ដោយស្ម័គ្រចិត្ត នៅតែជាការបន្ទាន់ភ្លាមៗសម្រាប់សុខភាព និងសិទ្ធិមនុស្សរបស់អ្នកប្រើប្រាស់គ្រឿងញៀនក្នុងប្រទេសកម្ពុជា។

## VII. សេចក្តីថ្លែងអំណរគុណ

របាយការណ៍នេះត្រូវបានស្រាវជ្រាវនិងសរសេរដោយបុគ្គលិកអង្គការឃ្លាំមើលសិទ្ធិមនុស្សម្នាក់ ហើយត្រូវបានកែតម្រូវនិងពិនិត្យឡើងវិញដោយលោកយ៉ូសែហ្វ អេម៉ុន ដែលជានាយកផ្នែកសុខភាព និងសិទ្ធិមនុស្ស និង រ៉េបេឃើះ សែហ្វើ ដែលជានាយកផ្នែកតស៊ូមតិសុខភាព និងសិទ្ធិមនុស្ស អាយស្លីង រ៉េយឌី ដែលជាទីប្រឹក្សាច្បាប់ជាន់ខ្ពស់, អ៊ាន ឡឺវីន នាយកកម្មវិធី សា៉រ៉ា ឃូម ជាអ្នកស្រាវជ្រាវជាន់ខ្ពស់នៅភូមិភាគអាស៊ី ដែលពួកគេទាំងអស់គ្នាធ្វើការនៅអង្គការឃ្លាំមើលសិទ្ធិមនុស្ស។ របាយការណ៍នេះ ត្រូវបានពិនិត្យមើលឡើងវិញដែរដោយលោកជេសិន បាបឺ។ ជំនួយការផលិតកម្ម គឺផ្តល់ដោយអាន់ឌ្រេ ខតថម, មីនុន ឡាមៀ, គ្រេស ឈ័រ, អាណា ឡូព្រីអូ និង ហ្វិតរ៉យ ហេបឃីន។ អង្គការឃ្លាំមើលសិទ្ធិមនុស្ស សូមថ្លែងអំណរគុណផងដែរដល់លោកហ្គាយ ចាម៉ាន់ សម្រាប់រចនានិងការធ្វើផែនទី។

អង្គការឃ្លាំមើលសិទ្ធិមនុស្ស សូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះអ្នកដែលបានចែករំលែកចំណេះដឹងនិងបទពិសោធន៍ជាមួយយើងខ្ញុំ។ បើគ្មានសាក្ខីភាពរបស់ពួកគេទេ របាយការណ៍នេះមិនអាចកើតមានឡើយ។

# ឧបសម្ព័ន្ធ ១ : លិខិតឆ្លើយឆ្លងជាមួយរាជរដ្ឋាភិបាលកម្ពុជា

**HUMAN RIGHTS WATCH**

350 Fifth Avenue, 34th Floor
New York, NY 10118-3299
Tel: 212-290-4700
Fax: 212-736-1300
Email: hrwnyc@hrw.org

Kenneth Roth, Executive Director
Michele Alexander, Development & Outreach Director
Carroll Bogert, Associate Director
Emma Daly, Communications Director
Barbara Guglielmo, Finance & Administration Director
Peggy Hicks, Global Advocacy Director
Iain Levine, Program Director
Andrew Mawson, Deputy Program Director
Suzanne Nossel, Chief Operating Officer
Dinah PoKempner, General Counsel
James Ross, Legal & Policy Director
Joe Saunders, Deputy Program Director

**Program Directors**

Brad Adams, Asia
Holly Cartner, Europe & Central Asia
David Fathi, United States
Georgette Gagnon, Africa
José Miguel Vivanco, Americas
Sarah Leah Whitson, Middle East & North Africa
Joseph Amon, HIV/AIDS
John Biaggi, International Film Festival
Peter Bouckaert, Emergencies
Richard Dicker, International Justice
Bill Frelick, Refugee Policy
Arvind Ganesan, Business & Human Rights
Steve Goose, Arms
Liesl Gerntholtz, Women's Rights
Scott Long, Lesbian, Gay, Bisexual & Transgender Rights
Joanne Mariner, Terrorism & Counterterrorism
Lois Whitman, Children's Rights

**Advocacy Directors**

Steve Crawshaw, United Nations
Juliette de Rivero, Geneva
Jean-Marie Fardeau, Paris
Marianne Heuwagen, Berlin
Lotte Leicht, European Union
Tom Malinowski, Washington DC
Tom Porteous, London

**Board of Directors**

Jane Olson, Chair
Bruce J. Klatsky, Vice-Chair
Sid Sheinberg, Vice-Chair
John J. Studzinski, Vice-Chair
Karen Ackman
Jorge Castañeda
Geoffrey Cowan
Tony Elliott
Hassan Elmasry
Michael G. Fisch
Michael E. Gellert
Richard J. Goldstone
James F. Hoge, Jr.
Wendy Keys
Robert Kissane
Joanne Leedom-Ackerman
Susan Manilow
Kati Marton
Barry Meyer
Pat Mitchell
Joel Motley
Joan R. Platt
Catherine Powell
Sigrid Rausing
Neil Rimer
Victoria Riskin
Amy L. Robbins
Shelley Rubin
Kevin P. Ryan
Jean-Louis Servan-Schreiber
Darian W. Swig
John R. Taylor
Shibley Telhami
Catherine Zennström

Robert L. Bernstein, Founding Chair, (1979-1997)
Jonathan F. Fanton, Chair (1998-2003)
Bruce Rabb, Secretary

HUMAN
RIGHTS
WATCH

www.hrw.org

**ជូនចំពោះឯកឧត្តមកែ គីមយ៉ាន**

**ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន**

អាស័យដ្ឋានលេខ២៧៥ មហាវិថីនរោត្តម

ភ្នំពេញ

ផ្ញើតាមទូរសារលេខ: +855-23-721 004

ផ្ញើតាមអ៊ីម៉ែល: info@nacd.gov.kh

ថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០០៩

**ឯកឧត្តមជាទីគោរព**

អង្គការឃ្លាំមើលសិទ្ធិមនុស្ស គឺជាអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិមួយ ដែលឃ្លាំមើលការរំលោភសិទ្ធិមនុស្សដោយថ្នាក់ដឹកនាំរដ្ឋ និងដែលមិនមែនរដ្ឋ នៅក្នុងបណ្តាប្រទេសជាង ៨០ នៅជុំវិញពិភពលោក ។

អង្គការឃ្លាំមើលសិទ្ធិមនុស្សកំពុងរៀបចំរបាយការណ៍មួយស្តីពី ប្រព័ន្ធព្យាបាលអ្នកប្រើប្រាស់គ្រឿងញៀនដោយចាំបាច់ នៅក្នុងប្រទេសកម្ពុជា។ របាយការណ៍របស់យើងខ្ញុំ បង្ហាញអំពីបញ្ហាទាក់ទងនឹងនិតិវិធីត្រឹមត្រូវ បញ្ហាសិទ្ធិទទួលបានការថែទាំសុខភាព សេរីភាពពីទារុណកម្ម ឬការប្រព្រឹត្តសាហាវឃោរឃៅ អមនុស្សធម៌ ឬ ការបន្ទាបបន្ថោក ឬការដាក់ទណ្ឌកម្ម។

យើងខ្ញុំសរសេរ លិខិតនេះមកកាន់ឯកឧត្តមដើម្បីស្នើសុំព័ត៌មានស្តីពីស្ថិតិ និងពត៌មានស្តីពីកម្មវិធីទាក់ទងនឹងកិច្ចខិតខំប្រឹងប្រែងលើការព្យាបាលអ្នកប្រើប្រាស់ គ្រឿងញៀនក្នុងប្រទេសកម្ពុជា។ អង្គការឃ្លាំមើលសិទ្ធិមនុស្ស មានឆន្ទះដើម្បីបង្កើតនូវលិខិតុបករណ៍ដែលផ្តល់ព័តមានគ្រប់គ្រាន់ និងជាក់ស្តែង។ យើងខ្ញុំស្វែងរកព័ត៌មាន នេះដើម្បីធានាថារបាយការណ៍របស់យើងខ្ញុំឆ្លុះបញ្ចាំងដោយត្រឹមត្រូវអំពីទស្សនៈ គោលនយោបាយ និងការអនុវត្តរបស់រាជរដ្ឋាភិបាលកម្ពុជាចំពោះប្រព័ន្ធព្យាបាលអ្នកប្រើប្រាស់គ្រឿងញៀនដែលចាំបាច់។

យើងខ្ញុំសង្ឃឹមថា**ឯកឧត្តម** ឬបុគ្គលិកក្រោមឱវាទ នឹងឆ្លើយតប និងផ្តល់ចំលើយចំពោះសំណួរដែលមានភ្ជាប់មកជាមួយ ដើម្បីឆ្លុះបញ្ចាំងនូវទស្សនៈរបស់**ឯកឧត្តម** នៅក្នុងរបាយការណ៍របស់យើងខ្ញុំ។ ដើម្បីអាចអោយយើងខ្ញុំបានយកមកពិចារណានូវចំលើយរបស់**ឯកឧត្តម** និងដាក់ក្នុង របាយការណ៍របស់យើងខ្ញុំដែលនឹងត្រូវចេញផ្សព្វផ្សាយពេលឆាប់ៗខាងមុខនេះ យើងខ្ញុំសូមថ្លែងអំណរគុណ ចំពោះការឆ្លើយតបជាលាយល័ក្ខអក្សរនៅត្រឹមថ្ងៃទី១៥ ខែតុលា ឆ្នាំ ២០០៩។

បន្ថែមលើព័ត៌មានខាងក្រោមដែលយើងខ្ញុំស្នើរសុំ សូមមេត្តាដាក់បញ្ចូលបន្ថែមឯកសារផ្សេងៗទៀត ស្ថិតិ និងសកម្មភាពផ្សេងៗរបស់រដ្ឋាភិបាល ចំពោះប្រព័ន្ធនៃការព្យាបាលអ្នកប្រើប្រាស់គ្រឿងញៀននៅក្នុងប្រទេសកម្ពុជា ដែល**ឯកឧត្តម**យល់ឃើញថាមានពាក់ព័ន្ធ។

សូមថ្លែងអំណរគុណ**ឯកឧត្តម**ទុកជាមុនចំពោះការចំណាយពេលវេលាដើម្បីឆ្លើយតបចំពោះបញ្ហាជាបន្ទាន់នេះ។

សូម**ឯកឧត្តម**ទទួលការគោរពដោយស្មោះស្ម័គ្រអំពីខ្ញុំ ។



**យ៉ូ អេម៉ុន**

**នាយកផ្នែកសុខភាពនិងសិទ្ធិមនុស្ស**

*ចំលងជូន :*

**ឯកឧត្តម ស ខេង**

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

អាស័យដ្ឋានលេខ ២៧៥ មហាវិថីនរោត្តម

រាជធានីភ្នំពេញ កម្ពុជា

ទូរសារ/ទូរសព្ទ: +855 23 721 190

អ៊ីម៉ែល: info@interior.gov.kh

**ឯកឧត្តម ទៀ បាញ់**

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងការពារជាតិ**

វិថីសហព័ន្ធរុស្ស៊ី

រាជធានីភ្នំពេញ កម្ពុជា

ទូរសារ : +855-23 883 274

អ៊ីម៉ែល: info@mond.gov.kh

**ឯកឧត្តមម៉ម ប៊ុនហេង**

**រដ្ឋមន្ត្រីសុខាភិបាល**

អាស័យដ្ឋានលេខលេខ១៥១-១៥៣ វិថីកម្ពុជាក្រោម

រាជធានីភ្នំពេញ កម្ពុជា

ទូរសារលេខ: + 855 23 882 317/723 832

អ៊ីម៉ែល: webmaster@moh.gov.kh

**ឯកឧត្តមអ៊ិត សំហេង**

រដ្ឋមន្ត្រីសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

អាស័យដ្ឋានលេខ ៧៨៨បេ មហាវិថីមុនីវង្ស

ភ្នំពេញ កម្ពុជា

ទូរសារលេខ: +85523 726086

អ៊ីម៉ែល: mosalvy@cambodia.gov.kh

**ឯកឧត្តមកែប ជុតិម៉ា**

**អភិបាលក្រុងភ្នំពេញ**

អាស័យដ្ឋានលេខ ៦៩ មហាវិថីព្រះមុនីវង្ស

១២២០១ ភ្នំពេញ កម្ពុជា

ទូរសារ: +855-23-72 41 56 /855-23-722 054

អ៊ីម៉ែល:phnompenh@phnompenh.gov.kh

យើងខ្ញុំសូមថ្លែងអំណរគុណដែល**ឯកឧត្តម**មានលទ្ធភាពផ្តល់ព័ត៌មានដូចខាងក្រោមៈ

## សាវតា និងព័ត៌មានស្ថិតិ

1. តើមណ្ឌលព្យាបាលអ្នកញៀនគ្រឿងញៀនដែលគ្រប់គ្រងដោយរដ្ឋាភិបាល មានចំនួនប៉ុន្មានដែលកំពុងតែដំណើរការក្នុងប្រទេសកម្ពុជាសព្វថ្ងៃ? ។ សូមបញ្ជាក់អំពីអាជ្ញាធររដ្ឋាភិបាលដែលទទួលខុសត្រូវគ្រប់គ្រងមណ្ឌលនីមួយៗ ។

2. អង្គការឃ្លាំមើលសិទ្ធិមនុស្សបានដឹងថា រដ្ឋាភិបាលមានផែនការផ្លូវការដើម្បីបង្កើនបន្ថែមចំនួនមណ្ឌលដែលគ្រប់គ្រងដោយរដ្ឋ ។ សូម **ឯកឧត្តម**មេត្តាផ្តល់ព័ត៌មានលំអិតអំពីចំនួនមណ្ឌលថ្មីដែលនឹងដាក់ដំណើរការនៅ ក្នុងរយៈពេលបីឆ្នាំនាពេលខាងមុខ រួមទាំងព័ត៌មានអំពីទីតាំងមណ្ឌល និងអាជ្ញាធរដែលទទួលខុសត្រូវគ្រប់គ្រងមណ្ឌលបង្កើតថ្មីនីមួយៗ ។ សូមបញ្ជាក់ថា តើនៅមណ្ឌលថ្មីនីមួយៗនឹងដាក់ឃុំឃាំងស្ត្រីដែលប្រើប្រាស់គ្រឿងញៀនឬទេ ។

3. **តើមណ្ឌលអប់រំ កែប្រែនិងបណ្តុះបណ្តាលវិជ្ជាជីវៈ**ដែលហៅកាត់ថា (CECVT) (នៅស្រុកកៀនស្វាយ ខេត្តកណ្តាល) គឺជាមណ្ឌលដែលគ្រប់គ្រងដោយរដ្ឋឬទេ?

    - ប្រសិនបើមែន
      សូមមានផ្តល់យោបល់អំពីមូលហេតុដែលមានការអះអាងថាមណ្ឌលនេះគ្រប់គ្រងដោយអង្គការមិនមែនរដ្ឋាភិបាល ។
    - ប្រសិនបើមិនមែន សូមផ្តល់យោបល់:
      ក) តើហេតុអ្វីមណ្ឌលនោះដែលចុះបញ្ជីក្នុងរបាយការណ៍របស់

**អ.ជប.គ.៣** ស្តីអំពីលទ្ធផលត្រួតពិនិត្យគ្រឿងញៀនឆ្នាំ២០០៧ ថាជា "មណ្ឌលអប់រំគ្រឿងញៀនគ្រប់គ្រងដោយរដ្ឋ" ( មានភ្ជាប់ជាមួយអត្ថបទបកប្រែជាភាសាអង់គ្លេសនៅ ទំព័រ៧៥ )

ខ) តើជនជាប់ឃុំឃាំងចំនួន៣៧៤នាក់ក្នុងឆ្នាំ២០០៨ នៅក្នុងខេត្តកណ្តាល ( អ.ជប.គ.៣ "របាយការណ៍សង្ខេបស្តីពីលទ្ធផលត្រួតពិនិត្យគ្រឿងញៀន ឆ្នាំ២០០៨" ដែលពុំបានផ្សព្វផ្សាយ មានភ្ជាប់មកជាមួយ) ត្រូវបានឃុំឃាំងពិតប្រាកដឬទេ?

4. សូមផ្តល់ទិន្នន័យសម្រាប់ឆ្នាំ២០០៨ និង ២០០៩ ( ដោយឡែកពីគ្នា) រហូតដល់ពេលបច្ចុប្បន្ន :

- តើមានមនុស្សប៉ុន្មាននាក់ដែលត្រូវបានឃុំឃាំងក្នុងមណ្ឌលព្យាបាលគ្រឿងញៀនដែលគ្រប់គ្រងដោយរដ្ឋាភិបាលក្នុងប្រទេសកម្ពុជា (បែងចែកទៅតាមភេទ)?
- តើកុមារអាយុក្រោម១៨ឆ្នាំមានប៉ុន្មាននាក់ដែលជាប់ឃុំឃាំងក្នុងមណ្ឌលព្យាបាលគ្រឿងញៀនដែលគ្រប់គ្រងដោយរដ្ឋាភិបាល?
- តើមានអ្នកជំងឺវិកលចរិតប៉ុន្មាននាក់ដែលជាប់ឃុំឃាំងក្នុងមណ្ឌលព្យាបាលគ្រឿងញៀនដែលគ្រប់គ្រងដោយរដ្ឋាភិបាលក្នុងប្រទេសកម្ពុជា?

5. តើអង្គការពីខាងក្រៅណាខ្លះ ( ដូចជាភ្នាក់ងារអង្គការសហប្រជាជាតិ អង្គការក្រៅរដ្ឋាភិបាលជាតិឬអន្តរជាតិ) ប្រសិនបើមាន ដែលកំពុងផ្តល់ការគាំទ្រ ផ្នែកហិរញ្ញវត្ថុ កម្មវិធីគ្រប់គ្រង ឬផ្តល់សេវាកម្មក្នុងមណ្ឌលព្យាបាលគ្រឿងញៀនដោយដែលគ្រប់គ្រងដោយរដ្ឋាភិបាល? តើពួកគេប្រតិបត្តិការនៅក្នុងមណ្ឌលណាខ្លះ?

ប្រសិនបើមានផ្តល់ជំនួយជាថវិកា តើមានទឹកប្រាក់ចំនួនប៉ុន្មាន? ប្រសិនបើផ្តល់ជាកម្មវិធីគ្រប់គ្រង ឬផ្តល់ជាសេវាកម្ម សូមបញ្ជាក់អំពីកម្មវិធីឬសេវាកម្មទាំងនោះ ។

## ក្របខ័ណ្ឌច្បាប់ និងគោលនយោបាយ

1. **អង្គការឃ្លាំមើលសិទ្ធិមនុស្ស**បានដឹងថា ប្រជាជនដែលប្រើប្រាស់គ្រឿងញៀននិង "ជនដែលសង្គមមិនរាប់អាន" ផ្សេងទៀត ដូចជាជនគ្មានផ្ទះសម្បែង អ្នកសុំទាន ក្មេងរស់តាមចិញ្ចើមថ្នល់ អ្នកបំរើសេវាផ្លូវភេទ និង ជនវិកលចរិត ដែលពួកគេត្រូវបាន ចាប់ខ្លួនជាប្រចាំក្នុងការឡោមព័ទ្ធរបស់នគរបាលរាជធានីភ្នំពេញ ។

   សូមមេត្តាផ្តល់ព័ត៌មានខាងក្រោម សម្រាប់ឆ្នាំ២០០៨ និង២០០៩ រហូតបច្ចុប្បន្ន (ឬស្ថិតិដែលមានក្នុងរយៈពេលពីរឆ្នាំចុងក្រោយ)

   - នៅក្នុងរាជធានីភ្នំពេញ ចំនួនចាប់ខ្លួនទៅតាមប្រភេទនីមួយដូចតទៅ: អ្នកប្រើប្រាស់គ្រឿងញៀន អ្នកគ្មានផ្ទះសម្បែង អ្នកសុំទាន កុមាររស់លើចិញ្ចើមថ្នល់ អ្នកបំរើសេវាផ្លូវភេទ និងអ្នកជំងឺវិកលចរិត ។ ប្រសិន **ឯកឧត្តម**មិនអាចផ្តល់ទិន្នន័យបាន សូមមេត្តាពន្យល់មូលហេតុ ។
   - ច្បាប់នានាឬគោលនយោបាយដែលផ្តល់សិទ្ធិអំណាចដល់នគរបាលក្នុងការអនុវត្តការចាប់ខ្លួនបែបនេះ ។

2. តើការឃុំឃាំងអ្នកជាប់នៅក្នុងមណ្ឌលព្យាបាលគ្រឿងញៀនដែលគ្រប់គ្រងដោយរដ្ឋាភិបាល ក្នុងប្រទេសកម្ពុជា ផ្អែកលើមូលដ្ឋានច្បាប់អ្វីដែរ? សូមបញ្ជាក់បញ្ញត្តិច្បាប់ ក្នុងច្បាប់ប្រទេសកម្ពុជា ហើយរដ្ឋអំណាចស្របច្បាប់ណាដែលផ្តល់អំណាចក្នុងការឃុំឃាំងនេះ ។

3. សូមបញ្ជាក់អំពីវិធី និងអំពីមន្ត្រីដែលធ្វើសេចក្តីសម្រេចឃុំឃាំងអ្នកណាម្នាក់ក្នុងមណ្ឌលព្យាបាលគ្រឿងញៀន — ថាជានីតិវិធីដែលផ្ទុយពីការកាត់ទោសបទឧក្រិដ្ឋ

4. អង្គការឃ្លាំមើលសិទ្ធិមនុស្សដឹងថា ទោះបីអ្នកដែលមិនមែនជាអ្នកប្រើប្រាស់គ្រឿងញៀន ក៏ត្រូវបានឃុំឃាំងក្នុងមណ្ឌលព្យាបាលគ្រឿងញៀន។ ហេតុអ្វីពួកគេដែលមិនប្រើគ្រឿងញៀនត្រូវជាប់ឃុំឃាំងនៅទីនោះដែរ?

5. អង្គការឃ្លាំមើលសិទ្ធិមនុស្សដឹងថា អ្នកដែលមានជំងឺវិកលចរិត ត្រូវបានឃុំក្នុងមណ្ឌលព្យាបាលគ្រឿងញៀនទីនោះ ។ហេតុអ្វីពួកគេទាំងនោះ ត្រូវបានឃុំនៅទីនោះ? សូមផ្តល់លំអិតអំពីគោលនយោបាយនិងការអនុវត្តក្នុងការព្យាបាល ការថែទាំ និងការគាំទ្រជាពិសេសចំពោះជនជាប់ឃុំឃាំងដែលមានជំងឺវិកលចរិត ។

6. អង្គការឃ្លាំមើលសិទ្ធិមនុស្សដឹងថាកុមារដែលជាប់ឃុំឃាំង ដេកក្នុងបន្ទប់ជាមួយមនុស្សពេញវ័យ ។ តើមណ្ឌលណាខ្លះដែលឃុំឃាំង កុមារក្រោមអាយុ១៨ឆ្នាំដាក់ឱ្យនៅដោយឡែកពីមនុស្សចាស់? ។ ប្រសិនបើគ្មាន ហេតុអ្វី? សូមផ្តល់លំអិតអំពីគោលនយោបាយនិងការអនុវត្តជាក់ស្តែង អំពីការផ្តល់សេវាព្យាបាល ថែទាំនិងការគាំទ្រជាពិសេសចំពោះកុមារ ។

7. សូមផ្តល់លំអិតស្តីពីបទបញ្ជាផ្ទៃក្នុងមណ្ឌល ចំពោះការល្មើសវិន័យរបស់មណ្ឌលជាពិសេស :

- តើជនជាប់ឃុំឃាំងត្រូវបានអនុញ្ញាត ឱ្យដាក់វិន័យទៅលើអ្នកជាប់ឃុំឃាំងដូចគ្នាដែរឬទេ?

- តើទម្រង់នៃការដាក់ទណ្ឌកម្មតាមរបៀបទាហាន ត្រូវបានអនុញ្ញាតដោយបុគ្គលិកមណ្ឌលឬជនជាប់ឃុំឃាំងដូចគ្នាដែរឬទេ? ។ ប្រសិនបើមាន តើទណ្ឌកម្មរបៀបទាហាន ត្រូវបានប្រើប្រាស់នៅក្នុងកាលៈទេសៈបែបណា?

8. តើបុគ្គលិកមណ្ឌល ឬជនជាប់ឃុំឃាំង ធ្វើការស៊ើបអង្កេតយ៉ាងដូចម្តេចចំពោះរបាយការណ៍ស្តីពីការប្រព្រឹត្តមិនល្អទៅលើជនជាប់ឃុំឃាំងដូចគ្នា? តើអ្នកទទួលខុសត្រូវចំពោះការប្រព្រឹត្តមិនល្អទៅលើអ្នកជាប់ឃុំឃាំង នឹងត្រូវទទួលរងទណ្ឌកម្មអ្វីខ្លះ?

9. ចាប់តាំងពីឆ្នាំ ២០០៦ តើមានពាក្យបណ្តឹងប៉ុន្មានករណីដែលត្រូវបានដាក់ប្តឹង ? តើមានបណ្តឹងប៉ុន្មានករណីត្រូវបានចាត់ការ ? តើការដាក់ទណ្ឌកម្មមានប៉ុន្មាន? ។ តើទណ្ឌកម្មបែបណា ដែលត្រូវបានអនុវត្ត?

10. សម្រាប់ឆ្នាំ២០០៨និង២០០៩ រហូតមកដល់បច្ចុប្បន្ន :
តើបំរុងថវិការសម្រាប់ជនជាប់ឃុំឃាំងម្នាក់ៗ មានចំនួនប៉ុន្មាន?
តើប្រាក់បំរុងនោះមានប៉ុន្មានភាគរយដែលទុកសម្រាប់ការចំណាយលើអាហារ?

11. យើងខ្ញុំដឹងថាក្រសួងមហាផ្ទៃ បានសរសេរគោលការណ៍ណែនាំបទដ្ឋានរបបអាហារសម្រាប់អ្នកទោស( មានភ្ជាប់ជាមួយ) ។
តើបទដ្ឋានទាំងនេះអនុវត្តទៅលើជនជាប់ឃុំឃាំងក្នុង មណ្ឌលព្យាបាលគ្រឿងញៀនដែរឬទេ? ។ ប្រសិនបើមិនមាន សូមពិពិណនា អំពីបទដ្ឋានដែលត្រូវអនុវត្ត ។

ការព្យាបាលគ្រឿងញៀន

1. **ការិយាល័យសហប្រជាជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀននិងឧក្រិដ្ឋកម្ម** (UNODC) និង**អង្គការសុខភាព ពិភពលោក** ផ្តល់អនុសាសន៍ថាការ ព្យាបាលគ្រឿងញៀន ដែលជាការបង្ខំគួរតែបង្ខំលើជនណាដែលស្ថិត "ក្នុងស្ថានភាពវិបត្តិពិសេសប្រឈមនឹងកត្តាគ្រោះថ្នាក់ខ្ពស់ ចំពោះខ្លួនឯងឬអ្នកដទៃ។ អនុសាសន៍បញ្ជាក់ទៀតថា ការព្យាបាល ត្រូវបានកំណត់សម្រាប់ល័ក្ខខ័ណ្ឌពិសេស និងក្នុងរយៈពេលជាកំណត់។ តើគោលនយោបាយរបស់ រដ្ឋាភិបាល បានយកអនុសាសន៍មក ពិចារណាដែរឬទេ? ប្រសិនបើមាន សូមបញ្ជាក់ថា ដោយរបៀបណា។ ប្រសិនមិនមាន សូមបញ្ជាក់ពីមូលហេតុ ហើយអ្វីដែលជំរុញឱ្យរដ្ឋាភិបាល អនុម័តគោលនយោបាយជាក់លាក់ ដាក់ឃុំឃាំងជាប្រចាំចំពោះ ជនប្រើប្រាស់គ្រឿងញៀន ដោយប្រឆាំងនឹងឆន្ទៈរបស់ពួកគេ  ក្នុងរយៈពេលដែលមិនជាក់លាក់។

2. អង្គការឃ្លាំមើលសិទ្ធិមនុស្សដឹងថាជនជាប់ឃុំឃាំង ត្រូវបានបង្ខំឱ្យធ្វើលំហាត់ប្រាណ និងពលកម្ម ដើម្បីបន្សាបជាតិញៀនអោយ"ហូរតាមញើស"។ អតីតអ្នកជាប់ឃុំឃាំង ក៏បានរាយការណ៍ថា ពួកគេត្រូវបានគេបង្ខំឱ្យហ្វឹកហាត់របៀបទាហាន។ សូមពន្យល់ បង្ហាញភស្តុតាងតាមបែបវិទ្យាសាស្ត្រ ដែលផ្តល់ប្រយោជន៍ដល់ការ ព្យាបាលអ្នកដែលប្រើប្រាស់គ្រឿងញៀន ដែលផ្អែកលើការអនុវត្តបែបនេះ?

3. តើបុគ្គលិកនៅមណ្ឌលព្យាបាលគ្រឿងញៀនដោយបង្ខំទាំងនេះ មានឧបករណ៍អ្វីខ្លះ? សូមមេត្តា**ឯកឧត្តម**បញ្ជាក់ថាតើឆ្មាំមណ្ឌលមានដំបងឆក់ដោយចរន្តអគ្គីសនីដែរឬ

ទេ? តើគោលនយោបាយសមស្របអ្វីខ្លះ សម្រាប់ពេលវេលាណាដែលត្រូវប្រើប្រាស់ដំបងឆក់ដោយចរន្តអគ្គិសនី?

4. តើធ្លាប់មានការដាក់ពាក្យបណ្តឹងអំពីការប្រើប្រាស់ខុសឬការរំលោភដោយប្រើដំបងឆក់ដោយចរន្តអគ្គិសនីដែរឬទេ? ប្រសិនបើមាន តើមានបណ្តឹងប៉ុន្មាន? តើការស៊ើបអង្កេតលើពាក្យបណ្តឹងនោះមានលទ្ធផលដូចម្តេច?

5. តើរាជរដ្ឋាភិបាលកម្ពុជានឹងធ្វើអ្វីខ្លះដើម្បីបង្កើនសិទ្ធិទទួលបានការព្យាបាលដោយស្ម័គ្រចិត្ត និងការព្យាបាលដែលផ្អែកលើភស្តុតាងនៃការប្រើប្រាស់គ្រឿងញៀនដោយផ្តល់អោយអ្នកជំងឺនៅក្រៅមន្ទីរពេទ្យ ។